ADB

# គោលការណ៍ណែនាំសម្រាប់ការរៀបចំរបាយការណ៍វាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

ខែ កុម្ភៈ ឆ្នាំ ២០០៦

នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ

ធនាគារអភិវឌ្ឍន៍អាស៊ី

# អក្សរកាត់

| | | |
|---|---|---|
| ADB | Asian Development Bank | ធនាគារអភិវឌ្ឍន៍អាស៊ី |
| CAP | country assistant program | កម្មវិធីជំនួយប្រចាំប្រទេស |
| CAPE | country assistance program evaluation | ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស |
| CSP | country strategy and program | យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស |
| DEC | Development Effectiveness Committee | គណៈកម្មាការដើម្បីប្រសិទ្ធភាពក្នុងការអភិវឌ្ឍ |
| DG | director general | អគ្គនាយក |
| DMC | developing member country | ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក |
| DP | development partner | ដៃគូអភិវឌ្ឍន៍ |
| EA | Executing Agency | ទីភ្នាក់ងារអភិវឌ្ឍន៍ |
| MDB | Multilateral Development Bank | ធនាគារអភិវឌ្ឍន៍ពហុភាគី |
| MDG | Millenium Development Goal | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ |
| NGO | nongovernment organization | អង្គការក្រៅរដ្ឋាភិបាល |
| NPRS | National Poverty Reduction Strategy | យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ |
| OED | Operations Evaluation Development | នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ |
| OECD-DAC | Organization for Economic Co-operation and<br>Development – Development Assistance Committee | អង្គការដើម្បីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង<br>ការអភិវឌ្ឍ - គណៈកម្មការជំនួយអភិវឌ្ឍន៍ |
| PCR | project or program completion report | របាយការណ៍បញ្ចប់កម្មវិធី/គម្រោង |
| PPER | project/program performance evaluation report | របាយការណ៍វាយតម្លៃការអនុវត្តកម្មវិធី/គម្រោង |
| PRS | poverty reduction strategy | យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ |
| TA | technical Assistance | ជំនួយបច្ចេកទេស |
| TCR | technical assistance completion report | របាយការណ៍បញ្ចប់ជំនួយបច្ចេកទេស |

# មាតិកា

I. សេចក្តីផ្តើម ១
ក. ប្រវត្តិ ១
ខ. ការវាយតម្លៃលទ្ធផលការងារធៀបទៅនឹងអាណត្តិ និងការប្តេជ្ញាចិត្តរបស់ប្រទេស ២
គ. ការវាយតម្លៃលើភាពស៊ីសង្វាក់គ្នានៃគម្រោង ៣
ឃ. វត្ថុបំណង និងគោលដៅវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៤
ង. ការគ្របដណ្តប់ និងវិសាលភាពនៃការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៥
II. វិធីសាស្ត្រវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៨
ក. សំណួរគន្លឹះៗ និងលក្ខណៈវិនិច្ឆ័យវាយតម្លៃ ៨
ខ. វិធីសាស្ត្រវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៩
III. មាតិការបាយការណ៍ ១៩
ក. ទម្រង់ និងការបញ្ចប់ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ១៩
ខ. សេចក្តីសង្ខេប ២១
គ. សេចក្តីផ្តើម ២១
ឃ. បរិបទអភិវឌ្ឍន៍ និងអាទិភាពរបស់រដ្ឋាភិបាល ២១
ង. យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ២២
ច. ការអនុវត្តកម្មវិធី ២៨
ឆ. លទ្ធផលសម្រេចបាន និងកត្តាដែលមានឥទ្ធិពលលើការអនុវត្ត ២៩
ជ. ការវាយតម្លៃ និងចំណាត់ថ្នាក់វាយតម្លៃលើលទ្ធផលការងារ ៣០
ឈ. លទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ ៣២
IV. ការអនុវត្តវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៣៣
ក. វិធីវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៣៣
ខ. ការជំរុញឱ្យមានការចូលរួម ៣៥
គ. ការធ្វើឱ្យមានសុពលភាពនូវយុទ្ធសាស្ត្រប្រចាំប្រទេស និងរបាយការណ៍បញ្ចប់កម្មវិធី ៣៧
ឃ. ការផ្តល់អនុសាសន៍ប្រកបដោយប្រសិទ្ធិភាព ៣៧
ង. ការរៀបចំកាលវិភាគវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស និងការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសមុន ៣៧
ច. ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកដែលមានផលប៉ះពាល់ត្រតូច ៣៨
ឆ. ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសបន្តបន្ទាប់ទៀត ៣៩
ឧបសម្ព័ន្ធ
១. គំរូរបាយការណ៍ ៤០
២. ចំណាត់ថ្នាក់ និងការវាយតម្លៃលទ្ធផលការងារ ៤៣
៣. លក្ខខណ្ឌយោង (គំរូវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសប៊ូតាន) ៥២
៤. ការវាយតម្លៃភាពជាម្ចាស់លើការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៥៦

៥. សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ :ការអង្កេតលើអតិថិជន/អ្នកពាក់ព័ន្ធ ជាមួយនឹងការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស ៦០
៦. ក្របខ័ណ្ឌវាយតម្លៃគុណភាពយុទ្ធសាស្ត្រ ៦៥

# I. សេចក្តីផ្តើម

## ក. ប្រវត្តិ

១. នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ (OED) នៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) គឺជាស្ថាប័នដែលអនុវត្តការវាយតម្លៃដោយឯករាជ្យ ដោយគ្របដណ្តប់លើគ្រប់ទិដ្ឋភាពទាំងអស់ ទាំងប្រតិបត្តិការរបស់វិស័យឯកជន និងសាធារណៈ ដែលក្នុងនោះ រួមមាន ការវាយតម្លៃទៅលើគោលនយោបាយ នីតិវិធី និងលើដំណើរការនានា ក៏ដូចជាវាយតម្លៃទៅលើបណ្តាប្រទេស វិស័យនានា ផលប៉ះពាល់ និងប្រធានបទ ។ ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស (CAPE) បានក្លាយជាលិខិតុបករណ៍វាយតម្លៃមួយដ៏សំខាន់ នាប៉ុន្មានឆ្នាំចុងក្រោយនេះ ខណៈដែលជំនួយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ប្រគល់ឱ្យប្រទេសជាអ្នកទទួលខុសត្រូវ ជាជំនួយផ្តោតលើការសម្រេចបាននូវលទ្ធផល ជាជំនួយមានភាពសុខដុម និងមានភាពបន្សុីគ្នាជាមួយនឹងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ។

២. ការវាយតម្លៃ គឺជាផ្នែកមួយដែលត្រូវបានដាក់បញ្ចូលទៅក្នុងវដ្តនៃការធ្វើផែនការរបស់ ADB ។ ការវាយតម្លៃនេះ មានវិមាត្រចំនួនពីរ : (i) ការវាយតម្លៃ ដោយខ្លួនឯង ដែលជាការវាយតម្លៃធ្វើឡើងដោយនាយកដ្ឋានប្រតិបត្តិការទាំងឡាយណា ដែលទទួលខុសត្រូវក្នុងការរៀបចំ និងអនុវត្តគម្រោង កម្មវិធី និងប្រតិបត្តិការជំនួយបច្ចេកទេសរបស់ខ្លួន និង (ii) ការវាយតម្លៃដោយឯករាជ្យ ដែលជាការវាយតម្លៃធ្វើឡើងដោយ OED ។ ការវាយតម្លៃដោយខ្លួនឯង ត្រូវមានលិខិតុករណ៍មួយចំនួន ដូចជា (i) របាយការណ៍ស្តីពីការអនុវត្តកម្មវិធី និងគម្រោង (ii) របាយការណ៍ស្តីពីការអនុវត្ត TA (iii) របាយការណ៍ត្រួតពិនិត្យ ដែលត្រូវបានរៀបចំក្នុងអំឡុងពេលអនុវត្តគម្រោង ជាទូទៅធ្វើឡើងរៀងរាល់ពាក់កណ្តាលត្រីមាស (iv) របាយការណ៍បញ្ចប់កម្មវិធី និងគម្រោង (PCRs) (v) របាយការណ៍បញ្ចប់ TA (TCRs) (vi) ការត្រួតពិនិត្យផលប័ត្ររបស់ប្រទេសនីមួយៗ ហើយក្នុងពេលខាងមុខនឹងមាន (vii) របាយការណ៍បញ្ចប់កម្មវិធី និងយុទ្ធសាស្ត្រប្រចាំប្រទេស ។ រីឯការវាយតម្លៃដោយឯករាជ្យរបស់ OED ត្រូវមានលិខិតុបករណ៍មួយចំនួនដែរ ដូចជារបាយការណ៍វាយតម្លៃការអនុវត្តកម្មវិធី និងគម្រោង ការវាយតម្លៃផលប៉ះពាល់ ការវាយតម្លៃគម្រោង របាយការណ៍ស្តីពីការវាយតម្លៃលទ្ធផលការងារ TA ការវាយតម្លៃពិសេស ការវាយតម្លៃកម្មវិធី ជំនួយតាមបណ្តាវិស័យ និង CAPEs ។

៣. ការរៀបចំ CAPE គឺជាភារៈកិច្ចវាយតម្លៃដ៏ចម្បង ។ ការរៀបចំនេះ ផ្អែកលើសម្ភារវាយតម្លៃដោយខ្លួនឯង និងសម្ភារវាយតម្លៃដោយឯករាជ្យដែលមានស្រាប់ ក៏ដូចជាផ្អែកលើយុទ្ធសាស្ត្រ និងផែនការរបស់រដ្ឋាភិបាល ទិន្នន័យស្តីពីការអនុវត្តបន្ទាប់បន្សំផ្សេងទៀត បណ្ណុំព័ត៌មានរបស់ប្រទេស កំណត់ត្រារបស់គម្រោង បទសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធ ការអង្កេតគំរូ និងលើប្រភពព័ត៌មានផ្សេងៗទៀត ។ CAPE ត្រូវបានធ្វើឡើង ដើម្បីផ្តល់ព័ត៌មាននានាដល់ការរៀបចំ យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសដែល ជាទូទៅ យុទ្ធសាស្ត្រ និងកម្មវិធីនេះ ត្រូវបានគេរៀបចំឡើងរៀងរាល់ប្រាំឆ្នាំម្តង សម្រាប់ប្រទេសកំពុងអភិវឌ្ឍជាសមាជិក (DMC) ។ CAPE ខិតខំស្វែងយល់ពីទំនាក់ទំនងដ៏ស្មុគស្មាញ រវាងជំនួយអភិវឌ្ឍន៍របស់ ADB និងដំណើរការសេដ្ឋកិច្ច និងសង្គមរបស់ DMC ក្នុងពេលដែលការវាយតម្លៃនេះ ព្យាយាមកំណត់នូវកាលានុវត្តភាព ដើម្បីលើកកម្ពស់ការអនុវត្តគម្រោងក្នុងកម្រិតថ្នាក់ប្រទេស ។ វត្ថុបំណងដ៏សំខាន់របស់ CAPE គឺការគាំទ្របង្កើតជាយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសសម្រាប់ពេលបន្ទាប់ តាមរយៈការវាយតម្លៃលើបទពិសោធន៍នៃប្រតិបត្តិការរបស់ធនាគារ ADB ដែលបានបញ្ចប់ និងដែលកំពុងអនុវត្តនៅក្នុងប្រទេស ។

៤. នៅពេល ADB ចាប់ផ្តើម CAPE ជាលើកដំបូងក្នុងឆ្នាំ១៩៩៨ នាពេលនោះ នៅមិនទាន់មានវិធីសាស្ត្រវាយតម្លៃការអនុវត្តកម្មវិធីជំនួយប្រចាំប្រទេសដែលទទួលយកជាអន្តរជាតិនៅឡើយទេ ។ ក្រោយមកទៀត OED បានសាកល្បងការពិសោធន៍លើវិធីមួយចំនួន ។ វត្ថុបំណងរបស់នាយកដ្ឋាននេះ គឺចង់ស្វែងយល់ថាតើវិធី និងវិធីសាស្ត្រអ្វីខ្លះ អាចដំណើរការបានល្អក្នុងការអនុវត្ត ។ គោលការណ៍ណែនាំទាំងនេះ ផ្អែកទៅលើបទពិសោធន៍ និងមេរៀនទាំងឡាយណាដែលទទួលបានពី CAPE ជំនាន់ទីមួយរបស់ ADB ហើយគោលការណ៍ណែនាំទាំងនេះ ក៏បានប្រើប្រាស់ការត្រួត

ពិនិត្យលើបទពិសោធន៍របស់ធនាគារអភិវឌ្ឍពហុភាគីផ្សេងទៀត (MDBs) ផងដែរ ។ ក្នុងពេលដែលគោលការណ៍ណែនាំទាំងនេះ ប្រើប្រាស់ទាំងស្រុងនូវបទពិសោធន៍ពីអន្តរជាតិ និងពី OED មានការរំពឹងទុកថាគោលការណ៍ទាំងនោះកាន់តែមានភាពល្អប្រសើរឡើង បើពិនិត្យទៅលើការប្រើប្រាស់គោលការណ៍ទាំងនោះ ។ ថ្មីនេះៗ OED បានដាក់ឱ្យប្រើប្រាស់នូវលិខិតុបករណ៍វាយតម្លៃកម្មវិធីជំនួយតាមវិស័យ ហើយបានចាប់ផ្តើមធ្វើការសិក្សាវាយតម្លៃពិសេសមួយទៅលើគោលនយោបាយរបស់ ADB ។ អ្នកវាយតម្លៃ ត្រូវបានលើកទឹកចិត្តឱ្យប្រើប្រាស់ក្របខ័ណ្ឌ CAPE ដែលអាចធ្វើការកែសម្រួលតាម ភាពសមស្របសម្រាប់ការវាយតម្លៃទាំងនោះបាន ។

## ខ. ការវាយតម្លៃលទ្ធផលការងារធៀបទៅនឹងអាណត្តិ និងការប្តេជ្ញាចិត្តរបស់ប្រទេស

៥. CAPEs ត្រូវតែមានការទទួលខុសត្រូវ និងកំណត់ឱ្យបាននូវមេរៀនជាចាំបាច់ ហើយធ្វើការវាយតម្លៃ និងបកស្រាយការអនុវត្តក្នុងពេលអតីតកាល ដើម្បីផ្តល់ការសន្និដ្ឋាន និងអនុសាសន៍សម្លឹងឆ្ពោះទៅមុខ ។ ការវាយតម្លៃនេះ ត្រូវបានប្រើដោយក្រុមប្រឹក្សាភិបាលរបស់ ADB ដើម្បីផ្ទៀងផ្ទាត់ថា ជំនួយរបស់ ADB មានភាពស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រ និងគោលនយោបាយរបស់ខ្លួន និងដើម្បីកំណត់ថាតើលទ្ធផលរំពឹងទុកពីការអភិវឌ្ឍអាចសម្រេចបានដែរ ឬទេ ។ សម្រាប់បុគ្គលិកប្រតិបត្តិការ CAPEs បានផ្តល់នូវមេរៀនដ៏មានសារៈប្រយោជន៍ដល់ពួកគេក្នុងការរៀបចំ CSPs ក្នុងពេលអនាគត ។ នៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍជាសមាជិក អ្នកពាក់ព័ន្ធជាច្រើន បានទទួលអត្ថប្រយោជន៍ ពីមេរៀនដែលបានកំណត់នូវក្នុង CAPEs ដើម្បីលើកកម្ពស់នូវប្រសិទ្ធភាពនៃការអភិវឌ្ឍដែលទទួលបានពីជំនួយខាងក្រៅ ។

៦. យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ (PRS) បានបង្កើតសេរីប៉ារ៉ាម៉ែត្រ ដែលត្រូវបានយកមកប្រើដើម្បីវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសរបស់ ADB ។ PRS បានកំណត់និយមន័យបេសកកម្ម ដ៏ថ្លៃថ្លារបស់ ADB ថាគឺជាការកាត់បន្ថយភាពក្រីក្រ ។

> គោលដៅតំបន់អាស៊ី-ប៉ាស៊ីហ្វិកចាកផុតពីភាពក្រីក្រ ពិតជាកំណត់នូវបេសកកម្មរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ។ វត្ថុបំណងប្រកបដោយយុទ្ធសាស្ត្រទាំងអស់នេះ នឹងត្រូវបន្តធ្វើតទៅទៀតតាមវិធីជាច្រើន ដែលនឹងរួមចំណែកប្រកបដោយប្រសិទ្ធភាពក្នុងការសម្រេចបានគោលដៅ [១] ខាងលើនេះ ។

៧. ស្ថិតក្នុងក្របខ័ណ្ឌ PRS ការគាំទ្ររបស់ ADB ចំពោះការកាត់បន្ថយភាពក្រីក្រ នឹងលេចជារូបរាងឡើងតាមរយៈអន្តរាគមន៍ជាច្រើនតម្រង់ទៅរកការធ្វើឱ្យមានកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពគាំទ្រប្រជាជនក្រីក្រ ការអភិវឌ្ឍសង្គមលើគ្រប់វិស័យ និងអភិបាលកិច្ចល្អ[២] ។ សារៈសំខាន់ជាបង្អួរទៅលើមូលដ្ឋានគ្រឹះទាំងបីនេះ គឺអាស្រ័យទៅលើកាលៈទេសៈរបស់ប្រទេសនៅក្នុងពេលវេលាណាមួយនោះ ។ PRS ក៏បានកំណត់នូវអន្តរាគមន៍ចំនួនប្រាំតាមផ្នែក និងតាមប្រធានបទផងដែរ (ពោលគឺ អន្តរាគមន៍កាត់ទទឹង) ដែលជាការបំពេញបន្ថែមទៅលើមូលដ្ឋានគ្រឹះទាំងបីសម្រាប់កាត់បន្ថយភាពក្រីក្រ ។ ផ្នែកទាំងប្រាំនោះ ត្រូវបានបញ្ជាក់ឱ្យកាន់តែច្បាស់ដោយការត្រួតពិនិត្យលើ PRS ។ មានដូចជា (i) សមភាពយេនឌ័រ (ii) និរន្តរភាពបរិស្ថាន (iii) ការអភិវឌ្ឍវិស័យឯកជន (iv) កិច្ចសហប្រតិបត្តិការក្នុងតំបន់ និង (v) ការអភិវឌ្ឍសមត្ថភាព ។ PRS តម្រូវឱ្យជំនួយរបស់ ADB ផ្តោតទៅលើប្រទេស (ពោលគឺ ឱ្យចាក់ឫសចូលទៅក្នុងបរិបទប្រទេស និងទៅក្នុងការវាយតម្លៃភាពក្រីក្រប្រចាំប្រទេស) មានភាពសុខដុមជាមួយនឹងកិច្ចខិតខំប្រឹងប្រែងទាំងឡាយរបស់ដៃគូអភិវឌ្ឍន៍ផ្សេងៗ អាចបញ្ចូលទៅក្នុងយុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS)

---

[១]. ធនាគារ ADB ឆ្នាំ២០០៤ ការប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រនៅក្នុងតំបន់អាស៊ី និងប៉ាស៊ីហ្វិក : យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក្រុងម៉ានីល

[២] យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រលើកដំបូង (PRS) ត្រូវបានអនុម័តក្នុងឆ្នាំ១៩៩៩ ។ កម្មវិធី និងយុទ្ធសាស្ត្រប្រចាំប្រទេស ដែលបានបង្កើតនៅមុនឆ្នាំ១៩៩៩ មានភាពស្របគ្នាជាមួយនឹងបណ្តា អាទិភាព និងគោលនយោបាយជាច្រើន ។ ទោះបីជាកម្មវិធីជំនួយប្រចាំប្រទេសរបស់ធនាគារ ADB នឹងត្រូវបានវាយតម្លៃទៅលើវិភាគទានរបស់វាទៅលើមូលដ្ឋានគ្រឹះសំខាន់នៃយុទ្ធសាស្ត្រ PRS ហើយទោះបីជាការកាត់បន្ថយភាពក្រីក្រ ការធ្វើឱ្យមានកំណើន ការអភិវឌ្ឍសង្គម និងអភិបាលកិច្ចល្អ បានក្លាយជាវត្ថុបំណងជាច្រើន ដ៏ចម្បងៗរបស់ធនាគារ ADB ក៏ដោយ ក៏នេះមិនមានន័យ ថាកម្មវិធី និងយុទ្ធសាស្ត្រពីមុនៗ មានភាពស្របគ្នាទាំងស្រុងជាមួយនឹងយុទ្ធសាស្ត្រ PRS ក្រោយឆ្នាំ១៩៩៩ ដែរ ។

យ៉ាងពេញលេញ និងផ្តោតលើការសម្រេចបានជាលទ្ធផល ។ PRS ក៏បានបង្ហាញពីគោលបំណងរបស់ថ្នាក់ដឹកនាំចង់ធ្វើការត្រួតពិនិត្យលទ្ធផលនៃការអភិវឌ្ឍនៅតាមកម្រិតថ្នាក់ប្រទេសផងដែរ :

> លទ្ធផលប្រចាំប្រទេស នឹងត្រូវបានត្រួតពិនិត្យ ដោយពិនិត្យមើលទៅលើមូលដ្ឋានគ្រឹះទាំងបី និងអាទិភាពតាមប្រធានបទ ហើយលទ្ធផលនេះ នឹងក្លាយជាបណ្តុំនៃលទ្ធផលរបស់អន្តរាគមន៍របស់ ADB នៅក្នុងប្រទេស ទាំងសេវាកម្ចី និងសេវាមិនមែនកម្ចី ។ បណ្តាក្រុម *(ការងារ)* នៅតាមប្រទេស ជាអ្នកទទួលខុសត្រូវចំពោះការត្រួតពិនិត្យ PRS នៅតាមកម្រិតថ្នាក់ប្រទេស ។ ការធ្វើបច្ចុប្បន្នភាព CSP នឹងត្រួតពិនិត្យទៅលើវឌ្ឍនភាពនៃទិន្នផល ( អ្វីដែលសម្រេចបាន) និងលទ្ធផល ( លេខយោង ១) ។

៨. ADB ក៏មានភាពប្តេជ្ញាចិត្តខ្ពស់ប្រកាន់ខ្ជាប់ទៅនឹងស្តង់ដាសាកលនៃការអនុវត្តល្អនៅក្នុងការផ្តល់នូវជំនួយមកពីខាងក្រៅផងដែរ ។ ហេតុដូច្នេះហើយ CAPEs ត្រូវបានប្រើដើម្បីវាយតម្លៃថាតើការប្តេជ្ញាចិត្តជាសាកលរបស់ ADB មានកម្រិតប៉ុណ្ណាសម្រាប់ប្រទេស ។ ចាប់តាំងពីជំនួបកំពូលសហស្សវត្សរ៍នៅក្នុងឆ្នាំ២000 ADB បានចូលរួមយ៉ាងសកម្មនៅក្នុងការពិភាក្សាជាអន្តរជាតិជាច្រើនដែលមានគោលដៅកំណត់ និងនាំយកការអនុវត្តល្អមកប្រើប្រាស់ ដើម្បីជំរុញវឌ្ឍនភាពឆ្ពោះទៅរកគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ។ នៅក្នុងកិច្ចពិភាក្សាតុមូល Marrakech ស្តីពីការគ្រប់គ្រងដើម្បីសម្រេចបានលទ្ធផលឆ្នាំ២00៤ សហគមន៍អភិវឌ្ឍន៍បានអះអាងបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ខ្លួនក្នុងការធ្វើសកម្មភាពឱ្យស្របតាមលទ្ធផលអភិវឌ្ឍន៍ដែលចង់បាន ។ សហគមន៍នេះ បានកំណត់ពីរបៀបដែលការគាំទ្រអាចរួមចំណែកឱ្យមានលទ្ធផលប្រចាំប្រទេស និងតម្រូវឱ្យប្រើប្រាស់ និងពង្រឹងប្រព័ន្ធវាយតម្លៃ និងការត្រួតពិនិត្យនៅតាម កម្រិតថ្នាក់ប្រទេស ដើម្បីតាមដាននូវវឌ្ឍនភាព និងវាយតម្លៃលទ្ធផល ។ វេទិកាជាន់ខ្ពស់ក្រុងប៉ារីស ស្តីពីប្រសិទ្ធភាពនៃជំនួយនាថ្ងៃទី៣ ខែមិនា ឆ្នាំ២00៥ បានចេញនូវសេចក្តីថ្លែងការមួយស្តីពីប្រសិទ្ធភាពនៃជំនួយដែលទទួលបានការយល់ព្រមពីសំណាក់អ្នកតំណាង និងពីស្ថាប័នអភិវឌ្ឍន៍ផ្សេងៗ មកពីជាង ១00ប្រទេស ។ វេទិកានេះ ផ្តោតទៅលើគោលការណ៍ភាពជាម្ចាស់របស់ប្រទេស ភាពសុខដុមជាមួយគ្នា ភាពស៊ីគ្នា ការគ្រប់គ្រងដើម្បីឱ្យសម្រេចបានលទ្ធផល និងការទទួលខុសត្រូវចំពោះគ្នាទៅវិញទៅមក ។ ការជំរុញឱ្យមានភាពជាម្ចាស់បានខ្លាំងដែលជារបៀបវារៈនៃការអភិវឌ្ឍ ត្រូវបានផ្តោតការយកចិត្តទុកដាក់ម្តងទៀតនៅក្នុងកិច្ចព្រមព្រៀងអន្តរជាតិដែលមានគោលដៅលើកកម្ពស់ប្រសិទ្ធភាពនៃជំនួយ ។

៩. CSP ត្រូវបានរៀបចំឡើងដើម្បីផ្ទេរគោលដៅសំខាន់ៗ វត្ថុបំណងជាយុទ្ធសាស្ត្រ និងអាទិភាពប្រតិបត្តិការផ្សេងៗរបស់ ADB ចូលទៅក្នុងយុទ្ធសាស្ត្រប្រចាំប្រទេស ដែលយុទ្ធសាស្ត្រទាំងនេះ នឹងជួយគាំទ្រ NPRS និងជាផ្នែកមួយដែលនាំឱ្យមានការសម្រេចបានតាមគោលដៅ CSP របស់ខ្លួន ។ CSP ត្រូវបានធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំឆ្លើយតបទៅនឹងការប្រែប្រួលនៅក្នុងការអភិវឌ្ឍ និងមេរៀនដែលបានទទួលពីការអនុវត្តកម្មវិធី ។ CSP រួមជាមួយនឹងយុទ្ធសាស្ត្រ ដែលបានធ្វើបច្ចុប្បន្នភាពខ្លួនឯងនោះ ក៏ជាយានមួយយ៉ាងសំខាន់សម្រាប់ បញ្ចូលនូវមេរៀនទាំងឡាយដើម្បីធ្វើឱ្យកាន់តែមានប្រសិទ្ធភាពនៃជំនួយរបស់ ADB ដល់ប្រទេសនីមួយៗ ។ ថ្នាក់ដឹកនាំ និងនាយកប្រតិបត្តិរបស់ ADB បានវាយតម្លៃយ៉ាងខ្ពស់ចំពោះវិសាលភាពចំពោះមេរៀនដែលទទួលបានពីការវាយតម្លៃដោយឯករាជ្យ ហើយដែលត្រូវបានបញ្ចូលទៅក្នុង CSP ។ សម្រាប់មូលហេតុនេះ ប្រសិនបើ CAPE ត្រូវបានគេរៀបចំរួចហើយ នោះវានឹងត្រូវបានដាក់ជូន និងលើកយកមកពិភាក្សាដោយក្រុមប្រឹក្សាភិបាលនៃគណៈកម្មាការដើម្បីប្រសិទ្ធភាពនៃការអភិវឌ្ឍមិនខាន មុននឹងដាក់ជូន CSP ។

## គ. ការវាយតម្លៃលើភាពស៊ីសង្វាក់គ្នានៃគម្រោង

១0. តាមលទ្ធភាពដូច្នេះ CAPEs គួរតែផ្អែកទៅលើវិធីសាស្ត្រដែលអាចឱ្យសហគមន៍ផ្តល់ជំនួយអភិវឌ្ឍន៍សាកល ធ្វើការប្រៀបធៀបអំពីប្រសិទ្ធភាព និងវិភាគទានដែលនាំឱ្យមានការសម្រេចបានជាលទ្ធផលនៃជំនួយរបស់ ADB នេះជាមួយនឹងប្រសិទ្ធភាព និងវិភាគទានពីសំណាក់អ្នកផ្តល់ជំនួយអភិវឌ្ឍន៍ផ្សេងទៀត ។ ការណ៍នេះ ប្រាប់ពីភាពចាំបាច់ក្នុងការតម្រូវឱ្យមានការកំណត់និយមន័យរួម លក្ខណៈវិនិច្ឆ័យវាយតម្លៃការអនុវត្តការវាយតម្លៃ វិធីដាក់ចំណាត់ថ្នាក់ និងបច្ចេកទេសផ្សព្វផ្សាយក្នុងចំណោមការិយាល័យវាយតម្លៃឯករាជ្យនៃទីភ្នាក់ងារផ្តល់ជំនួយទាំងនេះ ។ ការធ្វើឱ្យស៊ីគ្នា

នូវវិធីវាយតម្លៃ ក៏អាចធ្វើឱ្យប្រសើរនូវការប្រើប្រាស់លទ្ធផលដែលធ្វើឡើងដោយបណ្ដារដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងៗទៀតផងដែរ ប្រសិនបើទីភ្នាក់ងារទាំងនោះ ប្រើប្រាស់នូវវិធី និងបទដ្ឋានរួម ។ បច្ចេកទេសវាយតម្លៃរួម ក៏មានតួនាទីសំខាន់ផងដែរ ប្រសិនបើមានការវាយតម្លៃទៅលើភាពស័ក្តិសិទ្ធនៃការអភិវឌ្ឍនៅក្នុងប្រទេសមួយនោះ ប្រសិនបើមានការយកមកប្រើនូវ MDGs យន្តការរៀបចំជំនួយរបស់អ្នកផ្ដល់ជំនួយ (ពោលគឺវិធីត្រួតពិនិត្យគ្រប់វិស័យ) និងកិច្ចព្រមព្រៀងដើម្បីធ្វើឱ្យជំនួយមានភាពសុខដុម និងបន្សីគ្នាជាមួយនឹង NPRS របស់អ្នកផ្ដល់ជំនួយផ្សេងទៀត ដែលក្នុងនោះមាន ADB ផងដែរ ។

១១. ក្រុមការងារទទួលបន្ទុកការវាយតម្លៃជំនួយនៃគណៈកម្មាការជំនួយអភិវឌ្ឍន៍របស់អង្គការដើម្បីកិច្ចសហប្រតិបត្តិការ និងការអភិវឌ្ឍ (OECD-DAC) បានរៀបចំសិក្ខាសាលាចំនួនពីររួចមកហើយ ស្ដីពីវិធីសាស្ត្រវាយតម្លៃកម្មវិធីប្រចាំប្រទេសនៅក្នុងឆ្នាំ១៩៩៤ និង ១៩៩៩ ។ សិក្ខាសាលាទាំងនេះ បានទទួលស្គាល់នូវសារៈសំខាន់ដែលចេះតែកើនឡើងនៃការវាយតម្លៃកម្មវិធីប្រចាំប្រទេស ខណៈពេលដែលស្ថាប័នផ្ដល់ជំនួយ បានចាប់ផ្ដើមពង្រីកចេញពីគម្រោងតែដោយឡែករបស់ពួកគេដែលជាទម្រង់ជាមូលដ្ឋានគាំទ្រការអភិវឌ្ឍនោះ ឆ្ពោះទៅរកការរួមបញ្ចូលគ្នានូវគម្រោងជាច្រើនដែលមានជំនួយកម្មវិធីតាមវិស័យ និងផ្អែកលើគោលនយោបាយ ។ សិក្ខាសាលាឆ្នាំ១៩៩៩ បានទទួលស្គាល់នូវកុងសង់ស៊ីសរួម *(ការរួមគ្នាជាឯកច្ឆ័ន្ទ)* ទៅលើលក្ខណៈវិនិច្ឆ័យវាយតម្លៃមូលដ្ឋានដែលប្រើដោយស្ថាប័នភាគច្រើនលើសលប់ ហើយយល់ស្របគ្នាថា លក្ខណៈវិនិច្ឆ័យសម្រាប់វាយតម្លៃក្នុងកម្រិតថ្នាក់ប្រទេស អាចប្រើប្រាស់លក្ខណៈវិនិច្ឆ័យទាំងឡាយណាដែលបានប្រើ វាយតម្លៃគម្រោងវិស័យសាធារណៈបាន (ពោលគឺ មានភាពទាក់ទងប្រសិទ្ធភាព ប្រសិទ្ធផល ផលប៉ះពាល់ និងនិរន្តរភាព) ។ ចាប់តាំងពី សិក្ខាសាលាក្នុងឆ្នាំ១៩៩៩ មក ចំនុចស្នូលរួមនៃការអនុវត្តល្អសម្រាប់ការវាយតម្លៃតាមប្រទេស បានវិវត្ត ហើយបន្តិចម្ដងៗ ការអនុវត្តទាំងនោះ ត្រូវបានយកមកប្រើ និងទទួលការឯកភាពពីការិយាល័យវាយតម្លៃឯករាជ្យនៃ MDB ផ្សេងៗទៀត ។ ក្រុមកិច្ចសហប្រតិបត្តិការ វាយតម្លៃនៃ MDB ដែលក្នុងនោះ ADB ក៏ជាសមាជិកដែរនោះ បានដាក់បញ្ហានៃវិធីសាស្ត្រវាយតម្លៃកម្មវិធីប្រចាំប្រទេស ក្នុងរបៀបវារៈរបស់ខ្លួន ។ គោលបំណងនោះ គឺបង្កើតឱ្យមាននូវបទដ្ឋានអនុវត្តន៍ល្អនានា សម្រាប់កិច្ចការរបស់ខ្លួន ដូចដែលក្រុមកិច្ចសហប្រតិបត្តិវាយតម្លៃ បានអនុម័តនូវបទដ្ឋានសម្រាប់វាយតម្លៃកម្រិតថ្នាក់គម្រោង ប្រតិបត្តិការរបស់វិស័យឯកជន និងកម្មវិធីផ្អែកលើគោលនយោបាយ ។

## ឃ. វត្ថុបំណង និងគោលដៅវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

១២. គោលដៅរបស់ CAPE គឺវាយតម្លៃវិភាគទានរបស់ ADB ដែលនាំឱ្យសម្រេចបាននូវលទ្ធផលនៅក្នុង DMC នៅក្នុងពេលវេលាកំណត់ជាក់លាក់ណាមួយ និងដើម្បីទាញយកបទពិសោធន៍ពីមេរៀន ដើម្បីឱ្យ ADB អាចដឹងពីរបៀបធ្វើឱ្យកាន់តែប្រសើរនូវការអនុវត្តកម្មវិធីជំនួយអភិវឌ្ឍន៍នាពេលអនាគតរបស់ខ្លួនបាន ។ នៅពេលដែលការវាយតម្លៃមួយ រួមបញ្ចូលគ្នានូវការពិនិត្យមើលទៅលើសកម្មភាព និងលទ្ធផលដែលសម្រេចបានកាលពីមុន ដោយប៉ាន់ស្មានទុកចំពោះលទ្ធផលពីប្រតិបត្តិការនាពេលបច្ចុប្បន្នរបស់ខ្លួនផងនោះ គោលបំណងរបស់ CAPE គឺការរួមចំណែកផ្ដល់នូវមេរៀនថ្មីៗ ដើម្បីជួយធ្វើឱ្យប្រសើរនូវ CSP ក្នុងពេលបន្តបន្ទាប់ និងដើម្បីផ្ដល់មេរៀនទូទៅដល់ ADB ។ CAPEs មិនត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីវាយតម្លៃលើវឌ្ឍនភាពការអភិវឌ្ឍរបស់ប្រទេសណាមួយនោះទេ ។ CAPEs ក៏មិនវាយតម្លៃទៅលើរដ្ឋាភិបាល ឬវឌ្ឍនភាពនៃការអភិវឌ្ឍរបស់ប្រទេសណានោះដែរ ។ ផ្ទុយមកវិញ CAPEs ផ្ដោតទៅលើលទ្ធផលនៃកម្មវិធីជំនួយជាក់លាក់ណានោះ ដែលមានការឯកភាពរវាងរដ្ឋាភិបាលនឹង ADB តែប៉ុណ្ណោះ ។

១៣. វត្ថុបំណងដ៏សំខាន់របស់ CAPE គឺដើម្បីកំណត់រកឱ្យឃើញ និងវាយតម្លៃកត្តាគន្លឹះ ដែលធ្វើឱ្យសម្រេចបាននូវលទ្ធផលក្រោមកម្មវិធីជំនួយរបស់ ADB ក្នុងគោលបំណងដើម្បីទាញយកនូវបទពិសោធន៍មេរៀន ។ កម្មវិធីជំនួយ តម្រូវឱ្យមានការវាយតម្លៃជាចាំបាច់ទៅលើភាពសមស្របនៃយុទ្ធសាស្ត្រដែលយកមកប្រើ និងថាតើកម្មវិធីនោះ សម្រេចនូវវត្ថុបំណងជាក់លាក់បានក្នុងកម្រិតណា ដែលវត្ថុបំណងទាំងនោះ ជាទូទៅ គឺជាវត្ថុបំណងតូចៗនៃវត្ថុបំណងអភិវឌ្ឍន៍ប្រទេស ។ ប្រសិនបើកម្មវិធីជំនួយរបស់ ADB មានភាពធំធេង ធៀបជាមួយនឹងកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ទាំងអស់របស់រដ្ឋាភិបាល នោះលទ្ធផលរបស់កម្មវិធី នឹងមានភាពស្រដៀងគ្នាទៅនឹងវឌ្ឍនភាពអភិវឌ្ឍន៍ទាំងអស់របស់ប្រទេសនោះដែរ ។ ផ្ទុយមកវិញ

កម្មវិធីជំនួយរបស់ ADB ភាគច្រើន គ្រាន់តែជាចំណែកដ៏តូចមួយនៃធនធានទាំងអស់ ដែលបានប្រើទៅលើកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍន៍ប្រទេសតែប៉ុណ្ណោះ ។ នៅក្នុង CAPE ខ្លួនឯងនេះ OED ធ្វើការវាយតម្លៃ (ហើយចាត់ ចំណាត់ថ្នាក់) ទៅលើតែលទ្ធផលណាដែល ADB បានរួមចំណែក និងមិនវាយតម្លៃលើដំណើរការអភិវឌ្ឍទាំងអស់របស់ប្រទេសនោះទេ ទោះបីជាដំណើរការនៃការអភិវឌ្ឍប្រទេសនេះ ជាប់ពាក់ព័ន្ធយ៉ាងច្បាស់ជាមួយនឹងវិនិច្ឆ័យលទ្ធផលរបស់កម្មវិធីក៏ដោយ ។

## ង. ការគ្របដណ្តប់ និងវិសាលភាពនៃការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

១៤. នៅក្នុង DMC ណាមួយក៏ដោយ ADB អាចមានតួនាទីយ៉ាងសកម្មនៅក្នុងវិស័យ និងអនុវិស័យជាច្រើន ហើយជំនួយអាចគ្របដណ្តប់ទៅលើគម្រោងដែលមានមុខព្រួញច្រើន ទៅលើបណ្តុំកម្មវិធីលើ TA និងលើផលិតផលកើតចេញពីចំណេះដឹង។ ជំនួយរបស់ ADB កើនឡើងហួសពីសកម្មភាពជាផ្លូវការរបស់ខ្លួនទៅទៀត ដើម្បីឱ្យមានតួនាទីនៅក្នុងការពិភាក្សាលើគោលនយោបាយ ក៏ដូចជានៅក្នុងការសម្របសម្រួល និងធ្វើជាកាតាលីករកៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ពីវិស័យឯកជន និងសង្គមស៊ីវិល ។ ជំនួយនេះ គឺជាការបន្សំចូលគ្នាពីផ្នែកជាច្រើន (ពោលគឺពីសេវាកម្ម និងសេវាមិនមែនកម្ចី) នៃជំនួយរបស់ ADB ហើយដែលជាជំនួយមួយយ៉ាងសំខាន់ ធ្វើឱ្យមានការជះឥទ្ធិពលទៅលើលទ្ធផលតាមកម្រិតថ្នាក់ប្រទេស ។CAPE នឹងធ្វើការកំណត់ និងវាយតម្លៃទៅលើបណ្តាសេវាកម្មជំនួយដែលបានរួមចំណែកធ្វើឱ្យមានលទ្ធផលអភិវឌ្ឍន៍ ។

១៥. នៅក្នុងប្រទេសជាច្រើន CAPE មិនអាចវាយតម្លៃទៅលើតួនាទី និងសកម្មភាពនៃជំនួយរបស់ ADB តែឯកឯងបានទេ ។ ការព្យាយាមដោះស្រាយជាមួយ បញ្ហាច្រើនពេក បានបង្កើតនូវហានិភ័យដែលធ្វើឱ្យលទ្ធផលរកឃើញនោះ មានភាពមិនស៊ីជម្រៅ ។ ផ្ទុយមកវិញ CAPE និងធ្វើការកំណត់ និងវាយតម្លៃស៊ីជម្រៅទៅលើ បញ្ហាគន្លឹះៗតែប៉ុណ្ណោះ ក្នុងគោលបំណងវាយតម្លៃឱ្យបានច្បាស់ពីមូលហេតុនាំឱ្យមានលទ្ធផល និងចងក្រងជាមេរៀន និងអនុសាសន៍សម្រាប់ជាជំនួយនាពេលក្រោយៗទៀត ។

១៦. CAPE នឹងគ្របដណ្តប់ទៅលើបរិបទប្រទេស គុណភាពនៃយុទ្ធសាស្ត្រ និងកម្មវិធីរបស់ ADB លើលទ្ធផលនិងការអនុវត្តរបស់ខ្លួន និងលើវិភាគទានរបស់ ADB ចំពោះការអភិវឌ្ឍទាំងអស់ ។ វិសាលភាពនេះ នឹងត្រូវកម្រិតដោយ (i) ផ្តោតទៅលើតែការប្រើប្រាស់ជំនួយក្នុងទសវត្សរ៍ចុងក្រោយដោយទទួលស្គាល់ថា លទ្ធផលក្នុងពេលបច្ចុប្បន្នទទួលរងឥទ្ធិពលពីប្រតិបត្តិការ និងយុទ្ធសាស្ត្រជំនួយដែលបានចាប់ផ្តើមឆាប់រហ័សពេក (ii) វាយតម្លៃទៅលើកម្លាំងចលករសំខាន់ៗ ដែលធ្វើឱ្យមានការវិវត្តកម្មវិធីជំនួយ និងកំណត់សកម្មភាពជំនួយចាំបាច់ (ពោលគឺ សកម្មភាព និងតួនាទីរបស់ជំនួយ) នៅក្នុងវិស័យណាមួយ ឬនៅក្នុងប្រធានបទណាមួយ និង (iii) អនុវត្តគំរូសមស្របទៅតាមគោលដៅចេញពីបណ្តាសកម្មភាពជំនួយសំខាន់ៗដែលពាក់ព័ន្ធ (ពោលគឺ គម្រោង កម្មវិធី TA ផលិតផលកើតចេញពីចំណេះដឹង សកម្មភាព កាតាលីករ និងសកម្មភាពសម្របសម្រួល) និងតួនាទីនៃនិវាសនដ្ឋានបេសកកម្មផងដែរ។

១៧. **ការជ្រើសរើសគំរូ** CAPE នឹងធ្វើការសនិដ្ឋានរបស់ខ្លួនតាមរយៈគំរូមានគោលបំណងដែលបានជ្រើសរើសចេញពីសកម្មភាពជំនួយរបស់ ADB ដែលគំរូទាំងនេះ ត្រូវបានរៀបចំឡើងដើម្បីឆ្លុះបញ្ចាំងពីកម្លាំងចលករសំខាន់ៗដែលធ្វើឱ្យមានការវិវត្តកម្មវិធីជំនួយតាមប្រធានបទ និងតាមវិស័យរបស់ ADB ។ គំរូនេះ គ្របដណ្តប់ទៅលើវិស័យសំខាន់ៗទាំងអស់ដែល ADB ជាប់ពាក់ព័ន្ធ ។ វិស័យ (និងអនុវិស័យ) ដែល ADB មានប្រតិបត្តិការបន្តិចបន្តួចនោះ ហើយគ្មានសេវាកម្ចីផ្តល់ជូននោះ ជាទូទៅ នឹងមិនត្រូវរាប់បញ្ចូលទេ ។ នៅក្នុងវិស័យនីមួយៗ (ឬតាមប្រធានបទនីមួយៗ) CAPE នឹងធ្វើការត្រួតពិនិត្យនូវកម្លាំងចលករកម្មវិធីសំខាន់ៗនៃជំនួយរបស់ ADB។ កម្លាំងចលករកម្មវិធី នីមួយៗ ជាទូទៅ គឺជាការបន្សំចូលគ្នានៃកម្មវិធី និងគម្រោងដែលបានបញ្ចប់ និងដែលកំពុងអនុវត្ត បូករួម TA ដែលជាប់ពាក់ព័ន្ធ ការងារសេដ្ឋកិច្ច និងការងារតាមវិស័យ ការពិភាក្សាគោលនយោបាយ និងសកម្មភាពសម្របសម្រួលជាមួយដៃគូរអភិវឌ្ឍន៍ ។

១៨. ទោះបីជា CAPE ជាទូទៅ កម្រិតការគ្របដណ្ដប់របស់ខ្លួនត្រឹមតែទៅលើការប្រើប្រាស់ជំនួយរបស់ ADB តែក្នុងទសវត្សរ៍កន្លងមក រួមមានការសម្រេចបាន លទ្ធផលតាមការរំពឹងទុកនៃប្រតិបត្តិការដែលកំពុងដំណើរការក៏ដោយ ក៏ CAPE នឹងត្រួតពិនិត្យនូវការរៀបចំកម្មវិធីជំនួយរបស់ ADB ក្នុងរយៈពេលវែងដែរដើម្បីឆ្លុះបញ្ចាំងពីលទ្ធផល និងសកម្មភាពនាពេលបច្ចុប្បន្ន ។ គម្រោងមុនៗ និងការផ្លាស់ប្ដូរក្នុងទ្រង់ទ្រាយណាមួយបង្គួរនៅក្នុងផលប័ត្រ អាចត្រូវបានយកមកប្រើដើម្បីវាយតម្លៃលើការរៀបចំកម្មវិធី និងយុទ្ធសាស្ត្ររបស់ ADB ក្នុងទសវត្សរ៍កន្លងមក ដោយចង្អុលបង្ហាញពីកាលានុវត្តភាពដែលបានខកខាន និងកំណត់រកឱ្យឃើញនូវកំហិតចំពោះការអភិវឌ្ឍដែលនៅមិន ទាន់មានការលាតត្រដាងណាមួយនៅឡើយនោះ ។

១៩. ស្ថិតនៅក្នុងកម្លាំងចលករដ៏សំខាន់ៗ របស់កម្មវិធី CAPEs គួរតែគ្របដណ្ដប់ការងាររបស់ខ្លួនលើគ្រប់មុខព្រួញទាំងអស់នៃតួនាទី និងប្រតិបត្តិការនៃជំនួយរបស់ ADB នៅក្នុង DMC ដែលជាប់ពាក់ព័ន្ធ ផ្នែកទាំងនោះមានដូចជា :

(i) ការងារសេដ្ឋកិច្ច និងការងារតាមវិស័យ តាមប្រធានបទ ដែលរ៉ាប់រងដោយបុគ្គលិក និងបុគ្គលិកជាទីប្រឹក្សា ឬទទួលហិរញ្ញប្បទានជាជំនួយផ្ដល់ការប្រឹក្សាខាងបច្ចេកទេសដែលក្នុងនោះ រួមមានរបាយការណ៍សេដ្ឋកិច្ច ការត្រួតពិនិត្យមើលលើសេដ្ឋកិច្ច យុទ្ធសាស្ត្រតាមវិស័យ និងរបាយការណ៍វាយតម្លៃ និងការសិក្សាតាមបណ្ដាប្រធានបទទៅលើបញ្ហាដែលប្រទាក់ក្រឡាគ្នា រួមមាន បញ្ហាបរិស្ថាន វិស័យឯកជន អភិបាលកិច្ច យេនឌ័រ ឬភាពក្រីក្រ

(ii) ការបង្កើតកម្មវិធីជំនួយប្រចាំប្រទេស រួមទាំងការបង្កើត និងការរៀបចំជាក់ស្ដែងនៃកម្មវិធី និងយុទ្ធសាស្ត្រប្រតិបត្តិការប្រចាំប្រទេសកាលពីលើកមុនៗ ផងដែរ

(iii) លទ្ធផលដែលបានធ្វើរបាយការណ៍ (ពោលគឺ ទិន្នផល លទ្ធផល និងផលប៉ះពាល់) ដោយផ្អែកលើទិន្នន័យផលប័ត្រដែលក្នុងនោះ រួមមានរបាយការណ៍ស្ដីពីវឌ្ឍនភាពនៃការអនុវត្តគម្រោង និង TA របាយការណ៍ស្ដីពីការវាយតម្លៃលើការអនុវត្តរបាយការណ៍កម្មវិធីជំនួយតាមវិស័យ និងការសិក្សាវាយតម្លៃពិសេស ដោយហេតុថារបាយការណ៍ និងការសិក្សាទាំងនោះ ធ្វើឡើងនៅក្នុងប្រទេសដែលជាប់ពាក់ព័ន្ធទាំងនោះ ហើយ

(iv) ដូចជាទៅលើផ្នែកនៃសេវាដែលមិនមែនកម្ចី រួមមាន ការពិភាក្សាគោលនយោបាយ ការធ្វើឱ្យមានសុខដុមនីយកម្ម និងការសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ ការផ្ដល់នូវចំណេះដឹងថ្មីៗ និងការជំរុញឱ្យមានភាពជាម្ចាស់ និងការចូលរួម

២០. **វិសាលភាព** CAPE គួរតែដោះស្រាយបញ្ហាជាក់លាក់ណាដែលតែងកើតមានជាទូទៅសម្រាប់ប្រទេសទាំងអស់ ក្នុងពេលដែលខ្លួន ក៏កំពុងតែគ្របដណ្ដប់ទៅ លើវិសាលភាពបញ្ហាសំខាន់ៗដែលសុទ្ធតែជាបញ្ហាជាក់លាក់តាមប្រទេសនីមួយៗនោះ ។ បញ្ហាទូទៅមានដូចជា :

(i) **បរិបទ** ឥទ្ធិពលនៃបរិការណ៍ប្រទេស (នយោបាយ សង្គម សេដ្ឋកិច្ច និងប្រវត្តិសាស្ត្រ) ទៅលើចរិតនៃបញ្ហាប្រឈមចំពោះការអភិវឌ្ឍន ការឆ្លើយ តបជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងតួនាទីជំនួយរបស់ ADB ។

(ii) **ភាពបន្សុីគ្នា** យុទ្ធសាស្ត្រ និងកម្មវិធីជំនួយប្រចាំប្រទេសទាំងអស់របស់ ADB និងភាពបន្សីនៃយុទ្ធសាស្ត្រ និងកម្មវិធីទាំងនោះជាមួយនឹង NPRS ឬផែនការអភិវឌ្ឍជាតិ ព្រមទាំងទំនាក់ទំនង និងការឆ្លើយតបរបស់ខ្លួន ទៅនឹងបញ្ហាប្រឈមចំពោះការអភិវឌ្ឍដែលបង្កដោយប្រទេសខ្លួនឯង ។

(iii) **ភាពសុីសង្វាក់គ្នា** កម្រិតដែលយុទ្ធសាស្ត្រ និងកម្មវិធីជំនួយរបស់ ADB ត្រូវបានសម្របសម្រួល រៀបចំ និងធ្វើសមាហរណកម្មជាមួយនឹងកម្មវិធី និងយុទ្ធសាស្ត្ររបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀតប្រកបដោយប្រសិទ្ធភាព ។ កម្រិតនេះ មានដូចជា ភាពសុីសង្វាក់គ្នា រវាងនីតិវិធីរបស់រដ្ឋាភិបាល ដែលជាអតិថិជន និងដៃគូអភិវឌ្ឍន៍ និងទាំងក្នុងចំណោមដៃគូអភិវឌ្ឍន៍ខ្លួនឯងផងដែរ ។

(iv) **ការរួមកម្លាំងគ្នា.** កម្រិតដែលយុទ្ធសាស្ត្រ និងកម្មវិធីជំនួយរបស់ ADB បានរួមបញ្ចូលរួមគ្នារវាងអន្តរាគមន៍ និងតួនាទីជំនួយដែលសម្រេចបាន នូវលទ្ធផលអភិវឌ្ឍន៍ ដែលលទ្ធផលនេះ មានលក្ខណៈទូលំទូលាយជាងលទ្ធផលដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងនៃជំនួយរបស់ភាគីតែម្ខាង ។

(v) **អភិបាលកិច្ចល្អ** កម្រិតដែលយុទ្ធសាស្ត្រ និងកម្មវិធីជំនួយរបស់ ADB គាំទ្រការរីកចម្រើននៅតាមវិស័យ និងអភិបាលកិច្ចស្នូលរួមមាន ដូចជាកិច្ចខិតខំប្រឹងប្រែងដើម្បីជួយរដ្ឋភិបាលប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ និងការលើកកម្ពស់ការអភិវឌ្ឍស្ថាប័នជាដើម ។

(vi) **ការអនុវត្ត.** ការប្រតិបត្តិ និងកត្តាជះឥទ្ធិពល ការអនុវត្តកម្មវិធីជំនួយរបស់ ADB ។ ការអនុវត្តនេះ រួមបញ្ចូលវឌ្ឍនភាពនៃកម្មវិធីដែលកំពុងដំណើរការ និងលទ្ធភាពដែលប្រតិបត្តិការទាំងនេះ សម្រេចលទ្ធផលគួរជាទីពេញចិត្ត ។

(vii) **លទ្ធផល** កម្រិតដែលកម្មវិធីជំនួយ និងយុទ្ធសាស្ត្រសម្រាប់ប្រទេសរបស់ ADB ធ្វើវិភាគទានជួយសម្រេចបាននូវទិន្នផល និងលទ្ធផលសំខាន់ៗនៅក្នុងវិស័យចម្បងៗ នៅក្នុងមូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រ (កំណើនការអភិវឌ្ឍសង្គម អភិបាលកិច្ចល្អ [លេខយោង ១][៣]) និងនៅក្នុងវិស័យតាមប្រធានបទសំខាន់ៗ (ការអភិវឌ្ឍវិស័យឯកជន និរន្តរភាពបរិស្ថាន) ដែលទទួលបានការគាំទ្រពី ADB ។

(viii) **ផលប៉ះពាល់** ការរួមវិភាគទានក្នុងរយៈពេលវែងចំពោះការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសេដ្ឋកិច្ច ដែលអាចសម្រេចបាន ឬដែលរំពឹងទុកតាមរយៈឥទ្ធិពលដោយផ្ទាល់ ដោយប្រយោល និងដែលជាកាតាលិករនៃជំនួយរបស់ ADB[៤] ។

(ix) **ការប្តេជ្ញាចិត្តរួមគ្នា** កម្រិតដែលជំនួយប្រចាំប្រទេស ជួយរួមចំណែកធ្វើឱ្យមានការប្តេជ្ញាចិត្តរួមគ្នា ដែលរួមមានវឌ្ឍនភាពឆ្ពោះទៅរកការសម្រេចបានគោលដៅនៃគោលនយោបាយតាមបណ្តាវិស័យ ដូចជា កិច្ចសហប្រតិបត្តិការក្នុងតំបន់ ការគាំពារគោលនយោបាយ និងគោលនយោបាយប្រឆាំងភាពក្រីក្រ

២១. បញ្ហាជាក់លាក់តាមប្រទេស ក៏អាចលើកយកមកពិភាក្សារកដំណោះស្រាយនៅក្នុង CAPE បានដែរ ។ ការលើកយកមកពិភាក្សានេះ រួមមានការលើកយកបញ្ហាដែលមានឥទ្ធិពលផ្ទាល់លើការកំណត់រកឱ្យឃើញនូវបញ្ហាប្រឈមចំពោះការអភិវឌ្ឍលើការបង្កើត និងការដាក់ឱ្យអនុវត្តកម្មវិធី និងយុទ្ធសាស្ត្ររបស់ ADB និងលើការសម្រេចឱ្យបាននូវលទ្ធផលជំនួយ ។

---

[៣] កម្រិតដែលគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ ADB ទទួលបានការគាំទ្រ ហើយជំនួយជាក់លាក់ដែលបានផ្តល់សម្រាប់ការប្រយុទ្ធប្រឆាំងអំពើពុករលួយ នឹងត្រូវបានវាយតម្លៃដែលជា ផ្នែកមួយនៃការត្រួតពិនិត្យមើលឡើងវិញទៅលើការគាំទ្ររបស់ ADB ដើម្បីអភិបាលកិច្ចល្អ ។

[៤] គំនិតផ្តួចផ្តើមតាមប្រធានបទផ្សេងៗ ដូចជាយេនឌ័រ និងការអភិវឌ្ឍក្នុងតំបន់ នឹងទទួលការវាយតម្លៃសម្រាប់ DMCs ទាំងនោះដែលប្រធានបទទាំងនេះ ត្រូវបានកំណត់ថាជាកំហិតដ៏ធ្ងន់ធ្ងរចំពោះការកាត់បន្ថយភាពក្រីក្រ ។

## II. វិធីសាស្ត្រវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

### ក. សំណួរគន្លឹះៗ និងលក្ខណៈវិនិច្ឆ័យវាយតម្លៃ

២២. CAPE ត្រូវបានរៀបចំឡើង ដើម្បីឆ្លើយសំនួរបីដែលជាប់ទាក់ទងគ្នាទៅវិញទៅមក :

(i) តើកម្មវិធី និងយុទ្ធសាស្ត្ររបស់ ADB ដែលយកមកប្រើដើម្បីដោះស្រាយបញ្ហាប្រឈមចំពោះការអភិវឌ្ឍ មានការប្រឈមមុខជាមួយនឹង DMC ដែរឬទេ ? តើ ADB ជួយរួមចំណែកសម្រេចឱ្យបាននូវវត្ថុបំណងការអភិវឌ្ឍចម្បង នៃប្រទេសនីមួយៗដោយរបៀបណា និងបានកម្រិតណាដូចដែលបានចែងនៅក្នុងយុទ្ធសាស្ត្ររបស់ប្រទេសនោះ? តើកម្មវិធី និងយុទ្ធសាស្ត្ររបស់ ADB មានភាពស៊ីគ្នាជាមួយនឹងអាទិភាពជាតិ ហើយត្រូវបានដាក់ចុះក្នុងស្ថានភាពល្អដែរ ឬទេ បើពិចារណាទៅលើអាណត្តិរបស់ ADB និងសមត្ថភាពរបស់ប្រទេស និងតើមានភាពសុខដុមជាមួយនឹងជំនួយដែលផ្តល់ដោយដៃគូអភិវឌ្ឍន៍ផ្សេងទៀតដែរ ឬទេ ? តាមការអនុវត្ត តើកម្មវិធី ADB មានភាពស្របតាមកម្មវិធី និងយុទ្ធសាស្ត្របត់បែនដែរ ឬទេ ?

(ii) តើជំនួយរបស់ ADB (ទាំងសេវាកម្ចី និងសេវាមិនមែនកម្ចី) មានប្រសិទ្ធភាពក្នុងការសម្រេចនូវវត្ថុបំណងគួរជាទីពេញចិត្តដែរ ឬទេ ? ប្រសិនបើមាន តើវត្ថុបំណងទាំងនោះសម្រេចបានប្រកបដោយប្រសិទ្ធភាពដែរ ឬទេ ? តើលទ្ធផលដែលសម្រេចបាននោះមាន និរន្តរភាពយូរអង្វែងដែរ ឬទេ ?

(iii) តើជំនួយរបស់ ADB មានបានរួមចំណែកសម្រេចនូវលទ្ធផល ដែលនឹងធ្វើឱ្យប្រសើរនូវសមត្ថភាពរបស់ DMC ដើម្បីប្រយុទ្ធប្រឆាំងនឹងភាពក្រីក្រ និងជំរុញការអភិវឌ្ឍសង្គមសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពដែរ ឬទេ ?

២៣. ចម្លើយចំពោះសំណួរទាំងនេះ អាស្រ័យលើប្រសិទ្ធភាពនៃកិច្ចខិតខំប្រឹងប្រែងជំនួយអភិវឌ្ឍន៍របស់ ADB ។ យោងតាមសន្ទានុក្រម[៥] វាយតម្លៃរបស់ OECD-DAC ប្រសិទ្ធភាពនៃការអភិវឌ្ឍ មានន័យថា " កម្រិតដែលវត្ថុបំណងនៃអន្តរាគមន៍ដើម្បីអភិវឌ្ឍន៍ អាចសម្រេចបាន ឬត្រូវបានរំពឹងទុកថានឹងសម្រេចបាន បើពិចារណាទៅលើសារៈសំខាន់ដែលមានជាបង្គួរនៃវត្ថុបំណងនោះ "ដោយការពង្រីកនិយមន័យការអនុវត្ត CAP អាចកំណត់និយមន័យបានថា ជាកម្រិតដែលកម្មវិធីរបស់ ADB សម្រេចបាននូវវត្ថុបំណងអភិវឌ្ឍន៍របស់ខ្លួន បើពិចារណាទៅលើសារៈសំខាន់ដែលមានជាបង្គួរនៃវត្ថុបំណងនោះ ។

២៤. ចាំបាច់ត្រូវមានសំណុំនៃលក្ខណៈវិនិច្ឆ័យមួយច្បាស់លាស់ ដើម្បីបង្កើតនូវសំណុំបទដ្ឋានមួយ សម្រាប់វត្ថុបំណងនៅពេលធ្វើការវិនិច្ឆ័យបែបវាយតម្លៃអំពីប្រសិទ្ធភាពអភិវឌ្ឍន៍នៃ CAP របស់ ADB ។ លក្ខណៈវិនិច្ឆ័យដែលនឹងត្រូវយកមកប្រើនោះ រួមមាន ទំនាក់ទំនង ប្រសិទ្ធផល ប្រសិទ្ធភាព និរន្តរភាព និងផលប៉ះពាល់នៃកិច្ចខិតខំប្រឹងប្រែងរបស់ជំនួយ ។ សូមជួយផ្តល់ជាអនុសាសន៍ឱ្យជ្រើសរើសយកលក្ខណៈវិនិច្ឆ័យទាំងនេះ ដើម្បីវាយតម្លៃប្រតិបត្តិការវិស័យសាធារណៈដែលអនុវត្តដោយ OECD-DAC និងដោយក្រុមកិច្ចសហប្រតិបត្តិការវាយតម្លៃរបស់ MDBs ។ លក្ខណៈវិនិច្ឆ័យទាំងនេះត្រូវបានគេបកស្រាយដើម្បីឆ្លុះបញ្ចាំងពីការអនុវត្ត CAP ដូចខាងក្រោម :

(i) **ភាពទាក់ទង** ភាពជាប់ទាក់ទងនេះ មួយផ្នែកគឺសំដៅទៅលើ (ក) ថាតើការផ្តោតយកចិត្តទុកដាក់ទៅលើកម្មវិធី និងយុទ្ធសាស្ត្ររបស់ ADB មានភាពស្របគ្នាជាមួយនឹងបេសកកម្មរបស់ ADB ដែរ ឬទេ រីឯមួយផ្នែកទៀត គឺថាតើកម្មវិធី និងយុទ្ធសាស្ត្រទាំងនេះមានភាពស្របគ្នាជាមួយនឹងស្ថានភាពសេដ្ឋកិច្ចសំខាន់ៗដែលកំពុងតែវិវត្តដែរ ឬទេ តើស្របជាមួយនឹងអាទិភាព និងសមត្ថភាពទទួលយករបស់ DMCs ដែរ ឬទេ (ខ) កម្រិតដែលការគាំទ្ររបស់ ADB មានភាពស៊ីគ្នាជាមួយនឹងយុទ្ធសាស្ត្រ និងគោលនយោបាយជាតិ (គ) កម្រិតដែលការគាំទ្ររបស់ ADB មានភាពស្របគ្នាជាមួយនឹងឧត្តមភាពផ្តល់ជំនួយ ដោយប្រៀបធៀបដែលកំពុងតែ

---

[៥] OECD/DAC. 2004. សន្ទានុក្រមវាក្យស័ព្ទគន្លឹះប្រើនៅក្នុងការវាយតម្លៃ និងការគ្រប់គ្រងផ្អែកលើលទ្ធផល. ទីក្រុងប៉ារីស

វិវត្តន៍របស់ ADB (ឃ) កម្រិតដែលអន្តរាគមន៍របស់ ADB សម្រេចបាននូវលទ្ធផលដល់កម្រិតដែលនាំឱ្យមានការប្រែប្រួល ត្រូវបានថ្លឹងថ្លែងធៀបទៅនឹងការសម្រេចនូវវត្ថុបំណងទាំងអស់ លើកម្រិតនៃការជ្រើសរើសយកមកប្រើ និងទៅលើកម្រិតដែលផ្តោតចំពោះបញ្ហា និង (ង) កម្រិតដែលជំនួយរបស់ ADB មានភាពសុខដុមជាមួយនឹងជំនួយរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ។ អនុលក្ខណៈវិនិច្ឆ័យទាំងនេះ មានគោលបំណងពិនិត្យមើលលើភាពស៊ីគ្នា លើការឯកភាពគ្នា លើភាពទូលំទូលាយ លើការឆ្លើយតបលើការកំណត់ស្ថានភាព និងលើភាពសុខដុមនៃកម្មវិធីជំនួយរបស់ ADB ។

(ii) **ប្រសិទ្ធផល** ប្រសិទ្ធផលធ្វើការប្រៀបធៀបការសម្រេចបាននៃគោលដៅ និងវត្ថុបំណង CAP ជាមួយនឹងការប្រើប្រាស់ធនធានជំនួយរបស់ ADB ។ ប្រសិទ្ធភាពនេះ ត្រូវបានវាស់វែងដោយពិនិត្យមើលលើកម្រិតនៃការប្រើប្រាស់ធនធានឱ្យអស់ពីលទ្ធភាពដូចជាទៅលើ (ក) វិភាគទានទាំងអស់នៃជំនួយរបស់ ADB ដែលនាំឱ្យមានវឌ្ឍនភាពសង្គមសេដ្ឋកិច្ចដែលផ្អែកលើមូលដ្ឋានទូលំទូលាយតាមរយៈការគាំទ្រគោលនយោបាយសំខាន់ៗ និងកំណែទម្រង់តាមស្ថាប័ន (ខ) អត្ថប្រយោជន៍ដោយផ្ទាល់ និងផ្នែកសេដ្ឋកិច្ចទាំងអស់នៃកម្មវិធីជំនួយរបស់ ADB (គ) កម្រិតនៃអត្ថប្រយោជន៍ដែលជំនួយរបស់ ADB បានធ្លាក់ដល់ដៃអ្នកក្រ (ឃ) កម្រិតនៃប្រសិទ្ធភាពចំណាយនៅក្នុងការដាក់ឱ្យអនុវត្តនូវកម្មវិធីជំនួយ និងការសម្របសម្រួលជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀតដោយប្រៀបធៀបជាមួយនឹងការចំណាយក្នុងការផ្តល់ជំនួយដល់ DMCs ដែលមានលក្ខណៈផ្សេងទៀត ។

(iii) **ប្រសិទ្ធភាព** ប្រសិទ្ធភាព សំដៅថាតើយុទ្ធសាស្ត្រ និងកម្មវិធីជំនួយទទួលបានជោគជ័យក្នុងកម្រិតប៉ុណ្ណា ក្នុងការរួមចំណែកសម្រេចបាននូវទិន្នផល និងលទ្ធផល ក្នុងការគាំទ្រនូគោលដៅ និងវត្ថុបំណងអភិវឌ្ឍន៍របស់ DMC ក្នុងកម្រិតម៉ាក្រូសេដ្ឋកិច្ចតាមបណ្តាវិស័យ និងតាមប្រធានបទនានានោះ ។ ប្រសិទ្ធភាពនេះ ក៏សំដៅទៅលើ ថាតើលទ្ធផលដូចដែលបានកំណត់នៅក្នុង CAP សម្រេចទទួលបានជាក់ស្តែងក្នុងកម្រិតប៉ុណ្ណាដែរ ។

(iv) **និរន្តរភាព** និរន្តរភាព ផ្តោតទៅលើលទ្ធភាពដែលការសម្រេចបាននូវអត្ថប្រយោជន៍ និងលទ្ធផលពីកម្មវិធី នឹងនៅតែបន្តមាន ។ និរន្តរភាពនេះ ផ្តោតលើទិដ្ឋភាព សារពើពន្ធ សង្គម នយោបាយសេដ្ឋកិច្ច និងបរិស្ថាន ។ និរន្តរភាព ត្រូវបានវាយតម្លៃដោយពិនិត្យទៅលើកម្រិតដែលអន្តរាគមន៍នៅក្នុង CAP បានរួមចំណែកឱ្យមានជោគជ័យលើការអភិវឌ្ឍយូរអង្វែងដែលទំនងជានឹងបង្ហាញនូវភាពធាប់រិលត្រលប់មករកសភាពដើមវិញចំពោះមុខហានិភ័យដែលបានរកឃើញនោះ ។

(v) **ផលប៉ះពាល់** ផលប៉ះពាល់ សំដៅទៅលើវិភាគទានរបស់ ADB ដែលនាំឱ្យមានការប្រែប្រួលក្នុងរយៈពេលវែងនៅក្នុងការអភិវឌ្ឍ ។ ផលប៉ះពាល់នេះ រាប់បញ្ចូលផងដែរពីកម្រិតដែល CAP ទទួលបានជោគជ័យក្នុងការរួមចំណែកសម្រេចនូវគោលដៅអភិវឌ្ឍន៍ដែលបានកំណត់នោះ (ពោលគឺ ស្ថានភាពសង្គមសេដ្ឋកិច្ច MDGs និងវត្ថុបំណង និងគោលដៅជាតិកាត់បន្ថយភាពក្រីក្រដែលបានកំណត់នោះ) ។ ផលប៉ះពាល់នេះ ក៏ត្រូវបានវាយតម្លៃផងដែរថាតើកម្មវិធីជំនួយ បានរួមចំណែកកសាងសមត្ថភាពស្ថាប័នរបស់ប្រទេសនីមួយៗក្នុងកម្រិតប៉ុណ្ណា ដើម្បីគ្រប់គ្រងការកាត់បន្ថយភាពក្រីក្រ ។ ការវាយតម្លៃនេះសំដៅទៅលើការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ប្រទេសមួយក្នុងការប្រើប្រាស់ធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងធនធានធម្មជាតិរបស់ខ្លួនប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពនៅក្នុងកិច្ចខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ ។ ផលប៉ះពាល់ ត្រូវបានកំណត់ដោយយោងទៅលើស្ថានភាពដែលផ្ទុយពីការពិត មានន័យថា តើនឹងមានអ្វីអាចកើតឡើងប្រសិនបើគ្មានជំនួយរបស់ ADB នោះ និងដោយយោងទៅលើទិន្នន័យគោលដែលអាចដកស្រង់បានពីសូចនាករមុន និងក្រោយការផ្តល់ជំនួយ និងពីតួលេខប្រៀបធៀបរវាងបណ្តាប្រទេស ។

## ខ. វិធីសាស្ត្រវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

២៥. វិធីសាស្ត្រ CAPE ធ្វើការវិភាគជំនួយប្រចាំប្រទេស ជារួម លើជំនួយដុល និងលើជំនួយតាមវិស័យសំខាន់ៗនៃជំនួយដុលនោះ ។ ការរួមបញ្ចូលគ្នារវាងវិធីពីលើចុះក្រោម និងពីក្រោមឡើងលើ ដើម្បីវាយតម្លៃការអនុវត្ត ត្រូវបានធ្វើឡើង ។ វិធីនេះ ពឹងផ្អែកលើការវិនិច្ឆ័យរបស់អ្នកវាយតម្លៃ ដែលប្រកបដោយបទពិសោធន៍ ប៉ុន្តែក៏មានការចាត់វិធានការមួយចំនួនផងដែរ ដើម្បីជំរុញវត្ថុវិស័យភាពនៃការអនុវត្ត ។

## ១. ខ្សែសង្វាក់ផលិតផលរបស់ធនាគារអភិវឌ្ឍន៍អាស៊ីនៅក្នុងបរិបទប្រទេសកំពុងអភិវឌ្ឍជាសមាជិក

២៦. ដំណាក់កាលទីមួយនៃវិធីសាស្ត្រ CAPE គឺការវាយតម្លៃតាមការគ្រោងទុក ថាតើជំនួយរបស់ ADB មានការជាប់ពាក់ព័ន្ធក្នុងកម្រិតណា បើពិនិត្យទៅលើបរិបទដែលកំពុងវិវត្តន៍នៃកាលានុវត្តភាព និងបញ្ហាប្រឈមចំពោះការអភិវឌ្ឍដែលជួបប្រទះដោយ DMC នោះ ។ បញ្ហានេះមានលក្ខណៈចាំបាច់ណាស់ ក្នុងការកំណត់រកឱ្យឃើញនូវបញ្ហាប្រឈម និងកាលានុវត្តភាពចសំខាន់ៗចំពោះការអភិវឌ្ឍដែលបានកើតឡើងជាយូរមកហើយនោះ បន្ទាប់មក ត្រូវប្រៀបធៀបកាលានុវត្តភាព និងបញ្ហាប្រឈមទាំងនោះ ជាមួយនឹងខ្សែសង្វាក់លទ្ធផល ដែលសម្រេចបាន (ពោលគឺទំនាក់ទំនងតាមការរំពឹងទុករវាងទិន្នន័យ ទិន្នផល លទ្ធផល និងផលប៉ះពាល់ដែលជួយដោយ ADB ទៅនឹងអ្វីដែល ADB មានបំណងចង់រួមចំណែកសម្រេចឱ្យបាន) ។ កត្តាសេដ្ឋកិច្ច និងនយោបាយសម្រាប់ការអភិវឌ្ឍកាលានុវត្តភាព និងបញ្ហាប្រឈម ចម្បង និងអាទិភាពសំខាន់ៗ ដែលបានអនុម័តដោយរដ្ឋាភិបាល ដើម្បីធ្វើការដោះស្រាយនូវបញ្ហាប្រឈមទាំងនេះ ត្រូវបានកំណត់ដោយការប្រើប្រាស់នូវ NPRS ផែនការអភិវឌ្ឍជាតិ របាយការណ៍សេដ្ឋកិច្ច និងនយោបាយ ផលិតផលដែលចេញពីចំណេះដឹង (ពោលគឺ របាយការណ៍ ការអភិវឌ្ឍអាស៊ី និងរបាយការណ៍ត្រួតពិនិត្យសេដ្ឋកិច្ចតាមប្រទេស) និងរបាយការណ៍ពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជាពិសេស ពីធនាគារពិភពលោក និងពីមូលនិធិរូបិយវត្ថុអន្តរជាតិ ។ គួរមានការយកចិត្តទុកដាក់ជាពិសេសផងដែរទៅលើការប្រើប្រាស់ភស្តុតាងចេញពីរបាយការណ៍របស់វិទ្យាស្ថានរបស់ ADB និងពីនាយកដ្ឋានស្រាវជ្រាវ និងសេដ្ឋកិច្ចរបស់ ADB ។

២៧. ដោយផ្អែកលើការប្រើប្រាស់យុទ្ធសាស្ត្រប្រចាំប្រទេស និងឯកសារកម្មវិធីប្រចាំប្រទេសរបស់ ADB ទិន្នន័យដែល ADB មានបំណងចង់ផ្តល់ និងលទ្ធផលដែល ADB មានបំណងចង់សម្រេចឱ្យបាន ត្រូវបានកំណត់ ។ ADB ផ្តល់នូវទិន្នផលជាច្រើនប្រភេទដែលនាំឱ្យមានលទ្ធផលជាបីកម្រិត : ទិន្នផល លទ្ធផល និងផលប៉ះពាល់ ។ នៅក្នុងខ្សែសង្វាក់លទ្ធផល ទិន្នន័យរបស់ ADB គឺជាមធ្យោបាយទាំងឡាយណាដែលត្រូវបានប្រមែប្រមូលដើម្បីអនុវត្តកម្មវិធីជំនួយមកពីខាងក្រៅ ។ ទិន្នន័យទាំងនោះ អាចជាធនធានហិរញ្ញវត្ថុ ធនធានមនុស្ស និងធនធានរូបវ័ន្តផ្សេងៗ ។ ទិន្នន័យទាំងនេះអាចបែងចែកទៅតាមគម្រោងដែលពាក់ព័ន្ធ តាមកម្មវិធី តាមការគាំទ្រ TA និងក៏អាចរាប់បញ្ចូលនូវសេវាដែលផ្តល់ជាជំនួយសម្របសម្រួលការពិភាក្សាលើគោលនយោបាយ និងការងារសេដ្ឋកិច្ច និងតាមវិស័យផងដែរ ។ នៅក្នុងករណីខ្លះ ទិន្នន័យទាំងនោះ សំដៅលើគម្រោង កម្មវិធី និងឬសេវាមិនមែនកម្ចីមួយៗប៉ុណ្ណោះ ប៉ុន្តែនៅក្នុងករណីភាគច្រើន ទិន្នន័យនេះ គឺជាការរួមបញ្ចូលគ្នារវាងសេវាកម្ចី និងសេវាមិនមែនកម្ចី ដែលជារឿយៗនៅក្នុងវិស័យណាមួយ ហើយដែលមានទិសដៅរួមចំណែកសម្រេចឱ្យបាននូវលទ្ធផលប្រហាក់ប្រហែលគ្នានឹងសមាសធាតុខាងលើនេះដែរ ។ រីឯទិន្នផលរបស់ ADB នោះគឺអ្វីៗដែលលេចចេញមកជាក់ស្តែង (រួមមានសេវាកម្មនានា) ពីកម្មវិធី ឬគម្រោង ។ ទិន្នផលនេះ ទាក់ទងនឹងការបញ្ចប់នូវសកម្មភាព ហើយគឺជាប្រភេទនៃលទ្ធផលដែល ទទួលឥទ្ធិពលលើខ្លាំងពីអ្នកគ្រប់គ្រងជំនួយមកពីខាងក្រៅ ។ ឧទាហរណ៍ជាក់ស្តែងនៃទិន្នផល គឺការកសាងផ្លូវ ឬរោងចក្រអគ្គិសនីដែល សាងសង់នៅក្រោមគម្រោងរបស់ ADB ។ លទ្ធផល គឺជាការប្រែប្រួលជាក់ស្តែង ឬតាមបំណងនៅក្នុងស្ថានភាពនៃការអភិវឌ្ឍដែលអន្តរាគមន៍របស់ ADB ខិតខំគាំទ្រ ។ លទ្ធផលនេះ រៀបរាប់នូវការប្រែប្រួលនៅក្នុងការអភិវឌ្ឍ និងការប្រែប្រួលស្ថានភាព ។ ឧទាហរណ៍ការចំណាយទៅលើថ្លៃដឹកជញ្ជូនទាប ឬការធ្វើដំណើរទៅកាន់ទីផ្សារកាន់តែប្រសើរឡើងទាំងនេះ ក៏ជាលទ្ធផលដែលកើតចេញពីអន្តរាគមន៍ផ្នែកដឹកជញ្ជូនដែលគាំទ្រដោយ ADB ផងដែរ ។ លទ្ធផល ក៏រាប់បញ្ចូលនូវការប្រែប្រួលនៅក្នុងការធ្វើគោលនយោបាយ និងការប្រែប្រួលនៅក្នុងបរិស្ថានដែលជួយឱ្យស្ថាប័នមានដំណើរការផងដែរ ដែលទាំងនេះ ជាលទ្ធផលបានមកពីការអនុវត្តកម្មវិធីជំនួយដែលបានព្រមព្រៀង ។ លទ្ធផលទាំងនោះ អាចមានដូចជាការប្រែប្រួលនូវតួនាទីរបស់វិស័យឯកជន និងសាធារណៈ ការប្រែប្រួលការអនុវត្តអភិបាលកិច្ចតាមវិស័យ ភាពប្រកួតប្រជែង ការបើកទូលាយអត្រាការចំណាយសាធារណៈ ភាពរឹងប៉ឹងប្រកបដោយការប្រុងប្រយ័ត្ននៃប្រព័ន្ធហិរញ្ញវត្ថុ ការលើកឡើងនៃគំនិតរបស់អ្នកពាក់ព័ន្ធនៅក្នុងការធ្វើសេចក្តីសម្រេចចិត្ត កម្រិតនៃការធ្វើវិមជ្ឈការ និងការប្រែប្រួលផ្សេងៗទៀតចំពោះគោលនយោបាយ និងតាមស្ថាបន័ ។ ផលប៉ះពាល់សំដៅទៅលើប្រសិទ្ធភាពទាំងអស់ និងក្នុងរយៈពេលយូរនៃអន្តរាគមន៍ផ្សេងៗ ។ នេះគឺជា លទ្ធផលដ៏វិសេសដែលអាចកំណត់បានថា ប៉ុន្តែមិនមែនមានន័យថាត្រូវតែបែបហ្នឹងនោះទេ ជាលទ្ធផលបានមកពីកម្មវិធីជំនួយដែលគាំទ្រដោយ ADB ដែលផ្ទុយពីទិន្នផល និងលទ្ធផលដែលឆ្លុះបញ្ចាំងភាគច្រើនទៅលើលទ្ធផលភ្លាមៗ និងដែលអាចកំណត់បានថា ជាលទ្ធផលបាន មកពីប្រតិបត្តិការរបស់ ADB ។ ការប្រែប្រួលនៅក្នុងវិស័យសេដ្ឋកិច្ច ទិន្នផល ប្រាក់ចំណូល ការនាំចេញ

អតិផរណា សុខភាព កម្រិតអប់រំ ភាពក្រីក្រ និងស្ថានភាពបរិស្ថាន គឺជាឧទាហរណ៍ដែលបញ្ជាក់ពីប្រភេទនៃអថេររបស់ផលប៉ះពាល់ដែលទទួលឥទ្ធិពលយ៉ាងខ្លាំងពីជំនួយរបស់ ADB ។ ដូចដែលបានបញ្ជាក់លម្អិតនៅក្នុងតារាង ១ខ្សែ សង្វាក់លទ្ធផលនៃជំនួយរបស់ ADB ត្រូវបានលើកយកមកធ្វើការវាយតម្លៃទាំងតាមរបៀបពីលើចុះក្រោម (deductive) និងពីក្រោមឡើងលើ (inductive) ។ នៅក្នុងការអនុវត្តជាក់ស្តែង ទំនងជាមិនមានវិឌ្ឍនកម្មដោយរលូន និងតាមលំដាប់លំដោយឱ្យទាន់ពេលវេលានៃអន្តរាគមន៍ទិន្នន័យជាជំនួយរបស់ ADB ទៅនឹងទិន្នផល លទ្ធផល និងផលប៉ះពាល់តាមបំណងនោះទេ ។ កត្តាផ្សេងទៀត ទំនងជាត្រូវចូលធ្វើអន្តរាគមន៍ ហើយបន្ទាប់ពីពិនិត្យមើលទៅលើទិដ្ឋភាពថាមពល និងទិដ្ឋភាពដែលងាយប្រែប្រួលគោលដៅចម្បងនៃការវាយតម្លៃ គឺធ្វើការតាមដាននូវដំណើរប្រព្រឹត្តិទៅជាក់ស្តែងនៃទិន្នន័យ ដែលជាជំនួយរបស់ ADB រួមចំណែកនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ពិតប្រាកដ ។

**រូបភាព ១ : វិធីពីលើចុះក្រោម និងពីក្រោមឡើងលើ ដើម្បីតាមដានខ្សែសង្វាក់លទ្ធផល**

**១. វិធីពីលើចុះក្រោម (Deductive)**

**២. វិធីពីក្រោមឡើងលើ (Inductive)**

| |
|---|
| **ផលប៉ះពាល់ :** តើមានការប្រែប្រួលអ្វីខ្លះសម្រាប់លទ្ធផលក្នុងរយៈពេលវែង ? ផលប៉ះពាល់សម្រាប់ថ្នាក់ជាតិ និងតាមវិស័យ ត្រូវបានពិនិត្យ ហើយទំនាក់ទំនងរវាងផលប៉ះពាល់នឹងជំនួយរបស់ ADB ត្រូវបានតាមដាន និង វាយតម្លៃ ? |
| **លទ្ធផល :** តើការប្រែប្រួលជាដុំកំភួនអ្វីខ្លះ ដែលបានកើតឡើង បើពិនិត្យមើលលើសេវាដែលបានផ្តល់សេវា សាធារណៈដែលបានគ្រប់គ្រង ឬក៏មានការប្រែប្រួលអ្វីខ្លះចំពោះបរិស្ថានដែលធ្វើឱ្យដំណើរការការកាត់បន្ថយភាពក្រីក្រដែលធនាគារ ADB បានរួមចំណែកធ្វើក្នុងអំឡុងពេលវាយតម្លៃនេះ ? តើមានកត្តាអ្វីផ្សេងទៀត ក្រៅពីជំនួយរបស់ ADB ដែលបានរួមចំណែកនាំឱ្យមានលទ្ធផលទាំងនេះ ? |
| **ទិន្នផលដែលជួយដោយ ADB :** តើមានទិន្នផលជាចម្បងៗអ្វីខ្លះដែលទទួលបានពីជំនួយរបស់ ADB ? តើមានកត្តាអ្វីខ្លះដែល ធ្វើឱ្យជះឥទ្ធិពលដល់ការអនុវត្ត ? តើគម្រោង និងជំនួយមិនមែនកម្ចីរបស់ ADB បាន សម្រេចបានលទ្ធផលជាក់ស្តែងអ្វីខ្លះ ? |
| **អន្តរាគមន៍ និងទិន្នន័យរបស់ ADB :** តើគម្រោង កម្មវិធី និងសកម្មភាពមិនមែនកម្ចីដែលជួយដោយ ADB មានគោលដៅធ្វើអ្វីខ្លះ ? តើអន្តរាគមន៍ និងទិន្នន័យ ដែលបានច្របាច់បញ្ចូលគ្នាតាមលក្ខណៈជាកម្មវិធីត្រូវបាន បម្លែងទៅជាអន្តរាគមន៍បែបយុទ្ធសាស្ត្រដោយរបៀបណា ? |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី

ប្រភព : ការប៉ាន់ស្មានរបស់ ADB

២៨. កម្រិតនៃការកំណត់ខ្សែសង្វាក់លទ្ធផល មានភាពប្រែប្រួលពីកម្មវិធីប្រចាំប្រទេសមួយទៅនឹងកម្មវិធីរបស់ប្រទេសមួយទៀត ។ កត្តាដែលជាដេទៃមីណង់ (កត្តាកំណត់) សំខាន់ៗដែលមានទាំងកត្តាភាពងាយស្រួល និងការលំបាកដែលគេបានប្រើវាដើម្បីធ្វើការវាយតម្លៃកម្មវិធីនោះ មានដូចជាគុណភាពនៃការវិភាគវិនិច្ឆ័យទៅលើប្រទេស ការកំណត់ឱ្យបានច្បាស់លាស់ទៅលើវត្ថុបំណង តក្កគម្រោង ការប៉ាន់ស្មានដោយប្រើចំណេះដឹងបានគ្រប់គ្រាន់ និងកត្តាហានិភ័យ ការរាប់បញ្ចូលសូចនាករទិន្នន័យ និងទិន្នផល ការកំណត់រង្វាស់គោលសម្រាប់ទិន្នផល និងលទ្ធផល ។ នៅក្នុងករណីខ្លះ គោលដៅ និងវត្ថុបំណង អាចត្រូវបានកំណត់យ៉ាងទូលំទូលាយ ហើយខ្សែសង្វាក់លទ្ធផលដែលភ្ជាប់ទិន្នន័យ ទិន្នផល លទ្ធផល និងផលប៉ះពាល់របស់កម្មវិធីជាមួយគ្នានោះ

អាចនិយាយថាសម្រេចបានដោយប្រើតែពាក្យមានន័យទូទៅតែប៉ុណ្ណោះ[៦] ។ នៅក្នុងករណីទាំងនេះ ខ្សែសង្វាក់លទ្ធផល ចាំបាច់ត្រូវដាក់បញ្ចូលជាថ្មីដោយផ្អែកទៅលើអ្វីដែលបានរៀបរាប់នៅក្នុង CSPs និងពិបទសម្ភាសន៍ជាមួយនឹងក្រុមមន្ត្រីរបស់ ADB ប្រចាំប្រទេស ។ នៅពេលដែល CSP ត្រូវបានកំណត់បានល្អហើយនោះ ចាំបាច់ត្រូវរៀបចំក្របខ័ណ្ឌការងារលទ្ធផលផ្លូវការ ដើម្បីដឹកនាំការវាយតម្លៃ ។

២៩. ការបំបែកកម្មវិធីជំនួយរបស់ ADB ទៅជាខ្សែសង្វាក់ចម្បងមួយ ឬច្រើន ធ្វើឡើងក្នុងគោលបំណងពីរបន្ថែមទៀត ។ ទីមួយ ការបំបែកនេះអាចឱ្យ CAPE ចាត់ទុកជំនួយរបស់ ADB ជាកម្លាំងចលករជាសើរីសម្រាប់កម្មវិធី (តាមវិស័យ ឬប្រធានបទ) ការណ៍នេះបានបង្កើតឱ្យមានអង្គភាពដ៏សំខាន់មួយរបស់ CAPE ។ កម្លាំងចលករទាំងនេះ គឺជាការច្របាច់បញ្ចូលគ្នានូវបណ្តាគម្រោង កម្មវិធី TA ការងារសេដ្ឋកិច្ច និងតាមវិស័យ ការពិភាក្សាគោលនយោបាយ និងកិច្ចខិតខំប្រឹងប្រែងសម្របសម្រួលក្នុងចំណោមដៃគូអភិវឌ្ឍន៍ដែលជារួម មានគោលដៅឆ្ពោះទៅរកការសម្រេចឱ្យបាននូវការប្រែប្រួល និងលទ្ធផលដែលពាក់ព័ន្ធ ។ ឧទាហរណ៍ នៅក្នុងវិស័យថាមពលរបស់ប្រទេសមួយ គម្រោង កម្មវិធី ជំនួយ ប្រឹក្សាបច្ចេកទេស សិក្ខាសាលា សិប្បសាលា និងសេវាមិនមែនកម្ចីជាច្រើន តែងតែអាចត្រូវបានដឹកនាំឆ្ពោះទៅរកគោលដៅរួមនៃការលើកកម្ពស់សមត្ថភាពហិរញ្ញវត្ថុនៃប្រព័ន្ធផ្គត់ផ្គង់ថាមពលរបស់ជាតិ ។ បើពិនិត្យពីទិដ្ឋភាពកម្មវិធីផ្តល់ជំនួយ គឺលទ្ធផលដែលរួមបញ្ចូលគ្នាទាំងនេះហើយដែលមានសារៈសំខាន់ ។ ទីពីរ ទំនាក់ទំនងរវាងហេតុ និងផលដែលបង្កប់នៅក្នុងខ្សែសង្វាក់លទ្ធផល មានមុខងារជាសំណុំ សម្មតិកម្មដែលអាចត្រូវបានធ្វើតេស្តក្នុងរយៈពេលនៃការវាយតម្លៃនេះបាន។ ដោយទាញយកឧទាហរណ៍ពីវិស័យថាមពលពីខាងលើ សម្មតិកម្មមួយចំនួនដែលអាចចាត់ទុកជាបានការនោះ មានដូចជា (i) អន្តរាគមន៍រួមបញ្ចូលគ្នារបស់ ADB នៅក្នុង "កម្លាំងចលករកម្មវិធី" ពិតជានាំទៅរកការធ្វើឱ្យប្រសើរឡើងពិតប្រាកដនៅក្នុងផ្នែកសមត្ថភាពហិរញ្ញវត្ថុនៃប្រព័ន្ធផ្គត់ផ្គង់ថាមពលមែន (ii) គោលដៅមានភាពសម ស្របហើយសម្រេចបាន និង (iii) ADB ដោយសហការជាមួយដៃគូរអភិវឌ្ឍន៍ផ្សេងទៀត បានផ្តល់នូវជំនួយគ្រប់គ្រាន់ដើម្បីឱ្យរដ្ឋាភិបាលសម្រេចបាននូវលទ្ធផលតាមបំណង ។

៣០. ក្រៅពីការកំណត់នូវខ្សែសង្វាក់លទ្ធផលណាខ្លះដែលជំនួយរបស់ ADB បានផ្តោតគោលដៅសម្រេចឱ្យបាននោះ CAPE ត្រូវវាយតម្លៃលើភាពសមស្របនៃ CSPs ដែលកំពុងដំណើរការរបស់ ADB ថា ជាឧបករណ៍ដើម្បីដឹកនាំការអនុវត្តកម្មវិធីជំនួយ ។ ការឆ្លើយតបនៃយុទ្ធសាស្ត្រ និងកម្មវិធីចំពោះបរិបទជាតិ អាចត្រូវបានវាយតម្លៃតាមរយៈការប្រៀបធៀបការបន្សីគ្នារវាងបរិបទប្រទេសជាមួយនឹងអាទិភាព ព្រមទាំងតាមរយៈការបន្សីគ្នារវាងយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលជាមួយនឹងអាទិភាព ដោយមានការបន្សីគ្នានេះនៅក្នុងខ្សែសង្វាក់លទ្ធផលដែលបង្កប់នៅក្នុងយុទ្ធសាស្ត្រប្រចាំប្រទេស និងការប្រែក្លាយយុទ្ធសាស្ត្រប្រចាំប្រទេសឱ្យទៅជាកម្មវិធីប្រចាំប្រទេសវិញ ។ ភាពជាប់ទាក់ទងនៃ CSP ចំពោះបញ្ហាប្រឈមរបស់ប្រទេស និងនៅតាមវិស័យ ត្រូវបានវាយតម្លៃដោយការពិនិត្យថា តើមួយផ្នែកនៃការផ្តោតយកចិត្តទុកដាក់ពីសំណាក់យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB មានភាពស៊ីគ្នាជាមួយនឹងបេសកកម្មរបស់ ADB ដែរ ឬទេ ហើយមួយផ្នែកទៀត តើការផ្តោតយកចិត្តទុកដាក់នេះ ក៏មានភាពស៊ីគ្នាជាមួយនឹងស្ថានភាពសេដ្ឋកិច្ចចម្បងៗដែលកំពុងវិវត្តន៍ជាមួយនឹងអាទិភាព និងសមត្ថភាពស្រូបយករបស់ DMC ផងដែរ ឬទេ ។ ដើម្បីធ្វើការវាយតម្លៃបែបនេះ នោះ CAPE ត្រូវពិនិត្យមើលកម្រិតដែលកម្មវិធី និងយុទ្ធសាស្ត្ររបស់ ADB មាន (i) ភាពឆ្លើយតបទៅនឹងតម្រូវការរបស់ជាតិ (ii) មានភាពបន្សីគ្នាជាមួយនឹងអាទិភាព និងកម្មវិធីរបស់រដ្ឋាភិបាល (iii) ភាពស៊ីគ្នា និងឯកភាពគ្នា (iv) ការដាក់ចំស្ថានភាព បើពិនិត្យលើឧត្តមភាពដោយប្រៀបធៀបរបស់ ADB និងសកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ និង (v) មានភាពសមស្របបើពិនិត្យទៅលើបរិបទដែល ADB កំពុងតែប្រតិបត្តិការនោះ ។ ព័ត៌មានចាំបាច់សម្រាប់ការវាយតម្លៃនេះ ភាគច្រើន បានដកស្រង់ចេញពីការពិនិត្យមើលការសិក្សាផ្សេងៗ និងពីបទសម្ភាសន៍ដែលបានរៀបចំបែបរចនាសម្ព័ន្ធដែលបានធ្វើឡើងទៅលើបុគ្គលិករបស់ ADB លើដៃគូអភិវឌ្ឍន៍ និងទៅលើមន្ត្រីរបស់រដ្ឋាភិបាលដែលជាប់ពាក់ព័ន្ធនៅក្នុងការធ្វើផែនការជាតិ និងការគ្រប់គ្រងជំនួយមកពីខាងក្រៅ ។

---

[៦] ក្នុងពេលដែលនេះជាការគិតខុសក្នុងការសន្និដ្ឋានថាកម្មវិធី និងយុទ្ធសាស្ត្រជំនួយប្រចាំប្រទេស មានភាពប្រសើរ ប្រសិនបើកម្មវិធី និងយុទ្ធសាស្ត្រនោះ មានភាពងាយស្រួលក្នុងការវាយតម្លៃនោះកត្តា នោះពិតជាជះឥទ្ធិពលដ៏ធ្ងន់ធ្ងរទៅលើកម្រិតដែលខ្សែសង្វាក់លទ្ធផល អាចត្រូវបានកំណត់រកឃើញ និងការអនុវត្តប្រៀបធៀបនឹងវត្ថុបំណង ត្រូវបានវាយតម្លៃ ។

## ២. ការតាមដានការផ្តល់ទិន្នន័យជាជំនួយ

៣១. CAP មិនអាចរួមចំណែកនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍បានទេ ប្រសិនបើទិន្នន័យជំនួយមិនត្រូវបានផ្តល់ឱ្យបានជាក់ស្តែងនោះ ។ នៅក្នុងដំណាក់កាលទីពីរ តាមវិធីសាស្ត្ររបស់ CAPE គេត្រូវធ្វើការវាយតម្លៃការដាក់ចុះ CAP ។ និន្នាការអនុវត្តនៃកម្មវិធីជំនួយ (ទាំងសេវាកម្ចី និងសេវាមិនមែនកម្ចីទាំងអស់) ត្រូវបានត្រួតពិនិត្យ ហើយកត្តាចម្បងៗដែលប៉ះពាល់ដល់ការអនុវត្ត CAP ក៏ត្រូវបានកំណត់ដែរ ។

៣២. ជំហានទីមួយ គឺធ្វើការប្រៀបធៀបរវាងការអនុវត្តកម្មវិធី ជាមួយនឹងអ្វីដែលមានចែងនៅក្នុងយុទ្ធសាស្ត្រដែលគេកំពុងដាក់ឱ្យអនុវត្តនោះ ។ ការប្រៀបធៀបនេះ អាចធ្វើបានតាមរយៈការថ្លឹងថ្លែងរវាងការសម្រេចបានជាលទ្ធផលនៃសេវាកម្ចី និង TA ជាមួយនឹងអ្វីដែលបានគ្រោងទុកនៅក្នុង CSP និងនៅក្នុងខ្សែបណ្តាញធ្វើបច្ចុប្បន្នភាពរបស់ CSP ។ ការថ្លឹងថ្លែងនេះ ជាប់ពាក់ព័ន្ធនឹងការត្រួតពិនិត្យនូវអ្វីដែលបានដាក់ចុះ និងអ្វីដែលបានគ្រោងទុកនៅក្នុងបណ្តាវិស័យសំខាន់ៗ ។ ការគូថ្លឹងនេះវាយតម្លៃថា តើមានលទ្ធផលជាទិន្នផលចេញពីការរួមកម្លាំងគ្នា និងពីការបំពេញបន្ថែមឱ្យគ្នាទៅវិញទៅមករវាងវិស័យ និងប្រធានបទនានា ព្រមទាំងចេញពីចំណុចជួបគ្នារវាងប្រតិបត្តិការវិស័យសាធារណៈរបស់ ADB និងប្រតិបត្តិការវិស័យឯកជនក្នុងកម្រិតប៉ុណ្ណា ។ ការដាក់ចុះនូវកម្មវិធីជំនួយ អាចមានភាពខុសគ្នាបង្គួរពីអ្វីដែលបានគ្រោងទុក ឧទាហរណ៍ ដូចជាដោយសារគ្រោះធម្មជាតិ ស្ថានភាពសេដ្ឋកិច្ចផ្លាស់ប្តូរឆាប់រហ័សពេក ការលំបាកក្នុងការអនុវត្ត ឬក៏ការរំពឹងទុកមិនសមស្រប ។ នៅចំណុចណាដែលមានភាពខុសគ្នាខ្លាំងរវាងកម្មវិធីដែលត្រូវបានគេដាក់ចុះ និងកម្មវិធីដែលគេបានគ្រោងទុក នោះមូលហេតុដែលនាំឱ្យមានបញ្ហានេះ ត្រូវកំណត់រកឱ្យឃើញដោយផ្អែកលើព័ត៌មានដែលអាចរកបាននៅក្នុងឯកសារគម្រោង ពីបទសម្ភាសន៍ជាមួយនឹងមន្ត្រី ADB និងមន្ត្រីរដ្ឋាភិបាល និងពីការរកឃើញនៃរបាយការណ៍ត្រួតពិនិត្យការគ្រប់គ្រងផលប័ត្រប្រចាំឆ្នាំ ។

៣៣. ជំហានទីពីរ គឺធ្វើការប្រៀបធៀបទៅលើដំណាក់កាលផ្សេងៗគ្នា ហើយដោយប្រើមធ្យមភាគគោលរបស់ ADB ធ្វើការវាយតម្លៃទៅលើប្រសិទ្ធភាពដែលតាមរយៈនេះកម្មវិធីជំនួយរបស់ ADB ត្រូវបានដាក់ចុះ និងលើទិន្នផលដែលរំពឹងទុក និងដែលសម្រេចបាននោះ ។ ប្រសិទ្ធផលដែលតាមរយៈនេះជំនួយរបស់ ADB ត្រូវបានផ្តល់នោះ ទទួលបានការវាយតម្លៃផងដែរទៅលើចំណុចជាច្រើន រួមមាន (ចំពោះចំណុចណាដែលអាចអនុវត្តបាន) ការប្រៀបធៀបរវាងអត្ថប្រយោជន៍នៃសកម្មភាពជំនួយសំខាន់ៗជាមួយនឹងការចំណាយទៅលើសកម្មភាពជំនួយទាំងនោះ (ពោលគឺ អត្រាចំណូលពីការវិនិយោគផ្ទៃក្នុងដែលផ្អែកទៅលើលទ្ធផលច្បាស់លាស់)) សូចនាករនៃថ្លៃដើមប្រតិបត្តិការ និងថ្លៃដើមឯកតាក្នុងការផ្តល់ជំនួយ ។ ការរកឃើញទាំងឡាយណាដែលទទួលបានពីគំរូនៃការវាយតម្លៃដោយខ្លួនឯង និងដោយឯករាជ្យលើគម្រោង កម្មវិធី និងជំនួយ គឺមានសុពលភាព[៧] ដើម្បីបញ្ជាក់ថាកម្មវិធី ត្រូវបានដាក់ចុះពិតប្រាកដមែន ហើយសម្រេចបានទិន្នផលដូចបានរាយការណ៍ ។ សេវាមិនមែនកម្ចី ក៏ត្រូវបានពិនិត្យផងដែរ ដែលនៅក្នុងនោះរួមមាន ការពិភាក្សា គោលនយោបាយ ការសម្របសម្រួល ជាមួយនឹងដៃគូអភិវឌ្ឍន៍ និងការផ្តល់ផលិតផលកើតចេញពីចំណេះដឹង ដើម្បីវាយតម្លៃទៅលើកម្រិតដែលសេវាមិនមែនកម្ចីត្រូវបានផ្តល់ និងទិន្នផលរបស់សេវាមិនមែនកម្ចីសម្រេចបានជាលទ្ធផល ។ កត្តាចម្បងៗដែលមានឥទ្ធិពលដល់ការអនុវត្ត ការអនុវត្តល្អៗដើម្បីទុកជាគំរូ និងការអនុវត្តមិនបានល្អដែលគួរត្រូវចៀសវាង ត្រូវបានទាញយកយ៉ាងប្រុងប្រយ័ត្នពីការវិភាគនេះ ហើយមានមុខងារជាលទ្ធផលដ៏សំខាន់ ដែលតាមរយៈលទ្ធផលនេះ អនុសាសន៍ទាក់ទងនឹងការអនុវត្ត អាចត្រូវបានផ្តល់ជូននៅទីបំផុត។

៣៤. នៅក្នុងប្រទេសមួយចំនួន ADB បានធ្វើវិមជ្ឈការប្រគល់ការទទួលខុសត្រូវអនុវត្តន៍កម្មវិធីមួយចំនួនធំ ដល់និវាសនដ្ឋានបេសកកម្មរបស់ខ្លួន ។ នៅក្នុងជំហានទីបីនេះ CAPE នឹងធ្វើការវាយតម្លៃទៅលើវិភាគទានរបស់និវាសនដ្ឋានបេសកកម្មចំពោះការរៀបចំកម្មវិធី[៨] ប្រចាំប្រទេស និងចំពោះការអនុវត្តទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាពនៃកម្មវិធីជំនួយដែលបានព្រមព្រៀងនោះ ។ ជំហាននេះ រួមមាន ការពិនិត្យមើលលើចំនួន

---

[៧] ជាទូទៅ គំរូពីគម្រោងសំខាន់ៗ ពីបណ្តាកម្មវិធី និងពី TA មានសុពលភាពក្នុងរយៈពេលនៃ CAPE ។

[៨] នៅក្នុងប្រទេសខ្លះ និវាសនដ្ឋានបេសកកម្ម ក៏មានតួនាទីសំខាន់ដែរក្នុងការជួយកំណត់ និងអនុវត្តការគាំទ្រកិច្ចសហប្រតិបត្តិការក្នុងតំបន់ ។ នៅក្នុងករណីខ្លះ គេគួរតែលើកយកមកពិភាក្សាអំពី តួនាទីរបស់និវាសនដ្ឋានបេសកកម្មនៅក្នុងការដាក់ចុះនូវកម្មវិធីជំនួយ ។

គ្រប់គ្រាន់នៃបុគ្គលិកធ្វើការនៅតាមនិវាសនដ្ឋានបេសកកម្ម ពិនិត្យមើលធនធាន និងការទទួលខុសត្រូវ ព្រមទាំងត្រួតពិនិត្យលើការបែងចែកការងាររវាងបុគ្គលិកនៅស្នាក់ការកណ្តាល និងនៅតាមនិវាសនដ្ឋាបេសកកម្ម ។

## ៣. ការវាយតម្លៃលទ្ធផល : ដំណើរការត្រីកោណ

៣៥. ដំណាក់កាលទីបី (ដំណាក់កាលសំខាន់ជាងគេបំផុត) នៅក្នុងវិធីសាស្ត្រ CAPE គឺការកំណត់ និងវាយតម្លៃលទ្ធផលនៃកម្មវិធីជំនួយរបស់ ADB ។ ការផ្តោតយកចិត្តទុកដាក់ជាចម្បង គឺលើលទ្ធផល (ពោលគឺ ការប្រែប្រួលនៅក្នុងលក្ខខណ្ឌអភិវឌ្ឍន៍ជាក់លាក់ និងវិភាគទានរបស់ ADB នាំឱ្យមានការប្រែប្រួលទាំងនេះ) ។ ដំណាក់កាលនេះ គឺសង្កត់ធ្ងន់ទៅលើកាលើកកម្ពស់ការយល់ដឹងអំពីលទ្ធផលផ្ទាល់ ធ្វើឱ្យប្រសើរឡើងនូវស្ថានភាពរបស់ខ្លួន និងអភិវឌ្ឍកត្តានានាដែលនាំទៅរកការប្រែប្រួលនេះ ។ កម្រិតនៃលទ្ធផលនេះ បង្ហាញយ៉ាងច្បាស់ថា តើជំនួយរបស់ ADB ប្រកបដោយប្រសិទ្ធភាពក្នុងកម្រិតប៉ុណ្ណា ក្នុងការរួមចំណែកឱ្យមានការប្រែប្រួលដែលជាផលប៉ះពាល់ទៅលើជីវិតរស់នៅរបស់ប្រជាជនក្រីក្រ ។ ក្នុងចំណោមលទ្ធផលច្រើនប្រភេទ ទិន្នផល អាចត្រឹមតែឆ្លុះបញ្ចាំងពីការណ៍ដែលគម្រោងត្រូវបានគេអនុវត្តតែប៉ុណ្ណោះ ហើយត្រូវប្រើរយៈពេលយូរដើម្បីស្គាល់ពីឥទ្ធិពលអភិវឌ្ឍន៍វិជ្ជមាននានា ។ ក្របខ័ណ្ឌពេលវេលាកាន់តែខ្លីដែលចាំបាច់ ដើម្បីសម្រេចបាននូវលទ្ធផលនានា អាចជួយឱ្យស្គាល់ទំនាក់ទំនងកាន់តែគួរឱ្យទុកជឿទុកចិត្ត រវាងជំនួយរបស់ ADB និងលទ្ធផតាមវិស័យ ឬតាមប្រធានបទ ។

៣៦. **ការវាស់វែងលទ្ធផល** ការវាយតម្លៃទៅលើផលប៉ះពាល់ និងលទ្ធផលតាមបណ្តាវិស័យ និងតាមប្រធានបទនានានោះ គឺដើម្បីញែកចេញនូវវិភាគទាន ឬខ្សែសង្វាក់នៃលទ្ធផលដែល សម្រេចបានគួរជាទីមោទនៈពីប្រតិបត្តិការរបស់ ADB ណាខ្លះដែលនាំទៅរកការប្រែប្រួលនៅក្នុងស្ថានភាពនៃការអភិវឌ្ឍ ។ ការប្រៀបធៀបដែលថា សមស្របហើយៗចំពោះការវាយតម្លៃទៅលើវិភាគទានរបស់ ADB ដែលនាំទៅរកលទ្ធផលអភិវឌ្ឍន៍ និងផលប៉ះពាល់នោះ គឺជាការផ្ទុយពីការពិត (ពោលគឺតើនឹងមានអ្វីកើតឡើង នៅពេលដែលគ្មានការគាំទ្ររបស់ ADB[៩] នោះ ។ ប្រសិនបើមិនមានការកំណត់ឱ្យបានត្រឹមត្រូវថាអ្វីទៅជាការផ្ទុយនឹងការពិតនោះទេ សូចនាករតំណាង (proxy indicator) វិធានការប្រយោល ការប្រៀបធៀបនៃបទពិសោធន៍ដែលទទួលបានពីបណ្តាប្រទេសផ្សេងៗ និងការបញ្ចូលគ្នារវាងសូចនាការបែបគុណវិស័យ និងបរិមាណវិស័យ គឺត្រូវតែយកមកប្រើជាភស្តុតាង ដើម្បីបញ្ជាក់ពីវិភាគទានរបស់ ADB ដែលនាំទៅរកការសម្រេចបាននូវលទ្ធផល និងដើម្បីផ្តល់ជាការណែនាំចំពោះការជ្រើសរើសជម្រើសជំនួយនាពេលអនាគត ។ សម្រាប់កម្មវិធីខ្លះ លទ្ធផលងាយស្រួលចងក្រងជាតួលេខ ។ ប៉ុន្តែសម្រាប់កម្មវិធីខ្លះ ដូចជាកំណែទម្រង់គោលនយោបាយ និងកម្មវិធីកសាងសមត្ថភាព លទ្ធផល មានលក្ខណៈជាគុណវិស័យ (បញ្ជាក់ពីកម្រិត នៃការធ្វើបានល្អ ឬអន់) និងមានចរិតជាកម្មវិធីរយៈពេលវែងទៀតផង ។

៣៧. វិធីសាស្ត្រទូទៅដែលគេចូលចិត្តប្រើបំផុតសម្រាប់វាយតម្លៃលទ្ធផល និងផលប៉ះពាល់ គឺវិធី "មុន និងក្រោយ" ។ តាមរយៈវិធីនេះ ស្ថានការណ៍ដែលមានមុនជំនួយអភិវឌ្ឍន៍ ត្រូវបានប្រៀបធៀបជាមួយនឹងស្ថានការណ៍ក្រោយមានជំនួយ ។ នេះគឺជាវិធីសាស្ត្រដែលគេចូលចិត្តប្រើបំផុត ប្រហែលជាដោយសារតែវិធីនេះ មានភាពងាយស្រួល និងមានការចំណាយតិចតួចក្នុងការប្រមូលទិន្នន័យ ។ ទោះជាដូច្នេះក៏ដោយ វិធីនេះ ត្រូវប្រើដោយមានការយកចិត្តទុកដាក់ ព្រោះវាអាចនាំទៅរកការសន្និដ្ឋានមិនត្រឹមត្រូវអំពីវិភាគទានរបស់ដៃគូអភិវឌ្ឍន៍ នៅពេលដែលមានកត្តាផ្សេងៗក្រៅពីជំនួយរបស់ខ្លួន គឺជាដេទែមីណង់ដ៏សំខាន់ចំពោះការប្រែប្រួលដែលគេបានសង្កេតនោះ ។

៣៨. វិធីមួយទៀតដើម្បីវាស់វែងលទ្ធផល គឺធ្វើការប្រៀបធៀបលទ្ធផលអភិវឌ្ឍន៍ និងផលប៉ះពាល់ ជាមួយនឹងស្ថានការណ៍ដែលមាននៅតាមបណ្តាប្រទេសដែលគេជ្រើសរើសសម្រាប់ប្រៀបធៀបនោះ នៅមានកម្រិតការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រហាក់ប្រហែលគ្នា ។ វិធីនេះ តម្រូវឱ្យមានទិន្នន័យគោលប្រៀបធៀប និងទិន្នន័យអនុវត្តន៍ សម្រាប់ក្រុមប្រទេសទាំងពីរ ។ តាមការពិត ដោយហេតុថា កត្តាជាច្រើនមិនអាចគ្រប់គ្រងបានសម្រាប់

---

[៩] ការកំណត់និយមន័យឱ្យបានហ្មត់ចត់ទៅលើពាក្យ ផ្ទុយពីការពិត គឺមិនសូវមានទេនៅក្នុង CAPEs ។ ទោះជាដូច្នេះក៏ដោយ មានករណីខ្លះដែលការឯកភាពរួមគ្នារបស់អ្នកជំនាញការកំពូលៗ អាចត្រូវបានយកមកប្រើដើម្បីកំណត់និយមន័យ សមស្របជាការផ្ទុយពីការពិត ។ ការពិចារណាទៅលើការផ្ទុយពីការពិត ក៏អាចជួយផ្តោតការយកចិត្តទុកដាក់ទៅលើតម្លៃបន្ថែម ជាពិសេសទៅលើ ការផ្តល់ហិរញ្ញប្បទានដែលបានផ្តល់ដោយកម្មវិធីជំនួយនោះ ។

ប្រទេសទាំងអស់នោះ ដូច្នេះវិធីនេះ ជាទូទៅ ត្រូវបានប្រើដើម្បីតែវិភាគ "លទ្ធផល" សំខាន់ៗ ដែលមានលក្ខណៈខុសគ្នាដាច់ស្រឡះរវាងបណ្ដាប្រទេសទាំងនោះ ប៉ុន្តែប្រទេសទាំងនោះមានចំណុចជាច្រើនដែលមានលក្ខណៈដូចគ្នាដែរ ។ នៅក្នុងការអនុវត្តជាក់ស្តែង ជម្រើសលើវិធីវាយតម្លៃផលប៉ះពាល់ គឺអាស្រ័យនៅលើទិន្នន័យនេះឯង ។ នៅក្នុងករណីខ្លះ ទិន្នន័យតែងតែមានក្នុងរូបភាពជាទិន្នន័យសមស្របផ្ទុយពីការពិត ឬក៏ជាទិន្នន័យប្រៀបធៀបច្បាស់លាស់រវាងប្រទេស និងប្រទេស ប៉ុន្តែនៅក្នុងករណីខ្លះទៀតទិន្នន័យនេះ មិនមានឡើយ ។

៣៩. ភស្តុតាងបានមកពីការពិសោធន៍ ដែលជាមូលដ្ឋាននៃការវាយតម្លៃទៅលើវិភាគទានរបស់ ADB នាំឱ្យសម្រេចបានលទ្ធផល ត្រូវបានប្រមូលមកពីប្រភពធំៗបី : សញ្ញាកូន្ទ ការវិភាគទិន្នន័យ និងការពិនិត្យលើការសិក្សាផ្សេងៗ ។ ការរកឃើញ និងសម្មតិកម្ម ដែលទាញចេញពី សញ្ញាកូន្ទ និងឯកសារដែលមានស្រាប់នោះ គឺមានសុពលភាពដោយបានប្រើប្រាស់វិធីប្រមូលទិន្នន័យបឋម និងមធ្យម ។ ការអះអាងបញ្ជាក់ពីប្រភពជាច្រើនទៀត ត្រូវបានប្រើដើម្បីធ្វើឱ្យការរកឃើញនោះ មានសុពលភាព និងដើម្បីបញ្ជាក់សម្មតិកម្មឱ្យច្បាស់ ។ ការអះអាងបញ្ជាក់ពីប្រភពផ្សេងៗបែបនេះ ជួយបង្កើតឱ្យមានទម្ងន់នៃភស្តុតាង ហើយតាមរយៈភស្តុតាងនេះ គេអាចទាញយកការសន្និដ្ឋាន និងការផ្តល់ជាអនុសាសន៍បាន ។ នៅក្នុងជំហាននេះ គឺជាការប្រៀបធៀបរវាងការរកឃើញដែលសម្រេចបានតាមបែបពីលើចុះក្រោម (ពោលគឺ ការអនុវត្តកម្រិតជាតិ និងតាមវិស័យដោយពិនិត្យមើលលើទ្ធផល និងផលប៉ះពាល់) ជាមួយនឹងការរកឃើញដែលទទួលបានតាមបែបពីក្រោមឡើងលើ (ពោលគឺ ការវាយតម្លៃលើសេវាកម្ចី និងមិនមែនកម្ចីជាក់លាក់) ហើយជំហាននេះ នឹងធ្វើការកែសម្រួលនូវភាពខុសគ្នាដែលអាចកើតឡើង ។ ការប្រើប្រាស់ដំណើរការត្រីកោណដើម្បីកំណត់ និងវាយតម្លៃលើវិភាគទានរបស់ ADB ដែលនាំឱ្យមានលទ្ធផល អភិវឌ្ឍន៍ និងផលប៉ះពាល់នោះ មានរៀបរាប់លម្អិតនៅក្នុងរូបភាព ២ ។

៤០. លទ្ធផលនៃជំនួយរបស់ ADB នឹងត្រូវធ្វើការត្រួតពិនិត្យទៅលើកម្លាំងចលករកម្មវិធីចម្បងៗ (ពោលគឺ ការរួមបញ្ចូលគ្នានូវសេវាកម្ចីជំនួយបច្ចេកទេស (TA) ការពិភាក្សាគោលនយោបាយ ការងារសេដ្ឋកិច្ច និងតាមវិស័យ និងការសម្របសម្រួលជាមួយអ្នកផ្តល់ជំនួយដែលមានគោលដៅសម្រេចនូវទិន្នផល លទ្ធផល និងផលប៉ះពាល់ស្រដៀងគ្នាដែរនោះ ។ ទោះជាយ៉ាងណាក៏ដោយ លក្ខណៈវាយតម្លៃទៅលើលទ្ធផលដែលបានពីសមាសភាគមួយៗនៃកម្លាំងចលករកម្មវិធីនោះ អាចមានភាពខុសផ្លែកគ្នាតាមប្រភេទលិខិតុបករណ៍ជំនួយ ។

៤១. **ការវាយតម្លៃលទ្ធផលនៃប្រតិបត្តិការកម្ចី.** លទ្ធផលនៃប្រតិបត្តិការកម្ចីដែលជាប់ពាក់ព័ន្ធ ហើយដែលស្ថិតនៅក្នុងកម្លាំងចលករកម្មវិធីតាមបណ្ដាវិស័យ ឬតាមប្រធានបទជាក់លាក់ នឹងត្រូវធ្វើការវាយតម្លៃ ។ CAPE នឹងធ្វើការត្រួតពិនិត្យ និងផ្ទៀងផ្ទាត់នូវការរកឃើញសំខាន់ៗដែលទាក់ទងនឹងលទ្ធផលនៃជំនួយរបស់ ADB តាមរយៈការវាយតម្លៃដោយខ្លួនឯង និងការវាយតម្លៃដោយឯករាជ្យទៅលើសកម្មភាព ផ្តល់ TA បណ្ដាកម្មវិធីផ្សេងៗ និងគម្រោងដែលបានបញ្ចប់ ។ លទ្ធផល ក៏អាចធ្វើការវាយតម្លៃតាមរយៈការចុះទៅដល់ទីកន្លែងសំខាន់ៗ ដែលសកម្មភាពរបស់ ADB កំពុងប្រតិបត្តិនៅទីនោះ តាមរយៈការជួបប្រជុំជាមួយនឹងអ្នកទទួលអត្ថប្រយោជន៍ពីគម្រោង កម្មវិធី និងតាមរយៈការជួបសម្ភាសន៍ជាមួយនឹងអ្នកតំណាងនៃទីភ្នាក់ងារអភិវឌ្ឍន៍សំខាន់ៗ (Executing Agencies = AEs) និងអ្នកពាក់ព័ន្ធផ្សេងទៀត ។ វត្ថុបំណង គឺដើម្បីធ្វើការវាយតម្លៃថា តើការរកឃើញសំខាន់ៗ ការសន្និដ្ឋាន និងការវាយតម្លៃជារួម នៅក្នុងដំណាក់កាលវាយតម្លៃដំបូង មានសុពលភាពដែរ ឬទេ បន្ទាប់ពីកម្មវិធីអនុវត្តក្នុងរយៈពេលមួយកន្លងទៅ ។

៤២. ចំពោះគម្រោង កម្មវិធី និង TA ដែលកំពុងដំណើរការ CAPE នឹងធ្វើការសន្និដ្ឋានអំពីលទ្ធភាព និងប្រភេទនៃលទ្ធផលរំពឹងទុក (ពោលគឺ ទិន្នផល លទ្ធផល និងផលប៉ះពាល់) ពីវឌ្ឍនភាពដែលសម្រេចបាន និងពីបរិបទដែលការអនុវត្តកំពុងតែដំណើរការ ។ CAPE ក៏នឹងធ្វើការវាយតម្លៃទៅលើលទ្ធផលនៃប្រតិបត្តិការនៅក្នុងវិស័យឯកជនរបស់ ADB ផងដែរដោយវាយតម្លៃជាចម្បងៗទៅលើកម្រិតដែលវិស័យ ឯកជននេះជួយដល់ប្រតិបត្តិការវិស័យសាធារណៈរបស់ ADB ជួយធ្វើឱ្យ មានកាតាលីករសមត្ថភាពកាន់តែខ្ពស់ និងជំរុញលំហូរចូលការ វិនិយោគផ្ទាល់ពីបរទេសឱ្យមានកំណើនឡើង ។

**រូបភាព ២ : ដំណើរការត្រីកោណនៃ CAPE**

**ការតាមដានពីការរួមចំណែករបស់ ADB ដើម្បីសម្រេចលទ្ធផល**




ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CAPE = ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស CSP = យុទ្ធសាស្ត្រនិងកម្មវិធីប្រចាំប្រទេស NGO = អង្គការក្រៅរដ្ឋាភិបាល
ប្រភព : នាយកដ្ឋានវាយតម្លៃប្រតិបត្តិការ

៤៣. **ការវាយតម្លៃលទ្ធផលការងារសេដ្ឋកិច្ច និងការងារតាមវិស័យ ការពិភាក្សាគោលនយោបាយ និង TA** ការងារសេដ្ឋកិច្ច និងការងារតាមវិស័យ ការពិភាក្សាគោលនយោបាយ និងអន្តរាគមន៍កសាងសមត្ថភាព បានរួមចំណែកនាំឱ្យមានការសម្រេចបានលទ្ធផលជាច្រើនដែលលទ្ធផលទាំងនេះជួយសម្រេចបាននូវលទ្ធផលក្នុងវិស័យដទៃទៀតបានយ៉ាងឆាប់រហ័ស និងច្រើនបង្គួរ ។ នៅក្នុងករណីខ្លះ ការពិភាក្សាគោលនយោបាយ ការងារសេដ្ឋកិច្ច និងការងារតាមវិស័យ និងការគាំទ្រ TA អាចត្រូវបានរៀបចំឡើងដោយកំណត់នូវ វត្ថុបំណងច្បាស់លាស់ (ពោលគឺ ដើម្បីជួយសម្រួលការរៀបចំកម្ចីនាពេលអនាគត) ហើយនៅក្នុងករណីខ្លះវត្ថុបំណងហាក់បីដូចជាមានភាពទូលំទូលាយពេកនៅក្នុងវិសាលភាពបែបនោះ ។ អន្តរាគមន៍មិនមែនកម្ចីអាចរួមចំណែកនាំឱ្យមាននូវចំណេះដឹងថ្មីៗ ការយល់ដឹង សមត្ថភាព និងលទ្ធភាព ព្រមទាំងការប្រែប្រួលជាក់ស្តែងនៅក្នុងប្រព័ន្ធយុត្តិធម៌ និងនិយតកម្ម និងនៅក្នុងចរិត និងខ្លឹមសារនៃផែនការយុទ្ធសាស្ត្រ និងគោលនយោបាយរបស់រដ្ឋាភិបាល ។ អន្តរាគមន៍មិនមែនកម្ចី អាចជំរុញឱ្យមានការប្រាស្រ័យទាក់ទងគ្នា និងទំនាក់ទំនងក្នុងចំណោមអង្គភាពវិស័យសាធារណៈផ្សេងៗ និងក្នុងចំណោមរដ្ឋាភិបាល វិស័យឯកជន និងសង្គមស៊ីវិល ។ បន្ថែមពីលើនេះ អន្តរាគមន៍មិនមែនកម្ចី អាចលើកកម្ពស់សមត្ថភាព ស្ថាប័នសាធារណៈ និងឯកជនឱ្យបំពេញនូវមុខងារតាមអាណត្តិរៀងខ្លួនៗរបស់ពួកគេបាន ។ CAPE គួរតែធ្វើការវាយតម្លៃ លទ្ធផលនានា "ច្បាស់លាស់" នៃសេវាមិនមែនកម្ចីផងដែរ (ពោលគឺ ដើម្បីកំណត់ថា តើ TA និងការងារសេដ្ឋកិច្ច និងការងារតាមវិស័យ បានរួមចំណែកជួយដល់កម្មវិធីកម្ចីដែរ ឬទេ) ដើម្បីត្រួតពិនិត្យមើលនូវទិន្នផលជំនួយ ដោយហេតុថា នៅក្នុងន័យនេះ ការជួយឱ្យបានគ្រប់គ្រាន់នូវសេវា មិនមែនកម្ចី ក៏មានសារៈសំខាន់ផងដែរ ។ ចំពោះការត្រួតពិនិត្យលទ្ធផល និងផលប៉ះពាល់នៃ CAP លទ្ធផលទូលំទូលាយនៃសេវាមិនមែនកម្ចី គួរត្រូវបានកំណត់ និងវាយតម្លៃ ។ នៅក្នុងផ្នែកកម្លាំងចលករតាមវិស័យ និងផ្នែកកម្លាំងចលករតាមប្រធានបទ CAPE គួរត្រួត

ពិនិត្យ វិសាលភាពដែលការងារសេដ្ឋកិច្ច និងការងារតាមវិស័យ ជំនួយ TA[១០] និង ការពិភាក្សាគោលនយោបាយ បានចូលរួមផ្តល់នូវចំណេះដឹងថ្មី ការយល់ដឹងថ្មី និងសមត្ថភាពថ្មី ព្រមទាំងនាំឱ្យមាននូវការប្រែប្រួលនៅក្នុងគោលនយោបាយ បរិស្ថាននិយតកម្ម និងស្ថាប័ន រួមមានដូចជាការធ្វើឱ្យប្រសើរឡើងនូវអាណត្តិ ការផ្តល់ហិរញ្ញប្បទាន គោលការណ៍លើកទឹកចិត្ត និងសមត្ថភាពគ្រប់គ្រងនៃស្ថាប័នសាធារណៈ និងឯកជនទាំងនោះ ដែលទទួលបានជំនួយពី ADB ផងដែរ ។

៤៤. **ការវាយតម្លៃលទ្ធផលនៃការសម្របសម្រួលក្នុងចំណោមដៃគូអភិវឌ្ឍន៍ និងជំរុញភាពជាម្ចាស់ប្រទេស** ADB សម្របសម្រួលសកម្មភាពរបស់ខ្លួនជាមួយនឹងដៃគូរអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីកាត់បន្ថយការបោះពុម្ពឡើងវិញ កាត់បន្ថយថ្លៃដើមប្រតិបត្តិការ និងជំរុញការឆ្លើយតបប្រកបដោយប្រសិទ្ធភាពទៅនឹងបញ្ហាប្រឈមនឹងការអភិវឌ្ឍតាមវិស័យនានា ។ ADB បានធ្វើការគាំទ្រទៅលើគោលការណ៍នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ២០០៥ និងទៅលើកិច្ចព្រមព្រៀងមួយចំនួនទៀតពីមុន ស្តីពីការលើកកម្ពស់ប្រសិទ្ធភាពជំនួយ ។ ស្របតាមការប្តេជ្ញាចិត្តទាំងនេះ ADB តែងតែជួយដល់បណ្តារដ្ឋាភិបាលប្រទេសផ្សេងៗ ដើម្បីអភិវឌ្ឍន៍សមត្ថភាពរបស់ស្ថាប័ននៃរដ្ឋាភិបាលទាំងនោះ ដើម្បីកំណត់យុទ្ធសាស្ត្រ និងអាទិភាពជាតិ និងចេះសម្របសម្រួលដើម្បីទទួលបានជំនួយមកពីប្រភពខាងក្រៅ ។ ទាក់ទងទៅនឹងការទទួលបាន ជំនួយពីប្រភពខាងក្រៅ CAPE នឹងធ្វើការត្រួតពិនិត្យការរៀបចំការសម្របសម្រួលជំនួយមកពីប្រភពខាងក្រៅ ហើយនឹងត្រួតពិនិត្យលើ តួនាទីរបស់ ADB នៅក្នុងការជួយរដ្ឋាភិបាល និងភាពជាម្ចាស់ប្រទេស ។ ទាក់ទងនឹងភាពជាម្ចាស់នេះ CAPE នឹងត្រួតពិនិត្យកម្រិត ដែលជំនួយរបស់ ADB ជួយជំរុញការជាប់ទាក់ទងរបស់អ្នកពាក់ព័ន្ធទាំងអស់នោះ (ឧ. រដ្ឋាភិបាល ផ្នែកឯកជន សង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល [NGOs] និងដៃគូអភិវឌ្ឍន៍ផ្សេងៗទៀត) នៅក្នុងការរៀបចំដោយប្រុងបយ័ត្ន និងអនុវត្តនូវ CSPs ។ ការត្រួតពិនិត្យនេះ ក៏នឹងមានការចូលរួមរបស់ ADB ក្នុងការពង្រឹងសមត្ថភាពរបស់រដ្ឋាភិបាល ឱ្យចេះរៀបចំកម្មវិធីវិនិយោគវិស័យសាធារណៈរបស់ខ្លួន ចេះកៀរគរជំនួយមកពីប្រភពខាងក្រៅ ចេះអនុវត្តគម្រោង និងកម្មវិធី និងចេះត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលនៃជំនួយមកពីខាងក្រៅ ។

៤៥. **ការវិភាគផលប៉ះពាល់** ទោះបីជាការផ្តោតយកចិត្តទុកដាក់ជាចម្បងនៃការវាយតម្លៃលទ្ធផល នឹងផ្អែកទៅលើការវិភាគលទ្ធផលក៏ដោយ ក៏ផលប៉ះពាល់ នឹងត្រូវបានកំណត់ និងវាយតម្លៃផងដែរ ។ CAPE នឹងធ្វើការប្រមូល និងបង្ហាញនូវសូចនាករនៃការអនុវត្តការងារសំខាន់ដែលទាក់ទងទៅនឹងភាពក្រីក្រ ស្ថានភាពសេដ្ឋកិច្ច សង្គម វិស័យ និងប្រធានបទ ហើយ CAPE នឹងផ្សាភ្ជាប់ទំនាក់ទំនងផ្សេងៗដែលអាចកើតមាន (បែបគុណវិស័យ) រវាងជំនួយរបស់ ADB និងដំណើរការវិវត្តនៅក្នុងសូចនាករទាំងនេះដែរ ។ សូចនាករនៃផលប៉ះពាល់ដែលមិនពាក់ព័ន្ធនឹងកម្មវិធី ក៏អាចត្រូវបានបញ្ចូលផងដែរ ដើម្បីកំណត់ និងបង្ហាញយ៉ាងលម្អិតនូវផ្នែកនានាដែល ADB (បើងាកមើលទៅក្រោយ) អាចបានចុះទៅជួយធ្វើអន្តរាគមន៍ ។ សម្រាប់អន្តរាគមន៍របស់ ADB ដែលផ្តល់ជាអត្ថប្រយោជន៍ដោយផ្ទាល់លើគោលដៅដែលបានកំណត់នោះ (ពោលគឺអន្តរាគមន៍ផ្តោតលើគោលដៅ) CAPE នឹងប្រើប្រាស់ទិន្នន័យដែលបានមកពីការអង្កេតទៅលើគម្រោង និងរបាយការណ៍ត្រួតពិនិត្យដើម្បីរៀបរាប់ពិលក្ខណៈ និងទំហំនៃអត្ថប្រយោជន៍របស់គម្រោង ។ ទិន្នន័យបែបនេះ ក៏អាចត្រូវប្រើប្រាស់ដើម្បីបង្ហាញយ៉ាងលម្អិតពីកម្រិតនៃលទ្ធផលដែលបានប៉ាន់ស្មាន និងរំពឹងទុកដែលកើតមានឡើងនៅ ក្នុងវិស័យនានា និងពីការប្រើប្រាស់លិខិតុបករណ៍ និងវិធី សាស្ត្រផ្តល់ជំនួយផ្សេងៗ ។

៤៦. **ការវិភាគ** បន្ទាប់ពីបានប្រមូលព័ត៌មានទាក់ទងនឹងលទ្ធផលរួចមក គឺដល់ដំណាក់កាលធ្វើវិភាគ និងធ្វើសំយោគ ។ ទិន្នន័យដែលប្រមូលបានត្រូវបានវិភាគទៅលើផ្នែកជាច្រើនដើម្បីបង្ហាញពីភាពខុសគ្នា ការប្រែប្រួល និងនិន្នាការ ។ ព័ត៌មានដែលគេបានប្រមូល ត្រូវបានរៀបចំទៅតាមសំណួរ និងសំណួរតូចៗផ្សេងៗគ្នា សម្រាប់វាយតម្លៃ ។ ទិន្នន័យដែលប្រមូលបាន ត្រូវបានវាយតម្លៃ ដើម្បីធានាឱ្យមានលទ្ធផលសំខាន់ៗនានា ដែលស៊ីសង្វាក់គ្នាទៅនឹងដំណាក់កាលផ្សេងៗគ្នានៃដំណើរការជំនួយអភិវឌ្ឍន៍ និងដើម្បីឱ្យបាននូវប្រភពទិន្នន័យផ្សេងៗគ្នាជាច្រើន ដែលមានភាពស្របគ្នាទៅវិញទៅមក

[១០] ជំនួយនេះក៏រាប់បញ្ចូលផងដែរនូវ TA ក្នុងតំបន់ ប្រសិនបើ TA មានជាប់ទាក់ទងដោយផ្ទាល់ជាមួយនឹងការសម្រេចបានជាកម្លាំងចលករកម្មវិធីចម្បងៗដែលត្រូវបានជ្រើសរើសដើម្បីធ្វើការវិនិច្ឆ័យនូវវិភាគទានរបស់ ADB ដែលនាំឱ្យសម្រេចបានលទ្ធផលអភិវឌ្ឍន៍នោះ ។

និងដើម្បីឱ្យមានភស្តុតាងរឹងមាំ ដែលអាចយកជាមូលដ្ឋានដើម្បីបញ្ជាក់ពីលទ្ធផលនៃការរកឃើញ និងការធ្វើសេចក្តីសន្និដ្ឋានសំខាន់ៗ ។ ក្រៅពីនេះ សំយោគនេះ នឹងផ្តល់នូវចម្លើយចំពោះសំណួរស្រាវជ្រាវ និងភស្តុតាងដើម្បីគាំទ្រ ឬបដិសេធសម្មតិកម្មដែលដឹកនាំការវាយតម្លៃនេះ ។

## ៤. ការកំណត់ការរួមវិភាគទានរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

៤៧. នៅក្នុងការអនុវត្ត ធនាគារ ADB រួមជាមួយដៃគូអភិវឌ្ឍន៍ផ្សេងទៀត បានរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងផ្តល់នូវជំនួយរួមដោយមានគោលដៅសម្រេចឱ្យបាននូវលទ្ធផល និងផលប៉ះពាល់អភិវឌ្ឍន៍ក្នុងកម្រិតជាក់លាក់មួយ ។ លទ្ធផល និងផលប៉ះពាល់អភិវឌ្ឍន៍ទាំងនោះ បានឆ្លុះបញ្ចាំងយ៉ាងច្បាស់អំពីឥទ្ធិពលរួមរបស់ភាគីទាំងប្រាំមួយ ៖ពោលគឺ (i) បណ្តារដ្ឋាភិបាលនៃ DMCs (ii) ADB (iii) ដៃគូអភិវឌ្ឍន៍ផ្សេងទៀត (iv) វិស័យឯកជន (v) សង្គមស៊ីវិល (vi) កត្តាពីខាងក្រៅ (ឧទាហរណ៍ គ្រោះធម្មជាតិ ការវិវត្តនៃសេដ្ឋកិច្ច ស្ថានភាពទីផ្សារសាកល វិបត្តិសេដ្ឋកិច្ចអន្តរជាតិ) ។ ស្ថិតនៅក្នុងកាលៈទេសៈណាមួយនោះ វិភាគទានជាអវិជ្ជមានពីសំណាក់ភាគីណាតែមួយ អាចជះឥទ្ធិពលលុបលើវិភាគទានជាវិជ្ជមានរបស់ធាតុទាំងប្រាំផ្សេងទៀត ហើយនឹងមិនបណ្តាលឱ្យមានលទ្ធផល និង/ឬផលប៉ះពាល់គួរជាទីពេញចិត្តទេ ។ ដំណាក់ទីបួននៃវិធីសាស្ត្ររបស់ CAPE មានគោលដៅដោះស្រាយបញ្ហានៃការកំណត់ដោយការត្រួតពិនិត្យលើកម្រិតជំនួយរបស់ ADB ដែលរួមចំណែកសម្រេចបាននូវលទ្ធផលនៃ"ការអនុវត្ត"ចម្បងៗ ឬថាតើលទ្ធផលទាំងនេះអាចកំណត់បានថាមកពីកត្តាផ្សេងទៀតដែលមិនមែនជាអន្តរាគមន៍របស់ ADB ដែរ ឬទេ ។ ការកំណត់នេះ ត្រូវបានធ្វើឡើងតាមរយៈការត្រួតពិនិត្យតួនាទីនៃកត្តាផ្សេងទៀត ដើម្បីកំណត់កម្រិតដែល ADB បានជួយរួមចំណែកដ៏មានតម្លៃដល់ដំណើរការឆ្ពោះទៅរកការសម្រេចបាននូវលទ្ធផល និងផលប៉ះពាល់ដែលគេបានសង្កេតនោះ ។ ដើម្បីសម្រេចបានគោលដៅនេះ សកម្មភាពតួអង្គសំខាន់ៗ ត្រូវបានពិនិត្យដើម្បីឱ្យស៊ីគ្នាជាមួយនឹងគោលនយោបាយ និងនីតិវិធីដែលចាំបាច់នាំឱ្យមានជោគជ័យនៃយុទ្ធសាស្ត្រជំនួយរបស់ ADB និងត្រូវបានគេត្រួតពិនិត្យទៅតាមបទដ្ឋានអន្តរជាតិលើការអនុវត្តល្អ ។

៤៨. ការកំណត់តម្រូវឱ្យមានការត្រួតពិនិត្យទៅលើលទ្ធផលសំខាន់ៗដែលបានលេចជារូបរាងឡើង ឬមិនទាន់បាន លេចជារូបរាងនៅឡើយ នៅក្នុងកម្លាំងចលករកម្មវិធីសំខាន់នីមួយៗ រួចហើយបែងចែកទំនួលខុសត្រូវដល់ភាគីទាំងប្រាំមួយដូចដែលបានរៀបរាប់ខាងលើ ។ ការបែងចែកនេះ អាចសម្រេចបាននៅក្នុង CAPE តាមរយៈការត្រួតពិនិត្យភស្តុតាងឯកសារ និងតាមរយៈការសម្ភាសន៍ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗ ដើម្បីវាយតម្លៃថា (i) តើសកម្មភាពរបស់អ្នកពាក់ព័ន្ធផ្សេងទៀត មានភាពស៊ីសង្វាក់គ្នា និងគាំទ្រដល់ដំណើរការសម្រេចលទ្ធផលដែល ADB កំពុងមានគោលដៅរួមវិភាគទានដែរ ឬទេ (ii) តើការប៉ាន់ស្មានអំពីខ្សែសង្វាក់លទ្ធផល មានភាពជាក់ស្តែង និងឆ្លើយតបសមស្របទៅនឹងវិបត្តិ និងភាពមិនច្បាស់លាស់ដែរ ឬទេ (iii) តើកម្មវិធី ដែលគេបានដាក់ចុះ មានស៊ីសង្វាក់គ្នាទៅនឹងគោលដៅសម្រេចលទ្ធផលអភិវឌ្ឍន៍ ដែលគេចង់បាន (ជាពិសេស លទ្ធផលអភិវឌ្ឍន៍) ដែរ ឬទេ និង (iv) តើមានភស្តុតាងណាមួយបញ្ជាក់ថាលទ្ធផលសំខាន់ៗដែលសម្រេចបាន គឺបានមកដោយសារកិច្ចខិតខំប្រឹងប្រែង ឬការចូលរួមពីសំណាក់អ្នកពាក់ព័ន្ធណាផ្សេងទៀត ឬក៏ដោយសារកត្តាពីខាងក្រៅដែរ ឬទេ ។

## ៥. ដំណាក់កាលសន្និដ្ឋាន និងផ្តល់អនុសាសន៍

៤៩. ដំណាក់កាលទីប្រាំនៃវិធីសាស្ត្រ CAPE នេះ មានដូចជាការធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់ជាអនុសាសន៍ដោយប្រុងប្រយ័ត្ន ។ ដើម្បីសន្និដ្ឋានទៅលើប្រតិបត្តិការ បញ្ហាប្រឈម និងកាលានុវត្តភាពក្នុងពេលអនាគតសម្រាប់ DMC ត្រូវតែកំណត់ និងសង្ខេបខ្លីៗ ។ ជាទូទៅ បញ្ហាប្រឈម និងកាលានុវត្ត ភាពទាំងនេះ អាចទទួលបានពីផែនការជាតិ NPRS និងបានមកពីការវាយតម្លៃរបស់ ADB ក្នុងពេលថ្មីៗនេះ ។ ភស្តុតាងបង្ហាញពីលទ្ធផលសំខាន់ៗ នឹងត្រូវបានបកស្រាយដោយពិចារណាទៅលើបញ្ហាប្រឈម និងកាលានុវត្តភាពនាពេលអនាគតរបស់ប្រទេសនីមួយៗ ដើម្បីបង្កើតជម្រើសទូទៅ និងអនុសាសន៍កាន់តែច្បាស់លាស់មួយចំនួនតូច ដែលម្រើស និងអនុសាសន៍ទាំងនោះ មានគោលដៅលើកកម្ពស់ប្រសិទ្ធភាពអភិវឌ្ឍន៍នាពេលអនាគតរបស់ ADB ។

៥០. **ការបដិសេធ** កំហិតនានានៃវិធីសាស្ត្ររបស់ CAPE ត្រូវបានគេទទួលស្គាល់ដោយស្មោះត្រង់ ហើយគេគួរតែបង្ហាញលទ្ធផល និងអនុសាសន៍នានារបស់ CAPE ដោយផ្អែកទៅលើគុណវុឌ្ឍិទាំងនេះជានិច្ច ។ ក្នុងការអនុវត្តជាក់ស្តែង ការរួមវិភាគទានរបស់ ADB ដែលនាំឱ្យសម្រេចបាន នូវលទ្ធផល គឺមិនអាចផ្តាច់ចេញ ឬកំណត់ទាំងស្រុងទៅលើតែ ADB បានទេ ដោយហេតុថា មានកត្តាផ្សេងៗទៀតផងដែរ ដែលជួយរួមចំណែកសម្រេចឱ្យបានលទ្ធផលអភិវឌ្ឍន៍រួមនេះ ។ ការណ៏ដែលចំណុចផ្ទុយពីការពិត មិនត្រូវបានសង្កេត ជាការបញ្ជាក់ថាវិភាគទានរបស់ ADB ដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ អាចកំណត់បានដោយការពិពណ៌នាក្នុងន័យប្រហាក់ប្រហែលតែប៉ុណ្ណោះ ។ នៅក្នុងករណីភាគច្រើន ការខ្វះ ឬការគ្មានគោលដៅ វត្ថុបំណងមុខព្រួញ និងសូចនាករអនុវត្តន៍ជាក់លាក់ដែលអាចត្រួតពិនិត្យបាននៅក្នុងយុទ្ធសាស្ត្ររបស់ប្រទេស និងការគ្មានកម្មវិធីជំនួយ គឺជាការបង្ហាញប្រាប់ថាខ្សែសង្វាក់លទ្ធផលដែលត្រូវធ្វើការវាយតម្លៃនោះ នឹងត្រូវបានកំណត់មិនច្បាស់លាស់ ។ ចំណុចខ្សោយនៅក្នុងប្រព័ន្ធត្រួតពិនិត្យ នឹងចៀសមិនផុតពីការដាក់កំហិតទៅលើភស្តុតាងដែលអាចត្រូវយកមកបង្ហាញ ។ CAPE ទំនងជាទាញយកការសន្និដ្ឋានពីសំណុំរង ឬពីគំរូនៃការអនុវត្តជំនួយប្រចាំប្រទេស បើពិនិត្យមើលលើអ្វីជាសេវាកម្ម និងអ្វីមិនមែនជាសេវាកម្ម ។ ជាចុងក្រោយ មានតែលទ្ធផល និងអនុសាសន៍ទាំងឡាយណាដែលត្រូវបានបង្ហាញប៉ុណ្ណោះដែលផ្អែកលើភស្តុតាងច្បាស់លាស់ ។

## III. មាតិការបាយការណ៍

## ក. ទម្រង់ និងការបញ្ជាប់ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

៥១. ជាទូទៅ CAPE នឹងអនុវត្តតាមរចនាសម្ព័ន្ធទូលំទូលាយដែលបានគូសបញ្ជាក់នៅក្នុងគោលការណ៏ណែនាំទាំងនេះ ។ ការអនុវត្តតាមរចនាសម្ព័ន្ធនេះ បានជួយដល់ការធានាឱ្យមានការស៊ីសង្វាក់គ្នារវាងការវាយតម្លៃ និងការកំណត់ព័ត៌មាននៅក្នុងរបាយការណ៏ ។ ទោះជាយ៉ាងណាក៏ដោយ ភាពខុសគ្នានៅតែមាន ដែលលក្ខណៈបែបនេះ គឺដើម្បីឆ្លើយតបទៅនឹងកាលៈទេសៈជាក់លាក់នៃកម្មវិធីណាមួយដែលបានបង្កើតឡើង ។ គោលការណ៏ណែនាំទាំងនេះ មានគោលបំណងជួយរៀបចំការវិភាគ និងរបាយការណ៏ ។ អ្នកវាយតម្លៃត្រូវប្រើការវិនិច្ឆ័យដ៏ត្រឹមត្រូវបំផុត ដោយផ្អែកលើសម្ថភាពជំនាញរបស់ខ្លួន ដើម្បីចៀសវាងភាពមិនចាំបាច់ និងការធ្វើច្រំដែល ហើយត្រូវយកចិត្តទុកដាក់ទៅលើបញ្ហាសំខាន់ៗវិញ ។

៥២. របាយការណ៏លម្អិត នឹងត្រូវរៀបចំឡើងដើម្បីដឹកនាំការរៀបចំ CAPE ។ របាយការណ៏នេះ នឹងកំណត់ពីវិធី វិធីសាស្ត្រ បញ្ហាគន្លឹះដែលត្រូវដោះស្រាយ ក្របខ័ណ្ឌពេលវេលា និងធនធានចាំបាច់ ។ របាយការណ៏លម្អិតនេះ នឹងត្រូវលើកយកមកពិភាក្សាជាមួយអង្គភាពរបស់ ADB ដែលពាក់ព័ន្ធក្នុងនោះ រួមមានក្រុមប្រចាំប្រទេស មុននឹងដាក់ជូនសុំការអនុម័តិពីអគ្គនាយក (DG) នៃ OED ។ បន្ទាប់ពីចុះធ្វើការស្រាវជ្រាវដល់ទីកន្លែងជាច្រើនរួចមក របាយការណ៏សង្ខេបមួយ (ប្រាំទំព័រ) ក៏ត្រូវបានរៀបចំ និងពិភាក្សាឡើងជាមួយនឹងអង្គភាពរបស់ ADB ដែលពាក់ព័ន្ធ និងថ្នាក់ដឹកនាំរបស់ OED ដោយសង្ខេបជាលម្អិតអំពីលទ្ធផល និងសេចក្តីសន្និដ្ឋានសំខាន់ៗ ។ បន្ទាប់មក សេចក្តីព្រាងរបស់ CAPE នឹងត្រូវគេរៀបចំឡើង និងត្រួតពិនិត្យឡើងវិញជាលើកដំបូងនៅក្នុង OED ។ បន្ទាប់មក សេចក្តីព្រាងនេះ នឹងត្រូវផ្សព្វផ្សាយដល់នាយកដ្ឋាន និងការិយាល័យរបស់ ADB ដែលពាក់ព័ន្ធ ។ បន្ទាប់ពីធ្វើការកែសម្រួលដើម្បីឆ្លុះបញ្ចាំងពីការធ្វើអត្ថាធិប្បាយនៃការិយាល័យរបស់ ADB ដែលពាក់ព័ន្ធរួចមក សេចក្តីព្រាងនេះ នឹងត្រូវបញ្ជូនទៅរដ្ឋាភិបាល ហើយរៀបចំការពិភាក្សាទៅលើលទ្ធផលរបស់ CAPE ។ នាយកអង្គភាព OED ដែលជាប់ពាក់ព័ន្ធ ជាធម្មតា តែងតែចូលរួមនៅក្នុងការពិភាក្សាទាំងនេះ ។ សម្រាប់កម្មវិធីធំៗ ក៏មានការចូលរួមពីអគ្គនាយក OED ផងដែរ ។ អនុសាសន៏របស់ CAPE គួរធ្វើឡើងឱ្យបានទាន់ពេលវេលានៅក្នុងដំណើរការវាយតម្លៃ ដើម្បីឱ្យគេអាចវាយតម្លៃអនុសាសន៏ទាំងនោះ ហើយអាចឱ្យបុគ្គលិកយកអនុសាសន៏ទាំងនោះប្រើបាន ។ អនុសាសន៏ទាំងឡាយណាដែលតម្រូវឱ្យ ADB ឬ DMCs/EAs អនុវត្តតាម គួរលើកយកមកពិភាក្សាឱ្យបានល្អិតល្អន់ទៅតាមចំណុចនៃរបៀបវារៈនីមួយៗ ហើយធ្វើការគូសបញ្ជាក់នៅពេល ដែលរបាយការណ៏ពង្រាងនេះ ត្រូវផ្ញើរជូនរដ្ឋាភិបាលដើម្បីសុំសេចក្តីអត្ថាធិប្បាយ ។ គួរតែរៀបចំអង្គប្រជុំថ្នាក់អគ្គនាយកមួយ ដើម្បីពិភាក្សាទៅលើការធ្វើអនុសាសន៏នេះ បន្ទាប់ពីពង្រាងរបស់ CAPE ត្រូវបានចែកផ្សាយដើម្បីសុំសេចក្តីអត្ថាធិប្បាយ និងបន្ទាប់ពីមានការកែសម្រួលសមស្រប ។ អង្គប្រជុំនេះ មានគោលដៅលើកកម្ពស់ការយល់ដឹង និងការទទួលយកបាន ពីបុគ្គលិកជាន់ខ្ពស់កាន់តែខ្លាំងក្លាឡើងថែមទៀត

ចំពោះលទ្ធផល និងអនុសាសន៍របស់ CAPE ។ បទអត្ថាធិប្បាយដែលទទួលបាន នឹងត្រូវធ្វើការពិចារណា ដើម្បីសរសេរបញ្ចប់របាយការណ៍ ។ ភាពខុសគ្នាទៅលើបញ្ហាសំខាន់ៗរវាងបណ្តានាយកដ្ឋានរបស់ ADB រដ្ឋាភិបាល និង OED ត្រូវរាយការណ៍ជូននៅក្នុងសេចក្តីបន្ថែម ឬលេខយោងនៅក្នុង CAPE ។

៥៣. រចនាបថ និងទម្រង់នៃ CAPE គួរប្រកាន់ខ្ជាប់ទៅនឹង *Handbook of Style and Usage* របស់ ADB ។ អត្ថបទសំខាន់ៗ មាន ៥០ ទំព័រជាអតិបរិមា ដោយមិនរាប់បញ្ចូលសេចក្តីបន្ថែម សម្រាប់កម្មវិធីធំៗ និង ៣៥ ទំព័រសម្រាប់កម្មវិធីតូចៗ ។[១១]

៥៤. រាល់របាយការណ៍វាយតម្លៃ និងការសិក្សារបស់ OED ទាំងអស់ ត្រូវបានផ្សព្វផ្សាយជាសាធារណៈអាស្រ័យលើការយល់ព្រមពីអគ្គនាយកនៅពេលណាដែលរបាយការណ៍ និងការសិក្សាទាំងនេះ ត្រូវបញ្ជូនទៅកាន់ថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាល ។ គ្រប់ CAPE ទាំងអស់ នឹងត្រូវធ្វើឡើងដោយគណៈកម្មាការដើម្បីប្រសិទ្ធផលនៃការអភិវឌ្ឍរបស់ ADB (DEC) ។ ការឆ្លើយតបរបស់ថ្នាក់ដឹកនាំទៅលើ CAPE ការឆ្លើយតបរបស់ OED (ប្រសិនបើមាន) និងសេចក្តីសង្ខេបរបស់ DEC អាចរកបានជាសាធារណៈ ។ របាយការណ៍វាយតម្លៃដែលទទួលបាន ការអនុម័តិបន្ទាប់ពីឆ្នាំ១៩៩៥ មក រួមទាំងរបាយការណ៍ទាំងអស់របស់ CAPE លោកអ្នកអាចចូលបើកមើលបានតាមរយៈអ៊ិនត្រាណែតរបស់ ADB និងតាមរយៈវែបសាយអ៊ិនធឺណែត (WWW.ADB.org/evaluation) ។

៥៥. ឯកសាររបស់ CAPE មានប្រាំពីរជំពូកធំៗ ដោយជំពូកទីមួយជាសេចក្តីផ្តើមអំពីវិធីសាស្រ្ត ជំពូកទីពីរ និងទីបីទាក់ទងនឹងការធ្វើការវិនិច្ឆ័យការបង្កើត និងការរៀបចំកម្មវិធីយុទ្ធសាស្រ្តប្រចាំប្រទេស ជំពូកទីបួនស្តីពីការអនុវត្តគម្រោង និងជំពូកទីប្រាំពាក់ព័ន្ធនឹងលទ្ធផលសម្រេចបាន ។ ជំពូកទីប្រាំមួយ នឹងធ្វើការវាយតម្លៃលើការអនុវត្ត ជារួមនឹងជំពូកទីប្រាំពីរ ពិភាក្សាទៅលើលទ្ធផល និងមេរៀនសំខាន់ៗ ព្រមទាំងផ្តល់អនុសាសន៍ ។ ជំពូកនីមួយៗសម្រាប់ CAPE មានដូចខាងក្រោម ៖

[១១] គំរូរៀបរាប់គោលៗនៃរបាយការណ៍សូចនាករសម្រាប់ CAPE មាននៅក្នុងសេចក្តីបន្ថែម ១ ។

## សេចក្តីសង្ខេប

I. សេចក្តីផ្តើម
II. បរិបទអភិវឌ្ឍន៍ និងអាទិភាពរបស់រដ្ឋាភិបាល
III. យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB
IV. ការអនុវត្តកម្មវិធី
V. លទ្ធផលសម្រេចបាន និងកត្តាជះឥទ្ធិពលដល់ការអនុវត្ត
VI. ការវាយតម្លៃ និងការចាត់ជាចំណាត់ថ្នាក់នៃការអនុវត្ត
VII. សេចក្តីបន្ថែមអំពីលទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ខ. សេចក្តីសង្ខេប

៥៦. អនុសាសន៍នៅក្នុង CAPE គួរមានឥទ្ធិពលទៅលើសេចក្តីសម្រេចចិត្តទាក់ទងនឹងប្រតិបត្តិការរបស់ ADB នាពេលអនាគតនៅក្នុងបណ្តាប្រទេសនីមួយៗ ។ ដូច្នេះ សេចក្តីសង្ខេបនេះ ដែលមានលទ្ធផល មេរៀន សេចក្តីសន្និដ្ឋាន និងអនុសាសន៍ សំខាន់ៗរបស់ CAPE មានសារៈសំខាន់យ៉ាងខ្លាំង ។ លទ្ធផល និងអនុសាសន៍ គួរកំណត់មធ្យោបាយឱ្យបានជាក់លាក់ក្នុងការលើកកម្ពស់ប្រសិទ្ធភាពអភិវឌ្ឍន៍នៃជំនួយរបស់ ADB ហើយក៏គួរដោះស្រាយនូវបញ្ហាយុទ្ធសាស្ត្រដែលទាក់ទងនឹង ADB និងប្រទេសនានាផងដែរ ។ អនុសាសន៍ទាំងនោះ គួរមានភាពច្បាស់លាស់ អាចឱ្យគេត្រួតពិនិត្យបាន អនុវត្តបាន មានទំនាក់ទំនងនឹងគ្នា មានគោលដៅសម្រេចលទ្ធផល និងគោរពតាមពេលវេលា ។ ចំណាត់ថ្នាក់វាយតម្លៃជារួមនឹងត្រូវបានគេធ្វើឡើង ដោយភ្ជាប់ជាមួយនឹងការពន្យល់ផងដែរ ។ ជាទូទៅ សេចក្តីសង្ខេប មានទាំងអស់ប្រាំទំព័រ ។

## គ. សេចក្តីផ្តើម

៥៧. ផ្នែកនេះ នឹងណែនាំអំពីគោលដៅ និងវត្ថុបំណងរបស់ CAPE សង្ខេបវិធីសាស្ត្រ និងលក្ខណៈដែលផ្នែកនេះ ត្រូវបានគេយកមកប្រើក្នុងករណីបែបនេះ ព្រមទាំងរៀបរាប់ត្រួសៗអំពីកំហិតលើការសិក្សា ។

## ឃ. បរិបទអភិវឌ្ឍន៍ និងអាទិភាពរបស់រដ្ឋាភិបាល

៥៨. ជំពូកនេះ រៀបរាប់អំពីបរិបទជាមូលដ្ឋានដែលគេបានបង្កើតឡើងនៅក្នុងយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB ។ ជំពូកនេះ ក៏បង្ហាញអំពីស្ថានភាពសេដ្ឋកិច្ច និងសង្គមរបស់ប្រទេសព្រមទាំងបញ្ហាប្រឈមសំខាន់ៗ ចំពោះការអភិវឌ្ឍ ។ ជាទូទៅ ជំពូកនេះ ត្រូវបានចងក្រងឡើងដោយការវិភាគឯកសាររបស់ ADB (ការងារសេដ្ឋកិច្ច និងការងារតាមវិស័យ យុទ្ធសាស្ត្រប្រចាំប្រទេស ឯកសាររៀបចំកម្មវិធី ឯកសារកម្មវិធីសំខាន់ៗ) រួមជាមួយនឹងការវិភាគទៅលើឯកសារជាផ្លូវការរបស់ប្រទេសនីមួយៗ ស្តីពីបញ្ហានៃការអភិវឌ្ឍ របាយការណ៍ពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត របាយការណ៍ពីផ្នែកឯកជន និងពីការសិក្សារបស់អ្នកស្រាវជ្រាវមុនៗដែលគេអាចរកបានផងដែរ ។ ជំពូកនេះ ក៏នឹងមានការវាយតម្លៃទៅលើការអភិវឌ្ឍវិស័យសេដ្ឋកិច្ច និងនយោបាយសំខាន់ៗ ហើយវានឹងវាយតម្លៃលើនិន្នាការទូទៅនៅក្នុងការអនុវត្តរបស់ប្រទេសដោយប្រើប្រាស់សូចនាករនៃការអនុវត្តគោលនយោបាយ និងអភិបាលកិច្ច ដូចដែលបានរាយការណ៍នៅក្នុង "ប្រព័ន្ធបែងចែកធនធានដោយផ្អែកលើការអនុវត្ត" របស់ ADB ។ វឌ្ឍនភាពដែលសម្រេចបានក្នុងការកាត់បន្ថយភាពក្រីក្រ និងដំណើរឆ្ពោះទៅរកការសម្រេចបានគោលដៅ MDG ក៏នឹងត្រូវលើកយកមកបរិយាយនៅក្នុងជំពូកនេះផងដែរ ។ ផ្នែកនេះ នឹងសង្ខេបអាទិភាពជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលដោយពឹងផ្អែកលើការធ្វើផែនការឯកសារ និង NPRS ហើយនឹងវាយតម្លៃលើគោលនយោបាយដែលគេកំពុងព្យាយាម សម្រេចឱ្យបានជាក់ស្តែង ។ ជំពូកនេះ ខិតខំឆ្លើយទៅនឹងសំណួរដូចខាងក្រោម :

(i) តើបញ្ហាចម្បងចំពោះការអភិវឌ្ឍនៅក្នុងប្រទេស មានអ្វីខ្លះ នៅក្នុងអំឡុងពេលចាប់ផ្តើមកម្មវិធីនោះ ?

(ii) តើបញ្ហាទាំងនោះ មានការផ្លាស់ប្តូរដែរ ឬទេ ក្នុងរយៈពេលដែលមានការត្រួតពិនិត្យឡើងនោះ ហើយប្រសិនបើមាន តើមានការផ្លាស់ប្តូរដូចម្តេចខ្លះ ?

(iii) តើបរិយាកាសនយោបាយ និងសេដ្ឋកិច្ចដែលកំពុងវិវត្តន៍នោះ មានឥទ្ធិពលដូចម្តេចខ្លះ ទៅលើបញ្ហាចម្បងចំពោះការអភិវឌ្ឍ ?

(iv) តើរដ្ឋាភិបាលមានប្រកាសបញ្ជាក់ជាផ្លូវការអំពីអាទិភាពអភិវឌ្ឍន៍ និងអំពីយុទ្ធសាស្ត្ររបស់ខ្លួនដែរ ឬទេ ? ប្រសិនបើមាន តើអាទិភាពទាំងនោះមានអ្វី ខ្លះ ហើយស្ថិតនៅក្នុងចំណាត់ថ្នាក់ណាមួយ ?

(v) តើគោលនយោបាយដែលគេបានប្រកាសឡើង មានភាពស៊ីសង្វាក់គ្នា ជាមួយគោលនយោបាយដែលកំពុងព្យាយាមសម្រេចឱ្យបាននោះ ឬទេ ?

(vi) តើតួអង្គផ្តល់ជំនួយអភិវឌ្ឍន៍ណាខ្លះ ដែលមានភាពសកម្មនៅក្នុងប្រទេស ក្នុងអំឡុងពេលអនុវត្តកម្មវិធីនោះ ? តើតួអង្គទាំងនោះមានអាទិភាពប្រតិបត្តិការអ្វីខ្លះ ហើយតើកិច្ចសហប្រតិបត្តិការរវាងតួអង្គទាំងនោះ ADB និងរដ្ឋាភិបាលមានលក្ខណៈដូចម្តេច ?

## ង. យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

៥៩. ជំពូកនេះ នឹងរៀបរាប់ដោយការពិចារណានូវការបង្កើត CSPs របស់ ADB ទៅតាមដំណាក់កាល ។ ជំពូកនេះ ក៏នឹងវាយតម្លៃតួនាទីរបស់ ADB នៅក្នុងការលើកកម្ពស់ការចូលរួម និងភាពជាដៃគូ និងវាយតម្លៃកិច្ចខិតខំប្រឹងប្រែងរបស់ខ្លួនក្នុងការសម្របសម្រួលជំនួយ និងការកៀរគរធនធាន និងការជ្រើសរើស ការច្នៃប្រឌិត ប្រសិទ្ធផល និងភាពច្បាស់លាស់នៃគោលបំណងរបស់ខ្លួនផងដែរ ។ ស្ថិតក្នុងស្ថានភាពមួយ ដែលធាតុទាំងនេះ ប៉ះពាល់ដល់ការរៀបចំកម្មវិធី គេក៏នឹងបង្កើតការវិនិច្ឆ័យលើតួនាទីរបស់តួអង្គផ្សេងទៀត ប៉ុន្តែការវិនិច្ឆ័យនេះ មានសារៈសំខាន់បន្ទាប់បន្សំប៉ុណ្ណោះ ។

៦០. គោលបំណងនៃការវិភាគ CSPs របស់ ADB ដែលកំពុងតែវិត្តន៍ គឺដើម្បីរកឱ្យឃើញនូវដំណើរការដែលត្រូវបានគេប្រើដើម្បីធ្វើឱ្យ CSP និងខ្លឹមសាររបស់វា លេចចេញជារូបរាងឡើង។ ការរុករកនេះ រួមមាន :

(i) ការស៊ីសង្វាក់គ្នា និងភាពសមស្របនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រដ្ឋាភិបាល ផែនការកាត់បន្ថយភាពក្រីក្រ តម្រូវការធនធាន ព្រមទាំងយុទ្ធសាស្ត្រសម្រាប់កៀរគរ និងប្រើប្រាស់ជំនួយអភិវឌ្ឍន៍ ។

(ii) ដើម្បីវាយតម្លៃទៅលើកម្រិត CSP របស់ ADB, CSPs ទាំងនេះ (ក) ត្រូវបានគេធ្វើឱ្យស៊ីសង្វាក់គ្នាជាមួយនឹងយុទ្ធសាស្ត្រ និងផែនការរបស់រដ្ឋាភិបាល (ខ) ត្រូវទទួលរងឥទ្ធិពលពីការងារសេដ្ឋកិច្ច និងការងារតាមវិស័យ (គ) ទទួលបានការពិភាក្សាគោលនយោបាយសមស្រប និងក្របខ័ណ្ឌវិភាគច្បាស់លាស់ និង (ឃ) ដើរស្របតាម PRS និងក្របខ័ណ្ឌការងារយុទ្ធសាស្ត្ររយៈពេលមធ្យមរបស់ ADB ព្រមទាំងស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រតាមវិស័យ និងយុទ្ធសាស្ត្រតាមប្រធានបទរបស់ប្រទេស ។ សម្រាប់ CSPs លើកក្រោយ នឹងលើកយកការពិភាក្សាអំពីកម្រិតនៃភាពក្រីក្រ វិស័យឯកជន អភិបាលកិច្ច និងការវាយតម្លៃទៅលើបរិស្ថាន និងយេនឌ័រ ។

(iii) សកម្មភាពរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត និងការរៀបចំសម្របសម្រួលឱ្យមានភាពសុខដុមនៃជំនួយដើម្បីកំណត់ថាតើ ADB ពិតជាបានជួយពូនជ្រុំប្រកបដោយប្រសិទ្ធភាពដល់ជំនួយរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀតដែរ ឬទេ ។ ការយកចិត្តទុកដាក់ ជាពិសេសគួរត្រូវបានធ្វើឡើងក្នុងកម្រិតដែល CSPs របស់ ADB បានរៀបចំឱ្យ ADB ផ្តល់ការគាំទ្រក្នុងផ្នែកទាំងឡាយណាដែល ADB មានឧត្តមភាពប្រៀបធៀប ។

(iv) ភាពស៊ីគ្នា និងគុណភាពនៃសេវាកម្មី និងមិនមែនកម្ចីដែលបានរៀបចំទុកជាមុន ។

(v) កម្រិតដែលកត្តាសេដ្ឋកិច្ចនយោបាយ ត្រូវបានលើកយកមកពិចារណាយ៉ាងច្បាស់លាស់នៅក្នុងការរៀបចំ CSP ។

៦១. កត្តាទាំងឡាយដែលត្រូវលើកយកមកពិចារណា មានដូចខាងក្រោម ៖

(i) របៀបវារៈអភិវឌ្ឍន៍ជាតិដែលគាំទ្រកម្មវិធីជំនួយ

(ii) ភាពជាម្ចាស់ និងសេដ្ឋកិច្ចនយោបាយអំណោយផលក្នុងការធ្វើសេចក្តីសម្រេចចិត្ត

(iii) ការវិភាគ និងចំណេះដឹងទៅលើប្រទេស និងបណ្តាវិស័យ មានភាពគ្រប់គ្រាន់

(iv) សមត្ថភាពរបស់ស្ថាប័នក្នុងការគ្រប់គ្រង និងប្រើប្រាស់ជំនួយពីខាងក្រៅ និងអនុវត្តកំណែទម្រង់ដែលបានព្រមព្រៀង

(v) កម្រិតដែលតក្កកម្មវិធីកំណត់គឺ (ក) គោលដៅដែលត្រូវសម្រេច (ខ) វត្ថុបំណងជាក់លាក់នៃជំនួយរបស់ ADB វង្វាស់កម្មវិធី ទិន្នផល លទ្ធផល និងផលប៉ះពាល់រំពឹងទុក (គ) ការប៉ាន់ស្មាន និងហានិភ័យចម្បងចំពោះការអនុវត្ត និង (ឃ) ជម្រើសនៃការរៀបចំ *(កម្មវិធី, គម្រោង)* ដែលបានគិតគូរពិចារណា

(vi) កម្រិតដែលហានិភ័យ (ទាំងកត្តាខាងក្នុង និងកត្តាខាងក្រៅ) ត្រូវបានកំណត់ ហើយវិធានការកាត់បន្ថយ និងយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ ទទួលបានការឯកភាព ។

(vii) ការទទួលបានការគាំទ្រគ្រប់គ្រាន់ពី ADB ដើម្បីធ្វើឱ្យប្រទេសនោះ មានលទ្ធភាពសម្រេចបាននូវវត្ថុបំណងដូចបានកំណត់ ការផ្តល់សនិទានភាពសម្រាប់ការផ្តល់ហិរញ្ញប្បទាន និងមានការវាយតម្លៃទៅលើផលប៉ះពាល់នៃការផ្តល់ហិរញ្ញប្បទាន (ជាពិសេស ទៅលើលទ្ធភាពទទួលបានកម្ចី) ដែរ ឬទេ ។

(viii) ការកំណត់សូចនាករនានា សម្រាប់ការធ្វើរបាយការណ៍ ការត្រួតពិនិត្យ និងការវាយតម្លៃ និងការបែងចែកការទទួលខុសត្រូវផ្សេងៗ និងការផ្តល់ថវិការសម្រាប់ការទទួលខុសត្រូវទាំងនោះ ។

៦២. **ការកំណត់លក្ខណៈទិន្នន័យរបស់ ADB** ផ្នែកនេះ នឹងធ្វើការកំណត់លក្ខណៈជំនួយរបស់ ADB លើខ្សែសង្វាក់លទ្ធផលមួយ ឬច្រើនដែលគេរំពឹងទុកថា ជំនួយនេះ នឹងត្រូវបានជួយផ្តល់ជាវិភាគទាន ។ ខ្សែសង្វាក់លទ្ធផលទាំងនេះ ត្រូវបានដកស្រង់ចេញពីប្រភពឯកសាររបស់ CSP និងមានតួនាទីជាអ្នកផ្តល់ក្របខ័ណ្ឌគោលដៅ វត្ថុបំណង និងការរំពឹងទុកការអនុវត្ត ដែលនឹងផ្តុយពីការវាយតម្លៃទៅលើកម្មវិធី ។ នៅក្នុងខ្សែសង្វាក់លទ្ធផលទិន្នន័យនានា គឺជាអន្តរាគមន៍បែបយុទ្ធសាស្ត្រ ដែលមានគោលដៅសម្រេចទិន្នផល លទ្ធផល និងផលប៉ះពាល់ ដែលគេបានកំណត់រួចហើយ ។ ទិន្នន័យទាំងនេះ អាចជាទម្រង់នៃការបញ្ចូលគ្នានូវគម្រោង កម្មវិធី ជំនួយ TA និងសេវាមិនមែនកម្ចីរបស់ ADB ទាំងនៅក្នុង និងក្រៅវិស័យនានា និងទាំងនៅក្នុង និងក្រោយអំឡុងពេលផ្សេងៗគ្នានៃអនុវត្តកម្មវិធី ។ ខ្សែសង្វាក់លទ្ធផល នឹងត្រូវបានលើកយកមកបង្ហាញ ដើម្បីពិចារណាទៅលើកម្លាំងចលករកម្មវិធីសំខាន់នីមួយៗ ។ ក្របខ័ណ្ឌលទ្ធផលជាផ្លូវការ អាចលើកយកមកបង្ហាញដើម្បីដឹកនាំការវាយតម្លៃ ជាចំណុចដែលតក្កកម្មវិធីមានភាពច្បាស់លាស់ ហើយដែលកម្មវិធីនេះ ក៏ត្រូវបើកទូលាយដើម្បីឱ្យមានភាពងាយស្រួលក្នុងការវាយតម្លៃផងដែរ ។

៦៣. **ការគ្របដណ្តប់តាមវិស័យ និងតាមប្រធានបទ.** ផ្នែកនេះ នឹងធ្វើការបែងចែកទិន្នន័យ ជំនួយរបស់ ADB តាមវិស័យ តាមមូលដ្ឋានគ្រឹះជាយុទ្ធសាស្ត្រនៃការកាត់បន្ថយភាពក្រីក្រ និងតាមគំនិតផ្តួចផ្តើមនៃប្រធានបទសំខាន់ៗ ។ នៅក្នុងផ្នែកនីមួយៗ ការបែងចែក នឹងកំណត់ (i) យុទ្ធសាស្ត្រដែលកំពុងដំណើរការរបស់ ADB (វិស័យ មូលដ្ឋានគ្រឹះ និងប្រធានបទ) រួមមាន គោលដៅ វត្ថុបំណង និងលទ្ធផលសំខាន់ៗ ដែលនឹងត្រូវសម្រេចឱ្យបាន (ii) កម្មវិធីកម្ចី និងកម្មវិធីមិនមែនកម្ចី ដែលត្រូវដាក់ចុះដើម្បីរួមវិភាគទាននាំឱ្យសម្រេចបានលទ្ធផលទាំងនេះ និង (iii) សេវាគាំទ្រ (ពោលគឺការងារសេដ្ឋកិច្ច និងការងារតាមវិស័យ ការសម្របសម្រួលជាមួយអ្នកផ្តល់ជំនួយ ការពិភាក្សាគោលនយោបាយ) ដែលនឹងត្រូវជួយបំពេញបន្ថែមដល់ការគាំទ្រដោយផ្ទាល់របស់ ADB ។ តួនាទីរបស់ ADB នៅក្នុងវិស័យនីមួយៗ ក៏គួរធ្វើការកំណត់ផងដែរ ក្នុងន័យថាតើ ADB គឺជាដៃគូអភិវឌ្ឍន៍នាំមុខគេដ៏ចម្បង ឬបន្ទាប់បន្សំដែរ ឬក៏យ៉ាងណា ។ នៅក្នុងការរៀបរាប់ពីការចូលពាក់ព័ន្ធរបស់ ADB គេគួរលើកយកមកដោះស្រាយ នូវវិស័យសំខាន់ៗ និងមូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រ ។ បញ្ហាតាមប្រធានបទជាក់លាក់ (ពោល គឺការអភិវឌ្ឍវិស័យឯកជន ការកសាងសមត្ថភាព បរិស្ថាន និងអភិបាលកិច្ច/អំពើពុករលួយ) គួរដាក់បញ្ចូលនៅក្នុងការបែងចែកដូចដែលបាន បង្ហាញនៅក្នុង CAPE ទាំងអស់ ។ បញ្ហាតាមប្រធានបទផ្សេងៗទៀត ក៏គួរ

ធ្វើការវាយតម្លៃផងដែរ ប្រសិនបើបញ្ហាទាំងនេះ ត្រូវបាន ចាត់ទុកថាជាកម្លាំងចលករដ៏សំខាន់នៃជំនួយរបស់ ADB នៅក្នុង DMC ដែលពាក់ព័ន្ធ ។ រាល់ប្រធានបទដែលទាក់ទងជាពិសេសទៅនឹង ជំនួយរបស់ ADB នៅក្នុង DMC ណាមួយ (ដូចជាសមាហរណកម្មតំបន់ ភាពជាដៃគូរវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ការអភិវឌ្ឍ តំបន់ និងការគាំទ្រការ ធ្វើពហុកម្មសេដ្ឋកិច្ច) អាចចាត់ទុក និងវាយតម្លៃថាជាបញ្ហាតាមប្រធានបទជាក់លាក់របស់ប្រទេស ។

៦៤. ការវាយតម្លៃ CSPs របស់ ADB ផ្តោតទៅលើការបង្កើតសនិទានភាពសម្រាប់កម្មវិធីជំនួយរបស់ ADB ទាំងក្នុងពេលចាប់ផ្តើមដំណើរការ និងក្នុងពេលត្រួតពិនិត្យ ។ ការវាយតម្លៃនេះ គ្របដណ្តប់ទាំងទៅលើគោលដៅ និងវត្ថុបំណងជំនួយរបស់ ADB ព្រមទាំងទៅលើការរួមបញ្ចូលគ្នានៃលិខិតុបករណ៍ដែលត្រូវទទួលការគាំទ្រ ដើម្បីឈានទៅរកការសម្រេចវត្ថុបំណងទាំងនោះផងដែរ ។ ការវាយតម្លៃនេះ ខិតខំឆ្លើយទៅនឹងសំណួរខាងក្រោម :[១២]

(i) តើបញ្ហាអភិវឌ្ឍន៍ណាខ្លះសម្រាប់ប្រទេស ដែលត្រូវបានលើកយកមកពិចារណារកដំណោះស្រាយនៅក្នុង CSPs ជាផ្លូវការរបស់ ADB ?

(ii) តើការវិនិច្ឆ័យរបស់ ADB មានគ្របដណ្តប់ទៅលើបញ្ហាអភិវឌ្ឍន៍សំខាន់ៗរបស់ប្រទេសដែរ ឬទេ ? ហើយតើការវិនិច្ឆ័យនោះមានផ្តោតទៅលើបញ្ហាទាំងឡាយណាដែល ADB មានឧត្តមភាពប្រៀបធៀបក្នុងការជួយដែរ ឬទេ ? តើមានការវិភាគ និងការងារសេដ្ឋកិច្ច និងការងារតាមវិស័យ គ្រប់គ្រាន់ដែរ ឬទេ ដើម្បីគាំទ្រ CSPs?

(iii) តើយុទ្ធសាស្ត្រ និងកម្មវិធីរបស់ ADB មានភាពបន្សុីគ្នាជាមួយនឹង NPRS របស់រដ្ឋាភិបាល ឬជាមួយនឹងគោលនយោបាយ និងកម្មវិធីអភិវឌ្ឍន៍ជាតិ សំខាន់ៗកម្រិតណា ?

(iv) តើ ADB មានយុទ្ធសាស្ត្រប្រទាក់ក្រឡាគ្នាអ្វីខ្លះ ដើម្បីសម្រេចឱ្យបានគោលដៅថ្នាក់កម្រិតកម្មវិធី ?

(v) តើយុទ្ធសាស្ត្ររបស់ ADB កំណត់គោលដៅ វត្ថុបំណង និងសូចនាករវឌ្ឍនភាពដែលអាចត្រួតពិនិត្យបាន ឱ្យបានច្បាស់លាស់ និងជាក់ស្តែងដែរ ឬទេ?

(vi) តើកម្មវិធីរបស់ ADB ស៊ីសង្វាក់គ្នាជាមួយនឹងយុទ្ធសាស្ត្រប្រចាំប្រទេសរបស់ខ្លួនដែរ ឬទេ ? តើជំនួយរបស់ ADB ត្រូវបានប្រើប្រាស់សមស្របដែរ ឬទេ នៅក្នុងបរិបទនៃសកម្មភាពជំនួយអភិវឌ្ឍន៍របស់តួអង្គផ្សេងទៀត ដោយរៀបចំទុកជាមុននូវបំណែងចែកការងារដែលប្រទាក់ក្រឡាគ្នាយ៉ាងល្អ ?

(vii) តើសកម្មភាពជំនួយកម្ចី និងមិនមែនកម្ចី ត្រូវបានគេរៀបចំបានល្អដែរ ឬទេ ? តើសកម្មភាពទាំងនោះ ទទួលការគាំទ្រពីការងារសេដ្ឋកិច្ច និងការងារតាមវិស័យសមស្របដែរ ឬទេ ? តើសកម្មភាពទាំងនោះ បានពង្រីកការអនុវត្តល្អនៅក្នុងប្រទេស ឬក្នុងតំបន់ដែរ ឬទេ ? តើសកម្មភាពទាំងនោះ មានធ្វើការពិចារណាទៅលើកត្តាសេដ្ឋកិច្ច សង្គម និងស្ថាប័ន ដែលជះឥទ្ធិពលដល់សមត្ថភាពរបស់ DMC ក្នុងការស្រូបយក និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវ ជំនួយមកពីខាងក្រៅដែរ ឬទេ ?

(viii) តើយុទ្ធសាស្ត្ររបស់ ADB ជាអ្នកធ្វើឱ្យកម្មវិធីកម្ចីដំណើរការទៅមុខ ឬក៏កម្មវិធីកម្ចីជាអ្នកធ្វើឱ្យយុទ្ធសាស្ត្រដំណើរការទៅមុខ ?

៦៥. តារាងទី ១ បង្ហាញនូវបញ្ហាសំខាន់ៗដែលត្រូវវាយតម្លៃនៅតាមបណ្តាវិស័យ មូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រ និងទិដ្ឋភាពតាមប្រធានបទនៃកម្មវិធីជំនួយរបស់ ADB ។ បន្ថែមពីលើនេះ ADB បានរៀបចំឯកសារជាច្រើនដើម្បីឱ្យខ្លួនមានអាណត្តិ គោលដៅ និងការណែនាំក្នុងការទទួលខុសត្រូវចំពោះសកម្មភាពនៅក្នុងវិស័យផ្សេងៗ និងនៅក្នុងប្រធានបទជាច្រើនទៀត ។ ឯកសារគោលនយោបាយ និងយុទ្ធសាស្ត្រ អាចធ្វើការត្រួតពិនិត្យបាន ដើម្បីកំណត់ជាលំអិតទៅលើបញ្ហាគន្លឹះៗ ដែលជាប់ពាក់ព័ន្ធនៅក្នុងវិស័យផ្សេងៗ និងនៅក្នុងប្រធានបទនានា ហើយដែលជាប់ពាក់ព័ន្ធនឹងការ

[១២] ខណៈពេលដែល OED នៅមិនទាន់បានព្រមព្រៀងទៅលើដំណើរការចងក្រងជារចនាសម្ព័ន្ធសម្រាប់ធ្វើការវាយតម្លៃ និងចាត់ចំណាត់ថ្នាក់គុណភាពនៃ CSPs អ្នកវាយតម្លៃ ត្រូវបានលើកទឹកចិត្តឱ្យធ្វើការចាត់ចំណាត់ថ្នាក់ ។ ឧទាហរណ៍នៃការចាត់ថ្នាក់យុទ្ធសាស្ត្រដែលធ្វើឡើងតាមរយៈការវាយតម្លៃ OED ថ្មីៗនេះ មាននៅក្នុងសេចក្តីបន្ថែម ៦ ។

អនុវត្តជំនួយរបស់ ADB បានល្អផងដែរ ។ របាយការណ៍គោលនយោបាយ និងយុទ្ធសាស្ត្រ អាចរកបានតាម ប្រព័ន្ធអ៊ិនធឺណិតតាមរយៈគេហទំព័រ http://www.ADB.org/Development/policies.asp ។

៦៦. ភាពជាម្ចាស់ គឺជាដៅទៃមីណង់ដ៏សំខាន់នៃការអនុវត្ត CAP ។ ទោះបីជាពាក្យ ម្ចាស់ប្រទេស គឺជាឃ្លាសមញ្ញមួយក៏ដោយ ក៏គេមិនអាចកំណត់និយមន័យនៃពាក្យនេះឱ្យបានល្អដែរ ។ ធាតុនៃភាពជាម្ចាស់ប្រទេស មានដូចជា : (i) ការជ្រើសរើសយុទ្ធសាស្ត្រ កំណែទម្រង់ វិស័យ និងគម្រោងនានា ដែលមានភាពបន្សីគ្នាជាមួយនឹងអាទិភាពរបស់រដ្ឋាភិបាល (ii) ការបែងចែកការទទួលខុសត្រូវបានច្បាស់លាស់នៅតាមកម្រិត EA ដើម្បីធ្វើផែនការ និងអនុវត្តគម្រោង និងដើម្បីកៀរគរថវិការបដិភាគឱ្យបានច្រើនមុននឹងធ្វើសេចក្តីសម្រេចចិត្តសុំខ្ចី ហើយ (iii) ផ្តល់ការគាំទ្រចំពោះគម្រោង និងកម្មវិធីដែលគេបានព្រមព្រៀង ដែលបង្ហាញតាមរយៈការបញ្ចេញសមត្ថភាក្នុងការប្រមែប្រមូលថវិការបដិភាគចាំបាច់ និង EAs ដែលមានបុគ្គលិកគ្រប់គ្រាន់ប្រកបដោយវិជ្ជាជីវៈ និងសមត្ថភាព ។ សូចនាករសំខាន់ៗនៃភាពជាម្ចាស់ប្រទេស គឺកម្រិតដែលមេដឹកនាំរដ្ឋាភិបាល និង EAs ផ្តល់ការគាំទ្ររួមគ្នាទៅលើកំណែទម្រង់ស្ថាប័ន និងគោលនយោបាយ ដែលទទួលបានការគាំទ្រពីជំនួយរបស់ ADB ។ ដើម្បីវាយតម្លៃភាពជាម្ចាស់លើយុទ្ធសាស្ត្រ និងកម្មវិធីរបស់ប្រទេស ផ្នែកនេះ នឹងឆ្លើយតបនូវសំណួរដូចខាងក្រោម :

(i) តើរដ្ឋាភិបាល[១៣] មានបានចូលរួមយ៉ាងសកម្មនៅក្នុងការរៀបចំ CSP ដែរ ឬទេ ?

(ii) តើ EAs និងទីភ្នាក់ងារទទួលខុសត្រូវក្នុងការគាំទ្រការអនុវត្តគោលនយោបាយនៅក្នុងវិស័យ និងកំណែទម្រង់ស្ថាប័នដូចដែលបានព្រមព្រៀង និងដែលបានគូសបញ្ជាក់នៅក្នុង CSP ដែរ ឬទេ ?

(iii) តើកំណែទម្រង់ក្នុងវិស័យ និងតាមប្រធានបទដែលបានព្រមព្រៀងនោះ ត្រូវបានអនុវត្ត និងមាននិរន្តរភាពដែរ ឬទេ ?

(iv) តើមានការឆ្លើយតបអ្វីខ្លះនៅពេលមានដំណើរភ្លាត់នៃគោលនយោបាយ និងការមិនអនុវត្តតាមគម្រោងនោះ ?

(v) តើក្រុមដែលមានចំណាប់អារម្មណ៍ និងសាធារណជនសំខាន់ៗ មានបានដឹងឮអំពីគោលបំណង វត្ថុបំណង និងលទ្ធផលនៃកម្មវិធីប្រចាំប្រទេស និងជាពិសេស កំណែទម្រង់ក្នុងវិស័យ និងតាមប្រធានបទនានា ដែលគាំទ្រដោយ ADB ដែរ ឬទេ ?

៦៧. **ការសម្រួលការវាយតម្លៃ.** ភាពដែលអាចវាយតម្លៃបាននៃ CSP មានលក្ខណៈខុសគ្នាពីប្រទេសមួយទៅប្រទេសមួយ ។ ផ្នែកនេះ គួរវាយតម្លៃត្រឹមកម្រិតដែល CSP របស់ ADB អាច "ធ្វើការវាយតម្លៃបាន" និងថាតើមានការរៀបចំបានគ្រប់គ្រាន់ដែរ ឬទេ សម្រាប់ការត្រួតពិនិត្យ និងវាយតម្លៃរបស់ខ្លួននោះ ។ ប្រសិនបើ ដំណើរការនោះនៅមានគម្លាត គេក៏គួរតែវាយតម្លៃផងដែរ នូវកម្រិតដែលកម្មវិធីជំនួយសម្រាប់ការកសាងសមត្ថភាពអាចសម្រេចបាន ។

[១៣] នៅប្រទេសណាដែលមានរដ្ឋាភិបាលគ្រប់គ្រងច្រើនលំដាប់ថ្នាក់ (ឧទាហរណ៍ ថ្នាក់សហព័ន្ធ ថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន) ជាការសំខាន់ណាស់ដែលត្រូវធ្វើការវាយតម្លៃការចូលរួមរបស់ថ្នាក់នីមួយៗផងដែរ ។

## តារាង ១ : បញ្ហាជាយុទ្ធសាស្ត្រដែលត្រូវធ្វើការវាយតម្លៃក្នុងកម្រិតថ្នាក់តាមវិស័យ និងប្រធានបទនានា នៅក្នុង CAPE

| បញ្ហា | ការគ្របដណ្តប់ដែលចាំបាច់/មិនចាំបាច់ | បញ្ហាជាយុទ្ធសាស្ត្រដែលត្រូវធ្វើការវាយតម្លៃ |
|---|---|---|
| យុទ្ធសាស្ត្រ និងកម្មវិធីក្នុងវិស័យ | ចាំបាច់ | ចំណុចខ្លាំងរបស់ ADB ស្ថិតនៅលើការផ្តល់ហិរញ្ញប្បទានវិនិយោគក្នុងចំនួនទឹកប្រាក់ច្រើនជាបង្គួរដោយសម្រេចបានផលប៉ះពាល់ក្នុងរយៈពេលមធ្យម និងវែង និងស្ថិតនៅលើការពិភាក្សាជាមួយបណ្តារដ្ឋាភិបាល ដើម្បីគាំទ្រគោលនយោបាយ និងកំណែទម្រង់ស្ថាប័នដែលបានផ្តល់ផលប៉ះពាល់ដោយប្រយោលគ្រប់តំបន់ ។ កម្រិតដែលតួនាទីនេះសម្រេចបានគួរលើកយកមកត្រួតពិនិត្យឱ្យបានល្អសម្រាប់វិស័យនីមួយៗ ពោលគឺវិស័យដែល ADB មានវត្តមានពាក់ព័ន្ធជាបង្គួរនៅក្នុងវិស័យទាំងនោះ ។ |
| កំណើនដើម្បីគាំទ្រអ្នកក្រីក្រ | ចាំបាច់ | បញ្ហាកំណើនដើម្បីគាំទ្រអ្នកក្រីក្រ រួមមានគុណភាពគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច គោលនយោបាយការងារ មូលដ្ឋានធនធានដែលធ្វើឱ្យដំណើរការវិស័យឯកជន និងគោលនយោបាយដែលមានឥទ្ធិពលដល់ការបែងចែកប្រាក់ចំណូល ។ |
| ការអភិវឌ្ឍសង្គម | ចាំបាច់ | កម្រិតដែលជំនួយរបស់ ADB បានជួយ DMCs រៀបចំផែនការអភិវឌ្ឍធនធានមនុស្ស និងរៀបចំគោលនយោបាយអភិវឌ្ឍស្ថាប័ន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដើម្បីផ្តល់សេវាសង្គមមូលដ្ឋានដល់អ្នកក្រីក្រប្រកបដោយប្រសិទ្ធិភាព ។ កម្រិតដែលជំនួយបានជួយគាំទ្រការអភិវឌ្ឍធនធានមនុស្ស កំណើនប្រជាជនប្រកបដោយនិរន្តរភាព ការអភិវឌ្ឍយេនឌ័រ ការបង្កើតសង្គមមូលធន និងការអភិវឌ្ឍចម្រុះ និងការការពារសង្គម ។ |
| អភិបាលកិច្ចល្អ (រួមមានការ ប្រឆាំងអំពើពុករលួយ) | ចាំបាច់ | អភិបាលកិច្ចស្ទួល និងអភិបាលកិច្ចតាមវិស័យ រួមមានបញ្ហានៃអភិបាលកិច្ចរួម កម្រិតដែលអភិបាលកិច្ចល្អ ( ការទទួលខុសត្រូវ តម្លាភាព ការចូលរួម) ត្រូវបានបញ្ជ្រាបចូលក្នុងប្រតិបត្តិការតាមវិស័យ និងការលើកទឹកចិត្តឱ្យមានការចូលរួមជាមួយសង្គមស៊ីវិល ។ គួរយកចិត្តទុកដាក់ជាពិសេសទៅលើកម្រិតដែលគោលនយោបាយប្រឆាំងអំពើពុករលួយរបស់ ADB ត្រូវបានពិចារណាដោះស្រាយ ការចាត់វិធានការការពារ ADB ពីការឆ្លងរោគពុករលួយ (ប្រសិនបើប្រទេស មានបញ្ហាអំពើពុករលួយធ្ងន់ធ្ងរ) និងយុទ្ធសាស្ត្រ និងវិធានការប្រឆាំងអំពើពុករលួយសម្រាប់ប្រទេស ។ |
| ការអភិវឌ្ឍវិស័យឯកជន | ចាំបាច់ | កម្រិតដែលជំនួយរបស់ ADB បានជួយ DMCs បង្កើតនូវបរិយកាសដែលផ្តល់ឱ្យមានការចូលរួមពីវិស័យឯកជននៅក្នុងការអភិវឌ្ឍ និងដើម្បីបង្កើតកាលានុវត្តភាពពាណិជ្ជកម្មតាមរយៈប្រតិបត្តិកាវិស័យសាធារណៈ ។ វិភាគទានចំពោះអភិបាលកិច្ចក្រុមហ៊ុន កំណែទម្រង់និយតកម្ម ដែលរួមមានការធ្វើឯកជនភាវូបនីយកម្ម ភាពជាដៃគូ តាមរយៈការចុះកិច្ចសន្យាបន្ត និងរវាងវិស័យឯនជន និងសាធារណៈ និងប្រតិបត្តិការវិស័យឯកជនដើម្បីបង្ហាញនូវវិធីថ្មីៗ និងដើម្បីជំនះឱ្យបាននូវឧបសគ្គចំពោះការវិនិយោគ ។ |
| និរន្តរភាពបរិស្ថាន | ចាំបាច់ | កម្រិតដែលជំនួយឥតសំណងផ្នែកបច្ចេកទេស គម្រោង និងកម្មវិធីសម្រាប់តំបន់ និងសម្រាប់ការផ្តល់ការប្រឹក្សា បានផ្តល់ជាវិភាគទានទៅលើ (i) អន្តរាគមន៍លើវិស័យបរិស្ថាន (ii) ការបញ្ជ្រាបបញ្ហាបរិស្ថាននៅក្នុងគម្រោងដែលមានគោលដៅជំរុញឱ្យមានកំណើនសេដ្ឋកិច្ច (iii) ការថែរក្សាប្រព័ន្ធទ្រទ្រង់ជីវិតនៅលើពិភពលោក និងនៅក្នុងតំបន់ (iv) ការជំរុញភាពជាដៃគូប្រកបដោយប្រសិទ្ធផលនិង (v) ការបញ្ចូលការយកចិត្តទុកដាក់លើវិស័យបរិស្ថានទៅក្នុងប្រតិបត្តិការរបស់ ADB ។ ចំពោះចំណុចណាដែលជាប់ទាក់ទងការបញ្ចូលនេះ រួមមានការវាយតម្លៃលើវិភាគទានផ្ទាល់របស់ ADB ក្នុងការកាត់បន្ថយភាពសឹករេចរឹលនៃបរិស្ថាន (នៅក្នុងតំបន់ដែលមានការគ្រប់គ្រងការបំពុលពណ៌ត្នោត និងបៃតង) វិភាគទានចំពោះការអភិរក្សធនធាន និងចំពោះការកសាងសមត្ថភាពស្ថាប័ន និងគោលនយោបាយប្រកបដោយប្រសិទ្ធផលនិងសមត្ថភាពនិយតកម្មដើម្បីជំរុញនិរន្តរភាពបរិស្ថាន ។ |
| សមភាពយេនឌ័រ | មិនចាំបាច់ | កម្រិតដែលវប្បធម៌ប្រពៃណី កំណត់ឱ្យមានការបែងចែកភេទ ឬស្ត្រី តម្រូវឱ្យមានជំនួយពិសេស ដើម្បីជួយឱ្យពួកគេអាចចូលរួមបានពេញលេញក្នុងសកម្មភាពសេដ្ឋកិច្ច និងសង្គម ។ កម្រិតដែលបញ្ហាយេនឌ័រ និងអភិវឌ្ឍន៍ ត្រូវបានលើកយកមកពិចារណាទៅលើការងារសេដ្ឋកិច្ច និងការងារតាមវិស័យ កម្ចី ជំនួយបច្ចេកទេស ការពិភាក្សាគោលនយោបាយ |

| | | |
|---|---|---|
| | | ការរៀបចំ CSP និងប្រតិបត្តិការផ្សេងៗជាច្រើនទៀត និងកម្រិតដែល ADB បានរួមចំណែកក្នុងការផ្តល់អំណាចដល់ស្ត្រី សមភាពយេនឌ័រ ការចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចរបស់ស្ត្រីក្រីក្រ កាន់តែមានសភាពប្រសើរឡើង និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ស្ត្រី ។ |
| ការអភិវឌ្ឍតំបន់ | មិនចាំបាច់ | កម្រិត និងវិធីដែលកិច្ចសហប្រតិបត្តិការក្នុងតំបន់ ត្រូវបន្តធ្វើ ដោយចាត់ទុកជាមធ្យោបាយដើម្បីឱ្យ DMCs លុបបំបាត់ការរារាំងជារូបវ័ន្ត និងរបស់ស្ថាប័នក្នុងការធ្វើពាណិជ្ជកម្ម និងការវិនិយោគ ដើម្បីរួមគ្នាបង្កើតនូវសម្បទានមួយក្នុងការផ្តល់នូវសេវាសាធារណៈសំខាន់ៗ ដើម្បីសម្របសម្រួលការប្រយុទ្ធប្រឆាំងឧក្រិដ្ឋកម្មពិភពលោក និងបញ្ហាសុខភាព និងដើម្បីចែករំលែកចំណេះដឹងរវាងគ្នានឹងគ្នា ។ |
| ការអភិវឌ្ឍសមត្ថភាព | ចាំបាច់ | កម្រិតដែល ADB ផ្តល់នូវការគាំទ្រតាមបែបយុទ្ធសាស្ត្រដើម្បីធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់ DMC ដើម្បីបង្កើត និងអនុវត្តនូវកំណែទម្រង់គោលនយោបាយ និងការវិនិយោគចាំបាច់សម្រាប់កាត់បន្ថយភាពក្រីក្រ ។ |
| ប្រធានបទជាក់លាក់ប្រចាំ ប្រទេស | មិនចាំបាច់ | បញ្ហាដែលបានកំណត់រកឃើញនៅក្នុងរបាយការណ៍លម្អិតដែលរបាយការណ៍នេះ គឺជាចំណុចផ្តោតការយកចិត្តទុកដាក់តែមួយគត់របស់ជំនួយ (លក្ខណៈពិសេសនៃការផ្តល់ជំនួយ) ឬក៏មធ្យោបាយតែមួយគត់ក្នុងការធ្វើឱ្យប្រសើរនូវប្រសិទ្ធភាពនៅក្នុង DMC ។ កត្តាខ្លះៗក្នុងចំណោមកត្តាទាំងនោះ អាចជាប់ទាក់ទងទៅនឹងគំនិតផ្តួចផ្តើម និងគោលនយោបាយថ្មីៗ (ដូចជាយុទ្ធសាស្ត្ររយៈពេលមធ្យម និងវែង គំនិតផ្តួចផ្តើមច្នៃប្រឌិតថ្មី និងប្រកបដោយប្រសិទ្ធផល យុទ្ធសាស្ត្រប្រចាំប្រទេសដែលមានប្រាក់ចំណូលមធ្យម គោលនយោបាយបែងចែកដោយផ្អែកលើការអនុវត្តសម្រាប់ ADB ការគ្រប់គ្រងដើម្បីលទ្ធផលអភិវឌ្ឍន៍) ដែលអាចជាប់ទាក់ទងទៅនឹងបញ្ហាផ្សេងៗដែលត្រូវលើកយកមកវាយតម្លៃនៅក្នុង CAPE ។ |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CAPE = ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស CSP = យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស DMC = ប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក

ប្រភព ៖ ដកស្រង់ចេញពី ADB. 2004. *Enhancing the Fight against Poverty in Asia and the Pacific: Poverty Reduction Strategy of the Asian Development Bank. Manila.*

## ច. ការអនុវត្តកម្មវិធី

៦៨. ផ្នែកនេះ វាយតម្លៃទៅលើប្រសិទ្ធភាពអនុវត្តន៍នៃកម្មវិធីជំនួយ ហើយផ្តោតការយកចិត្តទុកដាក់ទៅលើការសម្រេចទិន្នផលដែលឧបត្ថម្ភដោយ ADB បានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ដែលបានមកពីជំនួយកម្ចី ជំនួយ TA ការសម្របសម្រួលជាមួយនឹងអ្នកផ្តល់ជំនួយ ការស្រាវជ្រាវ និងការប្រឹក្សាគោលនយោបាយរបស់ ADB ។ ការវាយតម្លៃការអនុវត្តកម្មវិធី ខិតខំឆ្លើយទៅនឹងសំណួរដូចខាងក្រោម :

(i) តើកម្មវិធីជាក់ស្តែងរបស់ ADB បានផ្សព្វផ្សាយជូនមតិសាធារណជននៅក្នុងប្រទេសដោយរបៀបណាក្នុងអំឡុងពេលអនុវត្តកម្មវិធី អំពីការប្តេជ្ញាចិត្ត ឬការបញ្ចេញសាច់ប្រាក់នៃជំនួយកម្ចី និងមិនមែនកម្ចី ?

(ii) តើសកម្មភាពនានា ត្រូវបានអនុវត្តជាក់ស្តែង ដូចការប៉ាន់ស្មានដែរ ឬទេ ?

(iii) តើកត្តាគន្លឹះអ្វីខ្លះ ដែលធ្វើឱ្យមានការប៉ះពាល់ដល់ការអនុវត្តសេវាកម្ចី និងមិនមែនកម្ចីរបស់ ADB ?

(iv) តើផលប័ត្រទូទៅ មានដំណើរការទៅយ៉ាងដូចម្តេច អំពីការប្រៀបធៀប សូចនាករអនុវត្តន៍នៃផលប័ត្រតាមបទដ្ឋានជាមួយនឹងមធ្យមភាគទូទៅរបស់ ADB និងមធ្យមភាគក្នុងតំបន់ ?

(v) តាមការវាស់វែងដោយប្រៀបធៀបទៅនឹងចំណាយនានារបស់ ADB ពេលវេលាធ្វើការរបស់បុគ្គលិក ADB និងបន្ទុកថ្លៃដើមប្រតិបត្តិការ ដែលរ៉ាប់រងដោយរដ្ឋាភិបាល តើទិន្នផលនានា ត្រូវបានចែកជូនតាមវិធីប្រកបដោយប្រសិទ្ធភាពដែរ ឬទេ ?

(vi) តើមានបញ្ហាចម្បងអ្វីខ្លះកើតឡើងនៅក្នុងអំឡុងពេលនៃការអនុវត្ត ? ហើយតើបញ្ហាទាំងនោះ ត្រូវបានដោះស្រាយដូចម្តេច ?

(vii) តើការអនុវត្តសកម្មភាពជំនួយសំខាន់ៗត្រូវបានវាយតម្លៃដោយរបៀបណា តាមរយៈការវាយតម្លៃខ្លួនឯង និងការវាយតម្លៃឯករាជ្យ? តើការអនុវត្ត ត្រូវបានប្រៀបធៀបទៅនឹងមធ្យមភាគក្នុងតំបន់ និងរបស់ ADB ដោយរបៀបណា ?

៦៩. រង្វាយតម្លៃលើការអនុវត្តកម្មវិធី ផ្អែកទៅលើសូចនាករតាមបទដ្ឋាននៃការអនុវត្តផលប័ត្រ ទាំងតាមកម្រិតប្រទេស និងតំបន់ ។ នៅក្នុងការរៀបចំផ្នែកនេះ អ្នកវាយតម្លៃ នឹងធ្វើការត្រួតពិនិត្យ និងប្រើប្រាស់សេចក្តីបន្ថែមប្រចាំប្រទេសដែលមាននៅក្នុង *របាយការណ៍ប្រចាំឆ្នាំ ស្តីពីកម្ចី និងការអនុវត្តផលប័ត្រជំនួយបច្ចេកទេស* របស់ OED ។ ក្រៅពីនេះ ផ្នែកនេះ និងពង្រីកលទ្ធផលដែលទទួលបានពីការវាយតម្លៃខ្លួនឯង និងការវាយតម្លៃឯករាជ្យ និងរបាយការណ៍ត្រួតពិនិត្យផងដែរ ។ ការវាយតម្លៃពីប្រសិទ្ធភាពយោងតាមគម្រោង កម្មវិធី និង TA នៅក្នុង PCRs របាយការណ៍បញ្ចប់គម្រោង ឬកម្មវិធី (TCRs) និង PPERS ក៏ត្រូវបានសង្ខេបនៅក្នុងផ្នែកនេះដែរ ។ អត្រាចំណូលពី ការវិនិយោគសេដ្ឋកិច្ចផ្ទៃក្នុងក្រោយការអនុវត្តម្រាប់ការវិនិយោគធំៗ អាចត្រូវបានលើកយកមកត្រួតពិនិត្យ ដើម្បីទុកជាសូចនាករមួយ ក្នុងចំណោមសូចនាករស្តីពីប្រសិទ្ធភាពគម្រោងវិនិយោគ ។ គេគួរធ្វើការប្រមូលផងដែរនូវតួលេខតំណាងផ្សេងៗសម្រាប់ថ្លៃដើមប្រតិបត្តិការឱ្យរដ្ឋាភិបាល រួមមានចំនួនបេសកកម្មក្នុងមួយឆ្នាំៗ ចំនួនពេលវេលាចុះធ្វើបេសកកម្មដែលមន្ត្រីជាន់ខ្ពស់របស់រដ្ឋាភិបាលបានរាយការណ៍ពី ការចំណាយពេលវេលាទាំងនោះដើម្បីគាំទ្រដល់បេសកកម្មរបស់ ADB និងចំនួនពេលវេលាជាមធ្យម ដែលមន្ត្រីរដ្ឋាភិបាលប្រើដើម្បីរៀបចំ អនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពជំនួយ ដែលឧបត្ថម្ភដោយ ADB ។

៧០. នៅក្នុងការវាយតម្លៃការអនុវត្តកម្មវិធី ADB អ្នកវាយតម្លៃ ចាំបាច់ត្រូវពិនិត្យទៅលើកម្រិតនៃការផ្តល់ឱ្យទិន្នន័យ ព្រមទាំងត្រូវពិនិត្យទៅលើកម្រិតនៃការចាត់វិធានដែលចាំបាច់ ដើម្បីធានាឱ្យមានការអនុវត្តពេញលេញនោះផងដែរ ។ ឧទាហរណ៍ ADB អាចគាំទ្រដល់ការតាក់តែងច្បាប់ថ្មីនៅក្រោមកម្ចីរបស់ខ្លួន ប៉ុន្តែ ប្រសិនបើច្បាប់នៅតែមិនទាន់បានរដ្ឋសភាអនុម័ត និងប្រកាសឱ្យប្រើប្រាស់បន្ទាប់ពីកម្ចីត្រូវបានបញ្ចប់ គ្មានទិន្នផលនៃការកែប្រែគោលនយោបាយជាក់ស្តែងណាមួយកើតឡើងឡើយ ។ ការត្រួតពិនិត្យទៅលើសូចនាករនៃការអនុវត្ត ការអង្កេត សកម្មភាព និងបទសម្ភាសន៍ដែលបានចងក្រងជារចនាសម្ព័ន្ធជាមួយនឹងអ្នកពាក់ព័ន្ធសំខាន់ៗ អាចត្រូវបានយកមកប្រើដើម្បីវាយតម្លៃទៅលើការអនុវត្តជំនួយដែលឧបត្ថម្ភដោយ ADB ថាតើជំនួយទាំងនោះ សម្រេចបានលទ្ធផល តាមការរំពឹងទុកដែរ ឬទេ ។

ឧបសម្ព័ន្ធ ១

## ជ. លទ្ធផលសម្រេចបាន និងកត្តាដែលមានឥទ្ធិពលលើការអនុវត្ត

៧១. ផ្នែកនេះនឹងពិភាក្សាពីវិភាគទានរបស់ ADB ដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ ។ នៅទីនេះ ការផ្តោតយកចិត្តទុកដាក់ជាចម្បង គឺទៅលើលទ្ធផល និងផលប៉ះពាល់ (ក្នុងកម្រិតណាមួយនោះ) ជាជាងទៅលើទិន្នផល[9] ។

(i) តើវិភាគទាំងអស់នៃជំនួយរបស់ ADB មានអ្វីខ្លះទៅ ដែលនាំឱ្យសម្រេចបាននូវលទ្ធផលក្នុងផ្នែកម៉ាក្រូសេដ្ឋកិច្ច វិស័យនានា និងមូលដ្ឋានគ្រឹះនៃការកាត់បន្ថយភាពក្រីក្រ និងតាមប្រធានបទ ?

(ii) តើមានភស្តុតាងអ្វីបញ្ជាក់ថាជំនួយរបស់ ADB ពិតជាបានរួមវិភាគទានដល់ការសម្រេចបាននូវគោលបំណងនៅក្នុងវិស័យ និងប្រធានបទជាក់លាក់ ដែលបានដាក់ចុះក្នុងអំឡុងពេលដំណើរការរៀបចំ CSP ?

(iii) តើលទ្ធផលទំនងជាអាចបន្តសម្រេចបានក្នុងកម្រិតណាទៀត បន្ទាប់ពីការបញ្ចប់ទៅនូវជំនួយរបស់ ADB នោះ ?

៧២. ការវាយតម្លៃលទ្ធផលនានា អាចធ្វើបានទៅតាមការប្រមូលផ្តុំកម្រិតផ្សេងៗគ្នាជាច្រើន (ពោលគឺតាមវិស័យ និងតាមប្រធានបទដែលបានធ្វើអន្តរាគមន៍) និងតាមមូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រ (ពោលគឺ កំណើន ការអភិវឌ្ឍសង្គម និងអភិបាលកិច្ចល្អ) ។ ដើម្បីកាត់បន្ថយការវាយតម្លៃជាន់គ្នា គេគួរលើកយកលទ្ធផលមកបង្ហាញជាមុនសិនទៅតាមវិស័យសំខាន់ៗដែល ADB ជាប់ពាក់ព័ន្ធ ដោយរៀបលទ្ធផលទាំងនោះទៅតាមកម្លាំងចលករកម្មវិធីដែលចាំបាច់ ។ ករណីសិក្សានានា ក៏អាចរាប់បញ្ចូលផងដែរ ដើម្បីបង្ហាញពីលទ្ធផលវិជ្ជមាន និងអវិជ្ជមាន ។ លទ្ធផលទាំងនេះគួរត្រូវបានគេចងក្រងឡើង ដើម្បីបង្ហាញពីកម្រិតដែលលទ្ធផលនៅក្នុងវិស័យសំខាន់ៗ រួមចំណែកសម្រេចបាននៅក្នុងមូលដ្ឋានគ្រឹះតាមប្រធានបទនីមួយៗ ហើយ ដែលមូលដ្ឋានគ្រឹះនេះ ជាកត្តាគាំទ្រយុទ្ធវិធីរបស់ ADB ក្នុងការកាត់បន្ថយភាពក្រីក្រ និងគាំទ្រការអនុវត្តដែលនាំឱ្យសម្រេចបាននូវលទ្ធផលតាមប្រធានបទនានា ដូចជាលទ្ធផលទាក់ទងនឹងការអភិវឌ្ឍវិស័យឯកជន និងនិរន្តរភាពបរិស្ថាន (ហើយប្រសិនបើពាក់ព័ន្ធ អាចជាប់ទាក់ទងទៅនឹងកិច្ចសហប្រតិបត្តិការក្នុងតំបន់ យេនឌ័រ និងការកសាងសមត្ថភាពរបស់ស្ថាប័ន) ។ វិភាគទានរបស់ ADB ដែលនាំឱ្យសម្រេចបានលទ្ធផល គួរលើកយកមកបង្ហាញតាមវិធីណាដែលអាចចៀសវាងភាពជាន់គ្នា និងការធ្វើដដែលៗ ។ ហេតុដូច្នេះ វិភាគទានរបស់ ADB ដែលនាំឱ្យសម្រេចបានលទ្ធផលក្នុងកម្រិតខ្ពស់ (ពោលគឺក្នុងកម្រិតមូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រ និងតាមប្រធានបទ) គួរលើកយកមកពិភាក្សាដោយសង្ខេប ដោយសង្កត់ធ្ងន់ទៅលើការវាយតម្លៃស្ថានភាពពេលដាក់ចុះជំនួយរបស់ ADB និងកម្រិតនៃបញ្ហាសំខាន់ៗដែលត្រូវបានលើកយកមកដោះស្រាយជាក់ស្តែង ។

៧៣. ទោះបីជាកម្រិតនៃការវិភាគ ធ្វើឡើងទៅលើវិស័យ ឬតាមប្រធានបទ ឬតាមមូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រក៏ដោយ ក៏វិធីវាយតម្លៃលទ្ធផលភាគច្រើនមានលក្ខណៈដូចៗគ្នាដែរ ។ ការវាយតម្លៃ គួរធ្វើការប្រៀបធៀបលទ្ធផលចម្បង (ពោលគឺ លទ្ធផល និងផលប៉ះពាល់សំខាន់ៗ) ទាំងលទ្ធផលជាគោលដៅ និងលទ្ធផលមិនមែនជាគោលដៅ ដែល ADB បានជួយផ្តល់ជាវិភាគទាន ជាមួយនឹងគោលដៅដែលមានស្រាប់ និងដោយក្រលេកមើលទៅខាងក្រោយ ជាមួយនឹងអ្វីៗដែលចាំបាច់ ដើម្បីសម្រេចបាននូវលទ្ធផល និងផលប៉ះពាល់ដែលគេចង់បាន នៅតាមវិស័យ តាមប្រធានបទ និងតាមការអភិវឌ្ឍជាតិ ។

៧៤. **ការផ្តោតយកចិត្តទុកដាក់ទៅលើវិស័យ និងគុណភាពផលប័ត្រ** ទិសដៅផែនការឆ្នាំ២០០៦-២០០៨ បានថ្លែងថា ដើម្បីសម្រេចឱ្យបានគុណភាព ADB នឹងខិតខំយកចិត្តទុកដាក់លើកម្មវិធីជំនួយទាំងកម្ចី និងមិនមែនកម្ចីបន្ថែមទៀត ។ យោងតាមគោលការណ៍ទូទៅ ADB គួរផ្តល់អាទិភាពដល់ផ្នែកប្រតិបត្តិការណា ដែលជាទីភ្នាក់ងារយ៉ាងសំខាន់ ។ ការអនុវត្តពីអតីតកាល ក៏គួរលើកយកមកពិចារណាផងដែរ ដោយផ្តល់អាទិភាព

---

[9] នៅក្នុងការផ្តោតយកចិត្តទុកដាក់ទៅលើលទ្ធផល CAPEs ត្រូវតែទទួលស្គាល់ថាខ្លួនមិនបានណែនាំឱ្យមានការរៀបរាប់ជាលំអិតជាមុននូវលទ្ធផល សម្រាប់ការអនុវត្ត CSP កាលពីអតីតកាលនោះទេ ។ នៅក្នុងពេលដែលជាការសំខាន់ដែល CAPE ត្រូវធ្វើការត្រួតពិនិត្យតើលទ្ធផលអ្វីខ្លះ សម្រេចបាន និងអ្វីខ្លះ មិនបានសម្រេច ដូច្នេះការខកខានណាមួយក្នុងការកំណត់ឱ្យបានច្បាស់លាស់ក្របខ័ណ្ឌលទ្ធផលជាមុន មិនគួរលើកយករឿងនេះធ្វើជាការរិះគន់ដល់ថ្នាក់ដឹកនាំ ឬអាជ្ញាធរប្រទេសទេ ព្រោះថាការតម្រូវបែបនេះ ទើបតែមានក្នុងរយៈពេលថ្មីៗនេះប៉ុណ្ណោះ ។ តាមរយៈការនិយាយបែបនេះ លទ្ធផលដោយគុណភាព ក៏អាចធ្វើការកំណត់ឱ្យបានពីកញ្ចប់ផងដែរ ។

ទៅលើវិស័យណាដែល ADB ទើបសម្រេចបានលទ្ធផលប្រកបដោយភាពជោគជ័យបំផុត ។ លទ្ធផលរបស់ CAPE អាចជួយកំណត់បាននូវផ្នែកដែល ADB សម្រេចបានលទ្ធផលដ៏ត្រចះត្រចង់ និងផ្នែកដែលខ្លួនសម្រេចបានលទ្ធផលតិចតួចបំផុតគ្រប់វិស័យ ផ្សេងៗគ្នាទាំងអស់ ដែល ADB ចូលពាក់ព័ន្ធ ។ ការអនុវត្តក្នុងវិស័យនានា នឹងត្រូវបានគេវាយតម្លៃថាជាផ្នែកមួយនៃការវាយតម្លៃទូទៅ ទៅលើប្រសិទ្ធភាពនៃ CAP របស់ ADB (ក្នុងឧបសម្ព័ន្ធ ២) ។ ជាទូទៅ ADB គួរតែបន្តការទំនាក់ទំនងជាមួយនឹងវិស័យណាដែលការអនុវត្តទទួលបានជោគជ័យ ឬសម្រេចបានជាបង្គួរ ហើយគួរដកខ្លួនចេញពីវិស័យណាដែលការអនុវត្ត មិនទទួលបានជោគជ័យអស់កាលជាយូរមកហើយ ។ សម្រាប់វិស័យណាដែលការអនុវត្តត្រូវបានវាយតម្លៃថាទទួលបានជោគជ័យត្រឹមតែមួយភាគនោះ ចាំបាច់នឹងត្រូវទទួលបានសនិទានភាពមួយសមស្របសម្រាប់បន្តទំនាក់ទំនង រួមជាមួយនឹងអនុសាសន៍នានាច្បាស់លាស់ដើម្បីជំរុញការអនុវត្តឱ្យទទួលបានជោគជ័យផងដែរ ។ ការអនុវត្តកន្លងមក មិនមែនជាកត្តាតែមួយគត់ដែលត្រូវធ្វើការពិចារណាក្នុងការសម្រេចថាតើ ADB នៅតែបន្តទំនាក់ទំនងនៅក្នុងវិស័យនានានោះដែរ ឬទេ ។ ក្រៅពីនេះ នៅមានកត្តាផ្សេងទៀតផងដែរ ដូចជាអាទិភាពរបស់រដ្ឋាភិបាល ការពិចារណាប្រកបដោយយុទ្ធសាស្ត្រ លទ្ធភាពដែលគេនឹងត្រូវជំនះឱ្យបានលើកកត្តាដែលនាំឱ្យការអនុវត្តមុនៗមានលក្ខណៈអន់ថយ និងបញ្ហាដែលទាក់ទងនឹងថវិការ និងបុគ្គលិករបស់ ADB ។

៧៥. **ការកំណត់** ការបែងចែក និងការកំណត់ទៅលើវិភាគទានដែលកម្មវិធីជំនួយរបស់ ADB បានធ្វើ ដើម្បីឆ្ពោះទៅរកលទ្ធផលអភិវឌ្ឍន៍ គឺជាបញ្ហាដ៏លំបាក ហើយចំពោះការអនុវត្តផ្ទាល់ គ្មានដៃគូអភិវឌ្ឍន៍ណា ធ្លាប់ទទួលខុសត្រូវពេញលេញ ចំពោះលទ្ធផលអភិវឌ្ឍន៍ណាមួយនៅឡើយទេ ។ ចំណុចសំខាន់បំផុតដែលគេអាចធ្វើបាន គឺត្រូវទទួលស្គាល់ថា ពិតជាមានកំហិតនានា ហើយត្រូវធ្វើការត្រួតពិនិត្យកត្តាគន្លឹះទាំងប្រាំមួយដែលមានឥទ្ធិពលទៅលើការសម្រេចបាននូវលទ្ធផល : ការអនុវត្តរបស់ ADB ការអនុវត្តរបស់រដ្ឋាភិបាល ការអនុវត្តរបស់វិស័យឯកជន ការអនុវត្តរបស់សង្គមស៊ីវិល ការអភិវឌ្ឍរបស់ដៃគូអភិវឌ្ឍន៍ និងកត្តាខាងក្រៅ (រួមមានការវិវត្តទីផ្សារ ជម្លោះ និងបាតុភូតធម្មជាតិ) ដែលហួសពីសមត្ថភាពក្នុងការគ្រប់គ្រងរបស់អ្នកពាក់ព័ន្ធ ។ នៅក្នុងផ្នែកនេះ កត្តានីមួយៗ នឹងត្រូវបានត្រួតពិនិត្យ (i) ដើម្បីវាយតម្លៃថា តើការអនុវត្តរបស់អ្នកពាក់ព័ន្ធនីមួយៗមានភាពស្រប និងជួយជ្រោមជ្រែងដល់ ADB ដែលមានបំណងរួមវិភាគទាន ក្នុងកម្រិតណា (ii) ដើម្បីវាយតម្លៃថា តើ ADB មានតួនាទីកម្រិតណាក្នុងការធ្វើជាកាតាលីករ ឬជួយជំរុញអ្នកពាក់ព័ន្ធផ្សេងទៀតធ្វើកិច្ច សហប្រតិបត្តិការ ដើម្បីសម្រេចនូវលទ្ធផលអភិវឌ្ឍន៍រួម និង (iii) ដើម្បីកំណត់កត្តាទាំងឡាយណាដែលហួសពីសមត្ថភាពគ្រប់គ្រងរបស់ ADB ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការកំណត់លក្ខណៈ និងទិសដៅនៃលទ្ធផលអភិវឌ្ឍន៍ ។ ការវាយតម្លៃលើការកំណត់បែបនេះ ក៏ជាការឆ្ពោះទៅរកការវាយតម្លៃមួយយ៉ាងលម្អិតលើការផ្តល់ថវិការបន្ថែមរបស់ ADB និងលើកម្រិតដែលការរៀបចំជំនួយ និងការអនុវត្តជំនួយរបស់ ADB ក្នុងតួនាទីជាកាតាលីករ ឬតួនាទីជាអ្នកបង្ហាញភស្តុតាង បើប្រៀបធៀបទៅនឹងកត្តាផ្សេងទៀត ដែលមានឥទ្ធិពលទៅលើលទ្ធផលអភិវឌ្ឍន៍ដែរនោះ ។

## ជ. ការវាយតម្លៃ និងចំណាត់ថ្នាក់វាយតម្លៃលើលទ្ធផលការងារ

៧៦. នៅក្នុងផ្នែកនេះ គេរៀបចំឱ្យមានការវាយតម្លៃសរុបលើការអនុវត្តកម្មវិធីប្រចាំប្រទេស និងការផ្តល់នូវសេចក្តីសង្ខេបដ៏ច្បាស់លាស់មួយអំពីកត្តាសំខាន់ៗ ដែលគាំទ្រដល់ចំណាត់ថ្នាក់វាយតម្លៃ ។ ការវាយតម្លៃ និងចំណាត់ថ្នាក់វាយតម្លៃលើការអនុវត្តនៅក្នុង CAPE ត្រូវបានរៀបចំឡើង ដោយមានតួនាទីចំនួនពីរគឺ គាំទ្រដល់ការទទួលខុសត្រូវ និងការកំណត់មេរៀន ។ ក្នុងតួនាទីជាលិខិតុបករណ៍សម្រាប់ គាំទ្រដល់ការទទួលខុសត្រូវ CAPE ត្រូវកែសម្រួលនូវការវាយតម្លៃទៅលើការអនុវត្តរួមមួយ ដែលស៊ីសង្វាក់គ្នា និងដែលផ្អែកលើភស្តុតាងជាក់លាក់ ។ ក្នុងតួនាទីជាលិខិតុបករណ៍គាំទ្រការកំណត់មេរៀន CAPE គួរផ្តោតការយកចិត្តទុកដាក់ទៅលើបញ្ហាទាំងឡាយណាដែលជាបញ្ហាស្នូល ចំពោះការវាយតម្លៃទៅលើប្រសិទ្ធិភាពអភិវឌ្ឍន៍ ។

៧៧. ការប្រើប្រាស់លក្ខណៈវិនិច្ឆ័យវាយតម្លៃដែលបានបង្កើតឡើងសម្រាប់ការវាយតម្លៃលទ្ធផលការងារ ត្រូវបានធ្វើឡើងដើម្បីជំរុញឱ្យមានលក្ខណៈរួមមួយ និងមានកម្មវិស័យភាពទៅតាមលក្ខណៈដែលការអនុវត្តត្រូវបានវាយតម្លៃ ។ ចំណាត់ថ្នាក់វាយតម្លៃជាផ្លូវការ ក៏អាចជួយក្នុងការកំណត់

និងបែងចែកកត្តាទាំងឡាយណាដែលរួមចំណែកទៅលើការអនុវត្តផងដែរ ។ ចំណាត់ថ្នាក់វាយតម្លៃលើការអនុវត្តតាមរបៀបតែមួយ ក៏អាចឱ្យបុគ្គលិកថ្នាក់ដឹកនាំ និងក្រុមប្រឹក្សាភិបាលធ្វើការប្រៀបធៀបទិដ្ឋភាពផ្សេងៗ និងដេទៃមីណង់នៃការអនុវត្តទូទាំងប្រទេសផងដែរ ។ ក្នុងកម្រិតដែលមានភាពប្រហាក់ប្រហែលគ្នាសមរម្យ លក្ខណៈវិនិច្ឆ័យ និងប្រព័ន្ធនៃការថ្លឹងថ្លែងត្រូវបាន MDBs ផ្សេងទៀតយកមកប្រើ ។ ការប្រើប្រាស់លក្ខណៈវិនិច្ឆ័យ និងប្រព័ន្ធថ្លឹងថ្លែងនេះ អាចឱ្យមន្ត្រីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ធ្វើការប្រៀបធៀបការអនុវត្តរបស់អ្នកផ្តល់ជំនួយម្នាក់ ជាមួយនឹងការអនុវត្តរបស់អ្នកផ្តល់ជំនួយដទៃទៀត ។

៧៨. **វិធីសាស្ត្រចាត់ចំណាត់ថ្នាក់វាយតម្លៃ** ចំណាត់ថ្នាក់វាយតម្លៃ និងការវាយតម្លៃលើការអនុវត្តដែលធ្វើឡើងដោយ CAPE បានឆ្លុះបញ្ចាំងពីវិធីសាស្ត្រដែលប្រើនៅក្នុង CAPE ខ្លួនឯង ។ ចំណាត់ថ្នាក់វាយតម្លៃការអនុវត្ត ត្រូវបានធ្វើឡើងតាមវិស័យនីមួយៗ (តាមរបៀបពីក្រោមឡើងលើ) និងតាមជំនួយប្រចាំប្រទេសជារួម (តាមរបៀបពីលើចុះក្រោម) រួចហើយធ្វើការចងក្រងដើម្បីចេញជាលទ្ធផលនៃចំណាត់ថ្នាក់វាយតម្លៃ និងការវាយតម្លៃលទ្ធផលការងារសរុប ។

៧៩. ការវាយតម្លៃបែបពីក្រោមឡើងលើ គឺជាការវាយតម្លៃ និងដាក់ចំណាត់ថ្នាក់ការអនុវត្តដាច់ដោយឡែកពីគ្នា យោងតាមលក្ខណៈវិនិច្ឆ័យស្នូលទាំងប្រាំ (គ្រឹះនៃការវាយតម្លៃ) សម្រាប់វិស័យនីមួយៗ យោងតាមភាពជាប់ទាក់ទង ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព និងផលប៉ះពាល់ ។ ការវាយតម្លៃបែបនេះ រាប់បញ្ចូលការឱ្យចំណាត់ថ្នាក់ និងការវាយតម្លៃបែបតួលេខទៅលើប្រសិទ្ធិភាពអភិវឌ្ឍន៍នៃសេវាកម្ចី និងមិនមែនកម្ចី ដែល ADB បានផ្តល់ទៅតាមវិស័យសំខាន់ៗដែលខ្លួនធ្វើប្រតិបត្តិការ ។ ប្រព័ន្ធចាត់ចំណាត់ថ្នាក់វាយតម្លៃជាលេខ ត្រូវបានប្រើប្រាស់សម្រាប់លក្ខណៈវិនិច្ឆ័យនីមួយៗ ដោយមានការថ្លឹងថ្លែងឱ្យមេគុណទៅលើលក្ខណៈវិនិច្ឆ័យទាំងឡាយណា ដែលឆ្លុះបញ្ចាំងពីវិភាគទាននៃកម្មវិធីដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ទាំងអស់ ។ ពិន្ទុថេរដែលគេបានកំណត់ ត្រូវបានប្រើដើម្បីរៀបចំបង្កើតឱ្យមានជាមូលវិចារណ៍សមស្រប (ជោគជ័យបំផុត ជោគជ័យ ជោគជ័យមួយផ្នែក មិនជោគជ័យ) នៅក្នុងលក្ខណៈវិនិច្ឆ័យ និងចំណាត់ថ្នាក់វាយតម្លៃរួមជាលេខ ។

៨០. វិធីវាយតម្លៃពីលើចុះក្រោម គឺជាការវាយតម្លៃ និងចំណាត់ថ្នាក់វាយតម្លៃដាច់ដោយឡែកពីគ្នា សម្រាប់ការកំណត់ស្ថានភាពនៃកម្មវិធីជំនួយរបស់ ADB វិភាគទានទាំងអស់របស់ ADB ដែលនាំឱ្យសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍ និងការអនុវត្តរបស់ ADB ។ ការកំណត់ស្ថានភាពសំដៅទៅលើកម្រិតដែលកម្មវិធីរបស់ ADB ទាក់ទងនឹងជំនួយជ្រើសរើសបញ្ហាត្រឹមត្រូវដើម្បីដោះស្រាយ និងជ្រើសរើសលិខិតុបករណ៍សមស្របដើម្បីដោះស្រាយបញ្ហាទាំងនោះ បន្ទាប់ពីពិចារណាទៅលើតម្រូវការជំនួយសម្រាប់ប្រទេសដែលកំពុង តែវិវត្តន៍ ។ វិភាគទានរបស់ ADB ដើម្បីសម្រេចឱ្យបាននូវលទ្ធផលអភិវឌ្ឍន៍ សំដៅទៅលើកម្រិតដែលចំនួនសរុបទាំងអស់នៃកម្មវិធីរបស់ ADB ទាក់ទងនឹងជំនួយបានរួមចំណែកយ៉ាងសំខាន់ក្នុងការសម្រេចលទ្ធផលអភិវឌ្ឍន៍ ។ ចំណាត់ថ្នាក់វាយតម្លៃទៅលើការអនុវត្តរបស់ ADB មានជាប់ពាក់ព័ន្ធនឹងការវាយតម្លៃគុណភាព និងការឆ្លើយតបនៃសេវាដែល ADB បានផ្តល់ជូនដើម្បីចូលរួមរៀបចំ និងសម្រេចលទ្ធផលអភិវឌ្ឍន៍ ។ ការចាត់ចំណាត់ថ្នាក់បែបពីលើចុះក្រោម គួរឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកខ្ចី EAs និងរបស់ដៃគូអភិវឌ្ឍន៍ បន្ថែមលើគំនិតកែលម្អដែលទទួលបានពីបុគ្គលិកប្រតិបត្តិការ ដូចដែលបានពាក់ព័ន្ធ ។ ចំណាតថ្នាក់វាយតម្លៃជាលេខ ត្រូវបានធ្វើឡើងសម្រាប់ការអនុវត្ត ស្របតាមលក្ខណៈវិនិច្ឆ័យនីមួយៗនៃលក្ខណៈវិនិច្ឆ័យពីលើចុះក្រោមទាំងបីនេះ ហើយចំណាត់ថ្នាក់វាយតម្លៃជាតួលេខនេះ ត្រូវប្រមូលចងក្រង ឡើងដើម្បីរៀបចំចំណាត់ថ្នាក់វាយតម្លៃទូទាំងប្រទេសដោយសង្ខេប ។

៨១. ចំណាត់ថ្នាក់វាយតម្លៃតាមវិស័យរួម (ពោលគឺ ពីក្រោមឡើងលើ) និងចំណាត់ថ្នាក់វាយតម្លៃទូទាំងប្រទេសរួម (ពោលគឺ ពីលើចុះក្រោម) ត្រូវបានបញ្ចូលគ្នា ដើម្បីបង្កើតចំណាត់ថ្នាក់វាយតម្លៃសរុបមួយ សម្រាប់ការអនុវត្តកម្មវិធី ។ ចំណាត់ថ្នាក់វាយតម្លៃលម្អិត និងវិធីសាស្ត្រវាយតម្លៃលទ្ធផលការងារ មានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ២ ។

៨២. ចំពោះការសរសេររៀបរាប់ពីការវាយតម្លៃ និងចំណាត់ថ្នាក់វាយតម្លៃការអនុវត្តនេះនៅក្នុងផ្នែកនេះ អ្នកវាយតម្លៃគួរធានាឱ្យមានការពិភាក្សាមួយដែលពិតជាធ្វើឡើងដោយភាពច្បាស់លាស់ និងសមហេតុផល ដើម្បីឆ្ពោះទៅរកការសន្និដ្ឋានមួយ ហើយជាពិសេស សម្រាប់ការវាយ

តម្លៃសរុប ។ ចំណាត់ថ្នាក់វាយតម្លៃទៅលើការអនុវត្តតាមវិស័យរួម គួរលើកយកមកបង្ហាញដោយប្រើប្រាស់វាក្យស័ព្ទបែបគុណ វិស័យ (ពោលគឺ ជោគជ័យបំផុត ជោគជ័យ ជោគជ័យមួយផ្នែក មិនជោគជ័យ) ហើយត្រូវមានសេចក្តីពន្យល់អំពីចំណាត់ថ្នាក់វាយតម្លៃតាមបែបលក្ខណៈវិនិច្ឆ័យវាយតម្លៃណាខ្លះ (ភាពជាប់ទាក់ទង ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព និងផលប៉ះពាល់សម្រាប់វិស័យនីមួយៗ) ដែលមានឥទ្ធិពលខ្លាំងលើចំណាត់ថ្នាក់វាយតម្លៃសរុបតាមវិស័យ ។ គួរលើកយកមកបង្ហាញផងដែរនូវចំណាត់ថ្នាក់វាយតម្លៃដែល បានព្រមព្រៀងឱ្យធ្វើ សម្រាប់ការដាក់ប្រទេសក្នុងស្ថានភាពណាមួយរបស់ ADB វិភាគទានទាំងអស់ ដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ និងលទ្ធផលការងាររបស់ ADB ។ ចំណាត់ថ្នាក់វាយតម្លៃទាំងនេះ គួរលើកយកមកពិភាក្សាតាមបែបគុណវិស័យ ហើយដោយមានភ្ជាប់នូវសេចក្តីពន្យល់ពីកត្តាសំខាន់ៗដែលមានឥទ្ធិពលលើចំណាតថ្នាក់វាយតម្លៃនេះ ។ បន្ទាប់ពីនេះ នឹងមានការវាយតម្លៃសរុបមួយទៀត ដែលត្រូវគេលើកយកមកបង្ហាញក្នុងទម្រង់ជាចំណាត់ថ្នាក់វាយតម្លៃ និងការវាយតម្លៃបែបគុណវិស័យរួមគ្នានៃការរួមចំណែកពីក្រោមឡើងលើ និងពីលើចុះក្រោមរបស់កម្មវិធីជំនួយ ។

៨៣. ចំណាត់ថ្នាក់វាយតម្លៃលម្អិត និងការវាយតម្លៃលទ្ធផលការងារ នឹងត្រូវធ្វើការរៀបចំជាឯកសារសាវតារដាច់ដោយឡែកមួយទៀតសម្រាប់ការប្រើប្រាស់ផ្ទៃក្នុងរបស់ OED ។ ការរៀបចំនេះ នឹងបង្ហាញ ព្រមទាំងពន្យល់អំពីពិន្ទុដែលឱ្យទៅលើលក្ខណៈវិនិច្ឆ័យនីមួយៗ (ពោលគឺ សម្រាប់វិស័យនីមួយៗ សម្រាប់ការអនុវត្តកម្មវិធីនៅតាមកម្រិតថ្នាក់ប្រទេស និងសម្រាប់ការអនុវត្តកម្មវិធីប្រចាំប្រទេសសរុប) ។

## ឈ. លទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

៨៤. ជំពូកចុងក្រោយនេះ នឹងផ្តល់នូវសេចក្តីសង្ខេបអំពីលទ្ធផលសំខាន់ៗដែលសម្រេចបាន នឹងលើកឡើងនូវបញ្ហាដែលអាចមានក្នុងពេលអនាគតដែលបានមកពីការវាយតម្លៃកន្លងមក។ ការវិនិច្ឆ័យបែបវាយតម្លៃ នឹងត្រូវធ្វើឡើងតាមរយៈការដាក់លក្ខណៈវិនិច្ឆ័យវាយតម្លៃចូលទៅក្នុងការអនុវត្តជំនួយរបស់ ADB ហើយការវិនិច្ឆ័យទាំងនេះ នឹងត្រូវចាត់ទុកថា ជាលទ្ធផលយ៉ាងសំខាន់នៃរបាយការណ៍នេះ ។ ដោយផ្អែកលើលទ្ធផលទាំងនេះ ផ្នែកនេះនឹងផ្តល់ជាមេរៀនមួយចំនួន ដែលយើងអាចកំណត់រកឃើញតាមរយៈការវាយតម្លៃជំនួយរបស់ ADB សម្រាប់ប្រទេស ហើយចំពោះចំណុចណាដែលជាប់ទាក់ទងផ្នែកនេះ នឹងធ្វើការផ្តល់ជាគំនិតពិចារណាសម្រាប់សកម្មភាពរបស់ ADB នាពេលអនាគត ។ នៅក្នុងមេរៀនទាំងនោះ រួមមានសេចក្តីសន្និដ្ឋានទូទៅ ទាំងសេចក្តីសន្និដ្ឋានវិជ្ជមាន និងអវិជ្ជមានដែលទទួលបានពីការត្រួតពិនិត្យទៅលើ កម្មវិធីប្រចាំប្រទេសទាំងមូល ដែលវាទាក់ទងនាពេលអនាគតជាមួយនឹង ADB និងគោលនយោបាយរបស់ស្ថាប័ននេះ អ្នកខ្ចី ឬទំនាក់ទំនងរបស់អ្នកខ្ចីជាមួយនឹងដៃគូអភិវឌ្ឍន៍ និងសង្គមស៊ីវិល ។

៨៥. អនុសាសន៍របស់ CAPEs គួរយកមកប្រើដើម្បីធ្វើវាល់សេចក្តីសម្រេចចិត្តដែលមានផលប៉ះពាល់ដោយផ្ទាល់ដល់ប្រតិបត្តិការរបស់ ADB នាពេលអនាគតនៅក្នុងប្រទេស និងនៅក្នុងវិស័យសំខាន់ៗ ។ អនុសាសន៍ គួរធ្វើឡើងនៅក្នុងបរិបទនៃបញ្ហាប្រឈម និងកាលានុវត្តន៍ភាពរបស់ប្រទេសនាពេលអនាគត ហើយអនុសាសន៍ទាំងនេះ គួរមានចំនួនកំណត់ និងអាចត្រួតពិនិត្យបាន មានភាពជាប់ទាក់ទង ផ្តោតលើគោលដៅឆ្ពោះទៅរកការសម្រេចបានលទ្ធផល និងមានភាពទៀងទាត់ពេលវេលា ។ អនុសាសន៍របស់ CAPEs គួរធ្វើឡើងក្នុងន័យស្ថាបនាជាជាងក្នុងបំណងអវិជ្ជមាន ឬបំផ្លាញ ។

៨៦. មានតែលទ្ធផល មេរៀន សេចក្តីសន្និដ្ឋាន និងអនុសាសន៍សំខាន់ៗប៉ុណ្ណោះ ដែលគេគួរលើកយកមកបង្ហាញនៅក្នុង CAPE ។ សេចក្តីសន្និដ្ឋាន និងអនុសាសន៍ មិនគួរធ្វើឡើងហួសពីព្រំដែននៃការអនុវត្តរបស់ CAPE ហួសពីភស្តុតាងដែលបានបង្ហាញ ឬហួសពីការវិភាគឡើយ ។ CAPE មានគោលបំណងរួមវិភាគទានដើម្បីរៀបចំ CSPs ថ្មីៗដោយកាន់តែបង្កើននូវការប្រុងប្រយ័ត្នប៉ុណ្ណោះ ។ CAPE មិនមែនជាតួអង្គជំនួសការរៀបចំបង្កើត (CSPs) នោះទេ ។ ដូច្នេះហើយ មិនចាំបាច់ធ្វើការវិភាគ និងធ្វើការវាយតម្លៃពេញលេញ ដែលចាំបាច់ត្រូវគាំទ្រ CSP នៅក្នុងបរិបទនៃ CAPE នោះឡើយ ។ គួរមានការប្រុងប្រយត្ន័ មុននឹងធ្វើការផ្តល់ជាអនុសាសន៍ជាយុទ្ធសាស្ត្រ ឬសម្រាប់កម្មវិធី ព្រោះថា អនុសាសន៍បែបនេះ តម្រូវឱ្យមានការវិភាគកាន់តែមានភាពល្អិតល្អន់ថែមទៀត ។

ឧបសម្ព័ន្ធ ១

# IV. ការអនុវត្តវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

## ក. វិធីវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

៨៧. CAPE ត្រូវបានអនុវត្តជាបួនដំណាក់កាលដោយប្រើរយៈពេលពី ៩ ទៅ ១២ ខែ ។ ការអនុវត្តនេះរួមមាន ការរៀបចំ ការប្រមូលទិន្នន័យ ការវិភាគ និងការធ្វើរបាយការណ៍ ។

៨៨. នៅក្នុងដំណាក់កាលត្រៀមរៀបចំ អ្នកគ្រប់គ្រងមានសមត្ថកិច្ចខាងវាយតម្លៃរបស់ OED ធ្វើការត្រួតពិនិត្យ រួចហើយសង្ខេបព័ត៌មានស្តីពីបរិបទប្រទេស យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB, ការអនុវត្តកម្មវិធី, លទ្ធផលនៃការវាយតម្លៃដោយខ្លួនឯង និងដោយឯករាជ្យ និងព័ត៌មានពាក់ព័ន្ធទទួលបានពីរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ។ របាយការណ៍ស៊ីជម្រៅដែលមានប្រហែលជា ១០ ទំព័រ ត្រូវបានរៀបចំ និងលើកយកមកពិភាក្សាជាមួយនឹងសហសេវិកត្រួតពិនិត្យរបស់ OED និងធ្វើឡើងដោយមានការផ្តល់ជាយោបល់ពីក្រុមប្រចាំប្រទេស ។ របាយការណ៍ស៊ីជម្រៅនេះគួរផ្តោតទៅលើ (i) គោលដៅ និងវត្ថុបំណងនៃ CAPE រួមមាន សំណួរសំខាន់ៗដែលរបាយការណ៍ នេះ នឹងត្រូវធ្វើការឆ្លើយតប (ii) បរិបទប្រទេស និងអាទិភាពអភិវឌ្ឍន៍របស់រដ្ឋាភិបាល (iii) ការវិវត្តន៍ CSP របស់ ADB (iv) បញ្ហាទូទៅ និងជាក់លាក់ប្រចាំប្រទេសសំខាន់ៗដែលនឹងត្រូវធ្វើការវាយតម្លៃ (v) វិធីសាស្ត្រ និងវិធីរបស់ CAPE (ដោយសង្ខេប) (vi) ធនធានចាំបាច់ ក្របខ័ណ្ឌពេលវេលាវាយតម្លៃ និងកាលវិភាគធ្វើរបាយការណ៍ (vii) លក្ខខណ្ឌការងារសម្រាប់សមាជិកក្រុមវាយតម្លៃ និង (viii) ថវិការ ។

៨៩. មុននឹងបញ្ចប់ របាយការណ៍ស៊ីជម្រៅ ក៏គួរលើកយកមកពិភាក្សាជាមួយនឹងបុគ្គលិកបេសកកម្មប្រចាំតាមទីស្នាក់ការនិវាសនដ្ឋាន មន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតផងដែរក្នុងអំឡុងពេលបេសកកម្មស្វែងយល់ដ៏ខ្លីមួយទៅកាន់ DMC ។ បេសកកម្មសិក្សាស្វែងយល់នេះ នឹងត្រូវប្រើដើម្បីបញ្ជាក់ពីការអាចទទួលយកបាននូវបញ្ហាសំខាន់ៗណែនាំអំពីវិធីសាស្ត្រ និងវិធីរបស់ CAPE ធ្វើការកំណត់និងធ្វើកាលវិភាគអង្គប្រជុំ ជាមួយអ្នកឆ្លើយតបសម្រាប់បេសកកម្មវាយតម្លៃសំខាន់ៗ ធ្វើការកំណត់បុគ្គលមានលក្ខណៈសម្បត្តិសមស្របចូលរួមក្នុងក្រុមវាយតម្លៃ និងដើម្បីកំណត់ និងប្រមូលប្រភពទិន្នន័យបន្ទាប់បន្សំ ។

៩០. ការរៀបចំរបាយការណ៍ស៊ីជម្រៅ និងបេសកកម្មសិក្សាស្វែងយល់ទៅកាន់ប្រទេស DMC បានធ្វើឱ្យបុគ្គលិកវាយតម្លៃមានកាលានុវត្តន៍ភាពក្នុងការកំណត់នូវដំណោះស្រាយលើបញ្ហាជាក់លាក់របស់ប្រទេស ដែលជាបញ្ហាបន្ថែមទៅលើសំណុំនៃបញ្ហាដែលបានកំណត់ជាបទដ្ឋាន ដែលនឹងត្រូវវាយតម្លៃនៅក្នុង CAPEs ទាំងអស់ (កថាខ័ណ្ឌ ១៨-២០) ។ បញ្ហាជាក់លាក់របស់ប្រទេស អាចមានដូចជាបញ្ហាប្រឈមនានា ដែលមានលក្ខណៈច្បាស់លាស់ចំពោះប្រទេស DMCs មួយចំនួននោះ (ឧ. ការជំរុញសមាហរណកម្មក្នុងតំបន់ ការប្រយុទ្ធប្រឆាំងនឹងការជួញដូរខុសច្បាប់ ការលើកកម្ពស់សមភាពយេនឌ័រ) ការប្រើប្រាស់ឧបករណ៍ជំនួយជាក់លាក់ដែលមានសារៈសំខាន់ច្រើនជាងនៅក្នុងបរិបទមួយចំនួននោះ (ឧ. តួនាទីនៃកម្មវិធីផ្តល់កម្ចីនៅក្នុងប្រទេសកាលអន្តរកាលនានា) និងការអភិវឌ្ឍភាពជាដៃគូក្នុងទម្រង់ពិសេស (ឧ. ការចូលរួមរបស់ NGO) ។ បន្ទាប់ពីមានការឯកភាពទៅលើរបាយការណ៍ស៊ីជម្រៅដោយ DG នៃ OED រួចហើយ ក្រុមវាយតម្លៃមួយ ត្រូវបានជ្រើសរើសឡើង ។ ដើម្បីជួយដឹកនាំក្រុមក្នុងការប្រមូលព័ត៌មាន ក្រុមនេះ នឹងទទួលបាននូវព័ត៌មានសាវតារសម្រាប់ការត្រួតពិនិត្យ លិខិតុបករណ៍វាយតម្លៃ[២] គោលការណ៍ណែនាំរបស់ CAPE និងលក្ខខណ្ឌការងារដែលឆ្លុះបញ្ចាំងពីបញ្ហាជាក់លាក់តាមប្រទេស និងការទទួលខុសត្រូវចម្បងរបស់ក្រុម ។ [៣] សមាសភាពនៃក្រុមវាយតម្លៃ គួរឆ្លុះបញ្ចាំងពីការអនុវត្តដោយឯករាជ្យ និងផ្តោតទៅលើលទ្ធផលសំខាន់ៗ ។ ក្រុមវាយតម្លៃនេះ គួរមានតុល្យភាពសមស្របទាក់ទងនឹងបទពិសោធន៍របស់

---

[២] ឧបករណ៍នេះ អាចមានដូចជាបញ្ជីសំណួរ កម្រងសំណួរ ម៉ាទ្រីចក្របខ័ណ្ឌវាយតម្លៃ ទម្រង់អង្កេត បញ្ជីអ្នកឆ្លើយតបដែលប្រកបដោយសក្តានុពល ។ល។

[៣] ឧទាហរណ៍អំពីលក្ខខណ្ឌការងារសម្រាប់ទីប្រឹក្សារបស់ CAPE ដែលដកស្រង់ចេញពី CAPE នៅក្នុងប្រទេស Bhutan មាននៅក្នុងសេចក្តីបន្ថែម ៣ ។ ហើយបញ្ជីសំណួរដែលអាច យកមកប្រើប្រាស់ដើម្បីវាយតម្លៃភាពជាម្ចាស់លើកម្មវិធី មាននៅក្នុងសេចក្តីបន្ថែម ៤ ។

ប្រទេស ជំនាញបច្ចេកទេស ការស្វែងយល់ពី ADB និងមានសមត្ថភាពវាយតម្លៃ ។ ដើម្បីធានាឱ្យមានឯករាជ្យភាព ភាពមិនលំអៀង និងសុច្ចរិតភាព គោលការណ៍ណែនាំទាក់ទងនឹងជម្លោះ ណ្តើមផលប្រយោជន៍របស់ OED នឹងត្រូវបានគេអនុវត្តតាម ដើម្បីជ្រើសរើសអ្នកប្រឹក្សាសម្រាប់ CAPE ។[៤]

៩១. នៅក្នុងដំណាក់កាលប្រមូលទិន្នន័យ ព័ត៌មានដែលត្រូវយកមកប្រើនៅក្នុង CAPE ជាទូទៅ ដកស្រង់ចេញពី (i) ការត្រួតពិនិត្យការសិក្សាមុនៗដែលធ្វើទៅលើបរិបទប្រទេសទូទៅ (ii) ការត្រួតពិនិត្យឯកសារដែលមានស្រាប់ទាំងរបាយការណ៍បោះពុម្ព និងមិនទាន់បោះពុម្ព និងអត្ថបទ និងឯកសារស្រាវជ្រាវ ឯកសារសរសេរដោយដៃ និងរបាយការណ៍បណ្តោះអាសន្នដែលអាចរកបានពី ADB ពីសំណាក់រដ្ឋាភិបាល ឬក៏ប្រភពឯករាជ្យ (iii) បទសម្ភាសន៍ដែលបានចងក្រងជារចនាសម្ព័ន្ធ និង/ឬ ការអង្កេតជាផ្លូវការ ទៅលើអ្នកមានវិជ្ជាជីវៈទាក់ទងនឹង ឬមានការយល់ដឹងអំពីប្រតិបត្តិការដែលផ្តល់ថវិការដោយ ADB (ដែលអាចមានដូចជាមន្ត្រីមកពី EAs និងអ្នកផ្សេងទៀតដែលជាប់ពាក់ព័ន្ធក្នុងការរៀបចំការអនុវត្ត និងការត្រួតពិនិត្យទៅលើសកម្មភាពជំនួយរបស់ ADB (iv) កិច្ចប្រជុំដែលមានរចនាសម្ព័ន្ធមិនសូវល្អ ជាមួយនឹងបណ្តាភាគីផ្សេងៗទៀតដែលមានទស្សនៈល្អៗ ដូចជាអ្នកសារព័ត៌មាន អង្គការ NGO ក្នុងស្រុក និងអង្គការសង្គមស៊ីវិលផ្សេងទៀត ដៃគូអភិវឌ្ឍន៍ និងអ្នកតំណាងវិស័យឯកជន (v) ការពិភាក្សាជាមួយនឹងប្រជាជនគ្រប់ស្រទាប់ រួមមានសមាជិកសង្គមស៊ីវិលទូទៅ និងជាពិសេស ជាមួយភាគីណាដែលទទួលរងឥទ្ធិពលដោយប្រការណាមួយពីប្រតិបត្តិការរបស់ ADB (vi) ការពិភាក្សាជាមួយអ្នកទទួល អត្ថប្រយោជន៍ និង (vi) ការចុះសង្កេតដល់ទីកន្លែងក្នុងតំបន់នៃគម្រោងដែលបានជ្រើសរើសទុក ។

៩២. បច្ចេកទេស និងលិខិតុបករណ៍វាយតម្លៃជាច្រើនប្រភេទ អាចនឹងត្រូវយកមកប្រើ ដើម្បីជួយចងក្រងការប្រមូលព័ត៌មានជារចនាសម្ព័ន្ធ និងដើម្បីធានាឱ្យមានទិដ្ឋភាពសំខាន់ៗនៃការអនុវត្តរបស់ប្រទេសដែលមិនត្រូវមើលរំលង ។[៥] បញ្ជីលិខិតុបករណ៍ និងបច្ចេកទេសសមស្រប មាននៅក្នុងតារាង ២ ។ ឧបករណ៍ និងបច្ចេកទេសបែបនេះ អាចត្រូវបានជ្រើសរើសយកមកប្រើក្នុងគោលបំណងដើម្បីឆ្លើយតបទៅនឹង សំណួរវាយតម្លៃក្នុងភាពដែលអាចទុកចិត្តបានប្រកបដោយសុពលភាពខ្ពស់ និងទោះជាស្ថិតនៅក្រោមកំហិតនៃពេលវេលា និងធនធានក៏ដោយ ។

៩៣. ក្រុមប្រចាំប្រទេសរបស់ ADB និងបុគ្គលិកបេសកកម្មនៅក្នុងនិវាសនដ្ឋាន គួរត្រូវបានជំរុញលើកទឹកចិត្តឱ្យចេះជួយក្រុមវាយតម្លៃក្នុងការកំណត់រកបុគ្គលមានលក្ខណៈសម្បត្តិសមរម្យ ដោយធ្វើការណាត់ជួប និងផ្តល់នូវទស្សនៈ និងគំនិតកែលម្អរបស់ពួកគេ ដល់ក្រុមវាយតម្លៃ ។ ដើម្បីជំរុញការផ្លាស់ប្តូរទស្សនៈគ្នារវាងក្រុមវាយតម្លៃ និងអ្នកឆ្លើយតបនោះដោយត្រង់ទៅត្រង់មក និងគ្មានការលំអៀងនោះ ការចូលពាក់ព័ន្ធណាមួយរបស់បុគ្គលិកបេសកកម្មប្រចាំនៅនិវាសនដ្ឋាន ឬបុគ្គលិកប្រតិបត្តិការរបស់ ADB ផ្សេងទៀតនៅក្នុងអង្គប្រជុំជាមួយនឹងមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀតនៅក្នុងប្រទេស មិនត្រូវបាន លើកទឹកចិត្តឡើយនៅក្នុងរយៈពេលប្រមូលទិន្នន័យនេះ ។

៩៤. នៅពេលដែលបេសកកម្មចុះពិនិត្យដល់ទីកន្លែងត្រូវបានបញ្ចប់ លទ្ធផលដំបូង ត្រូវបានគេលើកយកមកបង្ហាញជូនរដ្ឋាភិបាល បុគ្គលិកបេសកកម្មប្រចាំនៅនិវេសនដ្ឋានរបស់ ADB និងអ្នកពាក់ព័ន្ធផ្សេងទៀត ដោយរៀបចំឱ្យមានជាសិក្ខាសាលាមួយ ឬច្រើន ។ បទបង្ហាញទាំងនេះ បានផ្តល់នូវកាលានុវត្តន៍ភាពដំបូងបំផុត ដើម្បីឱ្យក្រុមវាយតម្លៃទទួលបាននូវគំនិតកែលម្អពីលទ្ធផលខ្លួនសម្រេចបាន និងអនុសាសន៍បឋមស្តីពីអ្នកមានវិជ្ជាជីវៈនៅក្នុងប្រទេស ។ បន្ទាប់ពីការបញ្ចប់ការងារចុះដល់ទីកន្លែងដ៏សំខាន់នេះ ហើយមុននឹងចាប់ផ្តើមសរសេររបាយការណ៍ដ៏ចាំបាច់របស់ CAPE របាយការណ៍ខ្លីមួយ (ប្រាំទំព័រ) និង/ឬបទបង្ហាញដោយប្រើកម្មវិធី PowerPoint នឹងត្រូវបានរៀបចំឡើង ដែលរបាយការណ៍នេះ ធ្វើការសង្ខេបទៅលើលទ្ធផល និងអនុសាសន៍សំខាន់ៗ ។ ការសង្ខេបនេះ នឹងត្រូវលើកយកមកពិភាក្សាជាមួយនឹងបុគ្គលិក ADB ដែលពាក់ព័ន្ធ និងថ្នាក់ដឹកនាំ OED ។

៩៥. នៅពេលដែលរបាយការណ៍ពង្រាងរបស់ CAPE បានរៀបចំរួចរាល់អស់ហើយ សហសេវិកត្រួតពិនិត្យរបស់ OED ត្រូវបានស្នើឱ្យធ្វើការត្រួតពិនិត្យឯកសារពង្រាងនោះ ។ បន្ទាប់ពីយល់ឃើញថាមានសុពលភាព និងក្រោយបានបញ្ចូលគំនិតកែលម្អបឋមទទួលបានពីក្រុមប្រចាំប្រទេស

---

[៤] ADB. 2005. គោលការណ៍ណែនាំដើម្បីចៀសវាងជម្លោះប្រយោជន៍នៅក្នុងការវាយតម្លៃដោយឯករាជ្យ. ម៉ានីល.

[៥] សូមមើលសេចក្តីបន្ថែម ៥ សម្រាប់ឧទាហរណ៍នៃការអង្កេតអតិថិជន/អ្នកទទួលអត្ថប្រយោជន៍ដែលបានយកមកប្រើដើម្បីកៀរគរព័ត៌មានត្រលប់ ក្នុងករណីរបស់សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ ។

ឧបសម្ព័ន្ធ ១

តាមភាពសមស្របរួចមក លទ្ធផលទាំងនេះ នឹងត្រូវលើកយកមកបង្ហាញជូនក្រុមប្រចាំប្រទេសដែលកំពុងធ្វើប្រតិបត្តិការដើម្បី ត្រួតពិនិត្យវិញ ។ បន្ទាប់មក នឹងមានការស្នើសុំការធ្វើអត្ថាធិប្បាយជាផ្លូវការពីសំណាក់អន្តរនាយកដ្ឋាន និងពីសំណាក់មន្ត្រីរដ្ឋាភិបាលផងដែរ ។ បេសកកម្មតាមដានមួយអាចត្រូវបង្កើតឡើងប្រចាំប្រទេស ដើម្បីពិភាក្សាអំពីលទ្ធផល ។ បន្ទាប់មក របាយការណ៍វាយតម្លៃ នឹងត្រូវធ្វើការកែសម្រួលឡើងវិញដោយដកស្រង់សេចក្តីអត្ថាធិប្បាយរបស់រដ្ឋាភិបាល និងបុគ្គលិករបស់ ADB ។ ក្រោយមកទៀត របាយការណ៍នេះ នឹងត្រូវត្រួតពិនិត្យដោយថ្នាក់ដឹកនាំរបស់ OED ដែលបន្ទាប់ពីការត្រួតពិនិត្យនេះទៅកិច្ចប្រជុំថ្នាក់ DG មួយនឹងត្រូវធ្វើឡើង ដើម្បីពិភាក្សាលើលទ្ធផល និងការធ្វើសេចក្តីសនិដ្ឋានសំខាន់ៗ ។ ហើយជាកិច្ចបញ្ចប់ របាយការណ៍នេះ នឹងត្រូវដាក់ជូន DG នៃ OED ដើម្បីធ្វើការអនុម័ត ។

## ខ. ការជំរុញឱ្យមានការចូលរួម

៩៦. ការជំរុញការលើកទឹកចិត្តឱ្យមានការចូលរួមនៅក្នុងដំណើរការ CAPE ត្រូវតែធ្វើតាមរយៈ (i) ការប្រឹក្សាជាមួយក្រុមប្រចាំប្រទេស និងរដ្ឋាភិបាលនៅក្នុងការរៀបចំរបាយការណ៍ស៊ីជម្រៅ (ii) ការប្រើប្រាស់បេសកកម្មសិក្សាស្វែងយល់ដើម្បីពន្យល់អំពីគោលដៅ វត្ថុបំណង លទ្ធផលរំពឹងទុក សំណួរស្រាវជ្រាវ និងវិធីវាយតម្លៃដល់អ្នកពាក់ព័ន្ធតាមមូលដ្ឋាន (iii) ការប្រឹក្សាជាមួយអ្នកពាក់ព័ន្ធថ្នាក់ជាតិ និងតាមមូលដ្ឋានក្នុងអំឡុងពេលបេសកកម្មវាយតម្លៃប្រតិបត្តិការ (iv) ការប្រើប្រាស់អង្កេតផ្លូវការ និងបទសម្ភាសន៍ដែលបានចងក្រងជារចនាសម្ព័ន្ធជាមួយនឹងមន្ត្រីរដ្ឋាភិបាលដើម្បីពង្រីកការជាប់ពាក់ព័ន្ធនៅក្នុងការវាយតម្លៃ (v) ការបង្ហាញលទ្ធផលបឋមដល់អ្នកពាក់ព័ន្ធនៅក្នុងប្រទេស (vi) ការផ្សព្វផ្សាយរបាយការណ៍ CAPE ដល់ក្រុមប្រចាំប្រទេស និងរដ្ឋាភិបាល ខណៈពេលដែលរបាយការណ៍នេះ ស្ថិតនៅក្នុងដំណាក់កាលពង្រាង ដើម្បីសុំសេចក្តីអត្ថាធិប្បាយ និងការត្រួតពិនិត្យ ហើយ (vii) ការរៀបចំកិច្ចប្រជុំជាប្រចាំមួយចំនួន និងមិនផ្លូវការ រវាងអ្នកតំណាងក្រុមប្រចាំប្រទេស និងសហសេវិកត្រួតពិនិត្យដើម្បីចែករំលែកលទ្ធផល និងផ្លាស់ប្តូរយោបល់គ្នាទៅវិញទៅមក (តារាង ២) ។ ការបិទផ្សាយរបាយការណ៍របស់ CAPE នៅតាមវែបសាយជួយធានាឱ្យសាធារណជន និងអ្នកពាក់ព័ន្ធដែលមានការចាប់អារម្មណ៍ទៅលើប្រសិទ្ធភាពនៃការអភិវឌ្ឍនោះ ទទួលបានព័ត៌មានអំពីលទ្ធផលទាំងនោះកាន់តែទូលំទូលាយឡើង ។

## តារាង ២ : លិខិតុបករណ៍ និងបច្ចេកទេសវាយតម្លៃសមស្របរបស់ CAPE

| បច្ចេកទេសវាយតម្លៃ | ការប្រើប្រាស់ប្រកបដោយសក្តានុពលសម្រាប់ CAPE |
|---|---|
| **អង្កេតគំរូ កម្រងសំណួរ** | ការអង្កេតអាចពង្រីកសមត្ថភាពរបស់ CAPE ទៅដល់អ្នកពាក់ព័ន្ធជាច្រើនទៀតបាន ខណៈពេលដែលកំពុងធ្វើការផ្តល់ចំណេះដឹងដែលបានចងក្រងជារចនាសម្ព័ន្ធ ដើម្បីធ្វើឱ្យសញ្ញាកូដខ្ញមានសុពលភាព និងដើម្បីធ្វើការវិភាគភាពខុសប្លែកគ្នារវាងការពិត និងសញ្ញាកូដខ្ញ ។ លទ្ធផលចេញពីការអង្កេតបែបនេះ មានភាពសមស្របណាស់ សម្រាប់ធ្វើការប្រៀបធៀបតាមស្ថិតិ ។ ការអង្កេតនេះ គួរធ្វើឡើងតាមវិធីងាយៗ និងអាចគ្រប់គ្រងបាន ហើយគួរត្រូវបានរៀបចំ ឡើងតាំងពីចាប់ដំណើរការដំបូងរបស់ CAPE ។ |
| **បទសម្ភាសន៍ជាមួយក្រុមគោលដៅ** | បទសម្ភាសន៍ជាមួយក្រុមគោលដៅ គឺជាបច្ចេកទេសវាយតម្លៃម្យ៉ាងបើថវិការតិច និងឆាប់រហ័ស ដែលបានផ្តល់នូវព័ត៌មានបែបគុណវិស័យ ។ អ្នកសម្របសម្រួលម្នាក់ ដឹកនាំការពិភាក្សាជាក្រុមដែលមានសមាជិកចូលរួមពី ៧ ទៅ ១១ នាក់ ប្រើរយៈពេលប្រហែលពី ១ ទៅ ២ ម៉ោង ទាក់ទងនឹងបទពិសោធន៍ អារម្មណ៍ និងចំណង់ចំណូលចិត្តរបស់ពួកគេទៅលើប្រធានបទ ។ គាត់លើកយកបញ្ហាដែលបានកំណត់រកឃើញនៅក្នុងក្របខ័ណ្ឌវាយតម្លៃមកបង្ហាញ និងប្រើប្រាស់បច្ចេកទេសសាកសួរ ដើម្បីប្រមូលទស្សនៈយល់ឃើញ ។ អ្នកចូលរួមប្រកបដោយសក្តានុពល មានដូចជាដៃគូ និងអ្នកពាក់ព័ន្ធសំខាន់ៗ (ឧ. រដ្ឋាភិបាល, បុគ្គលិក គម្រោង និងមន្ត្រីរដ្ឋាភិបាលម្ចាស់ជំនួយមន្ត្រី ADB) និងអ្នកជំនាញការដែលបានទទួលស្គាល់ ។ |
| **កិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធ** | ការចូលរួមយ៉ាងសកម្មរបស់អ្នកពាក់ព័ន្ធក្នុងរយៈពេលនៃការធ្វើវិភាគនេះ អាចបង្កើននូវការគាំទ្រពីសំណាក់ភាគីខាងក្រៅ ហើយកិច្ចប្រជុំនេះ ផ្តល់នូវវេទិកាដើម្បីពិភាក្សា និងកំណត់លទ្ធផល និងអនុសាសន៍ជាអាទិភាព ។ កិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធ ប្រព្រឹត្តទៅហួសពីបទសម្ភាសន៍ជាមួយក្រុមគោលដៅទៅទៀត ព្រោះអង្គប្រជុំនេះ ជាប់ពាក់ព័ន្ធជាមួយនឹងក្រុមមានចំណាប់អារម្មណ៍ជាច្រើន ដែលមានការយកចិត្តទុកដាក់ផ្ទាល់ទៅលើលទ្ធផល និងអនុសាសន៍របស់ CAPE ។ |
| **ការត្រួតពិនិត្យ/ការវិភាគឯកសារដែលមានស្រាប់** | ក្នុងដំណាក់កាលរៀបចំ គេបានធ្វើការត្រួតពិនិត្យឯកសារដែលមានស្រាប់ ដើម្បីសំយោគរបាយការណ៍ និងឯកសារជាប់ពាក់ព័ន្ធដែលអាចប្រើបាន ។ ការត្រួតពិនិត្យឯកសារដែលមានស្រាប់បន្ថែមទៀតទំនងជាតម្រូវឱ្យធ្វើឡើងនៅពេលដែលក្រុមវាយតម្លៃ បានបង្កើតឡើង និងនៅពេលដែលការផ្តោតយកចិត្តទុកដាក់ចម្បងរបស់ CAPE ត្រូវបានកំណត់រួចហើយ ។ ការត្រួតពិនិត្យឯកសារដែលមានស្រាប់ គួរបញ្ចប់ឱ្យបានរួចរាល់ មុននឹងចាប់ផ្តើមបេសកកម្មប្រចាំប្រទេស ។ |
| **ការចុះពិនិត្យ/ការអង្កេតដល់ទីកន្លែង** | ការចុះដល់ទីកន្លែង មានសារៈសំខាន់ណាស់ដើម្បីធ្វើឱ្យលទ្ធផលអភិវឌ្ឍន៍ដែលគេបានដឹង មានសុពលភាព ហើយនឹងអាចជួយបំពេញបន្ថែមដល់បច្ចេកទេសវាយតម្លៃផ្សេងទៀត ។ CAPE គួរតែធ្វើការចុះពិនិត្យដល់ទីកន្លែងដើម្បីបញ្ជាក់ឱ្យកាន់តែច្បាស់ និង/ឬពិនិត្យមើលឱ្យបានជាក់ស្តែងនូវកត្តាជោគជ័យ ឬបរាជ័យទាំងនោះ ។ ការជ្រើសរើសទីកន្លែងដើម្បីចុះពិនិត្យ គួរស៊ីសង្វាក់គ្នាជាមួយនឹងកម្លាំងចលករគន្លឹះរបស់កម្មវិធី ហើយត្រូវ ភ្ជាប់ជាមួយនឹងការតាមដានលទ្ធផលអភិវឌ្ឍន៍នៃជំនួយរបស់ ADB ។ |
| **បទសម្ភាសន៍ជាមួយអ្នកផ្តល់ ព័ត៌មានសំខាន់ៗ** | បទសម្ភាសន៍ជាមួយអ្នកផ្តល់ព័ត៌មានសំខាន់ៗ គឺជាបទសម្ភាសន៍ដែលមានលក្ខណៈបែបគុណវិស័យ និងស៊ីជម្រៅទៅលើបុគ្គលដែលជាអ្នកផ្តល់ព័ត៌មានដែលគេបានជ្រើសរើសចំនួនពី ១៥ ទៅ ៣៥ នាក់ សម្រាប់បការយល់ឃើញជាលើកដំបូងរបស់ពួកគេទៅលើប្រធានបទដែលពួកគេចាប់អារម្មណ៍ ។ បទសម្ភាសន៍នេះ ត្រូវបានចងក្រងជារចនាសម្ព័ន្ធធូរលុង ដោយផ្អែកទៅលើបញ្ជីសំណួរដែលត្រូវពិភាក្សា ។ តែបទសម្ភាសន៍ទាំងនេះ មានសារៈប្រយោជន៍នៅពេលដែលគេចង់ដឹងអំពីទឹកចិត្ត និងទស្សនៈរបស់ដៃគូរ និងនៅពេលដែលទិន្នន័យបែបបរិមាណវិស័យដែលគេប្រមូលបាន ត្រូវបានបកស្រាយ និងផ្តល់ជាអនុសាសន៍ ។ |
| **ការវិភាគនិន្នាការ** | ការវាយតម្លៃនិន្នាការនានាបែបបរិមាណវិស័យដោយប្រើប្រាស់ប្រភពទិន្នន័យបន្ទាប់បន្សំ អាចយកមកប្រើដើម្បីធ្វើតេស្ត៍ និងធ្វើឱ្យសញ្ញាកូដខ្ញរបស់អ្នកពាក់ព័ន្ធមានសុពលភាព ។ |
| **ការអង្កេតក្នុងទ្រង់ទ្រាយតូច/ ការស្ទាបស្ទង់មតិ** | ការអង្កេតតូចៗទៅលើអ្នកពាក់ព័ន្ធពីខាងក្រៅ និងទៅលើសាធារណជនទូទៅ ដូចជាអ្នកទទួលអត្ថប្រយោជន៍ជាដើម អាចយកមកប្រើដើម្បីជួយបំពេញការវិភាគឱ្យបែបស៊ីជម្រៅដែលមានស្រាប់ ឬដើម្បីបញ្ជាក់អំពីបញ្ហាសំខាន់ៗ ។ ការអង្កេតតូចនេះ ខុសផ្លែកពីការអង្កេតទូទៅត្រង់ថា សវនកៈមិនបានជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយនឹង ADB ទេ ហើយក៏មិនរំពឹងទុកឱ្យពួកគេមានការយល់ដឹងអំពី ADB ដែរ ប៉ុន្តែពួកគេ អាចជាអ្នកទទួលបានអត្ថប្រយោជន៍ពីកិច្ចគាំទ្ររបស់ ADB ។ |

ADB = ធនាគារអភិវឌ្ឍន៍អាស៊ី CAPE = ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

ប្រភព : ការប៉ាន់ស្មានរបស់ ADB

## គ. ការធ្វើឱ្យមានសុពលភាពនូវយុទ្ធសាស្ត្រប្រចាំប្រទេស និងរបាយការណ៍បញ្ចប់កម្មវិធី

៩៧. ADB នឹងធ្វើការរៀបចំរបាយការណ៍បញ្ចប់ CSP ដែលរៀបចំឡើងដោយបុគ្គលិកប្រតិបត្តិការជាការចាំបាច់មុននឹងធ្វើការរៀបចំរបាយការណ៍ស្តីពីបញ្ហាដែលមាននៅក្នុង CSP ។ មានការប៉ាន់ស្មានទុកហើយថា របាយការណ៍នេះ នឹងគ្របដណ្តប់ទៅលើវឌ្ឍនភាពដែលបានសម្រេចនៅក្នុងលទ្ធផល CSP លើកត្តាដែលប៉ះពាល់ដល់ការអនុវត្ត CSP លើមេរៀនដែលបានកំណត់ និងលើអនុសាសន៍សម្រាប់ CSP លើកក្រោយ ។ OED ត្រូវបានតម្រូវឱ្យធ្វើការបញ្ចប់ដោយធ្វើឱ្យមានសុពលភាពនូវរបាយការណ៍បញ្ចប់ CSP ។ នៅពេលដែលរបាយការណ៍បញ្ចប់ CSP ត្រូវបានរៀបចំជាប្រចាំនោះ CAPE នឹងមិនចាំបាច់យកចិត្តទុកដាក់ខ្លាំងទៅលើគុណភាពនៃ CSP ពេកទេ ដោយហេតុថាមានការវាយតម្លៃទូលំទូលាយដោយខ្លួនឯងរួចហើយទៅលើ CSPs ។ ហេតុដូច្នេះ CAPE អាចយកចិត្តទុកដាក់បន្ថែមទៀតទៅលើវិភាគទានរបស់ ADB ដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ក្នុងវិស័យនានាតាមប្រធានបទ និងក្នុងកម្រិតថ្នាក់ប្រទេស ក៏ដូចជាផ្តោតយកចិត្តទុកដាក់ទៅលើ ដេទែមីណង់នៃការអនុវត្តទៅតាមកម្រិតផ្សេងៗគ្នានេះដែរ ។

៩៨. OED នឹងធ្វើការលើកទឹកចិត្ត និងជួយដល់ដំណើរការនៃការវាយតម្លៃដោយខ្លួនឯងទៅលើការអនុវត្តរបស់ប្រទេស ដោយធ្វើឱ្យរបាយការណ៍បញ្ចប់ CSP នេះ មានសុពលភាព បន្ទាប់ពីរបាយការណ៍ទាំងនេះ ត្រូវបានរៀបចំរួច ។ ការធ្វើឱ្យរបាយការណ៍ទាំងនេះមានសុពលភាព នឹងមានការជាប់ពាក់ព័ន្ធនឹងការត្រួតពិនិត្យឯកសារដែលមានស្រាប់នៃរបាយការណ៍បញ្ចប់ CSP រួមទាំងសុពលភាពរបស់ខ្លួន អំពីការអនុវត្តតាមគោលការណ៍ណែនាំរៀបចំរបាយការណ៍បញ្ចប់ CSP និងគោលនយោបាយ និងការអនុវត្តវាយតម្លៃប្រចាំប្រទេសដែលអាចទទួលយកបានជាទូទៅ ។

## ឃ. ការផ្តល់អនុសាសន៍ប្រកបដោយប្រសិទ្ធិភាព

៩៩. អនុសាសន៍នៅក្នុង CAPE គួរត្រូវបានយកមកប្រើដើម្បីធ្វើការសម្រេចចិត្តដែលមានការប៉ះពាល់ដោយផ្ទាល់ទៅលើប្រតិបត្តិការរបស់ ADB នាពេលអនាគតនៅក្នុងប្រទេស និងនៅក្នុងវិស័យសំខាន់ៗ ។ ហេតុដូច្នេះហើយ រាល់ព័ត៌មានទាំងអស់ដែលបានលើកយកមកបង្ហាញនៅក្នុង CAPE គួរមានទំនាក់ទំនងសមស្របទៅនឹងលទ្ធផល និងអនុសាសន៍សំខាន់ៗ ។ ប្រសិនបើមាន ការបង្ហាញព័ត៌មានខាងក្រៅ គួរដកចេញទៅដាក់នៅក្នុងឧបសម្ព័ន្ធគាំទ្រវិញ ។

១០០. លទ្ធផល និងអនុសាសន៍របស់ CAPE គួរកំណត់នូវជម្រើសផ្សេងៗសម្រាប់ថ្នាក់ដឹកនាំពិចារណា ព្រមទាំងកំណត់នូវវិធី និងមធ្យោបាយជាក់លាក់ ដែលតាមរយៈនេះ ថ្នាក់ដឹកនាំអាចលើកកម្ពស់ប្រសិទ្ធភាពអភិវឌ្ឍន៍នៃជំនួយរបស់ ADB ។ តាមលទ្ធភាពដែលអាចធ្វើបាន អនុសាសន៍របស់ CAPE គួរផ្តល់ឱ្យបានឆាប់រហ័ស និងទាន់ពេល ក្នុងដំណើរការវាយតម្លៃ ដើម្បីឱ្យអនុសាសន៍ទាំងនោះ អាចត្រូវបានបុគ្គលិកប្រតិបត្តិការយកមកវាយតម្លៃ និងយកមកប្រើប្រាស់បាន ។ អនុសាសន៍នានារបស់ CAPE ដែលស្នើរឱ្យ ADB ឬ DMCs ចាត់វិធានការណាមួយនោះ គួរលើកយកមកពិភាក្សានៅក្នុងការធ្វើបទបង្ហាញ ក្នុងពេលដំបូងស្តីពីលទ្ធផលរបស់ CAPE និងត្រូវធ្វើការគូសបញ្ជាក់ផងដែរ នៅពេលដែលរបាយការណ៍ពង្រាងត្រូវបានផ្ញើរជូនរដ្ឋាភិបាលដើម្បីសុំសេចក្តីអត្ថាធិប្បាយ ។ បន្ទាប់ពីពង្រាងរបស់ CAPE ត្រូវបានចែកផ្សាយដើម្បីសុំសេចក្តីអត្ថាធិប្បាយ និងបានធ្វើការកែសម្រួលសមស្របនៅក្នុងរបាយការណ៍នោះរួចមក កិច្ចប្រជុំជាលើកទីពីរ គួរធ្វើឡើងជាមួយបុគ្គលិកប្រតិបត្តិការជាន់ខ្ពស់របស់ ADB ដើម្បីពិភាក្សាអំពីអនុសាសន៍ទាំងនោះ ។ កិច្ចប្រជុំនេះ នឹងអាចឱ្យថ្នាក់ដឹកនាំ និងបុគ្គលិកជាន់ខ្ពស់នៃអនុសាសន៍របស់ CAPE មានការយោគយល់គ្នាបន្ថែមទៀត ហើយសង្ឃឹមថា អាចទទួលយកបាននូវអនុសាសន៍ទាំងនោះ ។

## ង. ការរៀបចំកាលវិភាគវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស និងការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសមុន

១០១. គេត្រូវតែធ្វើផែនការ CAPE ទុកជាមុនក្នុងរយៈពេលប្រហែលជាពីរឆ្នាំ មុននឹងរៀបចំ CSP ថ្មីមួយ ប្រសិនបើគេត្រូវធ្វើឱ្យលទ្ធផលទាំងឡាយរបស់ CAP មានសុពលភាពអាចប្រើប្រាស់បាន នៅពេលដំណើរការរៀបចំ CSP នោះ កំពុងតែលូតលាស់ ។ CAPE គួរត្រូវបានរៀបចំ និងអាចឱ្យគេប្រើបាន ក្នុងរយៈពេលពី ៣ ទៅ ៩ ខែមុននឹងមានការពិភាក្សារបស់ក្រុមប្រឹក្សាភិបាលទៅលើ CSP ដែលបានធ្វើផែនការរួចហើយ ។ ការរៀបចំ

ជាមុននេះ នឹងផ្តល់កាលានុវត្តិភាពគ្រប់គ្រាន់ដើម្បីធ្វើឱ្យមានទំនាក់ទំនងកាន់ឱ្យតែស្និទ្ធស្នាលរវាងក្រុម CAPE និងក្រុម CSP ប្រចាំប្រទេស ។ ដោយមានការប្រឹក្សាយោបល់ពីនាយកដ្ឋាន ប្រតិបត្តិការថ្នាក់ដឹកនាំ នឹងធ្វើការកំណត់ថាតើប្រទេសណាខ្លះ ដែលនឹងត្រូវធ្វើផែនការ CSP ថ្មី ហើយ OED នឹងរៀបចំកាលវិភាគមានកំណត់ពេលទៅលើ CAPEs សម្រាប់ពេលអនាគត ដែលបន្ទាប់មក នឹងត្រូវបានគេបង្ហាញនៅក្នុងផែនការការងារប្រចាំឆ្នាំរបស់ OED ។

១០២. ពេលពិចារណាទៅលើកំហិតនៃបុគ្គលិក និងធនធានផ្សេងៗទៀត គេប្រហែលជាមិនអាចរៀបចំ CAPEs សម្រាប់ប្រទេសទាំងអស់ដែលកំពុងតែរៀបចំ CSPs ថ្មីនោះទេ ។ នៅក្នុងការជ្រើសរើសករណីតាមប្រទេសនីមួយៗដើម្បី CAPE គេតែងតែគិតទៅលើទំហំ និងសារៈសំខាន់នៃ CAP រយៈពេលដែល CAPE ត្រូវបានគេរៀបចំសម្រាប់ប្រទេសនោះ និងលទ្ធភាពដែលថា CAPE ណាមួយនោះ នឹងនាំមកនូវការរកឃើញដែលមានអត្ថប្រយោជន៍ធំធេង ។

១០៣. នៅក្នុងបណ្តាប្រទេសដែលមានផលប័ត្រតូចល្មម ហើយចំពោះទីណាដែលមានសន្និធិធនធានគ្រប់គ្រាន់សម្រាប់វាយតម្លៃដោយខ្លួនឯង និងដោយឯករាជ្យទៅលើគម្រោង កម្មវិធី និង TA គេគួរធ្វើការវាយតម្លៃទៅលើការអនុវត្តជំនួយប្រចាំប្រទេសនៅក្នុងវិស័យ និងប្រធានបទសំខាន់ៗក្នុងអំឡុងពេលនៃ CAPE នោះ ។ ទោះជាយ៉ាងណាក៏ដោយ សម្រាប់ប្រទេសអ្នកខ្ចីសំខាន់ៗដែលមានកម្មវិធីជំនួយធំៗ និងស្មុគស្មាញបែបនេះ ចាំបាច់ត្រូវធ្វើការសិក្សាត្រៀមដើម្បីរៀបចំ CAPE ដែលត្រូវអនុវត្តតាមវិធីសាស្ត្រស្រដៀងគ្នាទៅនឹងវិធីសាស្ត្រដូចដែលបានរៀបរាប់គោលៗសម្រាប់ CAPEs ដែរ ។ ការសិក្សាត្រៀមបែបនេះ មានដូចជា :

(i) **ការវាយតម្លៃកម្មវិធីជំនួយតាមវិស័យ** ការវាយតម្លៃនេះ មានភាពប្រហាក់ប្រហែលគ្នានឹងការវាយតម្លៃរបស់ CAPE ដែរ ប៉ុន្តែការវាយតម្លៃនេះ ធ្វើឡើងតែទៅលើវិស័យតន្លឹះៗដែលមានការជាប់ពាក់ព័ន្ធរបស់ ADB តែប៉ុណ្ណោះ ។ វិស័យសំខាន់ៗមួយចំនួនតូច អាចលើកយកមកពិនិត្យដាច់ដោយឡែក ដើម្បីទុកជាការចាប់ផ្តើមឆ្ពោះទៅរកការអនុវត្ត CAPE ក្នុងទ្រង់ទ្រាយធំ ។

(ii) **ការវាយតម្លៃផលប៉ះពាល់** ការសិក្សាពិសេសៗទៅលើផលប៉ះពាល់យោងតាមប្រភេទនៃប្រតិបត្តិការរបស់ ADB អាចធ្វើឡើងមុន CAPE ។ ការសិក្សានេះ ពិតជាអាចទៅរួច ប្រសិនបើការវាយតម្លៃផលប៉ះពាល់តម្រូវឱ្យមាន ដូចជា ការអង្កេតក្នុងទ្រង់ទ្រាយធំ និងផ្លូវការ ឬការអង្កេតទៅលើភាពទទួលបានអត្ថប្រយោជន៍នៅតាមតំបន់គម្រោងជាច្រើន ។

(iii) **ការសិក្សាវាយតម្លៃពិសេស** ប្រទេសជាច្រើន អាចត្រូវដាក់បញ្ចូលទៅក្នុងការសិក្សាវាយតម្លៃពិសេសដោយសិក្សាទៅលើប្រភេទជាក់លាក់នៃលិខិតុបករណ៍ជំនួយ ឬគំនិតផ្តួចផ្តើមក្នុងប្រធានបទនានា ដើម្បីបង្កើននូវមូលដ្ឋានចំណេះដឹងវាយតម្លៃជាក់លាក់សម្រាប់ប្រទេស ក្នុងគោលបំណងទុកប្រើថ្ងៃក្រោយនៅក្នុង CAPE ។

១០៤. ការកំណត់ពេលវេលាសម្រាប់ CAPE ក៏នឹងត្រូវលើកយកមកធ្វើការពិចារណាផងដែរដូចគ្នាទៅនឹងការការកំណត់ពេលវេលាសម្រាប់ PPERs ដែរ ដែល PPERs មួយចំនួនខុសៗគ្នា អាចត្រូវបានគេកំណត់នៅក្នុងប្រទេសមួយ មុន CAPE ។

## ច. ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសនៅក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិកដែលមានផលប័ត្រតូច

១០៥. មានប្រទេសមួយចំនួនដែល កន្លងមក ADB មានតួនាទីតិចតួចប៉ុណ្ណោះក្នុងការចូលរួម ។ នៅក្នុងករណីបែបនេះ គេប្រហែលជាមិនអាចធានាថា នឹងមាន CAPE មួយពេញលេញសម្រាប់ប្រទេសទាំងនោះឡើយ ។

១០៦. ប្រសិនបើ CAPE មួយត្រូវបានចាប់ផ្តើមនៅក្នុងប្រទេស DMC ដែលមានផលប័ត្រជំនួយតូចមួយ វិធីសាស្ត្រ វិធី និងរចនាសម្ព័ន្ធធ្វើរបាយការណ៍ដដែល នឹងត្រូវយកមកប្រើដូចដែលបានរៀបរាប់លម្អិតពីខាងលើ ប៉ុន្តែរបាយការណ៍របស់ CAPE ខ្លីជាង (ពោលគឺ មិនលើសពី ៣៥ ទំព័រ) ហើយកម្រិតនៃធនធានដែលបានបែងចែកសម្រាប់ភារៈកិច្ចនោះ នឹងឆ្លុះបញ្ចាំងឱ្យឃើញពីទំហំវាយតម្លៃដែលមានទំហំតូចជាងដែរ ។

ឧបសម្ព័ន្ធ ១
នៅក្នុងករណីបែបនេះ បេសកកម្មសិក្សាស្វែងយល់ និងបេសកកម្មចុះពិនិត្យដល់ទីកន្លែង អាចនឹងត្រូវច្របាច់បញ្ចូលគ្នា ហើយរយៈពេលប្រមាណជាពី ៦ ខែទៅ ៩ ខែ នឹងត្រូវលៃទុកដើម្បីរៀបចំ CAPE ។

១០៧. ប្រសិនបើ CAPE ត្រូវធ្វើនៅក្នុងប្រទេសដែល ADB មានផលប័ត្រជំនួយតូច ប្រហែលពុំចាំបាច់ធ្វើសេចក្តីសនិដ្ឋានអំពីការងារ ធៀបនឹងគំរូនៃសេវាកម្ម TA ការងារសេដ្ឋកិច្ច និងការងារតាមវិស័យ និងការពិភាក្សាគោលនយោបាយឡើយ ។ ចំពោះប្រទេសណាដែល ADB មានផលប័ត្រយ៉ាងតូចនោះ ជាការប្រសើរ គួរត្រួតពិនិត្យទៅលើលទ្ធផលនៃជំនួយកម្ចី និងមិនមែនកម្ចីទាំងអស់ដែល ADB បានផ្តល់ក្នុងមួយទសវត្សរ៍កន្លងមក ដោយរាប់ទាំងប្រតិបត្តិការកំពុងបន្ត អមដោយលទ្ធផលដែលកម្លាំងចលករកម្មវិធីធំ និងតូចរបស់ខ្លួនបានរៀបចំ ។ អត្ថប្រយោជន៍នៃការគ្របដណ្តប់ទៅលើជំនួយកម្ចី និងមិនមែនកម្ចីទាំងអស់នេះគឺ យើងអាចទទួលបានរូបភាពកាន់តែច្បាស់លាស់អំពីវិភាគទានរបស់ ADB ដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ រួមទាំងនៅក្នុងផ្នែកទាំងឡាយណាដែល ADB មានតួនាទីចូលរួមតិចតួចនៅក្នុងកម្មវិធីជំនួយទាំងអស់នោះ ។

## ឆ. ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសបន្តបន្ទាប់ទៀត

១០៨. ខណៈដែលមានការយកចិត្តទុកដាក់ទៅលើលទ្ធផលនៃជំនួយអភិវឌ្ឍន៍ក្នុងទសវត្សរ៍កន្លងមក CAPE លើកដំបូងដែលត្រូវបានរៀបចំសម្រាប់ DMC ណាមួយ ត្រូវតែតាមដានការវិវត្តទាំងអស់នៃជំនួយរបស់ ADB និងតាមដានទំនាក់ទំនងរវាងបរិបទប្រទេស អាទិភាព និងយុទ្ធសាស្ត្រជាតិ ចាប់តាំងពីការចាប់ផ្តើមនៃជំនួយរបស់ ADB ។ ចំពោះ CAPEs ក្រោយៗទៀត មិនចាំបាច់មានការត្រួតពិនិត្យទៅលើជំនួយរបស់ ADB ដូចដែលធ្លាប់ធ្វើកន្លងមកនោះទេ ។ CAPEs ក្រោយៗទៀត គួរអនុវត្តតាមបទដ្ឋានគោលការណ៍ណែនាំរបស់ CAPE ប៉ុន្តែ CAPEs នេះ ក៏គួរតែបញ្ចូលនូវសេចក្តីសង្ខេបអំពីលទ្ធផល និងអនុសាសន៍សំខាន់ៗនៃ CAPE លើកមុន ហើយក៏គួរធ្វើការវាយតម្លៃពីកម្រិតដែលលទ្ធផល និងអនុសាសន៍ទាំងនោះ ត្រូវបានយកមកប្រើនៅក្នុង CSPs ដែលបានលេចជារូបរាងឡើងក្រោយ CAPE នោះ ។

១០៩. CAPEs លើកក្រោយៗ នឹងធ្វើការត្រួតពិនិត្យទៅលើការអនុវត្តកម្មវិធីជំនួយរបស់ ADB ក្នុងអំឡុងទសវត្សរ៍កាលពីអតីតកាល ក៏ប៉ុន្តែសង្កត់ធ្ងន់ទៅលើរយៈពេលដោយហេតុថា CAPE លើកចុងក្រោយនោះ បានបញ្ចប់រួចរាល់ហើយ ។ ជំនួយជាកម្ចី និងមិនមែនកម្ចីនៅក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ ភាគច្រើននៅមានប្រតិបត្តិការរបស់វាដែលកំពុងតែដំណើរការនៅឡើយ ឬទើបតែបញ្ចប់នៅពេលថ្មីៗនេះ ។ នៅក្នុងករណីបែបនេះ CAPE នឹងប្រើប្រាស់ការវាយតម្លៃរបស់ខ្លួនបានមកពីការរួមចំណែកពី ADB ដែលនាំឱ្យសម្រេចបានលទ្ធផលអភិវឌ្ឍន៍ ជាមូលដ្ឋានសម្រាប់ទិន្នផលដែលបានប៉ាន់ស្មានទុក លទ្ធផល និងផលប៉ះពាល់នៃប្រតិបត្តិការដែលកំពុងដំណើរការ ហើយ CAPE នឹងកំណត់នូវកត្តាសំខាន់ៗដែលទំនងជាមានឥទ្ធិពលទៅលើការអនុវត្តកម្មវិធី ។

១១០. ប្រសិនបើប្រតិបត្តិការដែលកំពុងដំណើរការក្នុងចំនួនដ៏ច្រើន មានឥទ្ធពលដ៏លើសលុបទៅលើផលប័ត្រជំនួយរបស់ CAPE ក្រោយៗ គេមិនអាចធ្វើការវាយតម្លៃលើប្រសិទ្ធផលនៃកម្មវិធីបានទេ ។ នៅក្នុងករណីបែបនេះ លក្ខណៈវិនិច្ឆ័យប្រសិទ្ធផល នឹងត្រូវដកចេញពីការកម្រិតគុណភាពវាយតម្លៃតាមវិស័យ និងការវាយតម្លៃលទ្ធផលការងារទាំងអស់ ។ ភាពជាប់ទាក់ទង ប្រសិទ្ធភាព និរន្តរភាព និងផលប៉ះពាល់នៃកម្មវិធីនៅក្នុងវិស័យផ្សេងៗគ្នា ក៏នៅតែត្រូវគេវាយតម្លៃដែរ ប៉ុន្តែភាគច្រើនត្រូវបានគេវាយតម្លៃទៅលើមូលដ្ឋានលទ្ធផលដែលមានការប៉ាន់ស្មានទុក (ជាជាងលទ្ធផលជាក់ស្តែង) ។

១១១. ដោយហេតុថា CAPE ក្រោយៗ ផ្អែកទៅលើលទ្ធផលរបស់ CAPE មុនៗ តម្រូវការពេលវេលា និងធនធានដើម្បីបំពេញភារៈកិច្ចទាំងនេះមានកាន់តែតិច ។ ដោយលទ្ធផល គួរត្រូវរាយការណ៍ក្នុងទម្រង់ស្រដៀងគ្នាទៅនឹង CAPE លើកដំបូងក៏ដោយ ក៏ CAPE ក្រោយៗនេះ គួរធ្វើបានខ្លីជាងមុន ។

ឧបសម្ព័ន្ធ ១

## គំរូរបាយការណ៍

១. នេះគឺជាគំរូសម្រាប់រៀបចំរបាយការណ៍ទាក់ទងនឹងរចនាសម្ព័ន្ធ និងមាតិកានៃការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស (CAPE) ។ គំរូនេះមានភាពស្របគ្នាជាមួយនឹងការណែនាំដែលមាននៅក្នុងជំពូកមាតិកា និងចំណងជើងដូចដែលបានផ្តល់ជូននៅក្នុងគោលការណ៍ណែនាំ ។ ចំនួនទំព័រត្រូវបានផ្តល់ទុកសម្រាប់តែជាការណែនាំប៉ុណ្ណោះ ។ ខណៈដែលចំណងជើងជំពូកសំខាន់ៗ ត្រូវដាក់នៅក្នុងគោលការណ៍ណែនាំ មាតិកានៃជំពូកនីមួយៗគួរត្រូវបានចងក្រងជារចនាសម្ព័ន្ធដើម្បីបង្ហាញភស្តុតាង និងលទ្ធផលឱ្យបានសមហេតុផល មានភាពច្បាស់លាស់ និងទាក់ទងគ្នា ។

**ពាក្យកាត់**

**សេចក្តីសង្ខេប** (៥ ទំព័រ)

**មាតិកា**

I. **សេចក្តីផ្តើម** (៣ ទំព័រ)

- ក. គោលដៅ និងវត្ថុបំណងរបស់ CAPE
- ខ. ការវាយតម្លៃប្រសិទ្ធភាពនៃការអភិវឌ្ឍ : ការប្រើប្រាស់វិធីសាស្ត្ររបស់ CAPE

II. **បរិបទអភិវឌ្ឍន៍ និងអាទិភាពរបស់រដ្ឋាភិបាល** (៤ ទំព័រ)

- ក. ស្ថានភាពនយោបាយ សេដ្ឋកិច្ច និងសង្គមដែលកំពុងវិវត្តន៍ សម្រាប់ការអភិវឌ្ឍ
- ខ. អាទិភាព និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់រដ្ឋាភិបាល

III. **យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី** (៥ ទំព័រ)

- ក. ការវិវត្តនៃយុទ្ធសាស្ត្រ និងកម្មវិធីជំនួយប្រចាំប្រទេសរបស់ធនាគារអភិវឌ្ឍន៍អាស៊ី
- ខ. លទ្ធផលរំពឹងទុកនៃកម្លាំងចលករកម្មវិធីសំខាន់ៗ
- គ. ការកំណត់ស្ថានភាពនៃជំនួយរបស់ ADB ប្រៀបធៀបជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀត

IV. **ការអនុវត្តកម្មវិធី** (៥ ទំព័រ)

- ក. និន្នាការនៅក្នុងការអនុវត្តកម្មវិធីកម្ចី និងមិនមែនកម្ចី
- ខ. សង្គតិភាពរវាងកម្មវិធីដែលបានគ្រោងទុក និងសម្រេចបាន
- គ. កត្តាជះឥទ្ធិពលដល់ការអនុវត្ត

V. **លទ្ធផលសម្រេចបាន និងកត្តាជះឥទ្ធិពលដល់លទ្ធផល** (២០ ទំព័រ)

- ក. ការរួមចំណែករបស់កម្មវិធីដែលនាំឱ្យមានលទ្ធផល និងផលប៉ះពាល់តាមវិស័យសំខាន់ៗ
- ខ. ការរួមចំណែករបស់កម្មវិធីដែលនាំឱ្យមានលទ្ធផល និងផលប៉ះពាល់ តាមមូលដ្ឋានគ្រឹះរបស់ ADB
- គ. ការរួមចំណែករបស់កម្មវិធីដែលនាំឱ្យមានលទ្ធផល និងផលប៉ះពាល់ តាមប្រធានបទ
- ឃ. កត្តាជះឥទ្ធិពលដល់ការសម្រេចបានលទ្ធផល

ង. ការកំណត់លទ្ធផល

VI. **ចំណាត់ថ្នាក់ និងការវាយតម្លៃលទ្ធផលការងារ** (៣ ទំព័រ)

ក. ការងារតាមវិស័យ

ខ. ការងារទូទាំងប្រទេស

គ. ការវាយតម្លៃសរុប

VII. **លទ្ធផលសំខាន់ៗ សេចក្តីសន្និដ្ឋាន និងអនុសាសន៍** (៥ ទំព័រ)

ក. លទ្ធផលសំខាន់ៗ

ខ. បញ្ហាប្រឈម និងកាលានុវត្តន៍ភាពនៅពេលអនាគត

គ. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

**សេចក្តីសន្និដ្ឋាន**[៦]

១. បញ្ជីគម្រោង និងជំនួយបច្ចេកទេស

២. ការវិវត្តផ្នែកនយោបាយ សេដ្ឋកិច្ច និងសង្គមរបស់ប្រទេស

៣. សេចក្តីសង្ខេបអំពីផែនការអភិវឌ្ឍជាតិ និងយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្ររបស់រដ្ឋាភិបាល

៤. សេចក្តីសង្ខេបអំពីយុទ្ធសាស្ត្រ និងផែនការវិវត្តប្រចាំប្រទេសរបស់ ADB

៥. និន្នាការរបស់ផលប័ត្រក្នុងអំឡុងពេលវាយតម្លៃ

៦. សេចក្តីសង្ខេបអំពីលទ្ធផលសំខាន់ៗរបស់គម្រោង និងការវាយតម្លៃកម្មវិធី និង TA

៧. ការវាយតម្លៃតាមវិស័យ[៧]

៨. ការវាយតម្លៃតាមប្រធានបទ

៩. លទ្ធផលពិសេសនៃការសិក្សាជាក់លាក់ទៅលើប្រទេស[៨]

[៦] គ្រប់ឧបសម្ព័ន្ធទាំងអស់ មិនសូវចាំបាច់ទេ ហើយឧបសម្ព័ន្ធ ដូចដែលមានភ្ជាប់មកខាងក្រោមនេះ គឺគ្រាន់តែជាគំរូមួយប្រភេទដែលបានដាក់បញ្ចូលនៅក្នុង CAPEs លើកមុនៗតែប៉ុណ្ណោះ ។ ឧបសម្ព័ន្ធរបស់ CAPEs មានមុខងារជាអ្នកផ្តល់នូវភស្តុតាង និងព័ត៌មានសារពើភារលម្អិតបន្ថែមទៀតឱ្យបានច្រើនជាងនៅក្នុងរបាយការណ៍ស្នូលតែប៉ុណ្ណោះ ។ ការស្រាវជ្រាវ និងលទ្ធផលរបស់ CAPE នៅក្នុងប្រធានបទពិសេសៗ ជាក់លាក់តាមប្រទេស ក៏អាចដាក់បញ្ចូលនៅឧបសម្ព័ន្ធបានដែរ ។

[៧] ជាទូទៅ ការវាយតម្លៃលម្អិតតាមវិស័យ គ្របដណ្តប់ទៅលើបរិការតាមវិស័យ យុទ្ធសាស្ត្រក្នុងវិស័យនានារបស់រដ្ឋាភិបាល, កម្មវិធីជំនួយតាមវិស័យរបស់ ADB ការអនុវត្តនូវកម្មវិធីជំនួយរបស់ ADB នៅតាមវិស័យនីមួយៗ និងលទ្ធផលនៃជំនួយ ក្នុងន័យពិនិត្យមើលទៅលើទិន្នផល លទ្ធផល និងផលប៉ះពាល់ដែលបានឯកភាព ។ ការរួមចំណែកកម្មវិធីជំនួយតាមវិស័យចំពោះមូលដ្ឋានគ្រឹះរបស់ ADB និងចំពោះវត្ថុបំណងតាមប្រធានបទដែលបានជ្រើសរើស ក៏ត្រូវបានត្រួតពិនិត្យដែរ ។ ចំណាត់ថ្នាក់ និងការវាយតម្លៃការងារនៃការរួមចំណែករបស់ ADB នៅក្នុងវិស័យនីមួយៗ ក៏ត្រូវបានដាក់បញ្ចូលដែរ ។

[៨] ឧទាហរណ៍នៃលទ្ធផលនេះ គឺឧបសម្ព័ន្ធស្តីពីភាពជាដៃគូរវាង ADB-NGO នៅក្នុង CAPE នៃប្រទេសបង់ក្លាដេស ។

ឧបសម្ព័ន្ធ ២

# ចំណាត់ថ្នាក់ និងការវាយតម្លៃលទ្ធផលការងារ

## ក. សេចក្តីផ្តើម

១. ការវាយតម្លៃការងាររបស់ CAPE (ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស) បានឆ្លុះបញ្ចាំងឱ្យឃើញពីវិធីសាស្ត្រដែលប្រើក្នុង CAPE ខ្លួនឯង ។ CAPE រៀបចំការវាយតម្លៃ និងចំណាត់ថ្នាក់វាយតម្លៃប្រតិបត្តិការរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅក្នុងវិស័យសំខាន់ៗ (ពោលគឺតាមវិធីពីក្រោមឡើងលើ) ហើយ CAPE ក៏វាយតម្លៃ និងចំណាត់ថ្នាក់វាយតម្លៃទៅលើស្ថានភាពទាំងអស់ដែល ADB កំពុងស្ថិតនៅ និងទៅលើការរួមចំណែកទាំងអស់របស់ ADB ដែលនាំឱ្យសម្រេចបានលទ្ធផលអភិវឌ្ឍន៍នៅក្នុងកម្រិតប្រទេស ពោលគឺវិធីពីលើចុះក្រោម ។ បន្ទាប់មក ការបញ្ចូលវិធីចំណាត់ថ្នាក់ពីក្រោមឡើងលើ និងពីលើចុះក្រោម ត្រូវបានធ្វើឡើងដើម្បីឈានដល់ការវាយតម្លៃការងារសរុប ។

២. វិធីពីក្រោមឡើងលើដែលប្រើដើម្បីកំណត់ចំណាត់ថ្នាក់វាយតម្លៃសរុប គឺដើម្បីវាយតម្លៃដាច់ដោយឡែក និងដើម្បីរៀបជាលំដាប់ថ្នាក់សម្រាប់វិស័យនីមួយៗនូវលក្ខណៈវិនិច្ឆ័យស្នូលទាំងប្រាំ (មូលដ្ឋានគ្រឹះនៃការវាយតម្លៃ) : ភាពទាក់ទង ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព និងផលប៉ះពាល់ ។ វិធីពីលើចុះក្រោម គឺដើម្បីវាយតម្លៃទៅលើការដាក់ប្រទេសស្ថិតនៅក្នុងស្ថានភាពណាមួយ និងទៅលើការរួមចំណែកដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍សម្រាប់កម្មវិធីទូទាំងប្រទេស ។ លក្ខណៈវិនិច្ឆ័យនីមួយៗនៅក្នុងវិស័យនីមួយៗ ត្រូវបានកំណត់ជាលេខគត់ ។ បន្ទាប់មក ការកំណត់ចំណាត់ថ្នាក់ទាំងនេះនឹងត្រូវបូកបញ្ចូលគ្នាតាមវិស័យនីមួយៗ លើគ្រប់វិស័យទាំងអស់ និងតាមលក្ខណៈវិនិច្ឆ័យកម្រិត ប្រទេសចំនួនពីរ ។ ពិន្ទុវាយតម្លៃដែលទទួលបានខុសគ្នាពីលក្ខណៈវិនិច្ឆ័យមួយទៅលក្ខណៈវិនិច្ឆ័យមួយទៀត ដោយបានឆ្លុះបញ្ចាំងពីការរួមចំណែករបស់វិស័យនីមួយៗ នៅក្នុងកិច្ចដំណើរការអភិវឌ្ឍទាំងអស់ ។ ជាចុងក្រោយ ពិន្ទុថេរដែលគេបានកំណត់ ត្រូវបានប្រើដើម្បីផ្តល់មូលវិចារណ៍សមស្រប (ជោគជ័យបំផុត ជោគជ័យ ជោគជ័យមួយផ្នែក មិនជោគជ័យ) ដល់ចំណាត់ថ្នាក់វាយតម្លៃជាលេខរួមគ្នា ។ អ្នក វាយតម្លៃ ក៏អាចដាក់បញ្ចូលនូវលក្ខណៈវិនិច្ឆ័យបន្ទាប់បន្សំជាក់លាក់សម្រាប់ប្រទេស និងផ្តល់ពិន្ទុផ្សេងៗគ្នា ដែលពិន្ទុទាំងនោះត្រូវបានប្រើ ដើម្បីបូកសរុបលក្ខណៈវិនិច្ឆ័យទាំងអស់ ឱ្យតែការផ្តល់ពិន្ទុផ្សេងៗគ្នានោះ មានហេតុផលសមស្រប និងបានរាយការណ៍នៅក្នុងរបាយការណ៍លម្អិត[១] របស់ CAPE ឬក៏មានការព្រមព្រៀមឱ្យមានការកែសម្រួលទៅលើរបាយការណ៍លម្អិតនោះនៅពេលក្រោយៗទៀត ។

## ខ. ការចាត់ចំណាត់ថ្នាក់ការងារក្នុងវិស័យ តាមវិធីពីក្រោមឡើងលើ

៣. ដោយហេតុថាកម្មវិធីជំនួយរបស់ ADB ត្រូវបានរៀបចំទៅតាមវិស័យតាំងពីដើមរៀងមក ការអនុវត្តកម្មវិធី នឹងត្រូវបានវាយតម្លៃមុនគេទៅលើវិស័យចម្បងនីមួយៗ ដែលទទួលបានការគាំទ្រពី ADB ។ លក្ខណៈវិនិច្ឆ័យវាយតម្លៃ ដូចជាភាពទាក់ទង ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព និងផលប៉ះពាល់ ត្រូវបានផ្តល់ជាចំណាត់ថ្នាក់យោងតាមបទដ្ឋានមួយដែលមាន ៤ ពិន្ទុ ។ ចំពោះលក្ខណៈវិនិច្ឆ័យណាទាក់ទងទៅនឹងការសម្រេចបាននូវលកទ្ធផលអភិវឌ្ឍន៍ (ពោលគឺ : ប្រសិទ្ធភាព និរន្តរភាព និងផលប៉ះពាល់) នឹងទទួលបានពិន្ទុគុណនឹង ២ ដើម្បីសង្កត់ធ្ងន់ទៅលើសារៈសំខាន់ដែល ADB បានព្រមព្រៀងក្នុងការរួមចំណែកយូរអង្វែងដើម្បីទទួលបានលទ្ធផលកាត់បន្ថយភាពក្រីក្រ ។ លក្ខណៈវិនិច្ឆ័យពីការចាត់ចំណាត់ថ្នាក់តាមវិស័យ និងប្រព័ន្ធដាក់ពិន្ទុ មានពន្យល់នៅខាងក្រោម ។

---

[១] របាយការណ៍ទស្សនទានសង្ខេបមួយដែលគូសបញ្ជាក់ពីវិធី និងបញ្ហាចម្បងៗដែលត្រូវដោះស្រាយនៅក្នុងការវាយតម្លៃ ត្រូវបានរៀបចំដោយប្រធានក្រុមបេសកកម្ម និងដោយមានការឯកភាពពី អគ្គនាយករបស់ OED ។

៤. **ភាពទាក់ទង** ភាពទាក់ទងនេះ សំដៅលើ (i) ថាតើការផ្តោតយកចិត្តទុកដាក់នៃយុទ្ធសាស្ត្រ និងកម្មវិធីតាមវិស័យនានារបស់ ADB មួយផ្នែក មានភាពស្របគ្នាជាមួយនឹងបេសកកម្មរបស់ ADB ដែរ ឬទេ ហើយមួយផ្នែកទៀត ថាតើការយកចិត្តទុកដាក់នោះ ស្របគ្នាជាមួយនឹងកាលៈទេសៈសេដ្ឋកិច្ចសំខាន់ៗដែលកំពុងតែវិវត្តន៍ អាទិភាពនានា និងសមត្ថភាពស្រូបយកនៃប្រទេសកំពុងអភិវឌ្ឍន៍ជាសមាជិក (DMC) ដែរឬទេ (ii) កម្រិតដែលការគាំទ្រតាមវិស័យនីមួយៗ ADB ស៊ីសង្វាក់គ្នាជាមួយនឹងគោលនយោបាយ និងយុទ្ធសាស្ត្រតាមវិស័យ (iii) កម្រិតដែលការគាំទ្រតាមវិស័យនានារបស់ ADB មានភាពស្របគ្នាជាមួយនឹងឧត្តមភាពជំនួយដោយប្រៀបធៀប ដែលបានវិវត្តន៍របស់ ADB (iv) កម្រិតដែលអន្តរាគមន៍នានានៅតាមវិស័យរបស់ ADB ដែលមានចំនួនទាបបំផុត ត្រូវបានថ្លឹងថ្លែងតាមវត្ថុបំណងនានា ដោយមានការសម្រិតសម្រាំង និងការយកចិត្តទុកដាក់ និង (v) កម្រិតដែលជំនួយតាមវិស័យរបស់ ADB មានភាពស្របគ្នាជាមួយនឹងជំនួយរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ។ លក្ខណៈវិនិច្ឆ័យបន្ទាប់បន្សំខាងលើ មានគោលបំណងផ្តោតទៅលើវិសាលភាពនៃភាពស៊ីគ្នា ការឯកភាពគ្នា ភាពទូលំទូលាយ ការឆ្លើយតប ការកំណត់ស្ថានភាព និងភាពស៊ីសង្វាក់គ្នានៃកម្មវិធីជំនួយតាមវិស័យនានារបស់ ADB ។ ការចាត់ចំណាត់ថ្នាក់នានា នឹងត្រូវបានធ្វើឡើងយោងតាមភាពទាក់ទងនៃយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB សម្រាប់វិស័យនីមួយៗដូចខាងក្រោម :

(i) **ទាក់ទងខ្លាំង** (៣ ពិន្ទុ) យុទ្ធសាស្ត្រ និងកម្មវិធីរបស់ ADB ត្រូវបានចាត់ទុកថា មានភាពទាក់ទងទាំងស្រុងទៅនឹងបញ្ហាប្រឈម និងកាលានុវត្តន៍ភាពចំពោះការអភិវឌ្ឍតាមវិស័យសំខាន់ៗ ជាការប្រគល់ឱ្យប្រទេសជាអ្នកទទួលខុសត្រូវ ស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រ និងអាទិភាពតាមវិស័យ ផ្តោតលើគោលដៅ មានតុល្យភាព មានសមត្ថភាពគ្រប់គ្រាន់ក្នុងការសម្រេចលទ្ធផល និងមានភាពសុខដុមជាមួយនឹងជំនួយដែល ផ្តល់ដោយដៃគូអភិវឌ្ឍន៍ផ្សេងទៀត (DPs) ។

(ii) **ទាក់ទង** (២ ពិន្ទុ) យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB ត្រូវបានចាត់ទុកថា មានភាពទាក់ទង តែមិនទាំងស្រុងទេ ទៅនឹងបញ្ហាប្រឈម និងកាលានុវត្តន៍ភាពចំពោះការអភិវឌ្ឍតាមវិស័យសំខាន់ៗ ជាការប្រគល់ឱ្យប្រទេសជាអ្នកទទួលខុសត្រូវ ស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រ និងអាទិភាពតាមវិស័យ ផ្តោតលើគោលដៅបានតិចតួច មានតុល្យភាពទូទៅ គ្រប់គ្រាន់ក្នុងការសម្រេចលទ្ធផល និងមានភាពសុខដុមជាមួយនឹង ជំនួយដែលផ្តល់ ដោយ DPs ផ្សេងទៀត ។

(iii) **ទាក់ទងមួយផ្នែក** (១ ពិន្ទុ) យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ ADB ត្រូវបានចាត់ទុកថាមានភាពទាក់ទងមួយផ្នែក នៅពេលដែលយុទ្ធសាស្ត្រ និងកម្មវិធីទាំងនោះដោះស្រាយបានក្នុងកម្រិតតិចតួចបំផុតនូវបញ្ហាប្រឈម និងកាលានុវត្តន៍ភាព ចំពោះការអភិវឌ្ឍសំខាន់ៗ ដែល DMC ជួបប្រទះ ជាការប្រគល់ឱ្យប្រទេសជាអ្នកទទួលខុសត្រូវមួយផ្នែក ស្របគ្នាមួយផ្នែកជាមួយនឹងយុទ្ធសាស្ត្រ និងអាទិភាពតាមវិស័យ មិនមានតុល្យភាពគ្រប់គ្រាន់ មិនទទួលបានធនធានគ្រប់គ្រាន់នៅក្នុងផ្នែកមួយចំនួន និងមានសុខដុមក្នុងកម្រិតតិចបំផុតជាមួយនឹងជំនួយដែលផ្តល់ដោយ DPs ផ្សេងទៀត ។

(iv) **មិនទាក់ទង** (០ ពិន្ទុ) យុទ្ធសាស្ត្រ និងកម្មវិធី ត្រូវបានចាត់ទុកថាមិនជាប់ទាក់ទង ប្រសិនបើយុទ្ធសាស្ត្រ និងកម្មវិធីនោះ មិនត្រូវបានដោះស្រាយបញ្ហាប្រឈម និងកាលានុវត្តន៍ភាពតាមវិស័យសំខាន់ៗទេ មិនអាចដំណើរការបានដោយសារគ្មានប្រទេសជួយគាំទ្រ មិនស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រ និងអាទិភាពតាមវិស័យ មិនបានផ្តោតឱ្យចំគោលដៅ មិនទទួលបានធនធានគ្រប់គ្រាន់បើប្រៀបធៀបជាមួយនឹងវត្ថុបំណងតាមវិស័យ និងគ្មានភាពសុខដុមជាមួយនឹងជំនួយដែលផ្តល់ដោយ DPs ផ្សេងទៀត ។

(v) អ្នកវាយតម្លៃ នឹងផ្តល់នូវសនិទានភាពសម្រាប់ការដាក់ពិន្ទុទៅលើភាពទាក់ទងនៅក្នុងវិស័យនីមួយៗ ។ សនិទានភាពនេះ ក៏អាចដកបញ្ចូលកត្តាជាក់លាក់របស់ប្រទេស ដែលជះឥទ្ធិពលដល់ការដាក់ពិន្ទុលើភាពទាក់ទងនេះដែរ ។[២]

---

[២] ឧទាហរណ៍ វាអាចថា ដូចជាការជំរុញសមាហរកម្មចូលក្នុងតំបន់ (ឬ លក្ខណៈវិនិច្ឆ័យជាក់លាក់សម្រាប់ប្រទេសផ្សេងទៀត) មានសារៈសំខាន់បំផុតនៅក្នុងវិស័យណាមួយនោះរបស់ DMC ។ នៅក្នុងករណីបែបនេះ ទាំងលក្ខណៈវិនិច្ឆ័យ និងការដាក់ពិន្ទុលើភាពជាប់ទាក់ទង អាចធ្វើការកែតម្រូវបាន ដើម្បីលើកយកអាទិភាពជាក់លាក់សម្រាប់ប្រទេសនេះធ្វើការពិចារណា ។

៥. **ប្រសិទ្ធភាព** ប្រសិទ្ធភាពនៃជំនួយជាកម្ចី និងមិនមែនជាកម្ចី សំដៅថា តើយុទ្ធសាស្ត្រតាមវិស័យ និងកម្មវិធីជំនួយ ទទួលបានជោគជ័យកម្រិតណា ក្នុងការរួមចំណែកសម្រេចនូវទិន្នផល និងលទ្ធផលនៅក្នុងការគាំទ្រគោលដៅ និងវត្ថុបំណងអភិវឌ្ឍន៍ក្នុងវិស័យនានារបស់ DMC នោះ ។ ប្រសិទ្ធភាពនេះ ក៏សំដៅទៅលើ កម្រិតដែលលទ្ធផលកំណត់នៅក្នុងកម្មវិធីជំនួយប្រចាំប្រទេស សម្រេចបានជាលទ្ធផលជាក់ស្តែងដែរ ។ ជាមួយគ្នានេះដែរ ប្រសិទ្ធភាព ក៏សំដៅទៅលើការសម្រេចបាននូវលទ្ធផល ពោលគឺកម្រិតដែលទិន្នផលកំណត់សម្រាប់អន្តរាគមន៍គាំទ្រផ្សេងៗគ្នាទាំងជាអន្តរាគមន៍កម្ចី និងមិនមែនកម្ចីនៅក្រោម CAP សម្រាប់វិស័យនានា សម្រេចបានលទ្ធផលជាក់ស្តែង ។

(i) **ប្រសិទ្ធភាពខ្ពស់** (៦ ពិន្ទុ) ប្រសិទ្ធភាព ត្រូវបានវិនិច្ឆ័យថាមានប្រសិទ្ធភាពខ្ពស់ ប្រសិនបើកម្មវិធីជំនួយតាមវិស័យនានានោះសម្រេចបាន ទាំងស្រុងនូវវត្ថុបំណងរបស់ខ្លួន ជួយរួមចំណែកក្នុងការសម្រេចឱ្យបាននូវទិន្នផល និងលទ្ធផលសំខាន់ៗ និងអាចបង្ហាញពីការអនុវត្តដ៏ល្អនៅលើផ្នែកជាច្រើនទៀត ។

(ii) **ប្រសិទ្ធភាព** (៤ ពិន្ទុ) ប្រសិទ្ធភាព ត្រូវបានវិនិច្ឆ័យថាមានប្រសិទ្ធភាព ប្រសិនបើកម្មវិធីជំនួយតាមវិស័យនានា សម្រេចបាននូវវត្ថុបំណងរបស់ខ្លួន ប្រហែលជាបីភាគបួននៅក្នុងវិស័យណានោះ, ជួយរួមចំណែកមួយផ្នែកក្នុងការសម្រេចបាននូវទិន្នផល និងលទ្ធផលសំខាន់ៗ អាចបង្ហាញពីការអនុវត្តល្អៗបាន ១-២ ផ្នែក និងអាចមានចំណុចខ្វះខាតបន្តិចបន្តួច ។

(iii) **ប្រសិទ្ធភាពតិច** (២ ពិន្ទុ) ប្រសិទ្ធភាព ត្រូវបានវិនិច្ឆ័យថាមានប្រសិទ្ធភាពតិច ប្រសិនបើកម្មវិធីជំនួយតាមវិស័យនានាអាចសម្រេចបាននូវវត្ថុបំណង ទិន្នផល និងលទ្ធផលរបស់ខ្លួនរវាងពីពាក់កណ្តាល ដល់បីភាគបួន ។

(iv) **គ្មានប្រសិទ្ធភាព.** (០ ពិន្ទុ) ប្រសិទ្ធភាព ត្រូវបានវិនិច្ឆ័យថា គ្មានប្រសិទ្ធភាព ប្រសិនបើកម្មវិធីជំនួយតាមវិស័យនានា សម្រេចបាននូវវត្ថុបំណង ទិន្នផល និងលទ្ធផលរបស់ខ្លួនតិចជាងពាក់កណ្តាល ហើយមានកង្វះខាតច្រើន ។

(v) អ្នកវាយតម្លៃ នឹងផ្តល់នូវសនិទានភាពសម្រាប់ការដាក់ពិន្ទុដែលបានឱ្យទៅលើប្រសិទ្ធភាពតាមវិស័យនានា ។ សនិទានភាពនេះក៏អាចដាក់បញ្ចូល កត្តាជាក់លាក់របស់ប្រទេស ដែលជះឥទ្ធិពលដក់ការវាយតម្លៃនៃប្រសិទ្ធភាពនេះបានដែរ ។

៦. **ប្រសិទ្ធផល** (៣ ពិន្ទុ). ប្រសិទ្ធផលធ្វើការប្រៀបធៀបការសម្រេចគោលដៅ និងវត្ថុបំណងនៃកម្មវិធីជំនួយតាមវិស័យ ជាមួយនឹងការប្រើប្រាស់ធនធានជំនួយរបស់ ADB ។ ប្រសិទ្ធភាពនេះ អាចធ្វើការវាស់វែងបានដោយពិនិត្យមើលទៅលើកម្រិតដែលធនធានរបស់ ADB ដែលបានផ្តល់ឱ្យវិស័យនីមួយៗ បានត្រូវគេយកមកប្រើប្រាស់យ៉ាងល្អ ដូចជា (i) វិភាគទានសរុបនៃជំនួយរបស់ ADB ដែលនាំឱ្យមានវឌ្ឍនភាពសេដ្ឋកិច្ចសង្គមដល់មនុស្សគ្រប់រូប តាមរយៈការគាំទ្រដល់គោលនយោបាយតាមវិស័យសំខាន់ៗ និងកំណែទម្រង់ស្ថាប័ន (ii) អត្ថប្រយោជន៍ដោយផ្ទាល់ផ្នែកសេដ្ឋកិច្ចសរុបដែលទទួលបានពីជំនួយតាមវិស័យរបស់ ADB (iii) កម្រិតដែលអត្ថប្រយោជន៍ទទួលបានពីជំនួយតាមវិស័យរបស់ ADB បានធ្លាក់ដល់ដៃអ្នកក្រីក្រ និង (iv) កម្រិតនៃចំណាយដើម្បីបានជំនួយនៅពេលផ្តល់កម្មវិធីជំនួយតាមវិស័យ និងនៅពេលសម្របសម្រួលប្រតិបត្តិការតាមវិស័យជាមួយ DPs ផ្សេងទៀត បើប្រៀបធៀបទៅនឹងចំណាយនៃការផ្តល់ជំនួយបែបនេះទៅឱ្យ DMCs ដែលមានស្ថានភាពប្រហាក់ប្រហែលគ្នាផ្សេងទៀត ។

(i) **ប្រសិទ្ធភាពខ្ពស់** (៣ ពិន្ទុ) កម្មវិធីជំនួយនៅក្នុងវិស័យណាមួយ ត្រូវចាត់ទុកថា មានប្រសិទ្ធិភាពខ្ពស់ នៅពេលដែលជំនួយរបស់ ADB បានចូលរួមលើកកម្ពស់កាន់តែខ្លាំងនូវគោលនយោបាយតាមវិស័យនានា និងបរិស្ថានដែលធ្វើឱ្យស្ថាប័នមានដំណើរការផលតបស្នងទៅលើគម្រោងធំៗ មានកម្រិតខ្ពស់ ផ្នែកជាច្រើននៃកម្មវិធី ត្រូវបានចាត់ទុកថាបានទទួលជោគជ័យ ផ្នែកជាច្រើននៃសកម្មភាពជំនួយបច្ចេកទេស (TA) ទទួលបានចំណាត់ថ្នាក់ "ជោគជ័យ" និងចំណាយក្នុងការផ្តល់ជំនួយ មានភាពតិចជាងយ៉ាងខ្លាំងសម្រាប់ប្រទេសផ្សេងទៀតដែលយកមកធ្វើការប្រៀបធៀប ។

(ii) **ប្រសិទ្ធផល** (២ ពិន្ទុ) កម្មវិធីជំនួយ ត្រូវបានចាត់ទុកថា មានប្រសិទ្ធផលនៅពេលដែលជំនួយរបស់ ADB បានរួមចំណែកធ្វើឱ្យមានការប្រសើរឡើងមួយចំនួនដែរ នៅក្នុងគោលនយោបាយតាមវិស័យនានា និងបរិស្ថានដែលធ្វើឱ្យស្ថាប័នដំណើរការ ចំណូលសេដ្ឋកិច្ចទៅលើគម្រោងធំៗ មានកម្រិតលើសពី ១២%, កម្មវិធីភាគច្រើន ត្រូវបានចាត់ទុកថា បានទទួលជោគជ័យ សកម្មភាពជំនួយ

TA ភាគច្រើន ត្រូវបានវាយតម្លៃថា "ជោគជ័យ" ហើយចំណាយនៃការផ្ដល់ជំនួយគឺមានចំនួនប្រហាក់ប្រហែលគ្នា ទៅនឹងចំណាយនៃការផ្ដល់ជំនួយសម្រាប់ប្រទេសដែលយកមកប្រៀបធៀប ។

(iii) **ប្រសិទ្ធភាពតិច** ( ១ ពិន្ទុ) កម្មវិធីនៃជំនួយ ត្រូវបានចាត់ទុកថា មានប្រសិទ្ធភាពតិច នៅពេលដែលជំនួយរបស់ ADB បានយ៉ាងតិចតួចបំផុតនៅក្នុងការលើកកម្ពស់គោលនយោបាយតាមវិស័យនានា និងបរិស្ថានដែលធ្វើឱ្យស្ថាប័នមានដំណើរការ ចំណូលសេដ្ឋកិច្ចចំពោះគម្រោងធំៗ មានកម្រិតតិចជាង ១២% ហើយចំណាយក្នុងការផ្ដល់ជំនួយ គឺមានភាពខ្ពស់ជាងចំណាយនៃការផ្ដល់ជំនួយសម្រាប់ប្រទេសដែលយកមក ប្រៀបធៀបពី ២០ ដល់ទៅ ៣០% ។

(iv) **គ្មានប្រសិទ្ធផល** (០ ពិន្ទុ). កម្មវិធីជំនួយ ត្រូវបានចាត់ទុកថាគ្មានប្រសិទ្ធផល ប្រសិនបើជំនួយរបស់ ADB មិនបានរួមចំណែកលើកកម្ពស់គោលនយោបាយសម្រាប់វិស័យនានា និងបរិស្ថានដែលធ្វើឱ្យស្ថាប័នដំណើរការ ចំណូលសេដ្ឋកិច្ចចំពោះការវិនិយោគធំៗ មានកម្រិតតិចជាង ១២% មានកម្មវិធីតាមវិស័យតិចតួចប៉ុណ្ណោះ ត្រូវបានចាត់ទុកថាទទួលបានជោគជ័យ ហើយចំណាយក្នុងការផ្ដល់ជំនួយ មានច្រើនជាង ៣០% ខ្ពស់ជាងចំណាយនៃការផ្ដល់ជំនួយរបស់ប្រទេសដែលយកមកប្រៀបធៀប ។

(v) អ្នកវាយតម្លៃ នឹងផ្ដល់ជាសនិទានភាពមួយចំពោះពិន្ទុដែលបានផ្ដល់ទៅលើប្រសិទ្ធផលតាមវិស័យ ។ សនិទានភាពនេះ ក៏អាចដាក់បញ្ចូលកត្តាជាក់លាក់ របស់ប្រទេសផ្សេងៗទៀត ដែលជះឥទ្ធិពលដល់ការឱ្យពិន្ទុទៅលើប្រសិទ្ធភាពនេះបានដែរ ។

៧. **និរន្តរភាព** លក្ខណៈវិនិច្ឆ័យនេះ ផ្ដោតទៅលើលទ្ធភាពដែល នឹងនាំឱ្យសម្រេចបានលទ្ធផល និងអត្ថប្រយោជន៍តាមវិស័យនីមួយៗ ទៅអនាគត ។ និរន្តរភាព ត្រូវបានវាយតម្លៃថា ជាកម្រិតដែលការត្រួតពិនិត្យអន្តរាគមន៍តាមវិស័យនានា បានជួយរួមចំណែកទាញយកផលចំណេញ អភិវឌ្ឍន៍យូរអង្វែង ដែលផលចំណេញនេះ ទំនងជាបង្ហាញនូវសមត្ថភាពទប់ទល់នឹងការប៉ះទង្គិចពីហានិភ័យដែលគេបានកំណត់ ។ និរន្តរភាព មានទិដ្ឋភាពសំខាន់ៗដូចជា សារពើពន្ធ សង្គម សេដ្ឋកិច្ចនយោបាយ និងបរិស្ថាន ។ ចំណាត់ថ្នាក់នានា នឹងត្រូវបានកំណត់ទៅតាមនិរន្តរភាពនៃកម្មវិធីរបស់ ADB សម្រាប់វិស័យនីមួយៗ ដូចខាងក្រោម :

(i) **ទំនងជាមានបំផុត** (៦ ពិន្ទុ) គេវាយតម្លៃថា ទំនងជាមាននិរន្តរភាពបំផុត ប្រសិនបើមានការបញ្ជាក់ថាអត្ថប្រយោជន៍ពីកម្មវិធីជំនួយ មានសមត្ថភាពទប់ទល់នឹងការប៉ះទង្គិចពីហានិភ័យដែលអាចធ្វើឱ្យខូចដល់អត្ថប្រយោជន៍ CAPE វិញនោះ ។[៣]

(ii) **ទំនងជាមាន** (៤ ពិន្ទុ) គេវាយតម្លៃថា ទំនងជាមាននិរន្តរភាព ប្រសិនបើអត្ថប្រយោជន៍នៃកម្មវិធីជំនួយ ងាយទទួលរងឥទ្ធិពលក្នុងកម្រិតជាមធ្យម ពីហានិភ័យដែលទំនងជាអាចមាន ។

(iii) **ទំនងជាមានតិចតួច** (២ ពិន្ទុ) គេវាយតម្លៃថា ទំនងជាមាននិរន្តរភាពតិចតួច ប្រសិនបើអត្ថប្រយោជន៍ពីកម្មវិធីជំនួយ ងាយទទួលរងគ្រោះក្នុងកម្រិតជាមធ្យម ពីហានិភ័យមួយចំនួន ។

(iv) **ទំនងជាមិនមាន** (០ ពិន្ទុ) គេវាយតម្លៃថា ទំនងជាមិនមាននិរន្តរភាព ប្រសិនបើមានហានិភ័យធ្ងន់ធ្ងរដែលគំរាមកំហែងដល់សមត្ថភាពទប់ទល់នឹងការប៉ះទង្គិចក្នុងការការពារអត្ថប្រយោជន៍ CAP ។

(v) អ្នកវាយតម្លៃ នឹងផ្ដល់នូវសនិទានភាពសម្រាប់ការដាក់ពិន្ទុដែលបានឱ្យលើនិរន្តរភាពតាមវិស័យ ។ សនិទានភាពនេះ ក៏អាចដាក់បញ្ចូលកត្តាជាក់លាក់របស់ ប្រទេសផ្សេងៗទៀត ដែលជះឥទ្ធិពលដល់ការវាយតម្លៃទៅលើនិរន្តរភាពនេះបានដែរ ។

---

[៣] កត្តាខ្លះៗក្នុងចំណោមកត្តាដែលធន់នឹងការប៉ះទង្គិចចម្បងៗ មានដូចជា : ភាពធន់នឹងការប៉ះទង្គិចពីជំនួយបច្ចេកទេស (រួមមាន ការផ្ដល់ហិរញ្ញវត្ថុតាមដំណាក់កាលបានគ្រប់គ្រាន់ដើម្បីប្រតិបត្តិ និងរក្សាទ្រព្យគម្រោង) ភាពធន់នឹងការប៉ះទង្គិចពីផ្នែកហិរញ្ញវត្ថុ (រួមមានគោលនយោបាយស្ដីពីការស្ដារចំណាយដើមឡើងវិញ) ភាពធន់នឹងការប៉ះទង្គិចពីផ្នែកសេដ្ឋកិច្ចការគាំទ្រសង្គម ភាពធន់នឹងការប៉ះទង្គិចពីផ្នែកបរិស្ថាន, ភាពជាម្ចាស់ដោយរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត ការគាំទ្ររបស់ស្ថាប័ន (រួមមានក្របខ័ណ្ឌគាំទ្រផ្នែកច្បាប់ និងនិយ័តកម្ម) និងភាពធន់នឹងការប៉ះទង្គិចពីកត្តាខាងក្រៅ ដូចជាការប្រែប្រួលចុះឡើងនៃពាណិជ្ជកម្មជាដើម ។

៨. **ផលប៉ះពាល់** ផលប៉ះពាល់ សំដៅទៅលើការចូលរួមសមស្របរបស់ ADB ដែលនាំឱ្យមានការផ្លាស់ប្តូរក្នុងរយៈពេលវែងទៅលើស្ថានភាពនៃការអភិវឌ្ឍតាមរយៈកម្មវិធីរបស់ខ្លួននៅក្នុងវិស័យជាក់លាក់ណាមួយ ។ ផលប៉ះពាល់នេះ គឺវាប់ទាំងកម្រិតទទួលបានជោគជ័យនៃកម្មវិធីក្នុងវិស័យនានាដែលធ្វើវិភាគទាននាំឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍ដែលបានកំណត់ (ពោលគឺ លក្ខខណ្ឌសេដ្ឋកិច្ចសង្គម កាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើនប្រាក់ចំណូល គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ដែលមិនមែនតាមរយៈប្រាក់ចំណូល [MDGs] ព្រមទាំងគោលដៅ និងវត្ថុបំណងកាត់បន្ថយភាពក្រីក្រជាតិដែលបានកំណត់ផ្សេងទៀត) ។ ផលប៉ះពាល់ ក៏ត្រូវបានគេវាយតម្លៃដោយពិនិត្យមើលទៅលើកម្រិតដែលកម្មវិធីតាមវិស័យបានរួមចំណែកឱ្យមានការកសាងសមត្ថភាពរបស់ស្ថាប័នក្នុងវិស័យនោះ ក្នុងការគ្រប់គ្រងការកាត់បន្ថយភាពក្រីក្រ ។ ការកសាងសមត្ថភាពរបស់ស្ថាប័នសំដៅទៅលើការធ្វើឱ្យប្រសើរឡើងនូវសមត្ថភាពរបស់វិស័យនោះក្នុងការប្រើប្រាស់ ប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល នូវធនធានមនុស្ស ហិរញ្ញវត្ថុ និងធនធានធម្មជាតិ ដើម្បីខិតខំកាត់បន្ថយភាពក្រីក្រ ។ ចំណាត់ថ្នាក់ នឹងត្រូវធ្វើឡើងទៅលើផលប៉ះពាល់ជាក់ស្តែង និងផលប៉ះពាល់រំពឹងទុកនៃកម្មវិធីរបស់ ADB សម្រាប់វិស័យនីមួយៗ ដូចខាងក្រោម :

(i) **ខ្ពស់** (៦ ពិន្ទុ) ផលប៉ះពាល់ជាក់ស្តែង និងផលប៉ះពាល់រំពឹងទុក ត្រូវបានវាយតម្លៃថា "ខ្ពស់" ប្រសិនបើមានការរួមចំណែកដ៏ច្បាស់លាស់មួយ បានសម្រេចគោលដៅអភិវឌ្ឍន៍តាមវិស័យ សមត្ថភាពរបស់ស្ថាប័ននៅក្នុងវិស័យនោះ គោលដៅ និងវត្ថុបំណងកាត់បន្ថយភាពក្រីក្រជាតិ ឬ MDGs ។

(ii) **បង្គួរ** (៤ ពិន្ទុ) ផលប៉ះពាល់ជាក់ស្តែង និងផលប៉ះពាល់រំពឹងទុក ត្រូវបានវាយតម្លៃថា "បង្គួរ" ប្រសិនបើមានការរួមចំណែកដ៏ច្បាស់លាស់មួយ បានសម្រេចគោលដៅអភិវឌ្ឍន៍តាមវិស័យ សមត្ថភាពរបស់ស្ថាប័ននៅក្នុងវិស័យនោះ គោលដៅ និងវត្ថុបំណងកាត់បន្ថយភាពក្រីក្រជាតិ ឬ MDGs ប៉ុន្តែនៅមាន ចំណុចខ្សោយខ្លះៗ នៅក្នុងផ្នែកសំខាន់នៃវិស័យដែលទទួលបានជំនួយនោះ ។

(iii) **មធ្យម** (២ ពិន្ទុ). ផលប៉ះពាល់ជាក់ស្តែង និងផលប៉ះពាល់រំពឹងទុក ត្រូវបានវាយតម្លៃថា "មធ្យម" ប្រសិនបើវឌ្ឍនភាពសម្រេចបានក្នុងកម្រិតមួយសម្រាប់ពង្រឹងសមត្ថភាពរបស់ស្ថាប័ននៃវិស័យនោះ និងប្រសិនបើមានភស្តុតាងតិចតួចដែលបញ្ជាក់ពីការចូលរួមរបស់កម្មវិធីជំនួយនៅក្នុងវិស័យនោះ ជួយសម្រេចបាននូវគោលដៅអភិវឌ្ឍន៍តាមវិស័យ និងគោលដៅ និងវត្ថុបំណងកាត់បន្ថយភាពក្រីក្រជាតិ ឬ MDGs ។

(iv) **តិចតួច** (០ ពិន្ទុ) ផលប៉ះពាល់ជាក់ស្តែង និងផលប៉ះពាល់រំពឹងទុក ត្រូវបានវាយតម្លៃថា "តិចតួច" ប្រសិនបើគ្មានវឌ្ឍនភាពណាមួយត្រូវបានមើលឃើញក្នុងការពង្រឹងសមត្ថភាពរបស់ស្ថាប័នទេ ភាពទន់ខ្សោយរបស់ស្ថាប័ននៅតែមានច្រើន ហើយគ្មានភស្តុតាងណាមួយបញ្ជាក់ពីការរួមចំណែកដែលទទួលបានពីកម្មវិធីជំនួយតាមវិស័យដែលនាំឱ្យសម្រេចបាននូវគោលដៅអភិវឌ្ឍន៍តាមវិស័យ គោលដៅ និងវត្ថុបំណងកាត់បន្ថយភាពក្រីក្រជាតិ ឬ MDGs ទេ ។

(v) អ្នកវាយតម្លៃ នឹងផ្តល់នូវសនិទានភាពសម្រាប់ការដាក់ពិន្ទុដែលបានផ្តល់ឱ្យលើផលប៉ះពាល់ ។ សនិទានភាពនេះ ក៏អាចដាក់បញ្ចូលកត្តាជាក់លាក់របស់ប្រទេសផ្សេងៗទៀត ដែលជះឥទ្ធិពលដល់ការវាយតម្លៃទៅលើផលប៉ះពាល់នេះបានដែរ ។

៩. **ចំណាត់ថ្នាក់វាយតម្លៃការងារតាមវិស័យ** ពិន្ទុសម្រាប់លទ្ធផលការងារតាមវិស័យ ត្រូវបានគណនាឡើងសម្រាប់ លទ្ធផលការងារក្នុងវិស័យនីមួយៗ នោះដោយការបូកពិន្ទុដែលបានឱ្យទៅតាមលក្ខណៈវិនិច្ឆ័យនីមួយៗ ។ ការអនុវត្តកម្មវិធីនៅក្នុងវិស័យនីមួយៗ ត្រូវបានវាយតម្លៃថា ទទួលបានជោគជ័យបំផុត ប្រសិនបើពិន្ទុសម្រាប់លទ្ធផលការងារនៅក្នុងវិស័យនោះមាន ឬលើសពី ២០ ពិន្ទុ វាយតម្លៃថាបានជោគជ័យ ប្រសិនបើពិន្ទុសម្រាប់លទ្ធផលការងារក្នុងវិស័យនោះ ស្ថិតនៅចន្លោះពី ១៦ ទៅ ១៩ វាយតម្លៃថា បានទទួលជោគជ័យមួយផ្នែក ប្រសិនបើពិន្ទុ សម្រាប់លទ្ធផលការងារនៅក្នុងវិស័យនោះស្ថិតនៅក្នុងចន្លោះពី ១១ ទៅ ១៥ និងវាយតម្លៃថាមិនជោគជ័យ ប្រសិនបើពិន្ទុសម្រាប់លទ្ធផលការងារក្នុងវិស័យនោះ មានត្រឹម ១០ ឬតិចជាងនេះ ។

១០. **ការបូកសរុបពិន្ទុពីគ្រប់វិស័យទាំងអស់** ពិន្ទុសរុបសម្រាប់លទ្ធផលការងារតាមវិស័យ នឹងត្រូវចាត់ទុកថាជារង្វាស់ទៅលើការវាយតម្លៃលទ្ធផលបែបពីក្រោមឡើងលើនៃកម្មវិធីជំនួយរបស់ ADB ។ ពិន្ទុសម្រាប់លទ្ធផលការងារតាមវិស័យ នឹងទទួលបានមេគុណ ២ សម្រាប់វិស័យធំៗ និងមេគុណ ១ សម្រាប់វិស័យតូច ។ វិស័យធំៗ គឺវិស័យទាំងឡាយណាដែល ADB គឺជាដៃគូអភិវឌ្ឍន៍នាំមុខ ហើយមានផលប័ត្រទូលំទូលាយនៃសេវាកម្ម និងមិនមែនកម្ម ឬក៏ ADB បានផ្តល់នូវជំនួយ ដែលនាំឱ្យសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍សំខាន់ៗនៅក្នុងវិស័យទាំងនោះ ។ រីឯវិស័យតូចៗ គឺវិស័យទាំងឡាយណាដែល ADB មិនមែនជាដៃគូអភិវឌ្ឍន៍នាំមុខ ហើយបានផ្តល់នូវការគាំទ្រសេវាកម្ម និងមិនមែនកម្មក្នុងកម្រិតមធ្យមតែប៉ុណ្ណោះ និងដែលការរួមចំណែកផ្តល់ជំនួយរបស់ ADB ដែលនាំឱ្យសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍ នោះស្ថិតក្នុងកម្រិតមួយនៅក្នុងវិស័យទាំងនោះ ។ ចំណាត់ថ្នាក់ពីក្រោមឡើងលើសរុប (ពោលគឺ ពិន្ទុសម្រាប់លទ្ធផលការងារតាមវិស័យនោះ) ត្រូវបានគណនាដូចខាងក្រោម :

ពិន្ទុសរុបសម្រាប់លទ្ធផលការងារតាមវិស័យ = Σ (Wi* ពិន្ទុសម្រាប់លទ្ធផលការងារតាមវិស័យ)/ ΣWi,

ឱ្យតម្លៃ Wi មេគុណ ១ សម្រាប់វិស័យតូចៗ និងមេគុណ ២ សម្រាប់វិស័យធំៗ

លទ្ធផលការងារតាមវិស័យសរុប ត្រូវបានវាយតម្លៃថាបានជោគជ័យបំផុត ប្រសិនបើពិន្ទុសរុបសម្រាប់លទ្ធផលការងារតាមវិស័យមានត្រឹម ២០ ពិន្ទុ ឬលើសពី ២០ ពិន្ទុ ថាបានជោគជ័យ ប្រសិនបើពិន្ទុសរុបសម្រាប់លទ្ធផលការងារតាមវិស័យ ស្ថិតនៅចន្លោះពី ១៦ ទៅ ១៩ ថាបានជោគជ័យមួយផ្នែក ប្រសិនបើពិន្ទុសរុបសម្រាប់លទ្ធផលការងារតាមវិស័យ ស្ថិតនៅចន្លោះពី ១១ ទៅ ១៥ និងថាមិនជោគជ័យ ប្រសិនបើពិន្ទុសរុបសម្រាប់លទ្ធផលការងារតាមវិស័យ មានត្រឹម ១០ ពិន្ទុ ឬតិចជាងនេះ ។

## គ. ការកំណត់ស្ថានភាពប្រទេស ការរួមចំណែកដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ និងលទ្ធផលការងាររបស់ធនាគារអភិវឌ្ឍន៍អាស៊ី

១១. ប្រសិទ្ធភាពអភិវឌ្ឍន៍របស់ ADB អាស្រ័យទៅលើការងាររបស់ ADB ខ្លួនឯងតែម្តងនៅក្នុងវិស័យសំខាន់ៗ ។ ប៉ុន្តែ ប្រសិទ្ធភាពនេះក៏អាស្រ័យទៅលើស្ថានភាពពេលផ្តល់ជំនួយ ការរួមចំណែកនៃជំនួយទាំងនោះទៅលើលទ្ធផលអភិវឌ្ឍន៍សរុបទាំងអស់ ព្រមទាំងគុណភាព និងការឆ្លើយតបនៃសេវារបស់ ADB ដែរ ។ វិធីពីលើចុះក្រោម ត្រូវបានប្រើប្រាស់ដើម្បី វាយតម្លៃ និងចាត់ចំណាត់ថ្នាក់ទៅលើការកំណត់ស្ថានភាពប្រទេសរបស់ ADB ទៅលើការរួមចំណែកទាំងអស់នៃកិច្ចខិតខំប្រឹងប្រែងរបស់ជំនួយដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍ជាតិ និងទៅលើគុណភាព និងការឆ្លើយតបនៃសេវាដែល ADB បានធ្វើឡើង ។ វិធីនេះធ្វើការវាយតម្លៃថា តើការជ្រើសរើសវិស័យនានា គំនិតផ្តួចផ្តើមតាមប្រធានបទ និងការចាប់ដៃគ្នាជាដៃគូដែលធ្វើឡើងដោយ ADB មានភាពសមស្រប ឬទេ បើពិនិត្យមើលទៅលើតម្រូវការ និងអាទិភាពរបស់ប្រទេសដែលកំពុងតែវិវត្តនោះ ។ ទាក់ទងទៅនឹងការកំណត់ស្ថានភាព វិធីនេះ ក៏ធ្វើការវាយតម្លៃទៅលើកម្រិតដែលការរួមចំណែកទាំងអស់របស់កម្មវិធី (ការរួមចំណែកដែលនាំឱ្យសម្រេចបានលទ្ធផលអភិវឌ្ឍន៍នោះ) សម្រេចបាននូវលទ្ធផលសមស្របដល់កម្រិតដូចការរំពឹងទុកនោះដែរ ឬទេ ។ បន្ទាប់មកវិធីនេះ ធ្វើការវាយតម្លៃទៅលើគុណភាពនៃសេវា ដែល ADB បានផ្តល់ ដែលមានឥទ្ធិពលដល់លទ្ធផល អភិវឌ្ឍន៍ ។

១២. **ការកំណត់ស្ថានភាពប្រទេស** នេះគឺជារង្វាស់មួយ សម្រាប់វាស់វែងថា តើ ADB បានឆ្លើយតបចំពោះបញ្ហាប្រឈម និងអាទិភាពអភិវឌ្ឍន៍របស់រដ្ឋាភិបាលដែលកំពុងតែដំណើរការ (ឬសូម្បីតែចំពោះអ្វីដែលជាការប៉ាន់ស្មាន) បានល្អកម្រិតណា ដោយផ្អែកទៅលើឧត្តមភាពដោយប្រៀបធៀបរបស់អង្គការនេះ និងថាតើ ADB រៀបចំយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសបានល្អកម្រិតណារហូតដល់ធ្វើឱ្យមានការពិចារណា សុំការគាំទ្រដែលគេអាចរកបានពីដៃគូអភិវឌ្ឍន៍ផ្សេងទៀត ។ ការកំណត់ស្ថានភាពរបស់ប្រទេស មានការពាក់ព័ន្ធនឹងការវាយតម្លៃសរុបទាំងអស់ទៅលើ (i) ភាពទាក់ទង (វាយតម្លៃមើលថាតើកាលានុវត្តន៍ភាពជាយុទ្ធសាស្ត្រដ៏ល្អ ដើម្បីទទួលជំនួយនោះ ត្រូវបានយកមកប្រើប្រាស់ដោយប្រសិទ្ធភាពដែរ ឬទេ) (ii) ការឆ្លើយតប (នេះគឺជាការកំណត់ពេលវេលា និងវិសាលភាពនៃការពាក់ព័ន្ធរបស់ ADB នៅក្នុងអ្វីដែលប្រែទៅជាអាទិភាពអភិវឌ្ឍន៍ចម្បងនៅក្នុងប្រទេសទៅវិញ) (iii) ភាពបត់បែនរបស់ប្រតិបត្តិការ (ដែលពិនិត្យមើលទៅលើលក្ខណៈ ដែលថាតើការបញ្ចូលគ្នារវាងសេវាកម្ម និងមិនមែនកម្ម

ព្រមទាំងដំណោះស្រាយរបស់ប្រតិបត្តិការ ត្រូវបានគេកែតម្រូវឱ្យស្របទៅតាម ស្ថានភាពជាក់ស្តែងនៃប្រទេសដោយរបៀបណា) (iv) ការគ្រប់គ្រងផលប័ត្រ (ដែលជាវិឌ្ឍនភាពសម្រេចបានដោយសារការអនុវត្តកម្មវិធីជំនួយដែលបានឯកភាពគ្នា) និង (v) ភាពជាដៃគូ (កំណត់កម្រិតដែល ADB មានសមត្ថភាពលើកស្ទួយឱ្យមានទំនាក់ទំនងយ៉ាងល្អជាមួយ នឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀតក្នុងក្របខ័ណ្ឌទូលំទូលាយនៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍនៅក្នុងប្រទេស) ។ ចំណាត់ថ្នាក់ នឹងត្រូវធ្វើឡើង ចំពោះការកំណត់ស្ថានភាពបែបយុទ្ធសាស្ត្រទៅលើយុទ្ធសាស្ត្រ និងកម្មវិធីជំនួយប្រចាំប្រទេសរបស់ ADB ដូចដែលពន្យល់ខាងក្រោម :

(i) **ខ្ពស់** (៨ ពិន្ទុ) CSPs របស់ ADB ស្របគ្នាទាំងស្រុងជាមួយនឹងអាទិភាព និងកម្មវិធីអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាល ផ្តោតទៅលើប្រទេស និងទទួលបានការគាំទ្រពេញទំហឹងពីសំណាក់រដ្ឋាភិបាល ត្រូវបានរៀបចំដើម្បីដោះស្រាយប្រកបដោយប្រសិទ្ធភាពទៅលើបញ្ហានានាដែលរាំងស្ទះដល់ការកាត់បន្ថយភាពក្រីក្រ ដោយផ្អែកទៅលើឧត្តមភាពប្រៀបធៀបរបស់ ADB មានភាពសុខដុមជាមួយនឹងជំនួយរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ត្រូវបានច្របាច់បញ្ចូលគ្នារវាងប្រតិបត្តិការកម្ចី និងមិនមែនកម្ចី និងត្រូវបានអនុវត្តទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធភាព ។

(ii) **បង្គួរ** (៦ ពិន្ទុ) ជាទូទៅ CSPs របស់ ADB ស្របគ្នាជាមួយនឹងអាទិភាព និងកម្មវិធីអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាល ទទួលការគាំទ្រពីសំណាក់រដ្ឋាភិបាល ដោះស្រាយនូវបញ្ហាចាំបាច់នានាចំពោះការអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដោយផ្អែកលើឧត្តមភាពប្រៀបធៀបរបស់ ADB ជាទូទៅ មានភាពស្របគ្នាជាមួយនឹងជំនួយរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ហើយជាទូទៅ ត្រូវបានឆ្លុះបញ្ចាំងនៅក្នុងកម្មវិធីកម្ចី និងមិនមែនកម្ចីសមស្រប ដែលត្រូវបានគេអនុវត្តប្រកបដោយប្រសិទ្ធភាព ។

(iii) **មធ្យម** (៤ ពិន្ទុ) CSPs របស់ ADB មិនស្របគ្នាទាំងស្រុងជាមួយនឹងអាទិភាព និងកម្មវិធីអភិវឌ្ឍន៍ជាតិរបស់រដ្ឋាភិបាលទេ ហើយទទួលបានការគាំទ្រតែមួយផ្នែកប៉ុណ្ណោះពីសំណាក់រដ្ឋាភិបាល ។ នៅពេលដោះស្រាយបញ្ហាសំខាន់ៗ CSPs មិនបានដោះស្រាយបញ្ហាចាំបាច់នានាដែលមានចំពោះការកាត់បន្ថយភាពក្រីក្រនោះទេ ។ ជំនួយដែលបានផ្តល់ មិនស្របគ្នាជាមួយនឹងជំនួយដែលបានផ្តល់ដោយដៃគូអភិវឌ្ឍន៍ផ្សេងទៀត ហើយមានគុណវិបត្តិ និងអតុល្យភាពទាំងនៅក្នុងកម្មវិធីកម្ចី និងមិនមែនកម្ចីដែលកម្មវិធីនេះធ្វើឱ្យប៉ះពាល់ដល់ការអនុវត្ត ។

(iv) **តិចតួច** (0 ពិន្ទុ) CSPs របស់ ADB អាចប្រតិបត្តិបានដោយសារអ្នកផ្តល់ជំនួយ និងមានតែមួយផ្នែកណានោះកាន់កាប់ដោយរដ្ឋាភិបាល ។ មានភស្តុតាងតិចតួចបំផុតដែលបញ្ជាក់ថា CSPs ទាំងនោះបានដោះស្រាយបញ្ហាចាំបាច់នានាដែលមានចំពោះការកាត់បន្ថយភាពក្រីក្រ ឬក៏បញ្ជាក់ថាជំនួយ នោះមានភាពស្របប្រកបយ៉ាងល្អជាមួយនឹងដៃគូអភិវឌ្ឍន៍របស់ជាតិ ។ ការអនុវត្ត មានកម្រិតខ្សោយ ដោយសារមានគុណវិបត្តិនៅក្នុងការរៀបចំកម្មវិធីកម្ចី និងមិនមែនកម្ចី ។

(v) អ្នកវាយតម្លៃ នឹងផ្តល់នូវសនិទានភាពសម្រាប់ការដាក់ពិន្ទុដែលបានឱ្យលើការកំណត់ស្ថានភាពប្រទេស ។ សនិទានភាពនេះ ក៏អាចដាក់បញ្ចូលកត្តាជាក់លាក់របស់ ប្រទេសផ្សេងៗទៀត ដែលជះឥទ្ធិពលដល់ការវាយតម្លៃទៅលើការកំណត់ស្ថានភាពប្រទេសបានដែរ ។

១៣. **ការរួមចំណែកដែលនាំឱ្យមានលទ្ធផលអភិវឌ្ឍន៍** នេះគឺជាការវាយតម្លៃទៅលើកម្រិតដែលកម្មវិធីប្រចាំប្រទេសទាំងអស់របស់ ADB បានរួមចំណែកនាំឱ្យសម្រេចបានលទ្ធផលអភិវឌ្ឍន៍នៅតាមកម្រិតថ្នាក់ជាតិ ។ ការវាយតម្លៃនេះ បានឆ្លុះបញ្ចាំងពីលទ្ធផលវិជ្ជមាន និងអវិជ្ជមានដែលកើតចេញពីការគាំទ្ររបស់ ADB ក្នុងវិស័យផ្សេងៗ (ដែលបានធ្វើការវាយតម្លៃរួចហើយតាមបែបពីក្រោមឡើងលើ) ។ ការវាយតម្លៃនេះ ផ្តោតជាចម្បងទៅលើការរួមចំណែករបស់ ADB ដែលនាំឱ្យសម្រេចបានលទ្ធផលនៅក្នុងកម្រិតនៃមូលដ្ឋានគ្រឹះកាត់បន្ថយភាពក្រីក្រ (ពោលគឺ កំណើនដើម្បីគាំទ្រអ្នកក្រ ការអភិវឌ្ឍសង្គមគ្រប់វិស័យ និងអភិបាលកិច្ចល្អ) និងនៅកម្រិតតាមប្រធានបទនៃអន្តរាគមន៍ ។ ចំណាត់ថ្នាក់ នឹងត្រូវធ្វើឡើងទៅលើការរួមចំណែករបស ADB ដែលនាំឱ្យសម្រេចបាននូវលទ្ធផលអភិវឌ្ឍន៍ ដូចខាងក្រោម :

(i) **ខ្ពស់** (៨ ពិន្ទុ) ADB បានរួមចំណែកសំខាន់ៗដែលនាំឱ្យសម្រេចបាននូវលទ្ធផលដែលជួយបង្កើនការគាំទ្រដល់អ្នកក្រ អភិវឌ្ឍន៍សង្គម និងអភិបាលកិច្ចល្អ ។ ជំនួយរបស់ ADB រួមចំណែកឱ្យមានលទ្ធផលជាវិជ្ជមាននៅក្នុងប្រធានបទជាច្រើន ។

(ii) **បង្គួរ** (៦ ពិន្ទុ) តាមរយៈការថ្លឹងថ្លែង ជំនួយរបស់ ADB បានជួយរួមចំណែកយ៉ាងល្អដល់ការសម្រេចបាននូវលទ្ធផលដែលជួយបង្កើនការគាំទ្រដល់អ្នកក្រ ការអភិវឌ្ឍសង្គម និងអភិបាលកិច្ចល្អ ។ ជំនួយរបស់ ADB រួមចំណែកឱ្យមានលទ្ធផលជាវិជ្ជមាននៅក្នុងប្រធានបទមួយចំនួន ។

(iii) **មធ្យម** (៤ ពិន្ទុ) តាមរយៈការថ្លឹងថ្លែង ជំនួយរបស់ ADB បានជួយរួមចំណែកដល់ការសម្រេចបាននូវលទ្ធផលដែលជួយបង្កើនការគាំទ្រដល់អ្នកក្រ អភិវឌ្ឍន៍សង្គម និងអភិបាលកិច្ចល្អ ប៉ុន្តែការអនុវត្តនៅក្នុងផ្នែកទាំងនេះ មានដំណើរយឺតយ៉ាវ មិនដូចការរំពឹងទុករបស់រដ្ឋាភិបាល និង ADB ឡើយ ។ វឌ្ឍនភាពខ្លះៗ ត្រូវបានចុះក្នុងបញ្ជីដោយសារមានការរួមចំណែករបស់ ADB ដល់កិច្ចខិតខំប្រឹងប្រែងផ្តល់ជំនួយទាំងអស់នៅក្នុងការលើកកម្ពស់លទ្ធផលនៅក្នុងប្រធានបទសំខាន់ៗ ។

(iv) **តិចតួច** (០ ពិន្ទុ) គ្មានភស្តុតាងដើម្បីបញ្ជាក់ថាកម្មវិធីជំនួយរបស់ ADB បានរួមចំណែកយ៉ាងជ្រាលជ្រៅ និងជាវិជ្ជមានក្នុងការកាត់បន្ថយភាពក្រីក្រ ឬធ្វើឱ្យសម្រេចបាននូវលទ្ធផលតាមប្រធានបទជាអាទិភាពទេ ។ ទោះជាគ្មានជំនួយរបស់ ADB ក៏ដោយ ក៏លទ្ធផលអភិវឌ្ឍន៍នៅតែមានសភាពដូចគ្នាច្រើនដែរ ។

(v) អ្នកវាយតម្លៃ នឹងផ្តល់នូវសនិទានភាពសម្រាប់ការដាក់ពិន្ទុដែលបានឱ្យទៅលើ ការរួមចំណែកទាំងអស់នៃកម្មវិធីក្នុងការធ្វើឱ្យមានលទ្ធផលអភិវឌ្ឍន៍ ។ សនិទានភាពនេះ ក៏អាចដាក់បញ្ចូលកត្តាជាក់លាក់របស់ប្រទេសផ្សេងៗទៀត ដែលជះឥទ្ធិពលដល់ការវាយតម្លៃទៅលើការរួមចំណែកទាំងអស់នៃកម្មវិធីក្នុងការធ្វើឱ្យមានលទ្ធផលអភិវឌ្ឍន៍បានដែរ ។

១៤. **លទ្ធផលការងាររបស់ ADB** លក្ខណៈវិនិច្ឆ័យនេះ ផ្តោតទៅលើដំណើរការទាំងឡាយណាដែលស្ថិតនៅពីក្រោយប្រសិទ្ធភាពរបស់ ADB នៅពេល ADB គេសពីការទទួលខុសត្រូវក្នុងនាមជាដៃគូអភិវឌ្ឍន៍ ។ ការផ្តោតនេះ រួមមាន : សំខាន់បំផុត គឺសំដៅទៅលើកិច្ចខិតខំប្រឹងប្រែង និងជោគជ័យរបស់ ADB នៅក្នុងការផ្តល់នូវការគាំទ្រប្រកបដោយគុណភាពនៃសេវាកម្មី និងមិនមែនកម្ចី ក្នុងការបង្ហាញ និងការប្រកាន់ខ្ជាប់ទៅនឹងការអនុវត្តលើសហអភិបាលកិច្ចល្អ ស្គាល់ពីតម្រូវការរបស់អតិថិជន និងឆ្លើយតបទៅនឹងតម្រូវការទាំងនោះ ជំរុញឱ្យអតិថិជនមានភាពជាម្ចាស់កម្មសិទ្ធិ ហើយបន្ទាប់មក គឺផ្តោតទៅលើកម្រិតដែលការងាររបស់ខ្លួន មានភាពស្របគ្នាជាមួយនឹងការងាររបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ។ លក្ខណៈវិនិច្ឆ័យនេះ ក៏ផ្តោតលើការអនុវត្តតាមគោលការណ៍ប្រតិបត្តិការមូលដ្ឋាន ការសម្រេចបានតាមវត្ថុបំណង កសាងសមត្ថភាព សង្គតិភាពនៅក្នុងការរួមចំណែករបស់ ADB យុទ្ធសាស្ត្រប្រចាំប្រទេស និងតាមវិស័យ និងការបម្រើសេវាជូនអតិថិជន ។ ចំណាត់ថ្នាក់នេះ គួរឆ្លុះបញ្ចាំងពីទស្សនៈរបស់អ្នកខ្ចី EAs និងរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ក្រៅពីគំនិតកែលម្អដែលទទួល បានពីបុគ្គលិកប្រតិបត្តិការ ។ ចំណាត់ថ្នាក់នានា នឹងត្រូវរៀបចំឡើងទៅតាមលទ្ធផលការងាររបស់ ADB ដូចខាងក្រោម :

(i) **ខ្ពស់** (៨ ពិន្ទុ) ADB ដែលបានផ្តល់នូវការបង្កើតជាយុទ្ធសាស្ត្រ និងកម្មវិធីប្រកបដោយគុណភាពខ្ពស់ ការរៀបចំគម្រោង និងកម្មវិធី និងសេវាចុះត្រួតពិនិត្យ គឺជាការឆ្លើយតបទៅនឹងតម្រូវការរបស់រដ្ឋាភិបាល ហើយទទួលរ៉ាប់រងនូវតួនាទីរបស់ខ្លួនស្របតាមការជំរុញភាពជាម្ចាស់កម្មសិទ្ធិរបស់អតិថិជន សមត្ថភាពរបស់អតិថិជនដែលបានប្រសើរឡើងរួចហើយ ការផ្គាប់ចិត្តអតិថិជន និងសហអភិបាលកិច្ចល្អ ។ ADB ជំរុញឱ្យមានភាពជាដៃគូយ៉ាងស្អិតរមួតជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជាមួយរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល ហើយ ADB ធ្វើប្រតិបត្តិដោយអនុវត្តទៅតាមអាណត្តិ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួនទាំងស្រុង ។

(ii) **បង្គួរ** (៦ ពិន្ទុ) តាមរយៈការថ្លឹងថ្លែង ADB ដែលបានផ្តល់នូវការបង្កើតជាយុទ្ធសាស្ត្រ និងកម្មវិធីប្រកបដោយគុណភាពខ្ពស់ ការរៀបចំគម្រោង និងកម្មវិធី និងសេវាចុះត្រួតពិនិត្យ ជាទូទៅ បានឆ្លើយតបទៅនឹងតម្រូវការរបស់រដ្ឋាភិបាល ហើយទទួលរ៉ាប់រងនូវបេសកកម្មរបស់ខ្លួនស្របតាមការជំរុញភាពជាម្ចាស់កម្មសិទ្ធិរបស់អតិថិជន ការលើកកម្ពស់សមត្ថភាពអតិថិជន ការផ្គាប់ចិត្ត អតិថិជន និង

សហាអភិបាលកិច្ចល្អ ។ ADB ជំរុញឱ្យមានភាពជាដៃគូយ៉ាងប្រពៃជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជាមួយ រដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល ហើយជាទូទៅ ADB ធ្វើប្រតិបត្តិការដោយអនុវត្តទៅតាមអាណត្តិ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួន ។

(iii) **មធ្យម** (៤ ពិន្ទុ) តាមរយៈការថ្លឹងថ្លែង គុណភាពនៃការបង្កើតយុទ្ធសាស្ត្រ និងកម្មវិធី ការរៀបចំគម្រោង និងកម្មវិធី និងសេវាចុះត្រួតពិនិត្យរបស់ ADB មានសភាពចម្រុះ ។ ADB អាចឆ្លើយតបបានមួយផ្នែកទៅនឹងតម្រូវការរបស់រដ្ឋាភិបាល ហើយទទួលរ៉ាប់រងនូវបេសកកម្មរបស់ខ្លួន បានយ៉ាងសមស្របបំផុតទៅនឹងការជំរុញភាពជាម្ចាស់របស់អតិថិជន ការលើកកម្ពស់សមត្ថភាពអតិថិជន ការផ្គាប់ចិត្តអតិថិជន និងសហាអភិបាលកិច្ចល្អ ។ ADB ជំរុញឱ្យមានភាពជាដៃគូមួយចំនួនតូចជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជាមួយរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិល ហើយ ADB ធ្វើប្រតិបត្តិការដោយមួយផ្នែក គឺអនុវត្តទៅតាមអាណត្តិ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួន ។

(iv) **តិចតួច** (០ ពិន្ទុ) តាមរយៈការថ្លឹងថ្លែង គុណភាពនៃការបង្កើតយុទ្ធសាស្ត្រ និងកម្មវិធី ការរៀបចំគម្រោង និងកម្មវិធី និងសេវាចុះត្រួតពិនិត្យ មានភាពអន់ខ្សោយ ។ ADB ឆ្លើយតបមិនបានគ្រប់គ្រាន់ទៅនឹងតម្រូវការរបស់រដ្ឋាភិបាល ហើយក៏មិនបានលើកកម្ពស់ឱ្យបានគ្រប់គ្រាន់នូវភាពជាម្ចាស់កម្មសិទ្ធិរបស់អតិថិជន ការលើកកម្ពស់សមត្ថភាពអតិថិជន ការផ្គាប់ចិត្តអតិថិជន និងសហាអភិបាលកិច្ចល្អ ។ ADB ជំរុញឱ្យមានភាពជាដៃគូជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ជាមួយរដ្ឋាភិបាល និងក្រុមសង្គមស៊ីវិលក្នុងចំនួនតិចតួចប៉ុណ្ណោះ ហើយប្រតិបត្តិការក្នុងផ្នែកជាច្រើនរបស់ ADB មិនស្របតាមអាណត្តិ គោលនយោបាយ និងយុទ្ធសាស្ត្ររបស់ខ្លួនឡើយ ។

(v) អ្នកវាយតម្លៃ នឹងផ្តល់នូវសនិទានភាពសម្រាប់ការដាក់ពិន្ទុដែលបានឱ្យលើលទ្ធផលការងាររបស់ ADB ។ សនិទានភាពនេះ ក៏អាចដាក់បញ្ចូលកត្តាជាក់លាក់របស់ប្រទេសផ្សេងៗទៀត ដែលជះឥទ្ធិពលដល់ការវាយតម្លៃទៅលើលទ្ធផលការងាររបស់ ADB ដែរ ។

១៥. **ចំណាត់ថ្នាក់សរុបទូទាំងប្រទេស** ចំណាត់ថ្នាក់សរុបទូទាំងប្រទេស ត្រូវធ្វើឡើងតាមរយៈការបូកសរុបពិន្ទុដែលបានឱ្យទៅលើការកំណត់ស្ថានភាព ការរួមចំណែកសម្រេចលទ្ធផល និងចំណាត់ថ្នាក់លើលទ្ធផលការងាររបស់ ADB ។ តាមរយៈវិធីពីលើចុះក្រោម លទ្ធផលការងារទូទាំងប្រទេស ត្រូវបានវាយតម្លៃថា ទទួលបានជោគជ័យខ្ពស់ប្រសិនបើពិន្ទុសរុប មានត្រឹម ២០ ពិន្ទុ ឬលើសពី ២០ ពិន្ទុ ថាបានជោគជ័យ ប្រសិនបើពិន្ទុសរុប ស្ថិតនៅចន្លោះពី ១៦ ទៅ ១៩ ថាបានទទួលជោគជ័យមួយផ្នែក ប្រសិនបើពិន្ទុសរុប ស្ថិតនៅចន្លោះពី ១១ ទៅ ១៥ និងថា មិនជោគជ័យ ប្រសិនបើពិន្ទុសរុប មានត្រឹមតែ ១០ ពិន្ទុ ឬតិចជាងនេះ ។

## ឃ. ការវាយតម្លៃសរុបលើការអនុវត្តកម្មវិធី (CAPE)

១៦. ការវាយតម្លៃសរុបលើការអនុវត្តកម្មវិធី (CAPE) ត្រូវបានធ្វើឡើងដោយការរួមបញ្ចូលគ្នារវាងការវាយតម្លៃតាមវិធីពីក្រោមឡើងលើ ដែលបានវាយតម្លៃទៅលើការងារនៅក្នុងវិស័យទាំងឡាយណាដែល ADB គាំទ្រ ជាមួយនឹងការវាយតម្លៃតាមវិធីពីលើចុះក្រោមដែលវាយតម្លៃទៅលើការកំណត់ស្ថានភាពរបស់ប្រទេសលើការរួមចំណែកសម្រេចបានលទ្ធផលសំខាន់ៗ និងលើលទ្ធផលការងាររបស់ ADB ។ គេផ្តល់មេគុណស្មើគ្នាសម្រាប់ការវាយតម្លៃតាមវិធីពីក្រោមឡើងលើ និងវិធីពីលើចុះក្រោម ។ ពិន្ទុលើលទ្ធផលការងារសរុបរបស់ CAPE ត្រូវធ្វើឡើងដោយការបញ្ចូលគ្នារវាងចំណាត់ថ្នាក់តាមវិស័យទាំងអស់ និងចំណាត់ថ្នាក់ទូទាំងប្រទេស ។ គេវាយតម្លៃថា ទទួលបានជោគជ័យខ្ពស់ ប្រសិនបើពិន្ទុសរុប មានត្រឹម ៤០ ពិន្ទុ ឬលើសពី ៤០ ពិន្ទុ ថាទទួលបានជោគជ័យ ប្រសិនបើពិន្ទុសរុប ស្ថិតនៅចន្លោះពី ៣០ ទៅ ៣៩ ថាទទួលបានជោគជ័យមួយផ្នែក ប្រសិនបើពិន្ទុសរុប ស្ថិតនៅចន្លោះពី ២០ ទៅ ២៩ និងមិនជោគជ័យ ប្រសិនបើពិន្ទុសរុបទាំងអស់ មានត្រឹម តែ ១៩ ឬតិចជាងនេះ ។

## លក្ខខណ្ឌយោង (គំរូវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសប៊ូតាន)

១. ស្ថិតនៅក្រោមការណែនាំរបស់អ្នកឯកទេសផ្នែកវាយតម្លៃបង្គោល ការវាយតម្លៃ នឹងត្រូវទទួលបានការគាំទ្រដោយទីប្រឹក្សាអន្តរជាតិពីររូប និងទីប្រឹក្សាក្នុងប្រទេសចំនួនពីររូបដែរ ។ ទីប្រឹក្សាទាំងនេះ ត្រូវធ្វើការសម្របសម្រួលចំណាត់តាំងការងារ និងកាលវិភាគការងាររបស់ខ្លួន និងធ្វើការផ្លាស់ប្តូរព័ត៌មានលើផ្នែកណាដែលមានអត្ថប្រយោជន៍ចំពោះគ្នាទៅវិញទៅមក ហើយការផ្លាស់ប្តូរទាំងនោះមានប្រយោជន៍ដល់លទ្ធផលនៃការវាយតម្លៃ។

២. ទីប្រឹក្សាអន្តរជាតិនីមួយៗ ត្រូវធ្វើរបាយការណ៍ស្តីពីប្រធានបទរបស់ខ្លួន *(ប្រធានវាយតម្លៃ)* ។ គម្រោងរបាយការណ៍ នឹងត្រូវធ្វើការឯកភាពក្នុងចំណោមអ្នកនៅក្នុងក្រុមវាយតម្លៃនោះ ដើម្បីធ្វើឱ្យរបាយការណ៍នីមួយៗ អាចប្រៀបធៀបបាន និងមានអត្ថប្រយោជន៍ក្នុងការរៀបចំរបាយការណ៍វាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសចុងក្រោយ ។

## ក. ទីប្រឹក្សាអន្តរជាតិ

### ១. អ្នកឯកទេសរៀបចំយុទ្ធសាស្ត្រ និងវាយតម្លៃគម្រោងពហុវិស័យ (រយៈពេលបីខែ)

៣. ទីប្រឹក្សាទទួលខុសត្រូវក្នុងការវាយតម្លៃបង្គោលទៅលើកម្មវិធីជំនួយប្រចាំប្រទេស (CAP) របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) តាមរយៈទិដ្ឋភាពនៃការវិភាគកម្មវិធីកម្ចី និងមិនមែនកម្ចី ដោយប្រៀបធៀបជាមួយនឹងយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការនានារបស់រដ្ឋាភិបាល ព្រមទាំងយុទ្ធសាស្ត្រ គោលនយោបាយ និងផែនការនានារបស់អ្នកផ្តល់ជំនួយផ្សេងទៀតដែរ ។ ទីប្រឹក្សាគួរមានចំណេះដឹងផ្នែកអភិវឌ្ឍន៍ និងមានបទពិសោធន៍ការងារទូលំទូលាយនៅក្នុងការធ្វើផែនការអភិវឌ្ឍន៍ ម៉ាក្រូសេដ្ឋកិច្ច ការរៀបចំគម្រោង ការអនុវត្ត និងការវាយតម្លៃ គម្រោងនៅក្នុងវិស័យនានាសំខាន់បំផុត គឺត្រូវមានបទពិសោធន៍ចុះធ្វើការតាមទីកន្លែងគោលដៅនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ។ ក្នុង នាមជាសមភាគីទីប្រឹក្សាក្នុងស្រុកត្រូវជួយទីប្រឹក្សាអន្តរជាតិ ។

៤. ទីប្រឹក្សាត្រូវអនុវត្តភារៈកិច្ចដូចខាងក្រោម :

(i) ជួយរៀបចំឯកសារដែលបរិយាយលម្អិតអំពីវិធីសាស្ត្រដែលត្រូវអនុវត្តពេលធ្វើការសិក្សា (ក) ម៉ាទ្រិកនៃសំណួរគន្លឹះដែលមានមុខងារជាមគ្គុទេសក៏ ក្នុងអំឡុងពេលពិភាក្សាជាមួយមន្ត្រីរដ្ឋាភិបាល និងអ្នកពាក់ព័ន្ធផ្សេងទៀត (ខ) ការវាយតម្លៃទៅលើយុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍរបស់ប្រទេសប៊ូតាន រួមទាំងការងារសេដ្ឋកិច្ចសង្គម និង (គ) ការវាយតម្លៃដំបូងទៅលើយុទ្ធសាស្ត្រ និងកម្មវិធីជំនួយរបស់អ្នកផ្តល់ជំនួយធំៗ ។

(ii) ត្រួតពិនិត្យឯកសារ និងស្វែងរកព័ត៌មានចាំបាច់ស្តីពីយុទ្ធសាស្ត្រប្រតិបត្តិការប្រចាំប្រទេសរបស់ ADB ចាប់តាំងពីឆ្នាំ១៩៩១-២០០៣ និងព័ត៌មានស្តីពីសកម្មភាពរបស់ដៃគូផ្សេងទៀត ដែលមានភាពទាក់ទងនឹងការសិក្សា ។

(iii) វិភាគកិច្ចការសេដ្ឋកិច្ចរបស់ ADB (របាយការណ៍សេដ្ឋកិច្ច និងការធ្វើបច្ចុប្បន្នភាព ការវិភាគ ការបោះពុម្ពផ្សាយ) និងវាយតម្លៃថាតើរបាយការណ៍ទាំងនេះ បានផ្តល់នូវការវាយតម្លៃយ៉ាងលម្អិត និងត្រឹមត្រូវទៅលើស្ថានភាពនៅក្នុងប្រទេសប៊ូតានដែរ ឬទេ ។

(iv) វាយតម្លៃថាតើការវិភាគសេដ្ឋកិច្ច/ការវិភាគលើវិស័យនានា មានសេចក្តីសន្និដ្ឋានសមហេតុផល និងស្របតាមសភាពការណ៍ពិតដែលអាចយកមកប្រើប្រាស់ដើម្បីរៀបចំផែនការយុទ្ធសាស្ត្របានដែរ ឬទេ ។

(v) វាយតម្លៃលើភាពសមស្របនៃការបង្កើត CAP បន្ទាប់ពីធ្វើការពិចារណាទៅលើបញ្ហា និងចំណោទនានាដែលបានកំណត់ និងប្រឈមចំពោះវិស័យនីមួយៗ នៅពេលពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ។

(vi) ដឹកនាំ និងសម្របសម្រួលសកម្មភាពទីប្រឹក្សាក្នុងស្រុក ជាពិសេសទៅលើការប្រមូលទិន្នន័យ (ឯកសារ របាយការណ៍ និងស្ថិតិ) រួមទាំងសូចនាករសម្រាប់វាស់វែងលទ្ធផល ។

(vii) ដោយផ្អែកទៅលើការវិភាគការរៀបចំ និងដោយបានប្រឹក្សាយោបល់ជាមួយអ្នកឯកទេសវាយតម្លៃបង្គោល និងទីប្រឹក្សាក្នុងស្រុក ត្រូវធ្វើការកំណត់គម្រោងណាដែលត្រូវចុះធ្វើអង្កេតដល់ទីកន្លែង ។

(viii) ចុះធ្វើការវាយតម្លៃដល់ទីកន្លែង ដោយមានកិច្ចសម្របសម្រួលពីសំណាក់ទីប្រឹក្សាក្នុងស្រុកដើម្បីវិភាគ និងវាយតម្លៃឱ្យបានស៊ីជម្រៅទៅលើគម្រោងកម្ចី និងជំនួយបច្ចេកទេស (TA) ឥតសំណង ។

(ix) វាយតម្លៃភាពទាក់ទងនៃយុទ្ធសាស្ត្រអភិវឌ្ឍន៍ទាំងរបស់រដ្ឋាភិបាល និងរបស់ ADB ទៅនឹងបញ្ហាផ្សេងៗនៅក្នុងប្រទេសប៊ូតាន រួមមានកង្វល់ស្តីពីម៉ាក្រូសេដ្ឋកិច្ច វិស័យ និងបញ្ហាដែលប្រទាក់ក្រឡាគ្នា ។

(x) សម្របសម្រួលតាមកិច្ចការរបស់ ADB ដែលកំពុងដំណើរការទាក់ទងនឹងប្រទេសប៊ូតាន ។

(xi) ដោយមានការសម្របសម្រួលជាមួយនឹងទីប្រឹក្សាអន្តរជាតិ និងទីប្រឹក្សាក្នុងស្រុកផ្សេងទៀត ការវាយតម្លៃ CAP និងយុទ្ធសាស្ត្រប្រតិបត្តិការរបស់ ADB ចាប់ពីឆ្នាំ១៩៨៣ ដល់ពេលបច្ចុប្បន្ន ត្រូវធ្វើឡើងដោយវាស់វែងភាពទាក់ទងតាមវិស័យ ប្រសិទ្ធភាព ប្រសិទ្ធភាព និរន្តរភាព ការអភិវឌ្ឍស្ថាប័ន និងផលប៉ះពាល់ផ្សេងទៀត ។

(xii) កំណត់មេរៀនបានមកពី CAP រួមមានកម្មវិធីកម្ចី និងមិនមែនកម្ចីដែលអនុវត្តដោយ ADB និងរៀបចំជាអនុសាសន៍ស្តីពីវិធីលើកកម្ពស់វិស័យនីមួយៗបន្ថែមទៀត ។

(xiii) ធ្វើសេចក្តីព្រាងរបាយការណ៍ CAPE លើផ្នែកដែលទាក់ទង ដោយបញ្ចូលលទ្ធផលជាមួយនឹងការវិភាគ ហើយដោយបានប្រឹក្សាយោបល់ជាមួយនឹងអ្នកឯកទេសវាយតម្លៃអភិវឌ្ឍន៍ស្ថាប័ន ។

(xiv) សរសេរបញ្ចប់នូវសេចក្តីព្រាងដែលបានកែសម្រួល លើរបាយការណ៍ CAPE ត្រង់ផ្នែកដែលទាក់ទងដោយបញ្ចូលមូលវិចារណ៍ជាមួយនឹងសំណូមពរពាក់ព័ន្ធដែលបានទទួល និងលទ្ធផលដែលបានមកពីការចូលរួមក្នុងសិក្ខាសាលា ។

(xv) រៀបចំកិច្ចការពាក់ព័ន្ធទាំងឡាយដែលទាក់ទងទៅនឹង CAPE តាមតម្រូវការរបស់អ្នកឯកទេសវាយតម្លៃបង្គោល ។

## ២. **អ្នកឯកទេសវាយតម្លៃការអភិវឌ្ឍស្ថាប័ន** (រយៈពេលពីរខែ)

៥. ទីប្រឹក្សា ទទួលខុសត្រូវក្នុងការវាយតម្លៃកម្រិតថ្នាក់ម៉ាក្រូទៅលើបញ្ហាកំណែទម្រង់គោលនយោបាយ ដែលប៉ះពាល់ដល់ស្ថាប័ននានានៅគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសប៊ូតាន់ ។ ទីប្រឹក្សា ទទួលខុសត្រូវក្នុងការវាយតម្លៃកម្មវិធីប្រចាំប្រទេស ដោយមើលពីទិដ្ឋភាពរបស់ ស្ថាប័ន និងតាមរយៈការវាយតម្លៃលទ្ធផលការងារទូលំទូលាយទៅលើប្រតិបត្តិការរបស់ TA ជាចម្បង ។ ទីប្រឹក្សាគួរមានចំណេះដឹងជាមូលដ្ឋានក្នុងផ្នែកសេដ្ឋកិច្ច ឬផ្នែកណាដែលទាក់ទង និងបទពិសោធន៍ច្រើននៅក្នុងការរៀបចំគម្រោង ការអនុវត្ត និងការវាយតម្លៃនៅក្នុង វិស័យផ្សេងៗទៀត ។ បទពិសោធន៍ការងារចុះធ្វើការដល់ទីកន្លែងគោលដៅ នៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍ដែលមានស្ថានភាពប្រហាក់ប្រហែល គឺតម្រូវឱ្យមានជាចាំបាច់ ។ ក្នុងនាមជាសមភាគី ទីប្រឹក្សាក្នុងស្រុក នឹងជួយទីប្រឹក្សាអន្តរជាតិ ។

៦. ទីប្រឹក្សានឹងត្រូវអនុវត្តភារៈកិច្ចដូចខាងក្រោម :

(i) ត្រួតពិនិត្យមើលពីទីកន្លែងដែលស្ថាប័នត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៨៣ នៅពេលដែល ADB ចាប់ផ្តើមប្រតិបត្តិការរបស់ខ្លួននៅក្នុងប្រទេសប៊ូតានដើម្បីកំណត់ស្ថានភាព និងបញ្ហាគន្លឹះដែលមាននៅពេលនោះ ។

(ii) ត្រួតពិនិត្យឯកសារ និងខិតខំស្វែងរកព័ត៌មានចាំបាច់ស្តីពី CAP របស់ ADB តាំងពីឆ្នាំ១៩៨៣-២០០៣ និងព័ត៌មានស្តីពីសកម្មភាពរបស់ម្ចាស់ជំនួយផ្សេងទៀតដែលទាក់ទងទៅនឹងការសិក្សា ។

(iii) ចូលរួមជាមតិយោបល់ផ្សេងៗសម្រាប់របាយការណ៍ទាក់ទងនឹងវិធីសាស្រ្តសម្រាប់ការសិក្សាស្រាវជាវ ដែលត្រូវរៀបចំឡើងដោយអ្នកឯកទេសរៀបចំយុទ្ធសាស្រ្ត និងវាយតម្លៃគម្រោងពហុវិស័យ ។

(iv) ពិភាក្សា និងកំណត់បញ្ហា និងចំណោទនានាក្នុងការអនុវត្ត ជាមួយនឹងអ្នកពាក់ព័ន្ធរបស់ ADB និងនៅក្នុងប្រទេសប៉ុន្តែទាក់ទងនឹងការកំហិតរបស់ស្ថាប័ន ។

(v) ត្រួតពិនិត្យ និងសម្របសម្រួលសកម្មភាពរបស់ទីប្រឹក្សាក្នុងស្រុក ជាពិសេសទាក់ទងនឹងការប្រមូលទិន្នន័យ (ឯកសារ របាយការណ៍ និងស្ថិតិ) ។

(vi) ផ្ទៀងផ្ទាត់ និងធ្វើឱ្យប្រសើរឡើងនូវការប្រមូលព័ត៌មាន តាមរយៈការពិភាក្សាជាមួយនឹងមន្ត្រីរដ្ឋាភិបាលពាក់ព័ន្ធ អ្នកផ្តល់ជំនួយ និងអ្នកពាក់ព័ន្ធផ្សេងទៀត ។

(vii) វាយតម្លៃទៅលើការអនុវត្តទូទៅនៃសេវាមិនមែនកម្ចីរបស់ ADB ដូចជាការសម្របសម្រួលជំនួយ និងគោលនយោបាយតាមរយៈគោលនយោបាយ / កំណែទម្រង់ស្ថាប័ន ។

(viii) វាយតម្លៃទៅលើការអនុវត្តទូទៅនៃសេវាមិនមែនកម្ចីរបស់ ADB ដូចជា TAs (ជំនួយបច្ចេកទេស) ប្រឹក្សាការកសាងសមត្ថភាពតាមស្ថាប័ន ព្រមទាំងការងារសេដ្ឋកិច្ច តាមប្រធានបទ និងតាមវិស័យដែលផ្អែកលើគោលនយោបាយ និង TAs សម្រាប់តំបន់ ។

(ix) ភាគច្រើន តាមទស្សនៈនៃការអភិវឌ្ឍស្ថាប័ន និងដោយមានការសម្របសម្រួលជាមួយនឹងទីប្រឹក្សាអន្តរជាតិ និងក្នុងស្រុកផ្សេងទៀត ការវាយតម្លៃ CAP របស់ ADB តាំងពីឆ្នាំ១៩៨៣ រហូតដល់ពេលបច្ចុប្បន្ន ត្រូវធ្វើឡើងដោយវាស់វែងភាពទាក់ទង ប្រសិទ្ធភាព ប្រសិទ្ធផល និរន្តរភាព និង ផលប៉ះពាល់របស់ខ្លួន ។

(x) កំណត់នូវមេរៀនដែលបានទទួលពីជំនួយប្រចាំប្រទេសដែលអនុវត្តដោយ ADB និងរៀបចំជាអនុសាសន៍ស្តីពីរបៀបធ្វើឱ្យប្រសើរបន្ថែមទៀតដល់ការអភិវឌ្ឍន៍ស្ថាប័ន និងការអនុវត្តវិស័យសាធារណៈ ។

(xi) ព្រាងផ្នែកទាំងឡាយណាដែលជាប់ពាក់ព័ន្ធទៅនឹងរបាយការណ៍ CAPE ដោយការបញ្ចូលលទ្ធផលទៅនឹងការវិភាគទៅក្នុងពង្រាងនោះ និងដោយបានប្រឹក្សាជាមួយអ្នកឯកទេសរៀបចំយុទ្ធសាស្រ្ត និងវាយតម្លៃគម្រោងពហុវិស័យផងដែរ ។

(xii) សរសេរបញ្ចប់នូវសេចក្តីព្រាងដែលបានកែសម្រួល លើរបាយការណ៍ CAPE ត្រង់ផ្នែកដែលពាក់ព័ន្ធដោយផ្តល់ជាមូលវិចារណ៍ និងសំណូមពរពាក់ព័ន្ធដែលទទួលបាន និងលទ្ធផលដែលបានមកពីការចូលរួមក្នុងសិក្ខាសាលា។

(xiii) រៀបចំកិច្ចការពាក់ព័ន្ធទាំងឡាយដែលទាក់ទងទៅនឹង CAPE តាមតម្រូវការរបស់អ្នកឯកទេសវាយតម្លៃបង្គោល ។

## ខ. **ទីប្រឹក្សាក្នុងស្រុក** (រយៈពេលពីរខែ/ម្នាក់)

៧. ទីប្រឹក្សាក្នុងស្រុក នឹងជួយទីប្រឹក្សាអន្តរជាតិ (ម្នាក់សម្រាប់អ្នកឯកទេសរៀបចំយុទ្ធសាស្រ្ត និងវាយតម្លៃគម្រោងពហុវិស័យ និងម្នាក់ទៀតសម្រាប់អ្នកឯកទេសវាយតម្លៃការអភិវឌ្ឍតាមស្ថាប័ន) ក្នុងការស្រង់ប្រភព និងត្រួតពិនិត្យឯកសារកម្មវិធីប្រចាំប្រទេសដែលជាប់ពាក់ព័ន្ធ ផែនការ និងរបាយការណ៍របស់រដ្ឋាភិបាល និងឯកសារពីប្រភពផ្សេងៗទៀត និងត្រូវដឹកនាំការសម្ភាសន៍ជាមួយនឹងអ្នកទទួលអត្ថប្រយោជន៍ ពីជំនួយរបស់ ADB នៅក្នុងមូលដ្ឋាន ដែលបានជ្រើសរើសរួចជាស្រេច ។

ឧបសម្ព័ន្ធ ៣

៨. ទីប្រឹក្សានីមួយៗ ត្រូវអនុវត្តនូវភារៈកិច្ចដូចខាងក្រោម ៖

(i) ដោយមានកិច្ចសហប្រតិបត្តិការជាមួយនឹងសមភាគីរបស់ខ្លួន ការត្រួតពិនិត្យគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយតាមវិស័យសំខាន់ របស់រដ្ឋាភិបាល និងវាយតម្លៃការអនុវត្តតាមវិស័យចាប់តាំងពីឆ្នាំ១៩៨៣ ត្រូវធ្វើឡើង ដោយពិចារណាទៅលើយុទ្ធសាស្ត្រ និងផែនការរបស់រដ្ឋាភិបាល ។

(ii) វាយតម្លៃប្រសិទ្ធភាពនៃអន្តរាគមន៍របស់ ADB នៅក្នុងវិស័យនានាដែលបានកត់សម្គាល់ដោយអ្នកទទួលអត្ថប្រយោជន៍, ទីភ្នាក់ងារអភិវឌ្ឍន៍ (EAs) និងអ្នកពាក់ព័ន្ធផ្សេងៗទៀត ។

(iii) ជួយត្រួតពិនិត្យរបាយការណ៍ផែនការ និងយុទ្ធសាស្ត្រជំនួយប្រចាំប្រទេស ការងារសេដ្ឋកិច្ច និងការងារតាមវិស័យដែលជាប់ពាក់ព័ន្ធ និងការពិភាក្សាគោលនយោបាយជាមួយនឹងរដ្ឋាភិបាលចាប់តាំងពីឆ្នាំ១៩៨៣ ។

(iv) ជួយត្រួតពិនិត្យកម្មវិធីជំនួយតាមវិស័យដែលជាប់ពាក់ព័ន្ធដូចដែលមាននៅក្នុង CAPs និងវាយតម្លៃនូវភាពទាក់ទង សង្គតិភាព និងផលប៉ះពាល់ ដែលនាំទៅរកវត្ថុបំណងជាយុទ្ធសាស្ត្រនៅក្នុងវិស័យនានានៃកម្មវិធីទាំងនោះ ។

(v) វាយតម្លៃកម្រិតនៃការគាំទ្រចំពោះវិស័យទាំងឡាយដែលជាប់ពាក់ព័ន្ធជាមួយនឹងទីភ្នាក់ងារអ្នកផ្តល់ជំនួយផ្សេងទៀតដោយផ្អែកទៅលើការសិក្សា និងរបាយការណ៍ដែលមាន ។

(vi) ត្រួតពិនិត្យឯកសារកម្មវិធី និងឯកសារគម្រោងដែលជាប់ពាក់ព័ន្ធ ដូចជារបាយការណ៍ស្តីពីសេដ្ឋកិច្ចប្រចាំប្រទេស ផែនការអភិវឌ្ឍរបស់រដ្ឋាភិបាល របាយការណ៍វាយតម្លៃ និងរបាយការណ៍បញ្ចប់គម្រោងដែលឯកសារទាំងអស់នេះជាប់ពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ ADB នៅក្នុងប្រទេស ប៊ូតាន់ ។

(vii) ដោយសហការជាមួយនឹងទីប្រឹក្សាអន្តរជាតិ ត្រូវជួយសម្រួលបន្ទុកការអង្កេត និងការចុះវាយតម្លៃដល់ទីកន្លែងដោយសហការឱ្យបានជិតស្និទ្ធជាមួយនឹង EA ទៅលើគម្រោងដែលគេបានជ្រើសរើស ។

(viii) ពិភាក្សាជាមួយនឹង EAs និងរដ្ឋាភិបាលផ្សេងៗទៀត និងបុគ្គលដែលមិនមែនជារដ្ឋាភិបាល អំពីបញ្ហា និងកង្វល់ទាក់ទងនឹងការអភិវឌ្ឍ ដូចជាលទ្ធផល និងផលប៉ះពាល់នៃជំនួយរបស់ ADB នៅក្នុងវិស័យនានា ។

(ix) ផ្អែកតាមប្រការ (iii) ដល់ (vi) និងប្រការ (vii) ដល់ (viii) កំណត់នូវវិស័យសំខាន់ៗនៃជំនួយរបស់ ADB និងធ្វើការវាយតម្លៃកម្រិតនៃសមិទ្ធផលដែលសម្រេចបានដូចដែលបានលើកឡើងនៅក្នុងវត្ថុបំណងតាមបណ្តាវិស័យ ដូចជា (ក) កំណើនសេដ្ឋកិច្ចដែលជួយលើកកម្ពស់កម្រិតជីវភាពរស់នៅ និងគុណភាពនៃជីវិត (ខ) ការកាត់បន្ថយភាពក្រីក្រ និង (គ) ការអភិវឌ្ឍស្ថាប័ន និងការកសាងសមត្ថភាព ។

(x) រៀបចំកិច្ចការពាក់ព័ន្ធទាំងឡាយដែលទាក់ទងទៅនឹង CAPE តាមតម្រូវការរបស់អ្នកឯកទេសវាយតម្លៃបង្គោល ។

# ការវាយតម្លៃភាពជាម្ចាស់លើការវាយម្លៃកម្មវិធីជំនួយប្រចាំប្រទេស

១. ភាពជាម្ចាស់ សំដៅលើកម្រិតដែលរដ្ឋាភិបាលផ្តាច់ជ្ជាចិត្តយ៉ាងពេញទំហឹងដើម្បីចូលរួម គ្រប់គ្រង និងទទួលខុសត្រូវចំពោះកម្មវិធីនៃជំនួយប្រចាំប្រទេស។[១] វាគឺជាដេទៃមីណង់ដ៏សំខាន់របស់ការអនុវត្តកម្មវិធី ។ នៅក្នុងប៉ុន្មានឆ្នាំថ្មីៗនេះ ការវាយតម្លៃទៅលើទំនាក់ទំនងរវាងប្រតិបត្តិការកម្ចីដែលផ្អែកលើគោលនយោបាយ និងភាពជាម្ចាស់របស់ប្រទេស កាន់តែមានសភាពស្មុគស្មាញ និងលេចចេញកាន់តែច្បាស់ ។ គេយកចិត្តទុកដាក់បន្ថែមទៀត ទៅលើកត្តាជាក់លាក់របស់ប្រទេសដែលកំណត់ភាពជាម្ចាស់ទៅលើកម្ចីដែលផ្អែកលើគោលនយោបាយ និងតួនាទីដែលធនាគារអភិវឌ្ឍពហុភាគី (MDBs) អាចជំរុញការប្តេជ្ញាចិត្តរបស់ប្រទេសឱ្យកាន់តែខ្លាំងឡើងក្នុងដំណើរការកំណែទម្រង់ ។

២. ជារឿយៗ ប្រព្រឹត្តិកិច្ចនៃភាពជាម្ចាស់ គឺមានសភាពមិនស៊ីជម្រៅទេនៅក្នុងការវាយតម្លៃប្រទេស ។ ដូចលោក Johnson (1993) បានកត់សម្គាល់ថា : "ការកំណត់ភាពជាម្ចាស់របស់អ្នកខ្ចី ជាទូទៅផ្អែកទៅលើហេតុការណ៍ពីរយ៉ាង : ហេតុការណ៍ទីមួយគឺ ការគ្មានបទដ្ឋានវត្ថុបំណងសូម្បីតែសម្រាប់ធ្វើការកំណត់ចុងក្រោយនូវអ្វីដែលបង្កើតឱ្យមានភាពជាម្ចាស់គ្រប់គ្រាន់លើកម្មវិធី ហើយហេតុការណ៍ទីពីរ គឺទំនាក់ទំនងរវាងភាពជោគជ័យនៃកម្មវិធី និងភាពជាម្ចាស់ ដែលអាចងាយទទួលរងនូវការលើកឡើងថា *ដោយសារតែមានហេតុការណ៍ ទីមួយនេះហើយ ទើបបណ្តាលឱ្យមានហេតុការណ៍ទីពីរ :* ប្រសិនបើកម្មវិធី ទទួលបានជោគជ័យ ភាពជាម្ចាស់ក៏កើតមានដែរ ។ ផ្ទុយទៅវិញ ប្រសិនបើកម្មវិធីបរាជ័យ ភាពជាម្ចាស់ក៏គ្មានដែរ ។ ខណៈដែលមនុស្សមួយចំនួនតូច ចោទសួរអំពីសារៈសំខាន់នៃភាពជាម្ចាស់ចំពោះភាព ជោគជ័យនៃកម្មវិធី បញ្ហាប្រឈមសម្រាប់ការវាយតម្លៃគឺ ការបង្កើតនូវសំណុំឧបករណ៍មានលក្ខណៈជាប្រព័ន្ធ ដើម្បីវាយតម្លៃការប្តេជ្ញាចិត្តយ៉ាងច្បាស់លាស់បំផុតក្នុងការរៀបចំ និងការអនុវត្តកម្មវិធីជំនួយដែលបានព្រមព្រៀង ។

៣. មានឧបករណ៍ផ្សេងៗគ្នាមួយចំនួនសម្រាប់ធ្វើការវាយតម្លៃភាពជាម្ចាស់ ត្រូវបានស្នើរ និងកែសម្រួលឡើងដោយអង្គភាពវាយតម្លៃរបស់ MDB ។ ឧបករណ៍ទាំងនោះមានដូចជា ការវិភាគមគ្គុទេសក៍ ការវិភាគអ្នកពាក់ព័ន្ធ និងការវិភាគការត្រៀមធ្វើកំណែទម្រង់ ។ ឧបករណ៍ទាំងនេះ អាចត្រូវបានយកមកប្រើនៅក្រោយពេលវាយតម្លៃ ដើម្បីពិនិត្យមើលទំនាក់ទំនងបន្តបន្ទាប់មកទៀតរវាងការអនុវត្តកម្មវិធី និងការប្តេជ្ញាចិត្តរបស់ប្រទេស ។

៤. ការវិភាគមគ្គុទេសក៍ គឺជាការវាយតម្លៃទៅលើចំណុចស្នូលនៃគំនិតផ្តួចផ្តើមក្នុងការបង្កើតកម្មវិធី គំនិតដ៏វាងវៃក្នុងចំណោមអ្នករៀបចំគោលនយោបាយសំខាន់ៗ សុឆន្ទៈនយោបាយក្នុងចំណោមអ្នកដឹកនាំជាន់ខ្ពស់ និងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានការស្រុះស្រួលមតិគ្នាក្នុងចំណោមអ្នកគាំទ្រទាំងឡាយ ។ ការវិភាគនេះចាប់ផ្តើមឡើងដោយការស្វែងយល់អំពីដំណើរការនយោបាយ និងអន្តរសកម្មរបស់ខ្លួនជាមួយនឹងការផ្លាស់ប្តូរគោលនយោបាយដែលគាំទ្រដោយកម្មវិធីជំនួយ ។ ការវិភាគនេះ កំណត់នូវកត្តាជ្រោមជ្រែងការធ្វើកំណែទម្រង់ និងវាយតម្លៃទៅលើកម្រិតនៃការគាំទ្រដែលក្រុមអ្នករៀបចំគោលនយោបាយទាំងអស់នោះអាចនឹងត្រូវការ ដើម្បីមានទំនោទៅរកការគាំទ្រផ្នែកនយោបាយលើកំណែទម្រង់ដែលឧបត្ថម្ភដោយកម្មវិធី ឬលើកំណែទម្រង់ផ្សេងទៀត ។

៥. ការវិភាគអ្នកពាក់ព័ន្ធ ត្រូវបានប្រើដើម្បីធ្វើផែនការកំណត់ក្រុមណាខ្លះ ដែលទទួលរងឥទ្ធិពលពីកម្មវិធី និងដើម្បីរៀបចំផែនការមួយដែលទាក់ទងទៅនឹងអ្នកពាក់ព័ន្ធផ្សេងៗទៀតនៅក្នុងការកំណត់ និងអនុវត្តកម្មវិធីជំនួយ ។ ការវិភាគនេះ កំណត់នូវវត្ថុបំណងសំខាន់ៗដែលអ្នកពាក់ព័ន្ធនីមួយៗ មាននៅក្នុងកម្មវិធីជំនួយ រួមទាំងអ្នកពាក់ព័ន្ធទាំងឡាយណាដែលទំនងជាទទួលបានជោគជ័យ និងបរាជ័យនៅក្នុងកំណែទម្រង់ដែលកម្មវិធីបាន

---

[១] សូមមើលប្រភពខាងក្រោមសម្រាប់ការពិភាក្សាលំអិតបន្ថែមទាក់ទងនឹងបញ្ហាដែលកើតមាននៅក្នុងការធ្វើរង្វាស់រង្វាល់ទៅលើភាពជាម្ចាស់ ³ (i) Bolt, Richard, M. Fujimura, C. Houser, F. Nixson, and J. Weiss. 2003. *Economic Analysis of Policy-Based Operations: Key Dimensions.* Economics and Research Department Special Study. Manila: ADB. p. 64; (ii) http://wwww.adb.org.; and (iii) Johnson, John H. and Suliman S. Watsy. 1993. *Borrower Ownership of Adjustment Programmes and the Political Economy of Reform.* World Bank Discussion Paper No. 199. World Bank.

គាំទ្រ ។ គេនឹងធ្វើការពិភាក្សាទៅលើយុទ្ធសាស្ត្រសម្រាប់រៀបចំអ្នកដែលអាចទទួលបានជោគជ័យ ឱ្យចូលទៅក្នុងក្រុមចម្រុះដែលគាំទ្រកម្មវិធីយុទ្ធសាស្ត្រ សម្រាប់ ជាការលើកទឹកចិត្តដល់អ្នកចាញ់ និងយុទ្ធសាស្ត្រដែលនាំឱ្យទទួលបានជោគជ័យលើភាគីអព្យា ក្រិត ដើម្បីធ្វើការគាំទ្រដល់កំណែទម្រង់។

៦. ការវិភាគការត្រៀមធ្វើកំណែទម្រង់ គឺជាការវាយតម្លៃទៅលើសនិទានភាពដែល MDBs ព្រមទាំងរដ្ឋាភិបាល និងបណ្ដាភាគីផ្សេងទៀតមាន ដើម្បីគាំទ្រទិដ្ឋភាពផ្សេងៗគ្នានៃកម្មវិធី ហើយការវិភាគនេះ ពិនិត្យមើលការរៀបចំស្ថាប័នដែលមានឥទ្ធិពលទៅលើសមត្ថភាពរបស់តួអង្គផ្សេងៗ ដើម្បីធ្វើឱ្យមានអានុភាពដល់ការសម្រេចចិត្ត និងការអនុវត្តកម្មវិធី ។ ចំណុចចាប់ផ្ដើមសម្រាប់ធ្វើការវិភាគការត្រៀមធ្វើកំណែទម្រង់ គឺការស្វែងយល់អំពីវត្ថុបំណងផ្សេងដែលជំរុញឱ្យភាគីទាំងនោះឯកភាពលើមាតិការបស់យុទ្ធសាស្ត្រ និងកម្មវិធីជំនួយប្រចាំប្រទេសនៃធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ។ ការវិភាគការត្រៀមធ្វើកំណែទម្រង់ ក៏មានបញ្ចូលការវាយតម្លៃទៅលើការផ្ដល់រង្វាន់លើកទឹកចិត្តដល់ស្ថាប័ន និងសមត្ថភាពសម្រាប់គ្រប់គ្រងដំណើរការផ្លាស់ប្ដូរដែរ ។ ការផ្លាស់ប្ដូរនៅក្នុងដំណាក់កាលរៀបចំ ឬអនុវត្តន៍ អាចធ្វើទៅបាន ប្រសិនបើការវិភាគការត្រៀមធ្វើកំណែទម្រង់ បង្ហាញថា ការលើកទឹកចិត្ត និងសមត្ថភាពដើម្បីគ្រប់គ្រងគម្រោងនៅពុំទាន់មានលក្ខណៈគ្រប់គ្រាន់នៅឡើយ ។

៧. សូម្បីតែ ពេលដែលឧបករណ៍វាយតម្លៃលើភាពជាម្ចាស់ជាផ្លូវការ មិនត្រូវបានយកមកប្រើក៏ដោយ ការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេសប្រកបដោយគុណភាពខ្ពស់ ទំនងជាអាចដោះស្រាយបាននូវបញ្ហាដែលទាក់ទងនឹងមគ្គុទេសក៏តាមបែបយុទ្ធសាស្ត្ររបស់រដ្ឋាភិបាលនៅក្នុងការកំណត់យុទ្ធសាស្ត្រ និងអាទិភាពកម្មវិធី សុឆន្ទៈនៃការគាំទ្រទៅលើកម្មវិធី និងសុឆន្ទៈនៃភាពជាម្ចាស់របស់សង្គមស៊ីវិល និងកម្រិតដែលការរៀបចំយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេស ក៏ជួយពង្រឹងនូវភាពជាម្ចាស់ជាតិបានដែរ ។ សំណួរជាច្រើនដែលការវាយតម្លៃនេះចូលរួមដោះស្រាយ មានដូចខាងក្រោមនេះ:

- (i) តើយុទ្ធសាស្ត្រ និងកម្មវិធីរបស់រដ្ឋាភិបាល អាចចាត់ទុកជាមូលដ្ឋានដ៏រឹងមាំពិតប្រាកដមួយសម្រាប់កម្មវិធីជំនួយប្រចាំប្រទេសរបស់ ADB បានដែរ ឬទេ ?
- (ii) តើរដ្ឋាភិបាលមានជួយជ្រោមជ្រែងដល់កម្មវិធីដែរ ឬទេ ហើយតើពួកគេមានការគាំទ្រផ្នែកនយោបាយក្នុងកម្រិតខ្ពស់ដែរ ឬទេ ?
- (iii) តើភ្នាក់ងារជំនួយ (EAs) និងភ្នាក់ងារផ្សេងៗទៀតដែលទទួលខុសត្រូវអនុវត្តកម្មវិធី គាំទ្រការអនុវត្តកម្មវិធីពេញទំហឹងដែរ ឬទេ ?
- (iv) តើក្រុមដែលមានចំណាប់អារម្មណ៍សំខាន់ៗ និងសាធារណជនទូទៅ មានបានដឹងឮគ្រប់គ្រាន់អំពីគោលបំណង វត្ថុបំណង និងលទ្ធផលនៃកម្មវិធីជំនួយប្រចាំប្រទេសរបស់ ADB (CAP) រួមទាំងការគាំទ្រលើគោលនយោបាយ និងកំណែទម្រង់តាមស្ថាប័នដែរ ឬទេ ?
- (v) តើរដ្ឋាភិបាលមានបានចូលរួមឱ្យបានសកម្មនៅក្នុងកិច្ចដំណើរការរៀបចំយុទ្ធសាស្ត្រ និងកម្មវិធីជំនួយប្រចាំប្រទេសដែរ ឬទេ ?
- (vi) តើកម្មវិធីដែលបានរៀបចំហើយនោះ នឹងកសាងសមត្ថភាព ឬជួយពង្រឹងភាពជាម្ចាស់របស់ជាតិដែរ ឬទេ ?

៨. សូចនាករអំពីភាពជាម្ចាស់មួយចំនួនផ្សេងទៀត ដែលត្រូវបានយកមកប្រើនៅក្នុងការវាយតម្លៃ MDB រួមមានកម្រិតដែលដំណើរការចូលរួមទាក់ទងទៅនឹងការប្រឹក្សាជាមួយអ្នកពាក់ព័ន្ធទាំងអស់ បានជួយរួមចំណែកដល់ការបង្កើតកម្មវិធី និងកម្រិតដែលសនិទានភាពសម្រាប់កម្មវិធី និងផលប៉ះពាល់ដល់កម្មវិធី ដែលទំនងជាកើតមាន ត្រូវបានបកស្រាយប្រាប់សាធារណជនទូទៅ ហើយធ្វើឱ្យពួកគេទទួលយក ។

៩. Johnson និង Watsy បានបង្កើតនូវក្របខ័ណ្ឌមួយ ដែលត្រូវបានយកមកប្រើដើម្បីវាយតម្លៃភាពជាម្ចាស់នៅក្នុងការវាយតម្លៃរបស់ធនាគារពិភពលោក ។ ប្រព័ន្ធនៃការវាយតម្លៃនេះ បានចាត់ទុកភាពជាម្ចាស់ ថាជាអថេរឯករាជ្យដែលមានវិមាត្រចំនួនបួន ។ វិមាត្រទាំងបួននោះមានដូចជា (ក) ចំណុចស្នូលនៃគំនិតផ្ដួចផ្ដើម (ខ) កម្រិតនៃគំនិតដ៏វាងវៃក្នុងចំណោមអ្នករៀបចំគោលនយោបាយ (គ) ការសំដែងនូវសុឆន្ទៈនយោបាយរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់ និង (ឃ) និងកិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានការស្រុះស្រួលមតិគ្នាក្នុងចំណោមអ្នកគាំទ្រទាំងឡាយ ។ វិមាត្រនីមួយៗ ក្នុងចំណោមវិមាត្រទាំងបួននេះចែកចេញជាបួនកម្រិត ដែលឆ្លុះបញ្ចាំងពីអានុភាពនៃភាពជាម្ចាស់ ។ កម្រិតទាំងបួននេះគឺ : ខ្ពស់ណាស់ ខ្ពស់ ទាប និង ទាបណាស់ ។ យោងតាមលំដាប់នៃអានុភាព លក្ខណៈវិនិច្ឆ័យនេះ ត្រូវបានកំណត់ដូចខាងក្រោម (ដើម្បីឆ្លុះបញ្ចាំងពីតួនាទីរបស់ ADB) :

(i) ចំណុចស្នូលនៃគំនិតផ្តួចផ្តើម:

(ក) គំនិតផ្តួចផ្តើមក្នុងការបង្កើត និងការអនុវត្តនូវការកែសម្រួលកម្មវិធី គឺប្រាកដជារបស់អ្នកខ្ចី ។

(ខ) កម្មវិធីត្រូវបានជំរុញ និងបង្កើតឡើង ដោយមានកិច្ចសហប្រតិបត្តិការរវាងរដ្ឋាភិបាល និង ADB ។

(គ) កម្មវិធី ត្រូវបាន ADB រៀបចំឡើង ហើយអ្នកខ្ចី មានការប្តេជ្ញាចិត្តយ៉ាងមោះមុតក្នុងការអនុវត្តតាមកម្មវិធីនេះ ដោយគ្មានការជំទាស់ចាំបាច់ណាមួយឡើយ ។ ហើយ

(ឃ) កម្មវិធីនេះ ត្រូវបាន ADB រៀបចំឡើង និងមានការពន្យាលើការផ្តល់ថវិការ ទោះបីជាគ្មានការយល់ព្រម និងមានភាពស្ទាក់ស្ទើរពីសំណាក់រដ្ឋាភិបាលក្នុងការអនុវត្តនូវទិដ្ឋភាពមួយចំនួនដែលមាននៅក្នុងកម្មវិធីនោះក៏ដោយ ។

(ii) កម្រិតនៃគំនិតដ៏វាងវៃក្នុងចំណោមអ្នករៀបចំគោលនយោបាយសំខាន់ៗ :

(ក) មានកុងសង់ស៊ីសដែលអាចសង្កេតបាន និងលម្អិតមួយក្នុងចំណោមរវាង ក្រសួង/អ្នកធ្វើសេចក្តីសម្រេចចិត្តសំខាន់ៗដែលអាចកត់សម្គាល់ដឹងបាន ទាក់ទងទៅនឹងប្រភេទនៃបញ្ហា និងវិធានការដោះស្រាយចាំបាច់ ។

(ខ) ការវិភាគរកមើលវិបត្តិ និងដំណោះស្រាយទូទៅសម្រាប់ការធ្វើកំណែទម្រង់ បន្តិចម្តងៗ បានក្លាយជារឿងដែលមិនអាចខ្វះបាននៅក្នុងវដ្តនៃការ ធ្វើគោលនយោបាយ ។

(គ) មានការមិនឯកភាពគ្នាមួយចំនួនទៅលើចរិតនៃវិបត្តិ និងការជំទាស់ពីទីភ្នាក់ងារអនុវត្តទាក់ទងនឹងកម្រិត និង/ឬជំហាននៃកំណែទម្រង់ ។ និង

(ឃ) មានការឯកភាពគ្នាតិចតួចណាស់ក្នុងចំណោមអ្នករៀបចំគោលនយោបាយស្តីពីលក្ខណៈ និងមូលហេតុនៃវិបត្តិ និង/ឬវិធានការសមស្រប ។

(iv) ការសំដែងសុឆន្ទៈនយោបាយរបស់មេដឹកនាំជាន់ខ្ពស់ :

(ក) វិធានការជាក់លាក់ និងទុកជាមុនប្រកបដោយប្រសិទ្ធភាព ត្រូវបានផ្តួចផ្តើមបង្កើតឡើងមុន និងនៅពេលចាប់ផ្តើមកម្មវិធី ។

(ខ) មានការប្រកាសជាសាធារណៈរបស់ថ្នាក់ដឹកនាំជាន់ខ្ពស់នៃរដ្ឋាភិបាល គាំទ្រពេញទំហឹង និងឥតសំចៃទៅលើការធ្វើកំណែទម្រង់ ។

(គ) ថ្នាក់ដឹកនាំនយោបាយជាន់ខ្ពស់ បានសំដែងនូវការប្តេជ្ញាចិត្តបន្តិចបន្តួចប៉ុណ្ណោះចំពោះការធ្វើកំណែទម្រង់ ទោះបីជាលក្ខណៈពិតនៃបញ្ញត្តិជាក់លាក់សំខាន់ៗ ត្រូវបានរៀបចំសម្រាប់ធ្វើការកំណត់នៅពេលក្រោយ ដោយទុកឱ្យដើរបញ្ច្រាស ឬដើរថយក្រោយក៏ដោយ ។ និង

(ឃ) នៅពេលចាប់ផ្តើមកម្មវិធី មិនមានការបង្ហាញឱ្យបានច្បាស់ថា តើរដ្ឋាភិបាល ពិតជាធ្វើសកម្មភាពជាក់ស្តែងដើម្បីជំនះឧបសគ្គ ឬការរារាំងណាមួយពីសាធារណជន ឬពីផ្នែកឯកជនទៅលើការធ្វើកំណែទម្រង់ដែលបានស្នើរឡើងដែរ ឬទេ ។

(iv) កិច្ចខិតខំប្រឹងប្រែងធ្វើឱ្យមានការស្រុះស្រួលមតិគ្នាក្នុងចំណោមអ្នកគាំទ្រទាំងឡាយ :

(ក) រដ្ឋាភិបាលបានចាប់ផ្តើមយុទ្ធនាការជាសាធារណៈទ្រង់ទ្រាយធំដើម្បីជួយរៀបចំកម្មវិធី និង/ឬដើម្បីជួយបំផុសឱ្យមានការគាំទ្រក្រៅពីសំណាក់រដ្ឋាភិបាលកណ្តាល ។

(ខ) មានការខិតខំប្រឹងប្រែងយ៉ាងខ្លាំងក្លាពីសំណាក់អ្នកធ្វើគោលនយោបាយជាន់ខ្ពស់ ដើម្បីជំរុញឱ្យមានការកិច្ចសហប្រតិបត្តិការពីភ្នាក់ងារអនុវត្តសំខាន់ៗ នៅក្នុងការដាក់ចុះនូវកម្មវិធីកំណែទម្រង់នេះឡើង ។

(គ) មានការឯកភាពគ្នាពីអ្នកធ្វើសេចក្តីសម្រេចចិត្តថ្នាក់កណ្តាល ខណៈដែលភ្នាក់ងារផ្សេងទៀត មានការជាប់ពាក់ព័ន្ធតែនៅក្នុងការអនុវត្តទៅលើផ្នែកខ្លះនៃកម្មវិធី និង

(ឃ) EAs ក្នុងវិស័យសំខាន់ និងថ្នាក់ខេត្ត មិនបានពិគ្រោះយោបល់ជាមុន ហើយក៏មិនបានចូលរួមនៅក្នុងការអនុវត្តកម្មវិធីដែរ ។

១០. លក្ខណៈវិនិច្ឆ័យទាំងនេះ ត្រូវបានយកមកប្រើនៅក្នុងករណីវាយតម្លៃមួយដែលធ្វើទៅលើ *ការកែសម្រួលតាមវិស័យ និងរចនាសម្ព័ន្ធ* របស់ *ធនាគារពិភពលោក ១៩៨០-១៩៩២* (លេខយោង ១ [iii]) ។ ការសិក្សានោះ បានរកឃើញនូវការជាប់ទាក់ទងគ្នាយ៉ាងសំខាន់រវាងភាពជាម្ចាស់កម្មវិធី និងការទទួលបានជោគជ័យ ។ នៅក្នុងឧទាហរណ៍នេះ ប្រទេសចំនួន ៤ មានភាពជាម្ចាស់ក្នុងកម្រិត ខ្ពស់ណាស់ ១៤ ប្រទេសទៀត ខ្ពស់ ៤២ ទាប និង ១៩ ទាបណាស់ ។ លក្ខណៈវិនិច្ឆ័យ ក៏ត្រូវបានយកមកប្រើនៅក្នុងការវាយតម្លៃប្រចាំប្រទេសរបស់ធនាគារពិភពលោកដែរ ដែលនៅក្នុងការវាយតម្លៃនោះ កម្មវិធីជំនួយ ស្ថិតនៅក្រោមគំនាបដែលធ្វើឱ្យមានកំណែទម្រង់គោលនយោបាយ ។

## សាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យឡាវ៖
## ការអង្កេតលើអតិថិជន/អ្នកពាក់ព័ន្ធជាមួយនឹងការវាយតម្លៃកម្មវិធីជំនួយប្រចាំប្រទេស

ឈ្មោះអង្គការ ..........................................................................................................................................................

១. តើអ្នកយល់យ៉ាងណាចំពោះតួនាទីរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) នៅក្នុងការផ្តល់ជំនួយជាកម្ចី និងមិនមែនកម្ចីដល់សាធារណរដ្ឋប្រជាមានិត្យប្រជាធិបតេយ្យឡាវ ?

១ = ជាអ្នកផ្តល់ជំនួយដ៏សំខាន់លើគ្រប់វិស័យទាំងអស់

២ = ជាអ្នកផ្តល់ជំនួយដ៏សំខាន់នៅក្នុងវិស័យជាច្រើន

៣ = ជាអ្នកផ្តល់ជំនួយដ៏សំខាន់នៅក្នុងវិស័យមួយចំនួន

៤ = ជាអ្នកផ្តល់ជំនួយតូចតាច

២. សូមបញ្ជាក់ឱ្យបានច្បាស់លាស់នូវវិស័យណាដែលអ្នកគិតថា ADB គឺជាអ្នកផ្តល់ជំនួយនាំមុខគេ ។

..........................................................................................................................................................

៣. តើមានវិស័យណាខ្លះដែលអ្នកយល់ថា ADB គួរកាត់បន្ថយ/ដកយកត្រលប់មកវិញនូវជំនួយរបស់ខ្លួន ? ប្រសិនបើមាន សូមបញ្ជាក់ឱ្យបានច្បាស់លើវិស័យនោះ (ទាំងនោះ) និងមូលហេតុនោះ (ទាំងនោះ) ។

១ = គ្មានទេ

២ = មាន (បញ្ជាក់លើវិស័យណាមួយ [ឬណាខ្លះ]) ..........................................................................................

(បញ្ជាក់ពីមូលហេតុ [អ្វីខ្លះ]) អ្នកអាចជ្រើសរើសចម្លើយនៅខាងក្រោមលើសពីមួយ ។

ក = ADB ទំនងជាធ្វើមិនបានល្អសោះនៅក្នុងវិស័យទាំងនោះ

ខ = ADB កំពុងតែធ្វើបានល្អហើយ ប៉ុន្តែតួនាទីរបស់អ្នកផ្តល់ជំនួយផ្សេងៗទៀត មានភាពសំខាន់ជាង

គ = ADB កំពុងតែធ្វើបានល្អហើយ ប៉ុន្តែគួរតែមានកិច្ចខិតខំប្រឹងប្រែងរួមជាមួយនឹងអ្នកផ្តល់ជំនួយផ្សេងទៀត

ឃ = ផ្សេងៗ (សូមបញ្ជាក់) ..........................................................................................

៤. តើអ្នកយល់យ៉ាងណាចំពោះកម្រិតនៃការសម្របសម្រួលជំនួយនៅក្នុងប្រទេស ?

១ = គួរឱ្យពេញចិត្តណាស់

២ = គួរឱ្យពេញចិត្ត

៣ = ត្រូវការការកែលម្អខ្លះៗ

៤ = ត្រូវការការកែលម្អច្រើនទៀត

៥. តើកម្រិតនៃការសម្របសម្រួលជំនួយអ្វីខ្លះ ដែលអ្នកយល់ថាប្រទេសនោះ ត្រូវការបំផុតនោះ ?

១ = កម្រិតជាយុទ្ធសាស្ត្រ (ត្រូវការការពិគ្រោះយោបល់ក្នុងចំណោមដៃគូអភិវឌ្ឍន៍ ដើម្បីធ្វើឱ្យយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសមានភាពស្របគ្នា ដើម្បីឱ្យស៊ីសង្វាក់គ្នាជាមួយនឹងផ្នែក/វិស័យដែលជាអាទិភាពរបស់រដ្ឋាភិបាល ដើម្បីសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ និងដើម្បីចៀសវាងការខិតខំប្រឹងប្រែងធ្វើជាន់គ្នា និងម្តងធ្វើបែបនេះ ម្តងទៀតធ្វើបែបនោះ) ។

២ = កម្រិតការពិភាក្សា (ត្រូវការការពិភាក្សាលើគោលនយោបាយរួមថែមទៀតក្នុងចំណោមអ្នកផ្តល់ជំនួយ ដើម្បីខិតខំស្វែងរកនូវបញ្ហាគន្លឹះ ជាមួយនឹងរដ្ឋាភិបាលដោយស៊ីសង្វាក់គ្នា និងដើម្បីបង្កើនការប្តេជ្ញាចិត្តរបស់រដ្ឋាភិបាលចំពោះកំណែទម្រង់ចាំបាច់ ពេលចៀសវាងគោលនយោបាយមិនស្របគ្នា/ប្រឆាំងគ្នា)

៣ = កម្រិតក្រុមការងារបច្ចេកទេស (ត្រូវមានការប្រជុំ ឬកិច្ចខិតខំប្រឹងប្រែងរួមគ្នាឱ្យបានច្រើនបន្ថែមទៀតនៅក្នុងកម្រិតក្រុមការងារបច្ចេកទេស រួមទាំងការ រៀបចំការត្រួតពិនិត្យផលប័ត្ររួមរបស់ប្រទេស)

៤ = កម្រិតផ្សេងៗទៀត (សូមបញ្ជាក់) ..................................................................................................

៦. តើអ្នកយល់យ៉ាណាចំពោះការខិតខំប្រឹងប្រែងរបស់ ADB នៅក្នុងការសម្របសម្រួលជំនួយជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀត (ឧ. ភ្នាក់ងាររបស់រដ្ឋាភិបាល អ្នកផ្តល់ជំនួយ ក្រុមវិស័យឯកជន សង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល) ?

១ = គួរឱ្យពេញចិត្តណាស់

២ = គួរឱ្យពេញចិត្ត

៣ = ត្រូវការការកែលម្អខ្លះៗ

៤ = ត្រូវការការកែលម្អច្រើនទៀត

៧. សូមបង្ហាញពីមធ្យោបាយដែល ADB លើកកម្ពស់សកម្មភាពសម្របសម្រួលជំនួយរបស់ខ្លួន (អ្នកអាចជ្រើសរើសចម្លើយច្រើនជាងមួយ) ។

១ = ធ្វើការពិភាក្សា/ការពិគ្រោះយោបល់បន្ថែមទៀតជាមួយនឹងដៃគូអភិវឌ្ឍន៍ផ្សេងទៀត ដើម្បីបង្កើនការស៊ីសង្វាក់គ្នាសម្រាប់យុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់ខ្លួនស្របគ្នាជាមួយនឹងយុទ្ធសាស្ត្រ និងកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត និងជាមួយនឹងអាទិភាព/តម្រូវការអភិវឌ្ឍរបស់រដ្ឋាភិបាល

២ = ធ្វើការពិភាក្សាគោលនយោបាយរួមបន្ថែមទៀត

៣ = ជួបប្រជុំរួមគ្នាឱ្យបានញឹកញាប់បន្ថែមទៀតជាមួយនឹងអ្នកផ្តល់ជំនួយផ្សេងទៀត ដើម្បីធ្វើឱ្យមានការស៊ីសង្វាក់គ្នានូវនីតិវិធីអនុវត្តន៍ (រួមមាន ការរៀបចំការ ត្រួតពិនិត្យផលប័ត្ររួមរបស់ប្រទេស)

៤ = ផ្សេងៗទៀត (សូមគូសបញ្ជាក់) ..................................................................................................

៨. តើអ្នកយល់យ៉ាងណាចំពោះជំនួយរបស់ ADB ចំពោះភាពទាក់ទងរបស់ខ្លួនទៅនឹងអាទិភាពអភិវឌ្ឍន៍ប្រទេសដែរ ឬទេ ?

១ = ទាក់ទងយ៉ាងខ្លាំង

២ = ទាក់ទង

៣ = ទាក់ទងមួយផ្នែក

៤ = គ្មានទាក់ទង

៩. តើអ្នកយល់យ៉ាងណាចំពោះជំនួយរបស់ ADB ក្នុងការជួយសម្រេចបាននូវលទ្ធផល/ផលប៉ះពាល់អភិវឌ្ឍន៍នៅក្នុងវិស័យសំខាន់ៗ ?

១ = មានប្រសិទ្ធភាពខ្ពស់

២ = មានប្រសិទ្ធភាព

៣ = មានប្រសិទ្ធភាពមួយផ្នែក

៤ = គ្មានប្រសិទ្ធភាព

១០. តើអ្នកយល់យ៉ាងណាចំពោះជំនួយរបស់ ADB ក្នុងការជួយបន្តឱ្យមាននិរន្តរភាពនៅក្នុងវិស័យសំខាន់ៗ ?

១ = ទំនងជាមានបំផុត

២ = ទំនងជាមាន

៣ = ទំនងជាមានតិចតួច

៤ = ទំនងជាមិនមាន

១១. តើអ្នកយល់យ៉ាងណាចំពោះជំនួយរបស់ ADB ក្នុងការរួមចំណែកជួយពង្រឹងសមត្ថភាពតាមស្ថាប័ននៃភ្នាក់ងាររដ្ឋាភិបាលដើម្បីផ្ដល់នូវសេវានានាឱ្យកាន់តែមានប្រសិទ្ធភាព ?

១ = ច្រើន

២ = បង្គួរ

៣ = មធ្យម

៤ = តិចតួច

១២. តើអ្នកយល់យ៉ាងណាចំពោះជំនួយរបស់ ADB ក្នុងការរួមចំណែកជួយលើកកម្ពស់អភិបាលកិច្ចល្អ (ឧ. លើកកម្ពស់ច្បាប់ និងបទបញ្ជាផ្សេងៗ ដើម្បីជួយបង្កើនតម្លាភាព/ការទទួលខុសត្រូវរបស់ភ្នាក់ងាររដ្ឋាភិបាល និងដើម្បីសម្របសម្រួលការអភិវឌ្ឍវិស័យឯកជន) ?

១ = ច្រើន

២ = បង្គួរ

៣ = មធ្យម

៤ = តិចតួច

១៣. តើអ្នកយល់យ៉ាងណាចំពោះតួនាទីរបស់និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសឡាវ (LRM) របស់ ADB នៅក្នុងការជួយលើកកម្ពស់ប្រតិបត្តិការរបស់ ADB ?

១ = មានអត្ថប្រយោជន៍យ៉ាងខ្លាំង

២ = មានអត្ថប្រយោជន៍

៣ = មិនសូវមានអត្ថប្រយោជន៍

៤ = គ្មានអត្ថប្រយោជន៍

ឧបសម្ព័ន្ធ ៥

១៤. សូមបង្ហាញពីមធ្យោបាយដើម្បីជួយលើកកម្ពស់ប្រតិបត្តិការរបស់និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសឡាវនៅក្នុងពេលអនាគត (អ្នកអាចជ្រើសរើសចម្លើយច្រើនជាងមួយ) ។

១ = បុគ្គលិកនៅនិវាសនដ្ឋានបេសកកម្មប្រចាំប្រទេសឡាវ គួរពិភាក្សា/ពិគ្រោះយោបល់ជាមួយនឹងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធឱ្យបានញឹកញាប់

២ = បុគ្គលិកនៅនិវាសនដ្ឋានបេសកកម្មប្រចាំប្រទេសឡាវ គួរចុះពិនិត្យតំបន់គម្រោងឱ្យបានញឹកញាប់

៣ = បុគ្គលិកនៅនិវាសនដ្ឋានបេសកកម្មប្រចាំប្រទេសឡាវ គួរផ្តោតគោលដៅតម្រង់រកអតិថិជនឱ្យបានច្រើន

៤ = ផ្សេងៗទៀត (សូមបញ្ជាក់) ..................................................................................................................

១៥. តើអ្នកយល់ថា អ្វីខ្លះជាចំណុចខ្លាំងនៃប្រតិបត្តិការរបស់ ADB (អ្នកអាចជ្រើសរើសចម្លើយច្រើនជាងមួយ) ?

១ = ការឆ្លើយតបទៅនឹងតម្រូវការអភិវឌ្ឍន៍ប្រទេស

២ = និរន្តរភាពនៅក្នុងវិស័យសំខាន់ៗ

៣ = ជំរុញឱ្យមានអ្នកទទួលអត្ថប្រយោជន៍/ការចូលរួមរបស់ប្រទេស និងភាពជាម្ចាស់

៤ = ផ្សេងៗ (សូមបញ្ជាក់) ..........................................................................................................................

១៦. តើអ្នកយល់ថា អ្វីខ្លះជាចំណុចខ្សោយនៃប្រតិបត្តិការរបស់ ADB (អ្នកអាចជ្រើសរើសចម្លើយច្រើនជាងមួយ) ?

១ = ខ្វះលក្ខណៈចងក្រងឱ្យបានល្អ និងឱ្យមានលក្ខណៈជាកម្មវិធី (ឧ. វិធីត្រួតពិនិត្យលើគ្រប់វិស័យទាំងអស់ [SAWP]) ដើម្បីផ្តល់ជំនួយមានលក្ខណៈជាប្រព័ន្ធ និងស៊ីសង្វាក់គ្នានៅតាមបណ្តាវិស័យ

២ = ការរៀបចំគម្រោង/កម្មវិធីមានមហិច្ឆតាខ្ពស់ពេក និងមានភាពស្មុគស្មាញនៅក្នុងវិស័យមួយចំនួន

៣ = ខ្វះការរួមកម្លាំងគ្នារវាងផ្នែកដែលពាក់ព័ន្ធ

៤ = ផ្សេងៗ (សូមបញ្ជាក់) .......................................................................................................................

១៧. សូមប្រាប់ពីមធ្យោបាយដើម្បីឱ្យប្រសើរនូវប្រតិបត្តិការរបស់ ADB នៅក្នុងពេលអនាគត (អ្នកអាចជ្រើសរើសចម្លើយច្រើនជាងមួយ) ។

១ = ផ្តោតទៅលើវិស័យតែមួយចំនួនតូច (សូមបញ្ជាក់ពីវិស័យឱ្យបានច្បាស់លាស់) .............................................................
.........................................................................................................................................................

២ = ផ្តល់នូវគម្រោងបន្ថែមទៀត ដល់និវាសនដ្ឋានបេសកកម្មប្រចាំប្រទេសឡាវ ដើម្បីធ្វើការអនុវត្ត

៣ = ប្រើវិធីសាស្ត្រ SWAP នៅក្នុងវិស័យមួយចំនួន

៤ = ផ្សេងៗ (សូមបញ្ជាក់) ......................................................................................................................

១៨. តើអ្នកយល់ថា អ្វីខ្លះជាឧបសគ្គចម្បង ក្នុងការប្រើវិធីសាស្ត្រ SWAP ?

១ = ការកំណត់និយមន័យផ្សេងគ្នាៗលើទស្សនទាន SWAP ក្នុងចំណោមអ្នកផ្តល់ជំនួយ

២ = មិនមានសមត្ថភាពគ្រប់គ្រាន់នៃទីភ្នាក់ងាររដ្ឋាភិបាលដែលពាក់ព័ន្ធ ក្នុងការប្រើ/អនុវត្ត SWAP

៣ = មិនមានការសម្របសម្រួលគ្រប់គ្រាន់ក្នុងចំណោមអ្នកផ្តល់ជំនួយដើម្បីជំរុញរដ្ឋាភិបាលឱ្យចាប់ផ្តើមប្រើប្រាស់/បង្កើត SWAP

៤ = ផ្សេងៗ (សូមបញ្ជាក់) ......................................................................................................................

១៩. តើអ្នកយល់ថារបៀបវារៈអភិវឌ្ឍន៍ប្រទេស (ឧ. កំណើនសេដ្ឋកិច្ចជាតិ និងយុទ្ធសាស្ត្រលុបបំបាត់ភាពក្រីក្រ [NGPES] និងផែនការរយៈពេលមធ្យមនាពេលបច្ចុប្បន្ន) ត្រូវបានដឹកនាំដោយរដ្ឋាភិបាលក្នុងកម្រិតណា ?

១ = រដ្ឋាភិបាលជាអ្នកដឹកនាំទាំងស្រុង

២ = រដ្ឋាភិបាលជាអ្នកដឹកនាំស្ទើរតែទាំងស្រុង

៣ = អ្នកផ្តល់ជំនួយជាអ្នកដឹកនាំស្ទើរតែទាំងស្រុង

៤ = អ្នកផ្តល់ជំនួយជាអ្នកដឹកនាំទាំងស្រុង

២០. តើអ្នកគិតថា មធ្យោបាយអ្វីខ្លះដែលមានសារៈសំខាន់បំផុតដើម្បីជួយលើកម្ពស់មគ្គុទេសក៏ភាព និងភាពជាម្ចាស់របស់រដ្ឋាភិបាលនៅក្នុងរបៀបវារៈអភិវឌ្ឍន៍ប្រទេស ?

១ = លើកកម្ពស់កិច្ចសម្របសម្រួលជំនួយទាំងអស់ក្នុងចំណោមដៃគូអភិវឌ្ឍន៍

២ = លើកកម្ពស់ប្រព័ន្ធសម្របសម្រួលក្នុងចំណោមភ្នាក់ងាររដ្ឋាភិបាលដែលទទួលខុសត្រូវលើការធ្វើផែនការ ការកៀរគរជំនួយ និងការត្រួតពិនិត្យភាពក្រីក្រ

៣ = បង្កើនការចូលរួមរបស់រដ្ឋាភិបាលនៅក្នុងការរៀបចំគម្រោង និងយុទ្ធសាស្ត្រ និងកម្មវិធីប្រចាំប្រទេសរបស់អ្នកផ្តល់ជំនួយ

៤ = ផ្សេងៗ (សូមបញ្ជាក់) ........................................................................................................................

........................................................................................................................

២១. ដើម្បីសម្រេចឱ្យបាននូវការកាត់បន្ថយភាពក្រីក្រប្រកបដោយនិរន្តរភាព តើអ្នកយល់ថា អាទិភាពអភិវឌ្ឍន៍ប្រទេសនៅក្នុងរយៈពេល ៥ ឆ្នាំទៀត មានអ្វីខ្លះទៅ ?

........................................................................................................................

........................................................................................................................

២២. តើអ្នកគិតថាប្រទេសឡាវ មានថវិការគ្រប់គ្រាន់ក្នុងការសម្រេចឱ្យបាននូវគោលបំណងអភិវឌ្ឍន៍ក្នុងរយៈពេលវែងដូចដែលបានកំណត់នៅក្នុង NGPES ដែរ ឬទេ ?

១ = ទេ *(គិតថាគ្មាន)*

២ = បាទ/ចាស *(គិតថាមាន)*

២៣. តើអ្នកគិតថាអ្វីជាកំហិត/បញ្ហាប្រឈមចម្បងៗចំពោះការអភិវឌ្ឍប្រទេស ?

........................................................................................................................

........................................................................................................................

ឧបសម្ព័ន្ធ ៦

# ក្របខ័ណ្ឌវាយតម្លៃគុណភាពយុទ្ធសាស្ត្រ



## ក. តើមានបានកំណត់សូចនាករវឌ្ឍនភាព មានបានរៀបចំចងក្រង និងកំណត់ជាចំនួនរង្វាស់គោល មានបានបង្កើតគោលដៅ ដែលចងភ្ជាប់ដោយពេលវេលាធៀបនឹងរង្វាស់គោលដែរឬទេ ?

១. សូចនាករទាំងបីនេះ ជាឧបករណ៍វាយតម្លៃថាតើលទ្ធផលរំពឹងទុកក្រោយពីការដាក់ចុះនូវយុទ្ធសាស្ត្រ ត្រូវបានរៀបរាប់កម្រិតប៉ុណ្ណា ដោយការប្រើប្រាស់វាក្យស័ព្ទវាស់វែងធៀបនឹងរង្វាស់គោលដែលកំណត់ជាតួលេខនោះ ។

២. ពិន្ទុខ្ពស់បំផុត មានន័យថាមានបង្ហាញនៅគ្រប់ផ្នែកទាំងអស់ និងសម្រាប់វិស័យមួយចំនួន (២) ។

៣. ការចាត់ចំណាត់ថ្នាក់ : ពិន្ទុស្ថិតនៅចន្លោះរវាង ២ និង ០ ។

## ខ. តើមានបានកំណត់គម្លាតយុទ្ធសាស្ត្រដែរឬទេ ?

៤. ទាក់ទងនឹងសូចនាករខាងលើ សូចនាករនេះ ជាអ្នកធ្វើការវាយតម្លៃថា តើមានការកំណត់ឱ្យបានច្បាស់លាស់នូវគម្លាតរវាងគោលដៅ និងរង្វាស់គោលដែរ ឬទេ ។

៥. ពិន្ទុខ្ពស់បំផុតមានន័យថាទំហំនៃភារៈកិច្ចដែលត្រូវដោះស្រាយដោយយុទ្ធសាស្ត្រ មានភាពច្បាស់លាស់ទាំងអស់ និងសម្រាប់វិស័យនីមួយៗ (៤) ។

## គ. របៀបវារៈជាយុទ្ធសាស្ត្រកាន់តែទូលំទូលាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី

៦. សូចនាករនេះ ធ្វើការវាយតម្លៃថា តើរបៀបវារៈជាយុទ្ធសាស្ត្រកាន់តែទូលំទូលាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី (គោលនយោបាយ និងយុទ្ធសាស្ត្រ ផ្តោតលើគ្រប់ផ្នែកដែលប្រទាក់ក្រឡាគ្នា និងតាមវិស័យ) ជះឥទ្ធិពលកម្រិតណា ទៅលើជម្រើសនានានៅក្នុងយុទ្ធសាស្ត្រប្រចាំប្រទេស ។ ទោះបីជាមិនទាន់អាចទទួលយកបានថាត្រឹមត្រូវក៏ដោយ ក៏ការពិត សូចនាករនេះ អាចថាជាការវាយតម្លៃទៅលើសមត្ថភាពនៃគោលនយោបាយទាំងនោះក្នុងការបញ្ចេញនូវឥទ្ធិពលរបស់វាដែរ ។

៧. ពិន្ទុខ្ពស់បំផុតមានន័យថាយុទ្ធសាស្ត្រ និងគោលនយោបាយទូទៅ តាមវិស័យ និងតាមប្រធានបទរបស់ ADB ត្រូវបានលើកយកមកពិចារណាយ៉ាងលម្អិត ហើយមានឥទ្ធិពលទៅលើការកំណត់ដែននៃប៉ារ៉ាម៉ែត្រថាអ្វីដែលគួរស្ថិតនៅក្នុងយុទ្ធសាស្ត្រ និងអ្វីគួរស្ថិតនៅខាងក្រៅយុទ្ធសាស្ត្រនៅតាមកម្រិតថ្នាក់ប្រទេស (១០) ។

៨. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង ០ ។

## ឃ. គោលនយោបាយនានារបស់ប្រទេស

៩. សូចនាករនេះ ជាអ្នកធ្វើការវាយតម្លៃថា តើកម្រិតយុទ្ធសាស្ត្រ ផែនការ និងគោលនយោបាយរបស់ប្រទេសដែលបានចែងរួចហើយនោះទទួលបានការវាយតម្លៃ និងលើកយកមកពិចារណានៅក្នុងការរៀបចំយុទ្ធសាស្ត្រកម្រិតណា ។ សូចនាករនេះ អនុវត្តភារៈកិច្ចរបស់ខ្លួនហួសពីការវាយតម្លៃសាមញ្ញទៅលើភាពបន្សុីគ្នាទៅទៀត ។ ភាពបន្សុីគ្នាជាមួយនឹងយុទ្ធសាស្ត្រអន់ខ្សោយ ឬភាពបន្សុីគ្នាទៅនឹងគោលនយោបាយ ដែលរដ្ឋាភិបាលគ្មានការប្តេជ្ញាចិត្តទៅលើ គឺមិនមែនជាសញ្ញាវិជ្ជមានទេ ។

១០. ពិន្ទុខ្ពស់បំផុត មានន័យថាគោលនយោបាយរបស់ប្រទេស ត្រូវបានធ្វើការវាយតម្លៃយ៉ាងប្រុងប្រយ័ត្ន ភាពទាក់ទងនៃគោលនយោបាយទាំងនេះ ត្រូវបានកំណត់ និងចំពោះចំណុចណាដែលទាក់ទង មានន័យថា យុទ្ធសាស្ត្ររបស់ ADB មានភាពបន្សុីគ្នាជាមួយនឹងគោលនយោបាយទាំងនោះ (១០) ។

១១. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ង. ការសម្របសម្រួលជាមួយនឹងដៃគូផ្សេងទៀត

១២. សូចនាករនេះ ធ្វើការវាយតម្លៃលើកម្រិតដែលកម្មវិធីរបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត ត្រូវបានលើកយកមកពិចារណា និងមានឥទ្ធិពលទៅលើជម្រើសរបស់ ADB ពោលគឺ " ការសម្របសម្រួលជំនួយ" ។ ការសម្របសម្រួលពិត។ គួរធ្វើឱ្យលើសពីការគ្រាន់តែចៀសវាងការជាន់គ្នា តែជាការចាប់យកនូវកាលានុវត្តន៍ភាពដើម្បីរួមកម្លាំងគ្នា ដែលក្នុងនោះ សូម្បីតែការកៀរគរថវិការ ក៏ត្រូវមានភាពសមស្របដែរ ។

១៣. ពិន្ទុខ្ពស់បំផុត មានន័យថា មានការវាយតម្លៃទៅលើកម្មវិធី និងយុទ្ធសាស្ត្ររបស់ដៃគូអភិវឌ្ឍន៍ផ្សេងទៀត មានការបង្ហាញនូវការខិតខំប្រឹងប្រែង ដើម្បីរួបរួមកម្លាំងគ្នា និងមានការពិភាក្សាជាមួយដៃគូ ។ គួរបង្ហាញឱ្យឃើញច្បាស់ចំពោះកាលានុវត្តន៍ភាពសម្រាប់ភាពជាដៃគូ ដោយឈរលើគោលការខិតខំស្មើៗគ្នា (១០) ។

១៤. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ច. មូលដ្ឋានវិភាគ (១០)

១៥. សូចនាករនេះ ធ្វើការវាយតម្លៃថាតើយុទ្ធសាស្ត្រ បានផ្អែកលើភស្តុតាងដែលទទួលបានពីការវិភាគដ៏ច្បាស់លាស់នោះក្នុងកម្រិតប៉ុណ្ណា ។

(i) ចំនួន ការគ្របដណ្តប់ និងស្ថានភាពលំបាកផ្នែកសេដ្ឋកិច្ច វិស័យនានា និងការសិក្សាផ្សេងៗ (ដែលត្រូវបានលើកជាសំណូមពរ/អនុវត្តដោយ ADB ឬ អ្នកផ្សេងទៀត) ដែលការវិភាគជាយុទ្ធសាស្ត្រ បានផ្អែកទៅលើចំណុចទាំងប៉ុន្មានខាងលើនេះ ។

(ii) បរិបទផ្នែកសេដ្ឋកិច្ច និងផលវិបាកនៃផ្នែកនេះ ត្រូវបានបកស្រាយយ៉ាងច្បាស់លាស់ ។

(iii) បរិបទគោលនយោបាយ និងផលវិបាកនៃផ្នែកនេះ ត្រូវបានបកស្រាយយ៉ាងច្បាស់លាស់ ។

(iv) បរិបទផ្នែកសេដ្ឋកិច្ច នយោបាយ និងផលវិបាកនៃផ្នែកនេះ ត្រូវបានបកស្រាយយ៉ាងច្បាស់លាស់ ។

(v) ការវាភាគទៅលើស្ថាប័ន ត្រូវបានធ្វើឡើង ហើយផលវិបាកនៃផ្នែកនេះ ត្រូវបានបូកបញ្ចូល ។

(vi) ការវិភាគទៅលើអ្នកពាក់ព័ន្ធ ត្រូវបានធ្វើឡើង ហើយផលវិបាកនៃផ្នែកនេះ ត្រូវបានបូកបញ្ចូល ។

(vii) មេរៀនដែលទទួលបានពីយុទ្ធសាស្ត្រមុនៗ ត្រូវបានកំណត់ និងដាក់ចូលទៅក្នុងយុទ្ធសាស្ត្រថ្មី ។

(viii) ការបង្កើតគំរូផ្នែកសេដ្ឋកិច្ច ត្រូវបានធ្វើឡើងដើម្បីប្រៀបធៀបវិធីជ្រើសរើស ជាពិសេស ទាក់ទងនឹងការស្វែងរកជម្រើសនានាផ្នែកគោលនយោបាយ ។

១៦. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ឆ. ការកំណត់ជម្រើស

១៧. សូចនាករនេះ ធ្វើការវាយតម្លៃថា តើ ADB មានបានធ្វើការពិចារណាឱ្យច្បាស់លាស់ទៅលើការស្វែងរកជម្រើសឱ្យបានច្រើនជាងមួយដែរ ឬទេ មុននឹងកំណត់វិធីជាយុទ្ធសាស្ត្ររបស់ខ្លួន។ តើ ADB មានបានស្នើរឱ្យមានការរៀបចំយុទ្ធសាស្ត្រដោយតំរិយាបទបើកចំហគំនិតរបស់ខ្លួនដែរ ឬទេ ឬតើយុទ្ធសាស្ត្រដែលបានតាក់តែងក្នុងគោលបំណងផ្តល់នូវហេតុផលការពារសេចក្តីសម្រេចចិត្តនោះ ត្រូវបានរៀបចំឡើងដែរ ឬទេ ។ ភស្តុតាងនៃការពិចារណាជម្រើស បានបង្ហាញឱ្យឃើញថាវិធី "តំរិយាបទលាក់គំនិត" មិនអាចមានប្រៀបជាងបានទេ ។

១៨. ពិន្ទុខ្ពស់បំផុតមានន័យថា វិធីស្វែងរកជម្រើសសម្រាប់យុទ្ធសាស្ត្រ ត្រូវបានលើកយកមកធ្វើការពិចារណាយ៉ាងល្អិតល្អន់ ហើយទទួលបានហេតុផលច្បាស់លាស់ក្នុងការជ្រើសរើសវិធីដែលជាទីពេញចិត្ត ។

១៩. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ជ. ការជាប់ទាក់ទងរបស់អ្នកពាក់ព័ន្ធ

២០. សូចនាករនេះ វាយតម្លៃពីកម្រិតដែលអ្នកពាក់ព័ន្ធ មានឥទ្ធិពល និងបង្ហាញភាពជាម្ចាស់លើការសម្រេចចិត្តអំពីជម្រើសជាយុទ្ធសាស្ត្រ។

២១. ពិន្ទុខ្ពស់បំផុតមានន័យថា អ្នកពាក់ព័ន្ធសំខាន់ៗទាំងអស់ បានចូលរួមនៅក្នុងការរៀបចំយុទ្ធសាស្ត្រ ហើយការរួមចំណែករបស់ពួកគេ ពិតជាមានអានុភាពយ៉ាងពិតប្រាកដ ទៅលើជម្រើសដែលមាន ។

២២. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ឈ. សង្គតិភាព និងភាពស៊ីគ្នា

២៣. សូចនាករនេះ វាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្រនេះ ចៀសវាងការប្រឆាំងគ្នាផ្ទៃក្នុងនៅក្នុងជម្រើសជាយុទ្ធសាស្ត្ររបស់ខ្លួន និងវាយតម្លៃពីកម្រិតដែលធាតុផ្សេងៗរបស់យុទ្ធសាស្ត្រ ភ្ជាប់គ្នាជាកម្មវិធីរួមមួយ ហើយមានភាពស៊ីគ្នា ។

២៤. ពិន្ទុខ្ពស់បំផុតមានន័យថា គ្មានការប្រឆាំងផ្ទៃក្នុងកើតឡើងទេនៅក្នុងយុទ្ធសាស្ត្រនោះ ហើយមានភាពស៊ីគ្នា និងការរួមកម្លាំងគ្នាដែលលេចចេញយ៉ាងច្បាស់នៅក្នុងប្រតិបត្តិការទាំងឡាយរបស់ ADB (ទាំងប្រតិបត្តិការសម្រាប់វិស័យសាធារណៈ និងឯកជន ជំនួយបច្ចេកទេស ការងារសេដ្ឋកិច្ច និងការងារតាមបណ្តាវិស័យ និងការពិភាក្សាលើគោលនយោបាយ) (១០) ។

២៥. ការចាត់ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ញ. ធនធានចាំបាច់/ការយកចិត្តទុកដាក់

២៦. សូចនាករនេះ ធ្វើការវាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្រ និងធនធានសព្វគ្រប់ដែលបានស្នើរឡើងសម្រាប់ផ្នែកណាមួយ ដើម្បីឱ្យគ្រប់គ្រាន់ក្នុងការសម្រេចបាននូវលទ្ធផលប្រកបដោយនិរន្តរភាព ។ កត្តាកំណត់សំខាន់ៗ អាចជាបញ្ហាធនធានមនុស្សរបស់ ADB ។ តើធនធានមនុស្សទាំងនេះកាន់តែមានតិចៗទៅរហូតដល់កម្រិតមួយដែលមិនអាចសម្រេចបាននូវគំនិត និងការគាំទ្រឱ្យបានគ្រប់គ្រាន់មែនទេ ?

២៧. ពិន្ទុខ្ពស់បំផុតមានន័យថា ចំណុចត្រូវយកចិត្តទុកដាក់ដ៏ច្បាស់លាស់ និងមានកម្រិត របស់វិស័យ និង/ឬអនុវិស័យ ក្រុមគោលដៅ និង/ឬ តំបន់ភូមិសាស្ត្រ មានភាពស្របគ្នាជាមួយនឹងទំហំនៃធនធានដែលមានទាំងអស់ ហេតុដូច្នេះលទ្ធផលដ៏សន្ធឹកសន្ធាប់ និងប្រកបដោយនិរន្តរភាព ទំនងជាអាច សម្រេចបាន (១០) ។

២៨. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង ០ ។

## ដ. ការប៉ាន់ស្មាន និងហានិភ័យ

២៩. សូចនាករនេះ ធ្វើការវាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្រ បានកំណត់យ៉ាងច្បាស់លាស់នូវហានិភ័យដែលអាចរារាំងចំណេះដឹងផ្នែកយុទ្ធសាស្ត្រ និងកំណត់យ៉ាងច្បាស់លាស់នូវការប៉ាន់ស្មានដែលនាំឱ្យមានភាពជោគជ័យ ។ វិធានការកាត់បន្ថយហានិភ័យ គួរត្រូវបានកំណត់ ហើយជាពិសេស គឺ ហានិភ័យសេដ្ឋកិច្ចនយោបាយ ។

៣០. ពិន្ទុខ្ពស់បំផុតមានន័យថា ការប៉ាន់ស្មាន និងហានិភ័យ ដែលទាក់ទងនឹងយុទ្ធសាស្ត្រ ត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងវិធានការកាត់បន្ថយ ហានិភ័យ ត្រូវបានរៀបចំ (១០) ។

៣១. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង ០ ។

## ឋ. និរន្តរភាព

៣២. សូចនាករនេះ ធ្វើការវាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្ររបស់ ADB បានផ្តល់នូវធនធានចាំបាច់ក្នុងមួយរយៈកាលកន្លងមក ។ តើយុទ្ធសាស្ត្រ នេះ ពិតជាផ្អែកលើបទពិសោធន៍ដែលមានពីមុនមក ដោយបានធ្វើការសិក្សាច្បាស់លាស់មែនទេ ?

៣៣. ពិន្ទុខ្ពស់បំផុតមានន័យថា មានភស្តុតាងច្បាស់លាស់ដែលបង្ហាញពីការប្តេជ្ញាចិត្ត ការផ្តោតយកចិត្តទុកដាក់លើផ្នែកណាមួយក្នុងរយៈពេល មធ្យម ដល់រយៈពេលវែង ហើយលទ្ធផលទទួលបានពីការប្តេជ្ញាចិត្តបែបនេះ រំពឹងថា នឹងមានការកើនឡើងជាលំដាប់ ដោយផ្អែកទៅលើចំណេះដឹង និងបទពិសោធន៍ដែលចេះតែកើនឡើងនោះដែរ ។

៣៤. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង ០ ។

## ឌ. ភាពជាដៃគូរ

៣៥. សូចនាករនេះ ធ្វើការវាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្រ បានបញ្ចូលភាពជាដៃគូពិតប្រាកដ (មិនមែនជាមួយ ADB ជាដៃគូនាំមុខគេជានិច្ច នោះឡើយ) ហើយលទ្ធផលដែលទទួលបានពីការរួមគ្នាបែបនេះ ហាក់ដូចជាមានភាពល្អជាងលទ្ធផលដែលសម្រេចបានដោយ ADB ធ្វើតែម្នាក់ឯង ។

៣៦. ពិន្ទុខ្ពស់បំផុតមានន័យថា កាលានុវត្តន៍ភាពនានានៃភាពជាដៃគូរួមគ្នា ត្រូវបានគេចាត់ទុកដូចជាភ្នាក់ងារផ្តល់រូបិយវត្ថុផ្សេងៗទៀត អង្គការ ក្រៅរដ្ឋាភិបាល ផ្នែកឯកជន និងសង្គមស៊ីវិល (១០) ។

៣៧. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង ០ ។

## ឍ. ការកំណត់ស្ថានភាព

៣៨. សូចនាករនេះ ផ្តោតលើការវាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្រ បានកំណត់ និងផ្តល់ហេតុផលសមស្របអំពីស្ថានភាពនៃឧត្តមភាពប្រៀបធៀបសម្រាប់ ADB ។

៣៩. ពិន្ទុខ្ពស់បំផុត មានន័យថាឧត្តមភាពប្រៀបធៀបរបស់ ADB ត្រូវបានកំណត់យ៉ាងច្បាស់លាស់ និងផ្តល់នូវហេតុផលសមស្រប ហើយយុទ្ធសាស្ត្រនេះ មានភាពស្របគ្នាយ៉ាងពិតប្រាកដ ជាមួយនឹងឧត្តមភាពប្រៀបធៀបទាំងនោះ ។

៤០. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ណ. ការត្រួតពិនិត្យ និងវាយតម្លៃលទ្ធផលការងារ

៤១. សូចនាករនេះ វាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្រ បានដាក់បញ្ចូលនូវមធ្យោបាយសម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃទៅលើភាពជោគជ័យរបស់យុទ្ធសាស្ត្រ និងលទ្ធផលដែលកើតចេញពីយុទ្ធសាស្ត្រ ។

៤២. ពិន្ទុខ្ពស់បំផុត មានន័យថា ដំណើរការនៃការត្រួតពិនិត្យ និងវាយតម្លៃ ត្រូវបានផ្តល់ជូនយ៉ាងពេញលេញ ដោយពិនិត្យមើលទៅលើអ្នកដែលនឹងត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងវិធី និងពេលវេលាដែលគេនឹងចុះធ្វើការត្រួតពិនិត្យ និងវាយតម្លៃផងដែរ ។ ការចំណាយផ្សេងៗ ត្រូវបានផ្តល់ជូន (១០) ។

៤៣. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ត. ការមានគំនិតច្នៃប្រឌិតថ្មី

៤៤. សូចនាករនេះ ធ្វើការវាយតម្លៃពីកម្រិតដែលយុទ្ធសាស្ត្រ បានបង្ហាញការច្នៃប្រឌិតថ្មីៗ ។

៤៥. ពិន្ទុខ្ពស់បំផុត មានន័យថា ការបញ្ចូលការច្នៃប្រឌិតថ្មីមានកម្រិតខ្ពស់ដោយផ្អែកទៅលើការសិក្សា និងដោយមានសនិទានភាពសមហេតុផលផងដែរ (១០) ។

៤៦. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។

## ថ. ភាពបត់បែន

៤៧. សូចនាករនេះ ធ្វើការវាយតម្លៃថា តើតម្រូវការភាពបត់បែន និងមធ្យោបាយក្នុងការបត់បែន ត្រូវបានគេបញ្ចូលគ្នាក្នុងកម្រិតណា ។

៤៨. ពិន្ទុខ្ពស់បំផុត មានន័យថា មានការប្រាប់យ៉ាងច្បាស់លាស់អំពីតួនាទី និងហេតុផលសម្រាប់យុទ្ធសាស្ត្របន្ទាន់ ហើយមានការពន្យល់យ៉ាងច្បាស់លាស់អំពីដំណើរការនៃការធ្វើសេចក្តីសម្រេចចិត្ត ។

៤៩. ចំណាត់ថ្នាក់ : ពិន្ទុរវាង ១០ និង 0 ។